ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# សៀវភៅណែនាំប្រតិបត្តិ
# ស្តីពី
# ការគ្រប់គ្រងតាមសាលារៀន

គម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា

ឆ្នាំ ២០១៨

# បុព្វកថា

ការគ្រប់គ្រងតាមសាលារៀន ជាយន្តការដ៏មានប្រសិទ្ធភាពមួយក្នុងការអនុវត្តវិមជ្ឈការនៃការអប់រំ ដើម្បីធានាឱ្យសេវាអប់រំមានប្រសិទ្ធភាពខ្ពស់។ ការគ្រប់គ្រងតាមសាលារៀនត្រូវបានចាត់ទុកជាវិធី (១) ប្រកួតប្រជែងការរក្សា ការពិនិត្យ និងតុល្យភាពផ្ទៃក្នុងរបស់ក្រសួងអប់រំ យុវជន និងកីឡា រួមមានការផ្តល់ធនធាន សិទ្ធិអំណាច និងការកសាងសមត្ថភាពដើម្បីបង្កើនលទ្ធផលសិក្សារបស់សិស្ស (២)ធ្វើឱ្យក្រសួងអប់រំ យុវជន និងកីឡាអាចឆ្លើយតបបានច្រើនជាងមុន ក្នុងការផ្តល់សេវាអប់រំនៅសាលារៀន និងក្នុងការដោះស្រាយបញ្ហាបានទាន់ពេល និងមានប្រសិទ្ធភាពខ្ពស់ (៣)កាត់បន្ថយភាពតានតឹងសង្គម និងនយោបាយ និងធានាបាននូវស្វ័យភាព និងតម្លាភាពមូលដ្ឋាន ដោយសារតែសាធារណជនបានរួមចំណែកទទួលខុសត្រូវ និងដោះស្រាយបញ្ហាជាមួយរដ្ឋ។ ក្នុងន័យនេះការគ្រប់គ្រងតាមសាលារៀន គឺការផ្តល់ស្វ័យភាពក្នុងការសម្រេចចិត្តទៅកម្រិតមូលដ្ឋាន ដោយផ្អែកលើលទ្ធផលនៃការអនុវត្តការងាររបស់សាលារៀន និងលទ្ធផលសិក្សារបស់សិស្ស។ ប្រការនេះជាជំហរអនុវត្តនូវការសម្រេចចិត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីឱ្យសាលារៀនទាំងអស់អាចសម្រេចបានស្តង់ដាទាំង៩ ស្តីពីសាលារៀនមានប្រសិទ្ធភាព។

ដើម្បីសម្រួលការអនុវត្តការងារនៅថ្នាក់សាលារៀន ថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ ក្រសួងអប់រំ យុវជន និងកីឡាបានចងក្រង **សៀវភៅណែនាំប្រតិបត្តិ ស្តីពីការគ្រប់គ្រងតាមសាលារៀន** មានបីផ្នែក ហើយផ្នែកនីមួយៗមានទំនាក់ទំនង និងបំពេញឱ្យគ្នាទៅវិញទៅមក បានជាប្រព័ន្ធគ្រប់គ្រងការអនុវត្តការងារអប់រំតែមួយ សម្រាប់តភ្ជាប់រវាងការរៀបរៀងផែនការកែលម្អសាលារៀន មកការអនុវត្ត និងមកការវាយតម្លៃការអនុវត្តផែនការនោះនៅកម្រិតសាលារៀន។ សៀវភៅណែនាំប្រតិបត្តិក៏បានតភ្ជាប់ការគ្រប់គ្រងតាមសាលារៀនមកផែនការតាមដាន និងវាយតម្លៃលទ្ធផលសិក្សា និងការអភិវឌ្ឍសាលារៀននៅការិយាល័យ មន្ទីរ និងក្រសួងអប់រំ យុវជន និងកីឡាផងដែរ។

ដូច្នេះ សៀវភៅណែនាំប្រតិបត្តិនេះ គឺសម្រាប់ជួយសាលារៀនឱ្យអនុវត្តជាក់ស្តែងនូវកំណែទម្រង់រដ្ឋបាលសាធារណៈក្នុងវិស័យអប់រំ ផ្តោតលើលទ្ធផលសិក្សារបស់សិស្ស និងបង្ហាញអំពីសកម្មភាពអន្តរាគមន៍ចាំបាច់ពីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីរួមគ្នាជួយដល់សាលារៀន និងដើម្បីធ្វើយ៉ាងណាឱ្យគុណភាពនៃការបង្រៀននៅថ្នាក់រៀន ក្លាយជាអាទិភាពខ្ពស់បំផុត។

ក្រសួងអប់រំ យុវជន និងកីឡា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ និងស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមរៀបចំ សៀវភៅណែនាំប្រតិបត្តិស្តីពី ការគ្រប់គ្រងតាមសាលារៀននេះ។

ក្រសួងសង្ឃឹមយ៉ាងមុតមាំថា គ្រប់ស្ថាប័ន គ្រឹះស្ថានសិក្សា ដៃគូអភិវឌ្ឍ និងភាគីពាក់ព័ន្ធទាំងអស់ នឹងបន្តរួមចំណែក និងគាំទ្រដល់ការអនុវត្តតាមសៀវភៅណែនាំនេះ ដើម្បីឈានទៅសម្រេចបានជោគជ័យក្នុងការអភិវឌ្ឍអប់រំនៅប្រទេសកម្ពុជា។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**

# ការទទួលស្គាល់

ក្រុមការងារបច្ចេកទេស ការគ្រប់គ្រងតាមសាលារៀន ដឹកនាំដោយ **ឯកឧត្តមបណ្ឌិតសភាចារ្យ ណាត ប៊ុនរឿន** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា សូមថ្លែងអំណរគុណដល់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួនណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និង **ឯកឧត្តម វង្សី វិស្សុត** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានផ្តល់ការណែនាំលើគោលនយោបាយ គោលការណ៍ និងដំណើរប្រតិបត្តិការ ក្នុងការរៀបចំសៀវភៅប្រតិបត្តិនេះ។

ក្រុមការងារគ្រប់គ្រងតាមសាលារៀន បានប្រើក្របខណ្ឌដំណោះស្រាយជាប្រព័ន្ធ សម្រាប់ការវាស់វែងលទ្ធផលអប់រំ ស្តីពីស្វ័យភាព និងគណនេយ្យភាពសាលារៀន របស់ធនាគារពិភពលោក ពីបទពិសោធគម្រោងនៅប្រទេសកម្ពុជា បទពិសោធមន្ត្រីអប់រំថ្នាក់ជាតិ និងក្រោមជាតិ និងបទពិសោធនាយកសាលារៀន ជាគោលដើម្បីរៀបចំសៀវភៅណែនាំប្រតិបត្តិនេះ។

ក្រុមការងារបច្ចេកទេស ការគ្រប់គ្រងតាមសាលារៀន សូមថ្លែងអំណរគុណដល់មន្ត្រីនៃមន្ទីរអប់រំយុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងសាលារៀន ដែលបានផ្តល់នូវបទពិសោធ និងគំនិតក្នុងការរៀបចំ សៀវភៅណែនាំប្រតិបត្តិនេះ។

ក្រុមការងារបច្ចេកទេស ការគ្រប់គ្រងតាមសាលារៀន ក៏សូមថ្លែងអំណរគុណដល់មន្ត្រីធនាគារពិភពលោក ដៃគូអភិវឌ្ឍ និងអង្គការសង្គមស៊ីវិល ដែលបានផ្តល់ប្រឹក្សាយោបល់សម្រាប់ឯកសារនេះផងដែរ។

# មាតិកា

ជំពូក ១៖ ........ 5
សារតារ ........ 5
១.១ សេចក្ដីផ្ដើម ........ 5
១.២ ចំណេះដឹងសាកលលោកពីការគ្រប់គ្រងតាមសាលារៀន៖ វិមជ្ឈការ និងការអប់រំ ........ 8
១.៣ វត្ថុបំណង និងវិសាលភាពនៃសេចក្ដីណែនាំ ........ 13
ជំពូក ២៖ ........ 14
សេចក្ដីណែនាំការគ្រប់គ្រងតាមសាលារៀន ........ 14
២.១ ការគ្រប់គ្រងតាមសាលារៀន៖ ស្វ័យភាព និងគណនេយ្យភាព ........ 14
២.២ ស្វ័យភាពក្នុងការធ្វើផែនការ និងការគ្រប់គ្រងថវិកាសាលារៀន ........ 20
២.២.១ ក្របខ័ណ្ឌការងារសាលារៀនមានប្រសិទ្ធភាព ........ 20
២.២.២ ការអនុវត្តស្វ័យភាពក្នុងការធ្វើផែនការ និងការគ្រប់គ្រងថវិកាសាលារៀន ........ 31
២.២.៣ ការគ្រោងថវិកា ការរៀបចំ និងការដាក់ស្នើគម្រោងសុំថវិកា ........ 35
២.៣ ការគ្រប់គ្រងបុគ្គលិក ........ 63
២.៣.១ វត្ថុបំណង និងដំណើរការអនុវត្ត ........ 63
២.៣.២ កិច្ចសន្យាលទ្ធផលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍសមត្ថភាព ........ 64
២. ៣. ៣. ការពិនិត្យឡើងវិញពាក់កណ្ដាលឆ្នាំ ........ 68
២. ៣. ៤. ការវាយតម្លៃដំណើរការអនុវត្តនៅដំណាច់ឆ្នាំ ........ 69
២. ៣. ៥. ការអភិវឌ្ឍវិជ្ជាជីវៈ៖ ការបំប៉ននៅនឹងកន្លែង ........ 71
២. ៤. តួនាទីសហគមន៍ និងអភិបាលកិច្ចសាលារៀន ........ 73
២.៤.១. ការចូលរួមរបស់សហគមន៍ ........ 73
២.៤.២. មាតាបិតានិងសិស្សចូលរួមការងារក្នុងវិស័យអប់រំ ........ 81
២.៥ ការវាយតម្លៃសាលារៀន និងការវាយតម្លៃសិស្ស ........ 91
២.៥.១ ប្រភេទ និងការវាយតម្លៃការអនុវត្តសាលារៀន ........ 91
២.៥. ២ ការប្រើប្រាស់លទ្ធផលវាយតម្លៃធ្វើឱ្យប្រសើរការអនុវត្តសាលារៀន ........ 99
២.៥.៣ ការវាយតម្លៃសិស្ស និងពេលវេលាវាយតម្លៃ ........ 100
២.៥.៤ ការប្រើលទ្ធផលតេស្តសិស្ស ........ 101
២.៦. គណនេយ្យភាពសាលារៀន ........ 104
២.៦.១ ប្រភេទគណនេយ្យភាព ........ 104
២.៦.២ ការវិភាគការអនុវត្តការងាររបស់សាលារៀន ........ 105
២.៦.៣ ការគ្រប់គ្រងហិរញ្ញវត្ថុ (មានលម្អិតក្នុងសៀវភៅប្រតិបត្តិមូលនិធិកែលម្អសាលារៀន) ........ 106
២.៦.៤ សូចនាករពិនិត្យតាមដានផលប៉ះពាល់នៃមូលនិធិកែលម្អសាលារៀន ........ 107
ជំពូក៣៖ ........ 110
ផែនការអនុវត្ត និងថវិកា ........ 110
៣.១ ផែនការអនុវត្ត ........ 111
៣.២ ថវិកា ........ 114
ជំពូក៤៖ ........ 114

ស្ថាប័ន និងអ្នកទទួលខុសត្រូវ ....114
៩.១. ក្រុមគ្រប់គ្រងគម្រោង ....116
៩.២. ក្រុមការងារការគ្រប់គ្រងតាមសាលារៀន ....116
៩.៣. ក្រុមការងារបង្កើនគុណវុឌ្ឍិគ្រូបង្រៀន ....116
៩.៤ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ....117
៩.៥ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ....117
៩.៦. គណៈកម្មការគ្រប់គ្រងសាលារៀន ....117
៩.៧. នាយកសាលា ....117
ជំពូក៥៖ ....118
គោលនយោបាយការពារសុវត្ថិភាពរបស់ធនាគារដែលត្រូវយកមកអនុវត្តចំពោះគម្រោង ....118
៥.១ គោលនយោបាយការពារសុវត្ថិភាពរបស់ធនាគារដែលត្រូវយកមកអនុវត្តចំពោះគម្រោង ....118
៥.២ ផលប៉ះពាល់បរិស្ថាន និងសង្គមជាសក្តានុពល ....120
ឧបសម្ព័ន្ធ ....123
ឧបសម្ព័ន្ធ: ឧបករណ៍វាយតម្លៃការអនុវត្តសាលារៀនផ្អែកតាមស្តង់ដាសាលារៀនមានប្រសិទ្ធភាព ....123
ទម្រង់៖ សំណើរបស់មន្ទីរការិយាល័យអប់រំ យុវជន និងកីឡា/ ....133
ឧបសម្ព័ន្ធ៖ ឧបករណ៍វាយតម្លៃរបស់ថ្នាក់ជាតិប្រើប្រាស់វាយតម្លៃការបំពេញការងាររបស់មន្ទីរអប់រំ យុវជន និងកីឡា ....134
ឧបសម្ព័ន្ធ: ឧបករណ៍វាយតម្លៃរបស់មន្ទីរអប់រំប្រើប្រាស់វាយតម្លៃការបំពេញការងាររបស់ការិយាល័យអប់រំយុវជន និងកីឡា ..138
ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ....142
សេចក្តីព្រាងស្តង់ដាវិជ្ជាជីវៈនាយកសាលារៀនចំណោះទូទៅ ....152

# ជំពូក ១៖

# សាវតារ

## វត្ថុបំណង និងវិសាលភាពនៃសៀវភៅណែនាំប្រតិបត្តិ

### ១.១ សេចក្តីផ្តើម

#### មូលហេតុនាំមកនូវការរៀបចំសៀវភៅណែនាំប្រតិបត្តិស្តីពី ការគ្រប់គ្រងតាមសាលារៀន

ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានបំណងធ្វើឱ្យសាលារៀនក្លាយជាកន្លែងផ្តល់សេវាអប់រំប្រកបដោយគុណភាព បរិយាប័ន្ន ប្រសិទ្ធភាព និងលើកកម្ពស់ការអប់រំពេញមួយជីវិតសម្រាប់ទាំងអស់គ្នា តាមរយៈការអនុវត្តការគ្រប់គ្រងតាមសាលារៀន ដែលនឹងអធិប្បាយនៅ ក្នុងសៀវភៅណែនាំប្រតិបត្តិនេះ។ សៀវភៅនេះត្រូវបានរៀបចំឡើងដោយផ្អែកលើគោលការណ៍ចំនួនបី៖ ទី១ ការពង្រឹងសមត្ថភាពប្រព័ន្ធអប់រំដើម្បីអនុវត្តការគ្រប់គ្រងតាមសាលារៀន ទី២ ការពង្រឹងប្រសិទ្ធភាពគ្រូបង្រៀនតាមរយៈការអនុវត្តការគ្រប់គ្រងការអនុវត្តការងាររបស់គ្រូបង្រៀន និងទី៣ ការលើកកម្ពស់ការចូលរួមរបស់សហគមន៍ក្នុងស្វ័យភាពនិងគណនេយ្យភាពសាលារៀន។

ការគ្រប់គ្រងតាមសាលារៀនមានគោលបំណងពីរគឺ ១- រៀបចំសាលារៀនឱ្យបំពេញបាននូវស្តង់ដាសាលារៀនមានប្រសិទ្ធភាព ដោយការកសាងសមត្ថភាពដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងសាលារៀន ដើម្បីធានាថាការគាំទ្រត្រូវបានផ្តល់ឱ្យសាលារៀនទាន់ពេលវេលា និង ២- កសាងសមត្ថភាពគ្រូបបង្រៀនដើម្បីអនុវត្តកម្មវិធីសិក្សារបស់ជាតិ។ ដើម្បីសម្រេចបាននូវគោលបំណងទាំងពីរខាងលើនេះ មានសកម្មភាពចំនួន៣ ដែលត្រូវអនុវត្ត៖ ១- ពង្រឹងការគ្រប់គ្រងតាមសាលារៀន ២- បំប៉នបន្ថែមនិងផ្តល់ការគាំទ្រផ្ទាល់ដល់គ្រូបង្រៀន និង ៣- សាងសង់និងកែលម្អអគារសិក្សា និងបរិស្ថានសិក្សា។ សៀវភៅណែនាំប្រតិបត្តិនេះរៀបរាប់ពីរបៀបអនុវត្តសកម្មភាពទី១ និងទី២។

#### ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល

រយៈពេល៣ទសវត្សរ៍កន្លងមក ប្រទេសកម្ពុជាបានសម្រេចនូវគោលដៅសហសវត្សរ៍សម្រាប់ការអប់រំនៅបឋមសិក្សាដែលបង្ហាញថាការចូលរៀននៅបឋមសិក្សាមានចំនួន៩៦ភាគរយ នៅឆ្នាំសិក្សា ២០១៥-

២០១៦។ ចំពោះគុណភាពវិញ ផ្អែកតាមលទ្ធផលនៃការធ្វើតេស្តថ្នាក់ជាតិលើសមត្ថភាពសិស្សថ្នាក់ទី៣ បង្ហាញថា សមត្ថភាពអាន និងគណិតវិទ្យារបស់សិស្សជាមធ្យមបានកើនឡើងប្រហែល៣០ពិន្ទុនៃពិន្ទុសមាមាត្ររវាងឆ្នាំ២០០៨ និងឆ្នាំ២០១៥ ការសម្រេចនេះអាចបកស្រាយថា ប្រហែលស្មើនឹង ០.៣០គម្លាតស្តង់ដា។ តាមន័យស្ថិតិគម្លាត ០.៣០ តំណាងឱ្យការរីកចម្រើនមួយដ៏ធំ ដោយសារការរីកចម្រើននៃប្រព័ន្ធទាំងមូល តែវាមិនតំណាងឱ្យគម្រោងណាមួយ ឬ ខេត្ត រាជធានី ណាមួយឡើយ។ ការរីកចម្រើននេះ បង្ហាញពីការប្តេជ្ញាចិត្តយ៉ាងច្បាស់លាស់របស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីកែលម្អគុណភាពអប់រំ។

ក្រសួងអប់រំ យុវជន និងកីឡា ជឿជាក់ថា ប្រសិនបើសិស្សអាចអាននិងគណនាលេខបាន នោះគេនឹងមានមូលដ្ឋានសម្រាប់សិក្សាមុខវិជ្ជាដទៃទៀតបាន។

ក្រសួងអប់រំ យុវជន និងកីឡា បានសម្រេចថាគុណភាពអប់រំជាគោលនយោបាយអាទិភាពសម្រាប់គ្រប់កម្រិតនៃការអប់រំ ហើយគុណភាពអប់រំនឹងដើរតួនាទីជាយុទ្ធសាស្ត្រធ្វើឱ្យកើនឡើងនូវការចូលរៀនរបស់សិស្ស។

នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ មានកម្មវិធីកំណែទម្រង់ចំនួន៣ ដែលទាក់ទងនឹងវិស័យអប់រំ។ កម្មវិធីកំណែទម្រង់ទី១ កម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដំណាក់ទី៣ ផ្តោតលើការលើកកម្ពស់ការផ្សារភ្ជាប់គ្នារវាងថវិកាគោលនយោបាយ និងក្រុមគោលដៅសេវា និងដំណាក់ទី៤ ផ្តោតលើការធានានូវគណនេយ្យភាពក្នុងការចំណាយទាំងលើកម្មវិធីរបស់វិស័យនិងហិរញ្ញវត្ថុ។ កម្មវិធីកំណែទម្រង់ ទី២ រដ្ឋបាលសាធារណៈ ផ្តោតលើការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃសេវាសាធារណៈ ការអភិវឌ្ឍសមត្ថភាពនិងកែទម្រង់ប្រាក់បៀវត្សនិងប្រាក់ឧបត្ថម្ភ។ កម្មវិធីកំណែទម្រង់ទី៣ ប្រជាធិបតេយ្យ និងការអភិវឌ្ឍ ថ្នាក់ក្រោមជាតិផ្តោតលើការអនុវត្តច្បាប់ហិរញ្ញវត្ថុនិងទ្រព្យរដ្ឋ ការអភិវឌ្ឍធនធានមនុស្សនិងស្ថាប័នរដ្ឋ និងការពង្រីក ប្រសិទ្ធផលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ សៀវភៅណែនាំប្រតិបត្តិនេះត្រូវបានរៀបចំឡើង ដើម្បីអនុវត្តនូវ កម្មវិធីកំណែទម្រង់នេះ។

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ បានកំណត់គោលនយោបាយចំនួន៣គឺ(១)ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ (២)លើកកម្ពស់គុណភាព និងប្រសិទ្ធភាពសេវាអប់រំ (៣)អភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ។ ក្រសួងអប់រំ យុវជន និងកីឡា បានអនុម័តនូវផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន ផ្អែកតាម SABER[1] ដោយផ្តោតលើ ១. អភិវឌ្ឍសមត្ថភាពគ្រូបង្រៀនជាប់ជាប្រចាំ និង ២. រក្សាទុកពួកគាត់ឱ្យនៅបម្រើការងារក្នុងប្រព័ន្ធអប់រំ។ សៀវភៅណែនាំប្រតិបត្តិនេះនឹងគាំទ្រដល់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការអនុវត្តផែនការទាំងពីរខាងដើម។

---

[1] SABER.....

ស្របជាមួយនឹងការរីកចម្រើន ប្រព័ន្ធអប់រំកម្ពុជានៅមានបញ្ហាប្រឈមមួយចំនួនដែលទាមទារឱ្យមានការយកចិត្តទុកដាក់កម្រិតខ្ពស់បន្ថែមទៀត។ ការសិក្សាជាសាកលបង្ហាញថា គុណភាពអប់រំគឺជាកត្តាគន្លឹះសម្រាប់កំណើនសេដ្ឋកិច្ច។ ក្នុងន័យនេះ ដើម្បីរួមចំណែកធ្វើឱ្យសេដ្ឋកិច្ចមានការរីកចម្រើន ចាំបាច់ត្រូវលើកកម្ពស់គុណភាពនៃការរៀន និងបង្រៀន មានន័យថាការចូលរៀននាំឱ្យសិស្សអាចបង្កើនចំណេះដឹង ពោលគឺបើសិស្សរៀនកាន់តែច្រើន នោះសេដ្ឋកិច្ចនឹងរីកចម្រើនកាន់តែឆាប់រហ័ស (Hanushek and Woessmann 2008)។ គួរកត់សម្គាល់ថា ប្រទេសដែលទទួលលទ្ធផលតេស្ត១កម្រិតពិន្ទុ ធ្វើឱ្យផលទុនសរុបក្នុងមួយនាក់ក្នុងមួយឆ្នាំច្រើនជាង២ពិន្ទុភាគរយរយៈពេល៤០ឆ្នាំ (Hanushek and Woessmann 2008)។ មួយវិញទៀត ការវិនិយោគតែលើហេដ្ឋារចនាសម្ព័ន្ធនឹងមិនមានផលវិជ្ជមានដល់ការីកចម្រើនផ្នែកសេដ្ឋកិច្ចទេ តែបើការវិនិយោគផ្តោតទាំងលើការអភិវឌ្ឍមូលធនមនុស្ស និងរចនាសម្ព័ន្ធ ជាពិសេសសម្រាប់វិស័យអប់រំ នោះនឹងអាចកំណត់បានពីកំណើនសេដ្ឋកិច្ច។

ពាក់ព័ន្ធនឹងការអភិវឌ្ឍមូលធនមនុស្ស តាមទិន្នន័យរបស់ក្រសួងអប់រំ យុវជន និងកីឡា និងការសិក្សាស្រាវជ្រាវរបស់ធនាគារពិភពលោក «**ការអប់រំមនុស្សជំនាន់ក្រោយ**» បង្ហាញនូវការបែងចែង និងប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន មានដូចជាការបែងចែកគ្រូបង្រៀនមិនស្របតាមតម្រូវការ ឧទាហរណ៍ ផលធៀបគ្រូ/សិស្សនៅមធ្យមសិក្សា ក្នុងរាជធានីភ្នំពេញគឺ **១/១៤.៨** តែនៅខេត្តព្រៃវែង **១/២៩.៩**។ ការបំពេញការងាររបស់គ្រូបង្រៀនវិញ ជាមធ្យម **៤៧.៦ភាគរយ** នៃសំណាកគំរូមានកិច្ចតែងការបង្រៀន ក្នុងនោះ **៦៦.២ភាគរយ** គឺជាគ្រូបង្រៀននៅតំបន់ប្រជុំជន និងមានតែ **៣៤.៧ភាគរយ** ប៉ុណ្ណោះ សម្រាប់គ្រូបង្រៀននៅតំបន់ជនបទនិងដាច់ស្រយាល។ គ្រូបង្រៀនដែលអវត្តមានញឹកញាប់ មានចំនួន **៦ភាគរយ** ក្នុងនោះ **៣.៦ភាគរយ** នៅតំបន់ប្រជុំជន **៧.៦ភាគរយ** នៅតំបន់ជនបទ និង**១០.២ភាគរយ**នៅតំបន់ដាច់ស្រយាល។

សរុបមក ក្រសួងអប់រំ យុវជន និងកីឡា ចាំបាច់ត្រូវពង្រឹងគណនេយ្យភាពក្នុងប្រព័ន្ធអប់រំ ដើម្បីធានាថាសាលារៀនទទួលបានធនធាន(គ្រូបង្រៀន និងសម្ភារូបវន្ត) ដែលមានគុណភាព ស្របតាមនិយាម/ស្តង់ដាកំណត់ ហើយសាលារៀនត្រូវប្រើប្រាស់ធនធានទាំងនោះឱ្យអស់លទ្ធភាព។ ផ្អែកតាមស្ថានភាពខាងលើ និងសមត្ថភាពដែលមានស្រាប់ ក្រសួងអប់រំ យុវជន និងកីឡា ផ្តោតលើការអន្តរាគមន៍ និងផ្តល់ការគាំទ្រដល់សាលារៀនមួយចំនួនដើម្បីក្លាយជាសាលារៀនមាន**ឧត្តមានុវត្ត** និងបំពេញបាននូវស្តង់ដាសាលារៀនមានប្រសិទ្ធភាព។ ការចូលរួម និងការប្តេជ្ញាចិត្តរបស់មន្ត្រីអប់រំនៅគ្រប់កម្រិត របស់សិស្សានុសិស្ស របស់សហគមន៍ និងមាតាបិតា/អ្នកអាណាព្យាបាល ជាកត្តាចាំបាច់ដែលមិនអាចខ្វះបាន។ លទ្ធផលពីការប្រឹក្សាយោបល់ជាមួយមន្ទីរ អប់រំ យុវជន និងកីឡាខេត្ត រាជធានី ចំនួន ១៤ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌចំនួន ៥៨ និងបុគ្គលិកអប់រំ សហគមន៍ និងមាតាបិតាសិស្ស ចំនួន ៣០សាលារៀន បានបង្ហាញនូវការគាំទ្រ និងការប្តេជ្ញាចិត្តចូលរួមអនុវត្តអភិក្រម**ការគ្រប់គ្រងតាមសាលារៀន**។

## ១.២ ចំណេះដឹងសាកលលោកពីការគ្រប់គ្រងតាមសាលារៀនៈ វិមជ្ឈការ និងការអប់រំ

### ក្របខ័ណ្ឌនៃគំនិតវិមជ្ឈការ ៖ ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានឆ្ពោះទៅរកគណនេយ្យភាព




ក្នុងបរិបទកម្ពុជាបច្ចុប្បន្ន ការទទួលខុសត្រូវថ្នាក់ជាតិ (ព្រួញជាច់ៗ) គឺផ្តល់ធាតុចូលដែលមានគុណភាពដល់សាលារៀន។ ឧទាហរណ៍ កង្វះអគារសិក្សាជាបញ្ហាប្រឈមចម្បងៈ នៅតំបន់ប្រជុំជនភាគច្រើនមានអគារសិក្សាគ្រប់គ្រាន់ ចំណែកតំបន់ជនបទនៅតែខ្វះខាតអគារសិក្សា។ មួយវិញទៀត គណនេយ្យភាពក្នុងការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាពគឺ (១)មិនមានភាពច្បាស់លាស់ ដូចជាការបើកថ្នាក់រៀនយឺត និងបិទថ្នាក់រៀនមុនម៉ោងកំណត់ (២)គ្រូបង្រៀន ២ ភាគ ៣ នៅជនបទមិនធ្វើកិច្ចតែងការបង្រៀន។ ភស្តុតាងទាំងនេះជាទាហរណ៍មួយបង្ហាញថាប្រសិទ្ធភាពនៃការអនុវត្តកិច្ចអន្តរាគមន៍**ថ្នាក់ជាតិ**នៅមានកម្រិត។

ក្នុងបរិបទសាកលលោក ការប្រើប្រាស់យន្តការអន្តរាគមន៍ **ថ្នាក់មូលដ្ឋាន** ដោយផ្ទាល់រវាងប្រជាពលរដ្ឋ និងអ្នកផ្តល់សេវាអប់រំ ឆ្លើយតបបានទាន់ពេលវេលាទៅតាមតម្រូវការបន្ទាន់របស់សាលារៀន (ព្រួញជាប់) មានន័យថា មានតែអ្នកនៅមូលដ្ឋានទេ ដែលដឹងពីតម្រូវការអាទិភាពរបស់សាលារៀន ហើយអាចសម្រេចចិត្តប្រើប្រាស់ធនធាន តាមតម្រូវការអាទិភាពដែលបានកំណត់ និងពិនិត្យតាមដានការប្រើប្រាស់ធនធាននេះរួមគ្នា។ សិទ្ធិសម្រេចនៅ**ថ្នាក់មូលដ្ឋាន**នេះជាផ្នែកមួយនៃកម្មវិធីវិមជ្ឈការវិស័យអប់រំ ដែលស្របទៅនឹងកម្មវិធីកំណែទម្រង់វិមជ្ឈការតាមបែបប្រជាធិបតេយ្យរបស់រាជរដ្ឋាភិបាល។

ការប្រើប្រាស់យន្តការអន្តរាគមន៍ **ថ្នាក់មូលដ្ឋាន** ធ្វើឱ្យសេវាសាធារណៈ មានប្រសិទ្ធភាពដូចមានរៀបរាប់ខាងក្រោម។

## យន្តការអន្តរាគមន៍ឆ្ពោះទៅរកការគ្រប់គ្រងតាមសាលារៀន

សាប៊ែរ (SABER) បង្ហាញលទ្ធផលការសិក្សាស្រាវជ្រាវពីរករណីដូចខាងក្រោម៖

**១. នៅអាមេរិកឡាទីន** មានករណីតិចតួចណាស់ ដែលការគ្រប់គ្រងតាមសាលារៀនធ្វើឱ្យមានការប្រែប្រួលខ្លាំងជាវិជ្ជមាន លើលទ្ធផលសិក្សារបស់សិស្ស (Patrinos 2011) ដោយហេតុថា យន្តការកិច្ចអន្តរាគមន៍ដែលបានប្រើនៅអាមេរិកឡាទីនគឺ ផ្អែកលើមូលដ្ឋានទាំងស្រុង ក្នុងបរិបទដែលរចនាសម្ព័ន្ធស្ថាប័ន នៅខ្សោយ ហើយសេវាសាធារណៈ នៅមានការរំខានដោយសង្គ្រាមស៊ីវិល។ ការប្រើអភិក្រមការគ្រប់គ្រងតាមសាលារៀនធ្វើឱ្យអវត្តមានគ្រូ និងសិស្សថយចុះ តែមិនបង្ហាញពីការប្រែប្រួលជាវិជ្ជមាន លើលទ្ធផលសិក្សារបស់សិស្សនោះទេ។

**២. នៅអឺរ៉ុប** មានភស្តុតាងយ៉ាងច្រើន ដែលបង្ហាញពីការប្រែប្រួលជាវិជ្ជមាន លើស្វ័យភាពសាលារៀន និង លទ្ធផលសិក្សារបស់សិស្ស (Eurydice 2007)។ យន្តការកិច្ចអន្តរាគមន៍តាមអភិក្រម ការគ្រប់គ្រងតាមសាលារៀនគឺជា ដំណោះស្រាយដ៏មានប្រសិទ្ធភាព ដោយសារស្ថាប័នមានភាពរឹងមាំ ហើយសាលារៀនមានស្វ័យភាព និងគណនេយ្យភាព។ ក្នុងន័យនេះ ការគ្រប់គ្រងតាមសាលារៀន នឹងមានប្រសិទ្ធភាព ប្រសិនបើ បុគ្គលិកអប់រំថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិមានសមត្ថភាព ធ្វើឱ្យការដឹកនាំគ្រប់គ្រងសាលារៀន ឆ្លើយតបទៅនឹងតម្រូវការអាទិភាពរបស់សិស្ស និងគ្រូបង្រៀនទាន់ពេលវេលា។ តម្រូវការអាទិភាពរបស់សិស្ស និងគ្រូបង្រៀនត្រូវបានកំណត់តាមរយៈ ទិន្នន័យនិងព័ត៌មាន ពិតដែលបានមកពី ការវាយតម្លៃសិស្ស គ្រូបង្រៀន និងសាលារៀន ហើយព័ត៌មានទាំងនោះ ត្រូវផ្សព្វផ្សាយជាសាធារណៈ។ ការប្រើប្រាស់ និងផ្សព្វផ្សាយទិន្នន័យ និងព័ត៌មានពិតជាប្រចាំ ព្រមទាំងការដោះស្រាយបញ្ហាប្រកបដោយប្រសិទ្ធភាព នឹងធ្វើឱ្យសហគមន៍ បុគ្គលិកអប់រំ មានទំនុកចិត្តលើសាលារៀន ធ្វើឱ្យបុគ្គលិកអប់រំជឿទុកចិត្តគ្នាទៅវិញទៅមក ជាពិសេសធ្វើឱ្យមាតាបិតា / អ្នកអាណាព្យាបាលសិស្ស មានទំនុកចិត្តលើគ្រូបង្រៀន និងសាលារៀន។

គំរូខាងក្រោមជាគំនូសសង្ខេបនូវអ្វីដែលបានរៀបរាប់នេះ៖

គំរូប្រព័ន្ធវដ្តបិទជិត 3A កំណត់ក្របខ័ណ្ឌការងារដើម្បីឱ្យសាលារៀនមានស្វ័យភាព និងគណនេយ្យភាព។




## កត្តាទាក់ទងនៅពេលគ្រោងកម្មវិធីវិមជ្ឈការ

កត្តាទាំងបីនៃគំនូសបំព្រួញខាងលើ ត្រូវបានយកមកវិភាគ និងប្រើប្រាស់ក្នុងការរៀបចំ ចងក្រងសៀវភៅណែនាំប្រតិបត្តិការគ្រប់គ្រងតាមសាលារៀន៖

**កត្តាទី១៖** ផលសម្រេចអាស្រ័យលើការប្តេជ្ញាចិត្ត របស់អ្នកនយោបាយ ពន្ធដារ និងគោលនយោបាយ ក៏ដូចជាអន្តរកម្មរវាងគ្នា នឹងគ្នានៅគ្រប់កម្រិត ក្នុងប្រទេសនីមួយៗ (Litvak and Seddon 1999; Bardhan 2002)។

**កត្តាទី២៖** ការអនុវត្តរចនាសម្ព័ន្ធគណនេយ្យភាព តាមសាលារៀនត្រូវមានការគាំទ្រពីថ្នាក់ដឹកនាំ ហើយថ្នាក់ដឹកនាំទៀតសោត ត្រូវយល់ឱ្យបានច្បាស់ពីគោលបំណង ក្នុងការផ្តល់សេវាអប់រំប្រកបដោយគុណភាព និងសមធម៌។ ការធ្វើមជ្ឈការហួសហេតុពេក ឬការអនុវត្តស្វ័យភាពនៅមូលដ្ឋានសុទ្ធសាធ នឹងនាំមកនូវហានិភ័យដល់សាលារៀន ដូចនេះចាំបាច់ត្រូវរៀបចំឱ្យមានប្រព័ន្ធមួយដ៏ប្រសើរ ដែលនាំមកនូវកិច្ចសហប្រតិបត្តិការរវាងថ្នាក់ជាតិ ក្រោមជាតិ និងថ្នាក់សាលារៀនក្នុងការធ្វើការសម្រេចចិត្ត។

**កត្តាទី៣៖** ដើម្បីឱ្យសាលារៀនមានប្រសិទ្ធភាព ការធ្វើវិមជ្ឈការត្រូវផ្តោតសំខាន់លើការផ្លាស់ប្តូរសិទ្ធិអំណាចនៃរចនាសម្ព័ន្ធមានស្រាប់នៅក្នុងសហគមន៍ (គណៈកម្មការគ្រប់គ្រងសាលារៀន) លើការបង្កើនកាឡានុវត្តភាពក្នុងការចូលរួមរបស់គ្រប់ភាគីពាក់ព័ន្ធ (ប្រជាពលរដ្ឋក្រីក្រ ប្រជាពលរដ្ឋងាយរងគ្រោះ) នៅក្នុងដំណើរការសាលារៀន(Bardhan 2002)។

ការសម្រេចចិត្តផ្អែកលើអភិក្រមការគ្រប់គ្រងតាមសាលារៀនត្រូវធ្វើឡើងដោយគោរពតាមសមាសភាពទាំង ៥ដូចខាងក្រោម៖

1. ស្វ័យភាពក្នុងការធ្វើផែនការ និងការគ្រប់គ្រងថវិកាសាលារៀន
2. ស្វ័យភាពក្នុងការគ្រប់គ្រងបុគ្គលិក
3. តួនាទីគណៈកម្មការគ្រប់គ្រងសាលារៀន/SMC និងអភិបាលកិច្ចសាលារៀន
4. ការវាយតម្លៃសាលារៀន និងសិស្ស
5. គណនេយ្យភាពសាលារៀន

ខ្លឹមសារលម្អិតសម្រាប់អនុវត្តនឹងមានរៀបរាប់នៅក្នុងសេចក្តីណែនាំប្រតិបត្តិការគ្រប់គ្រងតាមសាលារៀន។

## បទពិសោធន៍ស្តីពីការគ្រប់គ្រងតាមសាលារៀននៅកម្ពុជា

គម្រោងកែលម្អគុណភាពអប់រំ (Education Quality Improvement Project) ដែលបានអនុវត្តនៅប្រទេសកម្ពុជាឆ្នាំ១៩៩៩-២០០៤ បានផ្តល់មូលនិធិដល់សាលារៀន ដោយប្រើប្រាស់អភិក្រម ការគ្រប់គ្រងតាមសាលារៀន។ ជាលទ្ធផលបង្ហាញថា (១)មានការពិភាក្សាការងារជាប្រចាំ នៅថ្នាក់សាលារៀន ក្រុង ស្រុក ខណ្ឌ និងខេត្ត-រាជធានី (២)ចាប់ផ្តើមមានការផ្លាស់ប្តូរជាវិជ្ជមាន លើការងាររដ្ឋបាលសាលារៀន ការរៀន-បង្រៀន បរិស្ថានសាលារៀន ការចូលរៀន អត្រាឡើងថ្នាក់ ការចូលរួមរបស់សិស្សស្រី គណនេយ្យភាពក្នុងការគ្រប់គ្រងសាលារៀន ការដឹកនាំនិងការឆ្លើយតបតម្រូវការមូលដ្ឋាន។ ប្រការនេះធ្វើឱ្យគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀន ទទួលបានការបំប៉នសមត្ថភាពជាប្រចាំ គោរពក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀនបានប្រសើរ និងធ្វើឱ្យសហគមន៍មានទំនុកចិត្តលើសាលារៀន។

ការផ្លាស់ប្តូរជាវិជ្ជមាន នៅសាលារៀនត្រូវបានបង្ហាញ តាមរយៈការរៀបចំឱ្យមាន ការប្រើប្រាស់បណ្ណាល័យប្រកបដោយប្រសិទ្ធភាព។ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត រាជធានី និងការិយាល័យ អប់រំយុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ បានជួយគាំទ្រដល់សាលារៀនផ្ទាល់ បានអនុវត្តគោលនយោបាយអប់រំប្រកបដោយភាពបត់បែន បានបង្កើតបណ្តាញគាំទ្ររឹងមាំ រវាងថ្នាក់កណ្តាល អ្នកជំនាញការក្នុងក្រុង ស្រុក ខណ្ឌ អ្នកជំនាញការមកពីអង្គការសង្គមស៊ីវិល និងមានគំនិតផ្តួចផ្តើម លើការកសាងសមត្ថភាព ដែលនាំទៅរកភាពខ្លាំងនៃបំណិនគ្រប់គ្រង។

បញ្ហាប្រឈមជាបទពិសោធន៍តាមរយៈការអនុវត្តគម្រោងរួមមាន៖

១. ការយកប្រយោជន៍ពីភាពបត់បែន ពង្រីកវិសាលភាពនៃសកម្មភាពមូលនិធិធ្វើជាទុន មុននឹងមានការសម្រេចចិត្តអនុវត្តជាក់ស្តែង នូវអ្វីដែលជាមេរៀនពិសោធន៍

២. យន្តការគ្រប់គ្រងនៅមានកម្រិត ដូចនេះត្រូវពង្រឹងតួនាទីថ្នាក់កណ្តាល ថ្នាក់ក្រោមជាតិ និងគ្រូបង្គោល

៣. សាលារៀនដែលបញ្ហាប្រឈមខ្លាំង ត្រូវការធនធាន និងជំនួយបច្ចេកទេសច្រើនជាងគេ

៤. ធនធានអាចមិនបានផ្តល់ទៅតាមតម្រូវការជាក់ស្តែង នៃសាលារៀននៅតំបន់ជួបការលំបាក។

៥. ត្រូវយកចិត្តទុកដាក់ខ្ពស់លើសមធម៌ ប្រាក់ឧបត្ថម្ភ ឬលាភសក្ការៈ

៦. ការពិនិត្យតាមដាន និងវាយតម្លៃ៖

ក. ធានានិរន្តរភាពនៃការពិនិត្យតាមដាន និងវាយតម្លៃជាផ្លូវការតាមរយៈការរៀបចំសិក្ខាសាលា របាយការណ៍ និងការឆ្លុះបញ្ចាំងពីមេរៀនពិសោធន៍កន្លងមក

ខ. ធ្វើអធិការកិច្ចរួមគ្នារវាងថ្នាក់ខេត្ត-រាជធានី និងក្រុង ស្រុក ខណ្ឌ ដោយកសាងក្រុមការងារជាក់លាក់ និងចែករំលែកបទពិសោធន៍ទទួលបានពីការធ្វើអធិការកិច្ច

គ. រៀបចំកាតរបាយការណ៍សាលារៀនដែលបង្ហាញនូវភាពជោគជ័យ និងប្រសិទ្ធភាពនៃការពិនិត្យតាមដាន និងអាចប្រើជាឧបករណ៍ជួយដល់ការរៀនសូត្រ និងកសាងសមត្ថភាព

ឃ. ពិនិត្យតាមដាន ថ្នាក់រាជធានី ខេត្ត ដើម្បីពិនិត្យ និងវាយតម្លៃលើការប្រែប្រួលជាវិជ្ជមាន និង

ង. វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ដែលជាផលសម្រេចឆ្លុះបញ្ចាំងពីការប្រែប្រួលជាវិជ្ជមានរបស់សាលារៀនដែលមានប្រសិទ្ធភាព។

## ១.៣ ទស្សនៈ បំណង និងវិសាលភាពនៃសេចក្តីណែនាំ

គោលបំណងនៃសេចក្តីណែនាំ គឺសម្រាប់មន្ត្រីថ្នាក់ក្រសួង រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សាលារៀន និងសហគមន៍យកទៅប្រើប្រាស់សម្រាប់ការបំប៉ន និងការគ្រប់គ្រងមានមូលដ្ឋាននៅសាលារៀន។ សៀវភៅណែនាំប្រតិបត្តិនេះ ក៏អាចត្រូវបានប្រើប្រាស់ជាឧបករណ៍គ្រប់គ្រង មានមូលដ្ឋាននៅសាលារៀន បន្ថែមលើប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើលទ្ធផល របស់អនុវិស័យដើម្បីពង្រឹងគុណភាពនៃការបង្រៀន និងគុណភាពសាលារៀន។

**វិសាលភាពនៃសេចក្តីណែនាំ**

| ល.រ | គោលដៅ | ចំនួន |
|---|---|---|
| 1 | សាលាមធ្យមសិក្សាបឋមភូមិ (បច្ចុប្បន្ន) | 100 |
| 2 | សាលាមធ្យមសិក្សាបឋមភូមិ (ថ្មី) | 30 |
| 3 | មន្ទីរអប់រំ យុវជន និងកីឡា | 25 |
| 4 | ការិយាល័យអប់រំ យុវជន និងកីឡា | 99 |
| 5 | មន្ត្រីអប់រំ | 2,500 |
| 6 | គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ | 3,000 |
| 7 | សិស្សមធ្យមសិក្សាបឋមភូមិ | 130,000 |
| 8 | សហគមន៍ និងមាតាបិតា | 300 |

# ជំពូក ២៖

# សេចក្តីណែនាំការគ្រប់គ្រងតាមសាលារៀន

## ២.១ ការគ្រប់គ្រងតាមសាលារៀន៖ ស្វ័យភាព និងគណនេយ្យភាព

តារាងខាងក្រោមអធិប្បាយពីតុល្យភាពនៃការទទួលខុសត្រូវរវាងក្រសួងអប់រំ យុវជន និងកីឡា ថ្នាក់ក្រោមជាតិ និងសាលារៀនលើការសម្រេចចិត្តទាក់ទងនឹងសកម្មភាពចម្បងៗ។ ការទទួលខុសត្រូវនេះត្រូវបានបែងចែកក្នុងគោលបំណងពង្រឹងប្រតិបត្តិការរបស់ប្រព័ន្ធនៅកម្រិតរចនាសម្ព័ន្ធសាលារៀន និងថ្នាក់ក្រោមជាតិ។

### ការសម្រេចចិត្តទាក់ទងនឹងសកម្មភាពចម្បងៗ

| សកម្មភាព | ថ្នាក់ជាតិនិងក្រោមជាតិ | សាលារៀន |
|---|---|---|
| ការគ្រោងថវិកា និងប្រាក់បៀវត្ស | កំណត់រូបមន្តថវិកា និងកម្រិតបៀវត្ស | ធ្វើផែនការ គ្រោងថវិកា រាយការណ៍ និងគ្រប់គ្រងការអនុវត្តបុគ្គលិក |
| ការជ្រើសរើសនិងការបញ្ជូនមន្រ្តី | ជ្រើសរើសនិងការបញ្ជូនមន្រ្តី | ជូនព័ត៌មានពីស្ថានភាពអនុវត្តរបស់មន្ត្រីនិងស្នើសុំការកែសម្រួល |
| កម្មវិធីសិក្សា | អភិវឌ្ឍកម្មវិធីសិក្សា | អនុវត្តកម្មវិធីសិក្សាតាមការណែនាំ និងកម្មវិធីបន្ថែម |
| ហេដ្ឋារចនាសម្ព័ន្ធ | រកមូលនិធិ សាងសង់សមត្ថភាព និងផ្តល់គ្រឿងសង្ហារឹម | គ្រប់គ្រងនិងសាងសង់សាលារៀន និងរកមូលនិធិ |
| ប្រតិទិនសិក្សា | កំណត់បទដ្ឋាន និងបែបបទពីប្រតិទិនសិក្សា | អនុវត្តបទដ្ឋាន និងបែបបទដោយបន្ស៊ីនឹងតម្រូវការមូលដ្ឋាន |
| ការពិនិត្យតាមដាន | អភិវឌ្ឍប្រព័ន្ធ និងសាងសង់សមត្ថភាពពិនិត្យតានដាន | អនុវត្តការពិនិត្យតាមដាននិងរាយការណ៍ពីការរីកចម្រើន |

| | | |
|---|---|---|
| មូលនិធិសាលារៀន | ផ្តល់មូលនិធិពីរដ្ឋ រកមូលនិធិពីរដ្ឋ និងរៀបចំ បែបបទពីការរកមូលនិធិនៅសាលារៀន | រកមូលនិធិនៅសាលារៀនទៅតាមគោលការណ៍ និងបែបបទក្នុងសេចក្តីណែនាំពីការរកមូលនិធិ |
| ការផ្សព្វផ្សាយព័ត៌មាន | កំណត់ទម្រង់ទិន្នន័យ៖ ធាតុចូល ថវិកា និងលទ្ធផលសិក្សា | ផ្សព្វផ្សាយ និងប្រើទិន្នន័យ |

## សិទ្ធិក្នុងការសម្រេចចិត្តមានរៀបរាប់នៅក្នុងរូបខាងក្រោមដែលមានឈ្មោះថាប្រព័ន្ធ3A មិនជិត



ខ្លឹមសារលម្អិតពីការអនុវត្តប្រព័ន្ធនេះ មានអធិប្បាយនៅក្នុងជំពូកនៃសៀវភៅណែនាំប្រតិបត្តិនេះ។ ស្វ័យភាព និងគណនេយ្យភាពសាលារៀនមានគោលបំណងចំនួន៥ ដែលមាននៅក្នុងជំពូកនៃសៀវភៅណែនាំប្រតិបត្តិនេះ។

## គណៈកម្មការគ្រប់គ្រងសាលារៀន និងរៀបចំបង្កើតគណៈកម្មការ

គណៈកម្មការគ្រប់គ្រងសាលារៀន ជារចនាសម្ព័ន្ធផ្លូវការ ដើម្បីគ្រប់គ្រងការអនុវត្តប្រចាំថ្ងៃ នៃការគ្រប់គ្រងតាមសាលារៀន។ គណៈកម្មការគ្រប់គ្រងសាលារៀន មានសមាសភាពចំនួន៦រូប ដែលជាមន្ត្រីក្រុមការងារគ្រប់គ្រងតាមសាលារៀន របស់ក្រសួងអប់រំ យុវជន និងកីឡា ក្រុមគ្រូបង្គោលមុខវិជ្ជាថ្នាក់ជាតិ គ្រូបង្រៀន និងបុគ្គលិកសាលារៀន តំណាងមាតាបិតា រួមបញ្ចូលទាំងគ្រួសារ អ្នកក្រ និងយ៉ាប់យឺន និងសហគមន៍ ដែលមានប្រធានភូមិ អ្នកមានប្រជាប្រិយ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។

នៅឆ្នាំ២០១៧ និង២០១៨ ដោយសារសមត្ថភាពសាលារៀន និងសហគមន៍នៅមានកម្រិត មន្ត្រីក្រសួងអប់រំ អាចដឹកនាំគណៈកម្មការគ្រប់គ្រងសាលារៀន និងអាចធ្វើជាប្រធានគណៈកម្មការ។ នៅក្រោយឆ្នាំ២០១៨ ប្រសិនបើគណៈកម្មការគ្រប់គ្រងសាលារៀន យល់ស្របថាខ្លួនមានសមត្ថភាពរឹងមាំ ហើយនោះ និងមិនត្រូវការមន្ត្រីក្រសួងអប់រំ ដឹកនាំគណៈកម្មការទេ នោះសមាសភាពរបស់គណៈកម្មការអាច ត្រូវបានពិនិត្យឡើងវិញ និងគណៈកម្មការដាក់ស្នើ សមាសភាពថ្មីមកការិយាល័យអប់រំ ក្រុង ស្រុក ខណ្ឌ ដើម្បីសម្រេច។

សមាសភាពនៃគណៈកម្មការគ្រប់គ្រងសាលារៀនមាន៖

១. ប្រធានគណៈកម្មការគ្រប់គ្រងសាលារៀនទទួលបន្ទុកមើលការខុសត្រូវប្រតិបត្តិការរួម

២. អនុប្រធាន ទទួលបន្ទុកការធ្វើផែនការ និងការគ្រប់គ្រងថវិកាសាលរៀន

៣. អនុប្រធាន ទទួលបន្ទុកការគ្រប់គ្រងមន្ត្រី

៤. សមាជិក ទទួលបន្ទុកការចូលរួមរបស់សហគមន៍ និងអភិបាលកិច្ចសាលារៀន

៥. សមាជិក ទទួលបន្ទុកការវាយតម្លៃសាលារៀន និងសិស្ស

៦. សមាជិក ទទួលបន្ទុក គណនេយ្យភាពសាលារៀន។

គណៈកម្មការគ្រប់គ្រងសាលារៀន ត្រូវបានសម្រេចដោយការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ។

នៅឆ្នាំ២០១៧ នាយកសាលារៀនគប្បីអញ្ជើញមាតាបិតា តំណាងមាតាបិតា រួមបញ្ចូលទាំងគ្រួសារអ្នកក្រនិងយ៉ាប់យ៉ឺន និងសហគមន៍ដែលមានប្រធានភូមិ អ្នកមានប្រជាប្រិយ សមាជិកក្រុមប្រឹក្សាឃុំសង្កាត់ គ្រូបង្រៀន និងបុគ្គលិកសាលារៀន និងមន្ត្រីក្រុមការងារគ្រប់គ្រងតាមសាលារៀន របស់ក្រសួងអប់រំ គ្រូបង្គោលមុខវិជ្ជាថ្នាក់ជាតិ ចូលរួមប្រជុំបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន។ លិខិតអញ្ជើញគប្បីផ្ញើតាមសិស្ស ឬគ្រូបង្រៀន ឬបុគ្គលិកសាលារៀន។ នាយកសាលារៀនធានាថាគ្រួសារក្រីក្រ ឬយ៉ាប់យ៉ឺនត្រូវបានអញ្ជើញឱ្យចូលរួមប្រជុំ។ មន្ត្រីក្រសួងអប់រំនឹងជួយការងារនេះនៅឆ្នាំសិក្សា២០១៧-២០១៨។

ការប្រជុំគប្បីធ្វើតាមរបៀបដូចខាងក្រោមៈ

1. មន្ត្រីក្រសួងអប់រំ/នាយក ឬ នាយិកាសាលារៀននឹងជូនព័ត៌មានសាវតារនៃការប្រជុំ (មានរៀបរាប់ក្នុងសាវតារ នៃសេចក្តីណែនាំ) វត្ថុបំណងនៃការប្រជុំ (ការបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន) សមាសភាព នៃអ្នកឈរឈ្មោះ និងគណៈកម្មការ និងជំហាននៃការជ្រើសរើសសមាសភាពគណៈកម្មការគ្រប់គ្រង សាលារៀន
2. ជំហាននៃការបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀនៈ
   - ស្នើសុំសមាជិកអង្គប្រជុំ ឈ្មោះអ្នកឈរឈ្មោះជាគណៈកម្មការគ្រប់គ្រងសាលារៀន
   - សរសេរឈ្មោះលើក្រដាសធំ និងដាក់លេខរៀងនៅខាងមុខឈ្មោះនីមួយៗ
   - សមាជិកអង្គប្រជុំបោះឆ្នោតជ្រើសយកឈ្មោះអ្នកនៅក្នុងបញ្ជីជាប្រធានគណៈកម្មការគ្រប់គ្រងសាលារៀន។ សមាជិកម្នាក់សរសេរលេខរៀងនៃឈ្មោះមនុស្សម្នាក់ ដែលខ្លួនចង់ជ្រើសរើសជាប្រធានគណៈកម្មការ ផ្តល់ដល់ប្រធានអង្គប្រជុំ ហើយប្រធានអង្គប្រជុំ គូសនៅខាងឈ្មោះអ្នកឈរឈ្មោះនោះ។ ចំពោះអ្នកឈរឈ្មោះណាដែលមានចំនួនគូសច្រើនជាងគេនឹងត្រូវបានជ្រើសរើសជាប្រធានគណៈកម្មការគ្រប់គ្រងសាលារៀន
   - អនុវត្តដូចគ្នាក្នុងការជ្រើសរើសសមាជិកគណៈកម្មការផ្សេងៗទៀត
   - បញ្ចប់ការជ្រើសរើសសមាសភាពទាំង៦រូប នៅក្នុងបញ្ជីចុងក្រោយទៅតាមតួនាទីនៃស្វ័យភាព និងគណនេយ្យភាពសាលារៀន
   - សមាជិកជាប់ឆ្នោតចុះហត្ថលេខាលើបញ្ជីចុងក្រោយ។
3. ដាក់ស្នើបញ្ជីឈ្មោះទៅការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ដើម្បីអនុម័ត។ អាណត្តិ របស់គណៈកម្មការគ្រប់គ្រងសាលារៀនគឺ១ឆ្នាំ។ ប្រសិនបើគណៈកម្មការមានដំណើរការធម្មតាគឺ អាចនៅបន្តដោយមានការយល់ព្រមពីការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ។ ប្រសិនបើគណៈកម្មការមិនដំណើរការ នោះត្រូវធ្វើការជ្រើសរើសជាថ្មីនៅឆ្នាំបន្ទាប់។

## តួនាទីនិងភារកិច្ចរបស់គណៈកម្មការគ្រប់គ្រងសាលារៀន និងនាយក ឬ នាយិកាសាលារៀន

| តួនាទីនិងភារកិច្ចរបស់គណៈកម្មការគ្រប់គ្រងសាលារៀន | តួនាទីនិងភារកិច្ចរបស់នាយក ឬ នាយិកាសាលារៀន |
|---|---|
| **ការធ្វើផែនការ និងការគ្រប់គ្រងថវិកាសាលារៀន** | |
| 1. អនុម័តសូចនាករផលសម្រេច និងក្រុមគោលដៅ សម្រាប់៣ឆ្នាំ<br>2. អនុម័តផែនការកែលម្អសាលារៀន និងថវិកាឆ្នាំ<br>3. ផ្តល់ការព្រមព្រៀងលើការវាយតម្លៃការអនុវត្តរបស់សាលារៀនធៀបជាមួយនឹងស្តង់ដាសាលារៀនមានប្រសិទ្ធភាព<br>4. គាំទ្រ និងជួយដល់ការរកមូលនិធិសាលារៀន។ | 1. សម្របសម្រួលការពិភាក្សា និងសម្របសម្រួលមនុស្សឱ្យធ្វើការជាមួយគ្នា ក្នុងការរៀបចំសូចនាករផលសម្រេច និងក្រុមគោលដៅសម្រាប់៣ឆ្នាំ និងផែនការកែលម្អសាលារៀន និងថវិកាឆ្នាំ<br>2. ដាក់ជូនលទ្ធផលវាយតម្លៃការអនុវត្តរបស់សាលារៀនធៀបជាមួយនឹងស្តង់ដាសាលារៀនមានប្រសិទ្ធភាពដល់គណៈកម្មការគ្រប់គ្រងសាលារៀន<br>3. គ្រប់គ្រង សម្របសម្រួលការពិភាក្សា និងសម្របសម្រួលមនុស្សឱ្យធ្វើការជាមួយគ្នាលើសកម្មភាពរកមូលនិធិសាលារៀន |
| **ការគ្រប់គ្រងមន្ត្រី** | |
| 5. អនុម័តរង្វាន់ដល់មន្ត្រីដែលបានបំពេញការងារបានល្អប្រសើរ<br>6. ស្នើវិធានការរដ្ឋបាលសម្រាប់មន្ត្រីមិនអនុវត្តភារកិច្ចដល់ថ្នាក់ក្រោមជាតិ<br>7. អនុម័តរង្វាន់សម្រាប់នាយក ឬ នាយិកាដែលបានបំពេញការងារល្អប្រសើរ | 4. អនុវត្តប្រព័ន្ធគ្រប់គ្រងការអនុវត្តការងាររបស់មន្ត្រី និងដាក់ស្នើ ផ្តល់រង្វាន់ដល់មន្ត្រីដែលបានបំពេញការងារល្អប្រសើរ<br>5. ស្នើដល់គណៈកម្មការគ្រប់គ្រងសាលារៀននូវវិធានការ<br>រដ្ឋបាលសម្រាប់មន្ត្រីមិនអនុវត្តភារកិច្ច |

| តួនាទីសហគមន៍ និងអភិបាលកិច្ចសាលារៀន | |
|---|---|
| 8. គាំទ្រក្នុងការដោះស្រាយបញ្ហាដែលលើកឡើង ដោយមាតាបិតានិងសិស្សពីការពិនិត្យតាមដានសាលារៀននិងថ្នាក់រៀន | 6. សម្របសម្រួលធានាដំណើរការដោយរលូននូវការអនុវត្តសកម្មភាពជាតួនាទីរបស់សហគមន៍ និងអភិបាលកិច្ចសាលារៀន<br>7. ពិនិត្យឡើងវិញនិងដាក់ស្នើការកែសម្រួលដើម្បី |

| | |
|---|---|
| 9. ធានាតម្លាភាពក្នុងការចូលរួមរបស់សហគមន៍ | ធានានូវតម្លាភាពក្នុង ការចូលរួមរបស់សហគមន៍ |
| **ការវាយតម្លៃសាលារៀន និងសិស្ស** | |
| 10. អនុម័តលទ្ធផលវាយតម្លៃការអនុវត្តរបស់ សាលារៀន<br>11. ទទួលស្គាល់របាយការណ៍រីកចម្រើនប្រចាំត្រីមាសពីការអនុវត្តផែនការកែលម្អសាលារៀន<br>12. ទទួលស្គាល់របាយការណ៍រីកចម្រើនប្រចាំឆ្នាំពីការសម្រេចសូចនាករនិងក្រុមគោលដៅផលសម្រេច | 8. សម្របសម្រួលការពិភាក្សា និងសម្របសម្រួលមនុស្សឱ្យធ្វើការវាយតម្លៃការអនុវត្តរបស់សាលារៀនធៀបនឹងស្តង់ដាសាលារៀនមានប្រសិទ្ធភាព<br>9. ចងក្រងទិន្នន័យ និងព័ត៌មានសម្រាប់ផលិតរបាយការណ៍ រីកចម្រើនប្រចាំត្រីមាស ពីការរីកចម្រើនការអនុវត្តផែនការកែលម្អសាលារៀនដល់គណៈកម្មការគ្រប់គ្រងសាលារៀន<br>10. ចងក្រងទិន្នន័យ និងព័ត៌មានសម្រាប់ផលិត និងដាក់ស្នើរបាយ ការណ៍រីកចម្រើនប្រចាំឆ្នាំពីការសម្រេចសូចនាករនិងក្រុមគោលដៅផលសម្រេច |
| គណនេយ្យភាពសាលារៀន | |
| 13. ទទួលស្គាល់របាយការណ៍ទាំងឡាយដែលត្រូវ ផ្សព្វផ្សាយជាសាធារណៈ | 11. រៀបចំនិងដាក់ស្នើនូវរបាយការណ៍ទាំងឡាយដែលត្រូវផ្សព្វផ្សាយជាសាធារណៈដល់គណៈកម្មការគ្រប់គ្រងសាលារៀន |

## ២.២ ស្វ័យភាពក្នុងការធ្វើផែនការ និងការគ្រប់គ្រងថវិកាសាលារៀន

### ២.២.១ ក្របខណ្ឌការងារសាលារៀនមានប្រសិទ្ធភាព

ខ្លឹមសារខាងក្រោមផ្តល់នូវក្របខណ្ឌ ការងាររបស់សាលារៀនដល់សាលារៀន សហគមន៍ មាតាបិតា គ្រូបង្រៀន និងសិស្សអាចរៀនសូត្រ ហើយធ្វើការសម្រេចចិត្តថា ត្រូវធ្វើសកម្មភាពអ្វីដែលឆ្លើយតបទៅនឹង តម្រូវការចាំបាច់ និងជាអាទិភាពសម្រាប់សាលារៀននីមួយៗរបស់ខ្លួន។ ក្រសួងនឹងផ្តល់មូលនិធិកែលម្អសាលារៀន ដល់សាលារៀន ដើម្បីបំពេញការងាររបស់ខ្លួន។ បន្ថែមទៀតក្រសួងនឹង ផ្តល់មូលនិធិដល់ថ្នាក់ជាតិក្នុងការបំប៉ន មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ សហគមន៍ និងមាតាបិតាក្នុងការចូលរួមអនុវត្ត កញ្ចប់ពិសេសនេះ និងមូលនិធិដល់គ្រូបង្រៀនចូលរៀនវគ្គ វិក្រឹតការគ្រូបង្រៀន ដើម្បីទទួលបានបរិញ្ញាបត្រអប់រំ។ ក្រសួងនឹងផ្តល់ថវិកាដល់មន្ទីរអប់រំ និងការិយាល័យអប់រំសម្រាប់ចុះជួយ និងបំពេញតម្រូវការខ្វះធាតុចូលដល់សាលារៀន។

#### ១ បេសកកម្មសាលារៀន

ផ្តល់ការអប់រំមានគុណភាពខ្ពស់ដល់សិស្សចូលរៀន នៅសាលារៀនមានប្រសិទ្ធភាពពីឆ្នាំសិក្សា ២០១៧-២០១៨ ដល់ឆ្នាំសិក្សា ២០២១-២០២២។

#### ២ រចនាសម្ព័ន្ធលទ្ធផលសាលារៀនមានប្រសិទ្ធភាព

| គោលបំណង | យុទ្ធសាស្ត្រ | ការវាស់វែង | លទ្ធផលចុងក្រោយ |
|---|---|---|---|
| **១. ធ្វើឱ្យប្រសើរការសិក្សា និងផលសិក្សា របស់សិស្ស** | ផ្តល់ជាប់ជាបន្តការជួយសិស្សរៀនយឺត រៀបចំលំនាំបង្រៀននិងប្រព័ន្ធតេស្ត ផ្តល់ការបំប៉នគ្រូនៅនឹងកន្លែង ផ្អែកលើ ការវាយតម្លៃ សមត្ថភាពគ្រូ ផ្តល់ការបំប៉នតាមរយៈវិក្រឹតការគ្រូឱ្យមានបរិញ្ញាបត្រ | ការវាយតម្លៃការបំពេញការងារ កិច្ចការគម្រោង វត្តមាន ផលិតផលគ្រូសិស្ស កាតលទ្ធផលសិក្សា | សិស្សនឹង៖<br>១. អានមានប្រសិទ្ធភាព និងទំនាក់ទំនងច្បាស់លាស់តាមការសរសេរនិងនិយាយ<br>២. ប្រើលេខនិងធ្វើលំហាត់ គណិតវិទ្យានិងវិទ្យាសាស្ត្រតាមសៀវភៅលំហាត់<br>៣. គិតដោយឯករាជ្យ ដាក់លាក់ប្រឌិតញាណ និងដោះស្រាយបញ្ហា<br>៤. គោរពអ្នកដទៃ និងមានចរិយាថ្លៃថ្នូ និងមានសីលធម៌<br>៥. ធ្វើកិច្ចការមានប្រសិទ្ធ ដោយបុគ្គលខ្លួនឯង និងជាក្រុម |
| **២. ផ្តល់បរិស្ថានសិក្សាមាន សុវត្ថិភាពនិង ផ្តោតលើសិស្ស** | គ្រប់គ្រងថ្នាក់រៀន និងគុណភាព ទិន្នន័យ រៀបចំឆ្លាសាលារៀនស្អាត មានអនាម័យ និងមានពណ៌បៃតង លើកទឹកចិត្ត គ្រូបង្រៀន តាមរយៈការគ្រប់គ្រង ការអនុវត្ត ផ្តល់ការលើកទឹកចិត្តសិស្សឆ្នើម | ស្ថិតិព័ត៌មាន៖ ចូលរៀន បោះបង់ ត្រួតថ្នាក់ ឡើងថ្នាក់ សិក្សាពីការចូលចិត្តសាលារៀន | |
| **៣. បង្កើនការ ចូលរួមពីមាតា បិតានិង សហគមន៍** | ពិនិត្យការអនុវត្តនិងតម្លាភាពសាលារៀន បង្កើតបរិយាកាសក្នុងប្រព័ន្ធ សាលារៀនដែលមានភាពបើកទូលាយមានការទុកចិត្ត និងសហការគ្នាជួបមាតាបិតា ទៀងទាត់ និងសួរសុខទុក្ខដល់ផ្ទះ | សន្និបាតឆ្នាំសិក្សា វាយតម្លៃកម្មវិធី ទស្សនាវដ្តីសាលា | |

| | | | |
|---|---|---|---|
| ៤. ធ្វើឱ្យប្រសើរ នូវប្រសិទ្ធភាព និងប្រសិទ្ធផលរបស់ប្រព័ន្ធ | ផ្តល់ធាតុចូលដល់សាលារៀនទាន់ពេលលើកទឹកចិត្តនាយកសាលាតាមរយៈការគ្រប់គ្រងការបំពេញការងារធ្វើឱ្យប្រសើរការអនុវត្តសាលារៀនតាមរយៈការរកឃើញពីខាងក្រៅ និងអនុវត្តការរកឃើញពីសវនកម្ម | ផែនការកែលម្អសាលារៀន ប័ណ្ណប្រៀបធៀបសូចនាករសាលារៀន | |

## ៣ កម្មវិធី និងសកម្មភាពសាលារៀនមានប្រសិទ្ធភាព

កម្មវិធីចម្បងៗសម្រាប់មូលនិធិ កែលម្អសាលារៀនមានចំនួន៤ ដែលសាលារៀននីមួយៗអាចយកប្រើប្រាស់ជាក្របខ័ណ្ឌរួម សម្រាប់ការធ្វើផែនការកែលម្អសាលារៀន និងគ្រោងស្នើមូលនិធិមកក្រសួងអប់រំ យុវជន និងកីឡា។

កម្មវិធីចម្បងៗទាំងបួននេះ បានរៀបចំឡើងស្របគ្នាជាមួយនឹង គោលបំណងទាំង៤របស់មូលនិធិកែ លម្អសាលារៀន។ កម្មវិធីទាំងបួននេះមាន៖

- កម្មវិធីបង្កើនគុណភាពបង្រៀនជាប្រព័ន្ធ
- កម្មវិធីកែលម្អបរិស្ថានសិក្សា
- កម្មវិធីពង្រឹងសមត្ថភាព និងការចូលរួមរបស់សហគមន៍ និងមាតាបិតា
- កម្មវិធីពង្រឹងការដឹកនាំ និងការគ្រប់គ្រងសាលារៀន

## កម្មវិធីខាងក្រោមជាកម្មវិធីគាំទ្រពីថ្នាក់ក្រសួង និងថ្នាក់ក្រោមជាតិ

ក្នុងកម្មវិធីនីមួយៗមានរៀបរាប់ពីការផ្សារភ្ជាប់រវាងគោលបំណង យុទ្ធសាស្ត្រ និងសកម្មភាពកម្មវិធីដូចមានខាងក្រោម៖

### ១. កម្មវិធីបង្កើនគុណភាពបង្រៀនជាប្រព័ន្ធ

| គោលបំណងទី១៖ ធ្វើឱ្យប្រសើរដល់ការសិក្សានិងផលសិក្សារបស់សិស្ស | |
|---|---|
| **យុទ្ធសាស្ត្រ** | **សកម្មភាពកម្មវិធី** |
| • ផ្តល់ការគាំទ្រជាប់ជាប្រចាំចំពោះសិស្សរៀនយឺត | • ការវាយតម្លៃសមត្ថភាពសិស្ស៖<br>○ សិស្សថ្នាក់ទី៧ នៅដើមឆ្នាំលើសមត្ថភាពភាសាខ្មែរនិងគណិតវិទ្យា ហើយរៀប |

| | |
|---|---|
| • **រៀបចំលំនាំបង្រៀននិងប្រព័ន្ធតេស្ត**<br>• **ផ្តល់ការបំប៉នគ្រូនៅនឹងកន្លែងផ្អែកលើការវាយតម្លៃសមត្ថភាពគ្រូ**<br>• **ផ្តល់ការបំប៉នតាមរយៈវិក្រឹតការគ្រូឱ្យមានបរិញ្ញាបត្រ** | ថ្នាក់បង្រៀនបន្ថែម<br>○ វាយតម្លៃនៅចុងការបង្រៀននៃគ្រប់មេរៀនឬម៉ោងបង្រៀន ដែលភ្ជាប់គោលគំនិតជាមួយការយល់ដឹង បិទការអនុវត្ត ហើយរៀបចំថ្នាក់បន្ថែមជួយដល់សិស្សរៀនយឺត<br>○ វាយតម្លៃនៅចុងឆមាសទី១ និងទី២<br>• សកម្មភាពក្រៅថ្នាក់៖ ធ្វើកិច្ចការគម្រោងជាក្រុម ឬ បុគ្គល រៀនបំណិនជីវិត បំណិនសិល្បៈ រៀនតាមក្លឹបសិក្សា ទស្សនកិច្ចនៅសហគមន៍<br>• វាយតម្លៃសមត្ថភាពគ្រូលើចំណេះដឹងពីមុខវិជ្ជា និងបំណិនគរុកោសល្យ<br>• រៀបចំផែនការ និងខ្លឹមសារបំប៉នគ្រូពេលបំពេញការងារ និងពង្រឹងសមត្ថភាពក្រុមបច្ចេកទេស រៀបចំលំនាំបង្រៀន ហាត់បង្រៀន ផលិតឯកសារសិក្សាមេរៀន ឬការស្រាវជ្រាវសកម្ម កិច្ចតែងការ សៀវភៅលំហាត់ និងសំណុំសំណួរតេស្ត ប្រើលទ្ធផលតេស្តកែលម្អការបង្រៀន និងផ្លិតកាតរបាយការណ៍ប្រៀបធៀបលទ្ធផលតេស្ត ថ្នាក់រៀនក្នុងគោលបំណងរៀនសូត្រ<br>• ការធ្វើវិក្រឹតការគ្រូបង្រៀន (ការទទួលខុសត្រូវរបស់ថ្នាក់ក្រសួង)<br>○ ជ្រើសរើសគ្រូបង្រៀន<br>○ មហាវិទ្យាល័យអប់រំ៖ ដាក់សំណើជារបាយការណ៍វាយតម្លៃមហាវិទ្យាល័យធៀបជាមួយនឹងស្តង់ដាមហាវិទ្យាល័យអប់រំគ្រូបង្រៀនមកគណៈកម្មការគ្រប់គ្រងគម្រោងរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលបញ្ជាក់នូវលទ្ធភាពផ្តល់វិក្រឹតការគ្រូបង្រៀន<br>○ គណៈកម្មការគ្រប់គ្រងគម្រោងពិនិត្យសំណើ និងសម្រេចចិត្តថាចុះពិនិត្យការអនុវត្តតាមមហាវិទ្យាល័យ ព្រមទាំងផ្តល់សិទ្ធិឱ្យមហាវិទ្យាល័យ អាចដាក់ស្នើគម្រោងថវិកាបាន<br>○ មហាវិទ្យាល័យរៀបចំលើកគម្រោងផែនការសកម្មភាព និងថវិកាមកគណៈកម្មការគ្រប់គ្រងគម្រោងរបស់ក្រសួងក្រសួងអប់រំ យុវជន និងកីឡា<br>○ គណៈកម្មការគ្រប់គ្រងគម្រោងរបស់ក្រសួងអប់រំ យុវជន និងកីឡា ពិនិត្យ និងសុំព័ត៌មានបន្ថែមតាមការចាំបាច់ អនុម័តលើគម្រោងផែនការ និងផ្ទេរថវិកាតាមកិច្ចសន្យា<br>○ ចុះពិនិត្យតាមដានការអនុវត្តរបស់មហាវិទ្យាល័យ និងសិស្ស |

២. កម្មវិធីកែលម្អបរិស្ថានសិក្សា

| គោលបំណងទី២៖ ផ្តល់បរិស្ថានសិក្សាមានសុវត្ថិភាព និងផ្តោតលើសិស្ស | |
|---|---|
| **យុទ្ធសាស្ត្រ** | **សកម្មភាពកម្មវិធី** |
| • **គ្រប់គ្រងថ្នាក់រៀន និងគុណភាពទិន្នន័យ រៀបចំ ធ្លាសាលារៀនស្អាត មានអនាម័យ និងមាន ពណ៌បៃតង**<br>• **លើកទឹកចិត្តគ្រូបង្រៀនតាមរយៈការគ្រប់គ្រងការអនុវត្ត**<br>• **ផ្តល់ការលើកទឹកចិត្តសិស្សឆ្នើម** | • វាយតម្លៃការគ្រប់គ្រងថ្នាក់រៀន និងរៀបផែនការកែលម្អថ្នាក់រៀនបំពេញនូវការខ្វះខាត<br>• រៀបចំថ្នាក់មុខវិជ្ជា<br>• នាយក-នាយករងពិនិត្យការបង្រៀនក្នុងថ្នាក់ និងផ្តល់យោបល់កែលម្អ<br>• គូរផែនទីក្នុងសាលារៀន រួមមានប្រព័ន្ធបង្ហូរទឹក ផ្លូវដើរ និងផ្លូវភ្ជាប់អគារសិក្សា សួនច្បារ ទីកន្លែងរៀនក្រៅថ្នាក់ [ក្រោមដំបូលដែលសង់លើផ្លូវដើរភ្ជាប់អគារសិក្សា] ទីកន្លែងកីឡា រោងជាង បង្គន់អនាម័យ ប្រព័ន្ធទឹក-ស្អាត ប្រព័ន្ធអគ្គិសនីដល់ថ្នាក់រៀន ។ល។<br>• រៀបចំផែនការសាងសង់ និងថែទាំហេដ្ឋារចនាសម្ព័ន្ធ ដាក់គម្រោងស្នើថវិកាមកក្រសួង ក្រសួងពិនិត្យ និងសម្រេចលើបរិមាណថវិកាស្នើ<br>• អនុវត្ត និងថែទាំហេដ្ឋារចនាសម្ព័ន្ធតាមបរិមាណគម្រោងស្នើថវិកា និងបរិមាណថវិកាបានអនុម័ត<br>• ពិភាក្សា និងរៀបចំកិច្ចសន្យាជាមួយបុគ្គលិកបង្រៀន និងមិនបង្រៀន<br>• វាយតម្លៃការអនុវត្តការងាររបស់បុគ្គលិកបង្រៀន និងមិនបង្រៀនតាមកិច្ចសន្យា និងប្រព័ន្ធវាយតម្លៃការអនុវត្តការងារ សម្រេចចិត្តថាអ្នកណាត្រូវបន្តកិច្ចសន្យា ឬត្រូវបញ្ឈប់<br>• ផ្តល់រង្វាន់លើកទឹកចិត្តអ្នកអនុវត្តបានប្រសើរ<br>• វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស និងផ្តល់រង្វាន់លើកទឹកចិត្តសិស្ស |

## ៣. កម្មវិធីពង្រឹងសមត្ថភាព និងការចូលរួមរបស់សហគមន៍ និងមាតាបិតា

| គោលបំណងទី១៖ កម្មវិធីពង្រឹងសមត្ថភាព និងការចូលរួមរបស់សហគមន៍ និងមាតាបិតា | |
|---|---|
| **យុទ្ធសាស្ត្រ** | **សកម្មភាពកម្មវិធី** |
| • **ពិនិត្យការអនុវត្តនិងតម្លាភាពសាលារៀន**<br>• **បង្កើតបរិយាកាសក្នុងប្រព័ន្ធសាលារៀនដែលមានភាពបើកទូលាយមានការទុកចិត្ត និងសហការគ្នា**<br>• **ជួបមាតាបិតាទៀងទាត់ និងសួរសុខទុក្ខដល់ផ្ទះ** | • រៀបចំវាយតម្លៃសាលារៀនដោយខ្លួនឯងនៅដំណាច់ឆ្នាំសិក្សាដោយផ្អែកលើទិន្នន័យនិងភស្តុតាងនៃសូចនាករសាលារៀនមានប្រសិទ្ធភាព<br>• រៀបចំផែនការកែលម្អសាលារៀន និងថវិកាសម្រាប់ឆ្នាំសិក្សាបន្ទាប់ ជាមួយគ្រប់អ្នកពាក់ព័ន្ធតាមការណែនាំ<br>• រៀបចំពិធីបើកបវេសនកាល ដោយជូនព័ត៌មានដល់គ្រប់អ្នកពាក់ព័ន្ធពីផែនការរបស់សាលារៀន<br>• ពិនិត្យធាតុចូលដែលថ្នាក់រៀននិងសិស្សត្រូវការ និងរៀបចំការប្រជុំទៀងទាត់កម្រិតថ្នាក់រៀនរវាងគ្រូបង្រៀន មាតាបិតា និងសិស្ស តាមការណែនាំ<br>• ធ្វើទស្សនកិច្ចសួរសុខទុក្ខដល់ផ្ទះគ្រួសារសិស្ស ដែលកូនចៅមករៀនមិនទៀងទាត់ឬរៀនយឺតឬប្រឈមនឹងការបោះបង់ការសិក្សា<br>• រៀបចំនិងបិទផ្សាយជាសាធារណៈនូវថវិកា និងការចំណាយលម្អិត ប្រចាំត្រីមាសនិងឆ្នាំ<br>• រៀបចំប្រជុំពិនិត្យឡើងវិញប្រចាំត្រីមាស ពីការរីកចម្រើនក្នុងការអនុវត្ត ផែនការឆ្នាំ ហើយសុំឱ្យថ្នាក់ក្រុង ស្រុក ខណ្ឌ ឬ រាជធានី ខេត្ត ជួយតាមការចាំបាច់<br>• រៀបចំពិធីជួបជុំគ្រួសារ ឬ សកម្មភាពសិល្បៈនៅសាលារៀន ប្រចាំត្រីមាស និងនៅចុងឆ្នាំ ដើម្បីចងសម្ព័ន្ធភាពសហប្រតិបត្តិការ រវាងសាលារៀននិងសហគមន៍-មាតាបិតានិងសិស្ស។ |

## ៤. កម្មវិធីពង្រឹងការដឹកនាំ និងការគ្រប់គ្រងសាលារៀន

| គោលបំណងទី៤៖ ធ្វើឱ្យប្រសើរនូវប្រសិទ្ធភាពនិងប្រសិទ្ធផលរបស់ប្រព័ន្ធ | |
|---|---|
| **យុទ្ធសាស្ត្រ** | **សកម្មភាពកម្មវិធី** |
| • ផ្តល់ធាតុចូលដល់សាលារៀនទាន់ពេល<br>• លើកទឹកចិត្តនាយកសាលាតាមរយៈការគ្រប់គ្រង ការបំពេញការងារ<br>• ធ្វើឱ្យប្រសើរការអនុវត្តសាលារៀនតាមរយៈការរកឃើញពីខាងក្រៅ និងអនុវត្តការរកឃើញពីសវនកម្ម | • ពិភាក្សា និងរៀបចំចុះកិច្ចសន្យាជាមួយនាយក-នាយករង។ វាយតម្លៃការអនុវត្ត និងសម្រេចចិត្តថាត្រូវបន្តកិច្ចសន្យា ឬ មិនបន្តកិច្ចសន្យានៅឆ្នាំបន្ទាប់<br>• គ្រប់គ្រង និងអនុវត្តការសាងសង់សំណង់អគារសិក្សាដែលជាថវិកាគ្រប់គ្រងដោយថ្នាក់ជាតិ<br>• ធានាថាគ្រប់ធាតុចូលដែលទទួល និងផលិតផលត្រូវបានប្រើប្រាស់ពេញលេញ៖ ចំនួនម៉ោងបង្រៀន វត្តមាន-អវត្តមានគ្រូបង្រៀន សៀវភៅសិក្សាគោល សៀវភៅលំហាត់និងសំណួរតេស្ត ឯកសារសិក្សាមេរៀន កិច្ចតែងការ សៀវភៅទំនាក់ទំនងមាតាបិតា សៀវភៅតាមដានការសិក្សាសិស្ស ។ល។<br>• ស្នើការជួយពីការិយាល័យអប់រំ ដោយមានការបញ្ចូលទៅក្នុងផែនការរបស់ការិយាល័យ និង កត់ត្រាពីការជួយរបស់ការិយាល័យ<br>• កត់ត្រា និងចងក្រងគ្រប់ព័ត៌មានត្រូវការសម្រាប់ការពិនិត្យតាមដានការងារអធិការកិច្ច សវនកម្ម និងការធ្វើផែនការឆ្នាំសិក្សាបន្ទាប់<br>• រៀបចំការប្រជុំបូកសរុបលទ្ធផលការសិក្សារបស់សិស្ស និងការបំពេញការងាររបស់សាលារៀនប្រចាំឆ្នាំជាមួយគ្រប់អ្នកពាក់ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ សហគមន៍ និងមាតាបិតាសិស្ស<br>• រៀបចំសកម្មភាពស្វែងរកមូលនិធិ និងចំណូលពីគ្រប់ប្រភព។ |

## កម្មវិធីខាងក្រោមជាកម្មវិធីគាំទ្រពីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ៖

### ១. ការពង្រឹងសមត្ថភាពមន្ត្រី និងប្រព័ន្ធថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងសាលារៀន

| គោលបំណងទី៩៖ កែលម្អប្រសិទ្ធភាព និងប្រសិទ្ធផលប្រព័ន្ធសាលារៀន | |
|---|---|
| **យុទ្ធសាស្ត្រ**<br>• កសាងសមត្ថភាពធនធានមនុស្សអនុវត្តគោលការណ៍ណែនាំមូលនិធិកែលម្អសាលារៀន<br>• កសាងសមត្ថភាពប្រព័ន្ធពិនិត្យតាមដានផ្អែកលើលទ្ធផល<br>• កសាងសមត្ថភាពអនុវត្តសកម្មភាពអាទិភាពរបស់ក្រសួង | **១.១ សកម្មភាពកម្មវិធីថ្នាក់ជាតិសម្រាប់សាលារៀនមានប្រសិទ្ធភាព**<br>• បំប៉នពីគោលការណ៍ណែនាំស្តីពីមូលនិធិកែលម្អសាលារៀន ដល់ សាលារៀន សហគមន៍និងមាតាបិតា ការិយាល័យ អយក . និងមន្ទីរ អយក. និងរៀបចំទស្សនកិច្ចក្រៅប្រទេសសម្រាប់អ្នកអនុវត្តផ្តើម<br>• ផ្តល់ការជួយកសាងសមត្ថភាព និងការគាំទ្រតាមរយៈការដឹកដៃវាយតម្លៃការបំពេញការងាររបស់សាលារៀន ការធ្វើផែនការ និងអនុវត្តផែនការ និងផ្តោតលើកិច្ចការគោលនយោបាយអាទិភាព<br>• ពិនិត្យតាមដាន និងផ្តល់ការគាំទ្រជាគំរូដល់ការិយាល័យ និងមន្ទីរ ក្នុងការជួយសាលារៀនអនុវត្តគោលការណ៍ណែនាំស្តីពីមូលនិធិកែលម្អសាលារៀន<br>• វាយតម្លៃ និងអនុម័តគម្រោងស្នើមូលនិធិកែលម្អពីសាលារៀន ការិយាល័យ និងមន្ទីរអប់រំ<br>• រៀបចំធ្វើការពិនិត្យឡើងវិញប្រចាំត្រីមាស ឆមាស និងឆ្នាំពីការរីកចម្រើនក្នុងការអនុវត្តមូលនិធិកែលម្អសាលារៀន និង វិក្រឹតការគ្រូបង្រៀន<br>• បង្កើតសៀវភៅលំហាត់ និងកម្រងសំណួរតេស្តដែលបញ្ជាក់នូវសមត្ថភាពសិស្សពេញលេញលើមុខវិជ្ជាសិក្សាគោល ពីថ្នាក់ទី៧ ដល់ទី៩។<br>**១.២ សកម្មភាពកម្មវិធីថ្នាក់ជាតិសម្រាប់វិក្រឹតការគ្រូបង្រៀន**<br>• វាយតម្លៃ និងអនុម័តគម្រោងស្នើសុំថវិកាមូលនិធិវិក្រឹតការគ្រូបង្រៀន<br>• រៀបចំ និងចុះហត្ថលេខាលើកិច្ចសន្យាផ្តល់សេវា<br>• ពិនិត្យតាមដានការអនុវត្តគម្រោងស្នើសុំថវិកា។ |

| គោលបំណងទី៤៖ កែលម្អប្រសិទ្ធភាព និងប្រសិទ្ធផលប្រព័ន្ធសាលារៀន | |
|---|---|
| | **២.១ សកម្មភាពកម្មវិធីថ្នាក់ក្រោមជាតិសម្រាប់មន្ទីរ អប់រំ យុវជន និងកីឡា ខេត្ត រាជធានី**<br>• មន្ទីរអប់រំ យុវជន និងកីឡា វាយតម្លៃដោយខ្លួនឯង លើការ អនុវត្តកិច្ចការគោលនយោបាយចម្បងទាំង៨ និងរៀបចំ ផែនការកែលម្អ កិច្ចការទាំង៨នេះ<br>• អនុវត្ត និងរាយការណ៍ពីការរីកចម្រើនក្នុងការអនុវត្តផែនការតាមការណែនាំ ដែលមាននៅក្នុងប្រព័ន្ធពិនិត្យតាមដាន និង វាយតម្លៃ<br>• ចុះពិនិត្យតាមដានការអនុវត្តរបស់ការិយាល័យអប់រំ និង សាលារៀន និងផ្តល់ការគាំទ្រដែលត្រូវការ<br>• រៀបចំវេទិកាចែករំលែកបទពិសោធន៍ស្តីពីការបង្រៀន គណិតវិទ្យា និងវិទ្យាសាស្ត្រ និងប្រធានបទផ្សេងទៀត<br>• កសាងបណ្តាញការងារជាមួយមន្ទីរអប់រំផ្សេងទៀត និងជួយចែករំលែកពិសោធន៍តាមតម្រូវការ។<br><br>**២.២ សកម្មភាពកម្មវិធីថ្នាក់ក្រោមជាតិសម្រាប់ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ**<br>• ការិយាល័យអប់រំវាយតម្លៃដោយខ្លួនឯងលើការអនុវត្តកិច្ចការគោលនយោបាយចម្បងទាំង៨ និងរៀបចំផែនការកែ លម្អកិច្ចការទាំង៨នេះ<br>• អនុវត្ត និងរាយការណ៍ពីការរីកចម្រើនក្នុងការអនុវត្តផែនការតាមការណែនាំ ដែលមាននៅក្នុងប្រព័ន្ធពិនិត្យតាមដាន និង វាយតម្លៃ<br>• ចុះពិនិត្យតាមដានការអនុវត្តរបស់សាលារៀន និងផ្តល់ការ គាំទ្រដែលត្រូវការ<br>• កសាងបណ្តាញការងារជាមួយមន្ទីរអប់រំផ្សេងទៀត និងជួយរំលែកពិសោធន៍តាមតម្រូវការ។ |

## ៤ ហានិភ័យដែលត្រូវលុបបំបាត់តាមរយៈការកសាងជំនឿទំនុកចិត្ត

ខាងក្រោមនេះបទពិសោធន៍ដែលបានជួបប្រទះកន្លងមកនៅសាលារៀន និងសហគមន៍ ហើយអាចបន្តជួបប្រទះពេលអនុវត្តគម្រោង ដូចនេះគ្រប់អ្នកពាក់ព័ន្ធចាំបាច់ត្រូវកសាងនូវជំនឿខាងក្រោមដែលអាចលុបបំបាត់ចោលនូវហានិភ័យទាំងនេះ ទីបញ្ចប់បេសកកម្មសាលារៀននឹងត្រូវធ្វើឱ្យបានសម្រេច។

| ហានិភ័យ | ជំនឿដែលត្រូវកសាង |
|---|---|
| **ការប្រទាញគ្នារវាងការចាប់អារម្មណ៍របស់សិស្ស និងមាតាបិតាក្នុងការបញ្ជូនកូនមកចូលរៀនជាមួយនឹងការរកចំណូលពីការចេញទៅធ្វើការងារ** | • គោលបំណងនៃការអប់រំគឺរៀបចំសិស្សសម្រាប់ជីវិតក្នុងពិភពលោកដែលភាពស្មុគ្រស្មាញនិងផ្លាស់ប្តូររហូត<br>• លទ្ធផលសិក្សានឹងត្រូវបានប្រសើរនៅពេលការសិក្សាមានភាពសកម្មនិងទាក់ទងនឹងជីវភាពរស់នៅ<br>• គ្រប់សិស្សរៀនតាមរបៀប និងល្បឿនខុសគ្នា។ |
| **សិស្សមកសាលារៀនតែមិនដល់សាលារៀន** | • ការសង្ឃឹមទុកពីលទ្ធផលសិក្សា អត្តចរិតរៀនសូត្រ និងការ ខិតខំរៀនសូត្រមានឥទ្ធិពលផ្ទាល់ដល់ការសម្រេចផលសិក្សា<br>• សមត្ថភាពភាសា និងគណិតវិទ្យាជាបំណិនមូលដ្ឋានកសាង ការសិក្សា<br>• គ្រប់សិស្សម្នាក់ៗមានសិទ្ធិទទួលឱកាសដើម្បីសិក្សានៅក្នុងបរិស្ថានដែលសមស្រប ពិសេសសម្រាប់សិស្សរៀនយឺត។ |
| **ភាពមិនប្រក្រតីក្នុងសាលារៀនលើកស្ទួយនូវចរិយា (មិនមានសីលធម៌ បំផ្លាញវិន័យ) និងចរិយាមានគុណធម៌** | • គ្រប់វិធីទំនាក់ទំនងរវាងសាលារៀន គ្រូបង្រៀននិងមាតាបិតា បង្កើតការយល់ដឹងពីបញ្ហា<br>• កិច្ចសន្យាជាមួយគ្រូបង្រៀននិងនាយកសាលាជាយានបង្កើតឡើងនូវការផ្តល់តម្លៃដល់បុគ្គលខ្លួនឯងជាគ្រូបង្រៀននិងនាយកសាលា។ |
| **សហគមន៍ មាតាបិតា សិស្ស សាលារៀន និងគ្រូបង្រៀនមិនមានគណនេយ្យភាពចំពោះការអប់រំ** | • សិស្សអាចនឹងរៀនបានជោគជ័យប្រសិនបើគេទទួលបានការគាំទ្រនៅផ្ទះ<br>• ការអប់រំជាការទទួលខុសត្រូវរួមរវាងសិស្ស គ្រួសារ សាលារៀន និងសហគមន៍។ |
| **ទឹកចិត្តធ្វើការទាបសម្រាប់មន្ត្រី និងគ្រូបង្រៀនក្នុងការបំពេញ ភារកិច្ច** | • លាភសក្ការៈជាសាច់ប្រាក់ និងលាភសក្ការៈមិនមែនជាសាច់ប្រាក់តាមរយៈការកសាងសមត្ថភាពនឹងផ្តល់ឱ្យ<br>• ដំណោះស្រាយរយៈពេលមធ្យម និងរយៈពេលវែងគឺការបង្កើនគុណវុឌ្ឍិស្របជាមួយការឡើងឋានៈ ការឡើងប្រាក់ បៀវត្ស និងការអភិវឌ្ឍវិជ្ជាជីវៈជាប់ជាបន្ត។ |

## ៥ គោលការណ៍ប្រតិបត្តិការ

ជាការចាំបាច់ណាស់ ដែលមន្ត្រីពាក់ព័ន្ធទាំងអស់ចាប់តាំងពីថ្នាក់សាលារៀន ថ្នាក់ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត និងថ្នាក់ជាតិត្រូវអនុវត្តការងារតាមគោលការណ៍ប្រតិបត្តិដូចខាងក្រោមៈ

១. គុណភាពនៃការបង្រៀនជាអាទិភាពខ្ពស់បំផុត។ គ្រប់ការសម្រេចចិត្តក្នុងការធ្វើផែនការ និងគ្រោងថវិកា និងសកម្មភាពប្រតិបត្តិប្រចាំថ្ងៃត្រូវមានទំនាក់ទំនងផ្ទាល់ជាមួយការកែលម្អគុណភាពនៃការបង្រៀន។

២. ភាពស៊ីគ្នារវាងកម្មវិធីសិក្សា ការបង្រៀន ការធ្វើតេស្តវាយតម្លៃការអនុវត្តរបស់សិស្ស និងការបំប៉នគ្រូបង្រៀនត្រូវតែមាន។ អ្នកជំនាញការជាគ្រូឧទ្ទេសថ្នាក់ជាតិ ព្រមទាំងថ្នាក់ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត នឹងជួយគាំទ្រដល់សាលារៀន និងសហគមន៍។

៣. ការសិក្សារបស់សិស្សអាចមានជាប់ជាបន្តបាន លុះត្រាតែមានការវាយតម្លៃសមត្ថភាពសិស្សលើមុខវិជ្ជា ភាសាខ្មែរ និងគណិតវិទ្យា ពិសេសនៅថ្នាក់ទី៧ ព្រមទាំងផ្តល់ការគាំទ្រដល់សិស្សរៀនយឺត។

៤. ការអប់រំដោយភាពរីករាយ និងគ្រួសារមានភាពរីករាយត្រូវតែរួមបញ្ចូលគ្នានៅក្នុងសកម្មភាពសាលារៀន។

៥. ការសម្រេចចិត្តត្រូវធ្វើផ្អែកលើទិន្នន័យ និងភស្តុតាងនៃសូចនាករសាលារៀនមានប្រសិទ្ធភាព និងមាន គណនេយ្យភាព។

៦. ការសម្រេចចិត្តដែលល្អត្រូវធ្វើនៅមូលដ្ឋានដើម្បីធានាថាការសម្រេចចិត្តនោះមានភាពស៊ីគ្នា រវាងតម្រូវការ មូលដ្ឋានជាមួយនឹងអាទិភាពថ្នាក់ជាតិ។ ថ្នាក់ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត និងថ្នាក់កណ្តាលមិនគួរគប្បីលូកដៃ ចូលក្នុងការធ្វើការសម្រេចចិត្តនេះឡើយ តែអាចជួយសម្របសម្រួលការពិភាក្សានៅមូលដ្ឋាន នៅឆ្នាំទី១ ឬទី២ ព្រោះ ជាការចាំបាច់ខណៈពេលដែលសមត្ថភាពមូលដ្ឋាននៅខ្សោយ។

៧. ផែនការកែលម្អសាលារៀន និងឯកសារការងារត្រូវតែជាឯកសាររស់។ ដូចនេះវាត្រូវមានការកែលម្អដើម្បី បន្ស៊ីគ្នាទៅនឹងការផ្លាស់ប្តូរដែលនាំមកនូវការរីកចម្រើន។ ការប្រឹក្សាយោបល់ជាមួយអ្នកជំនាញការថ្នាក់ក្រោមជាតិ ឬថ្នាក់ជាតិ អាចធ្វើបានប្រសិនបើចាំបាច់។

៨. ភាពជាម្ចាស់ និងគណនេយ្យភាពជាការទទួលខុសត្រូវរួមគ្នា។ ដូចនេះមិនគួរគប្បីមានអ្នកណាម្នាក់ដែលនិយាយថាមិនដឹង ឬ ផ្តល់ព័ត៌មានដែលមិនអាចយល់បានពីអ្វីដែលកើតឡើងទាក់ទងនឹងការទទួលខុសត្រូវរបស់ខ្លួនឡើយ។

៩. ការពិនិត្យតាមដាន ការវាយតម្លៃ ការធ្វើតេស្តសិស្ស និងការផ្តល់ព័ត៌មានត្រឡប់ទៀងទាត់ដល់សាធារណៈ ជាការលើកកម្ពស់គណនេយ្យភាពហើយ។

## ៦ បញ្ហាប្រឈមក្នុងការអនុវត្តជាក់ស្តែង

បញ្ហាប្រឈមជាក់ស្តែង ដែលគណៈកម្មការគ្រប់គ្រងសាលារៀន និងនាយក ឬនាយិកាសាលារៀន នឹងជួបប្រទះពេលអនុវត្តកម្មវិធី ត្រូវដោះស្រាយអាចមាន៖ ១.សមត្ថភាពស្ថាប័នខ្សោយ ២.សមត្ថភាពធនធានមនុស្សខ្សោយ និង៣.ឯកសារគតិយុត្តិសម្រាប់ការអនុវត្តកម្មវិធីមានការខ្វះខាត។ ដើម្បីអនុវត្តសេចក្តីណែនាំមានមូលដ្ឋាននៅសាលារៀននេះ ក្រសួងនឹងរៀបចំ៖

១. ក្រុមការងារដឹកនាំនិងគ្រប់គ្រងតាមសាលារៀន
២. ក្រុមគ្រូបង្គោលថ្នាក់ជាតិភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម (ប្រវត្តិវិទ្យា)
៣. ក្រុមការងារវិក្រឹតការគ្រូបង្រៀន
៤. កំណត់មហាវិទ្យាល័យដែលមានស្តង់ដាក្នុងការផ្តល់ការបង្រៀនកម្មវិធីវិក្រឹតការគ្រូបង្រៀន
៥. រៀបចំជាក្រុមតូចៗ ហើយក្រុមតូចៗនីមួយៗ នឹងទទួលខុសត្រូវតាមតំបន់ភូមិសាស្ត្ររាជធានី ខេត្តច្បាស់លាស់។

ការពង្រឹងសមត្ថភាពស្ថាប័នថ្នាក់ក្រោមជាតិ កិច្ចសហការរវាងនាយកដ្ឋានជំនាញ និងនាយកដ្ឋានគាំទ្រនឹងត្រូវចាត់តាំងឱ្យទទួលខុសត្រូវជាក់លាក់តាម រាជធានី ខេត្ត។ ការរៀបចំនេះអាចជួយផ្តល់ការគាំទ្រដល់ថ្នាក់ក្រោមជាតិ និងអាចបង្កើតឡើងនូវប្រព័ន្ធគណនេយ្យភាពច្បាស់លាស់។ បច្ចុប្បន្ននាយកដ្ឋាននិមួយៗនៅបន្តធ្វើផែនការដាច់ដោយឡែកពីគ្នា និងមិនទាន់បានរៀបចំផែនការជាអនុវិស័យដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់សាលារៀនឡើយ។ នៅមានកង្វះខាតមន្ត្រីមានសមត្ថភាពនៅការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ដែលនាំឱ្យមានការលំបាកនូវការផ្តល់ការគាំទ្រទាន់ពេលវេលាដល់សាលារៀន។

សមត្ថភាពធនធានមនុស្សនៅថ្នាក់ជាតិ និងក្រោមជាតិក្នុងការដឹកនាំ និងគ្រប់គ្រងនៅមានកម្រិត។ មន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនឹងប្រើប្រាស់ប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើលទ្ធផល និងសេចក្តីណែនាំស្តីពីការគ្រប់គ្រងតាមសាលារៀននេះដើម្បីបំពេញនូវកង្វះសមត្ថភាពនេះ។ បទពិសោធន៍ក្នុងការធ្វើផែនការ ការអនុវត្ត ការពិនិត្យតាមដាន ការគ្រប់គ្រងហិរញ្ញវត្ថុ និងការធ្វើរបាយការណ៍ក្នុងបរិបទការគ្រប់គ្រងតាមសាលារៀនមានភាពខ្សោយនៅឡើយ។

## ២.២.២ ការអនុវត្តស្វ័យភាពក្នុងការធ្វើផែនការ និងការគ្រប់គ្រងថវិកាសាលារៀន

### ១ ការរកមូលនិធិសាលារៀន

ផ្អែកលើកម្រិតនៃស្វ័យភាពខាងលើ គណៈកម្មការគ្រប់គ្រងសាលារៀនមានកិច្ចការដូចខាងក្រោម៖

**ក-ការកសាងគ្រឹះសម្រាប់ការស្វែងរកមូលនិធិ**

ក្រុមការងារថ្នាក់ជាតិនឹងរៀបចំការប្រជុំ ពីការរកមូលនិធិដល់គណៈកម្មការគ្រប់គ្រងសាលារៀន អំពីស្វ័យភាពនៃការរកមូលនិធិ ពិសោធន៍ពីសាលារៀនផ្សេងទៀត និងពិភាក្សាពីលទ្ធភាពអាចធ្វើបានរបស់សាលារៀនក្នុងការរកមូលនិធិ។ តម្លាភាពក្នុងការស្វែងរក និងការគ្រប់គ្រងមូលនិធិគឺជាជំហានដំបូងដើម្បីកសាងនូវការទុកចិត្តពីសហគមន៍ និងមាតាបិតាលើសាលារៀន។ ការប្រើប្រាស់មូលនិធិដែលធ្វើឱ្យប្រសើរនូវលទ្ធផលសិក្សារបស់សិស្ស ជាភស្តុតាងពីគណនេយ្យភាពរបស់សាលារៀន។ សកម្មភាពនេះនឹងបន្តពង្រឹង និងរក្សានិរន្តភាពនៃទំនុកចិត្តពីមាតាបិតា និងសហគមន៍ មកលើសាលារៀន និងគ្រូបង្រៀន។

ក្រុមការងារថ្នាក់ជាតិនឹងជួយសម្របសម្រួលការពិភាក្សាជាមួយគណៈកម្មការគ្រប់គ្រងសាលារៀនក្នុងការកសាងផែនការសកម្មភាពសាមញ្ញសម្រាប់រកមូលនិធិនៅឆ្នាំសិក្សាបន្ទាប់។

គណៈកម្មការគ្រប់គ្រងសាលារៀន អាចបញ្ចូលទៅក្នុងផែនការនូវការធ្វើទស្សកិច្ចសិក្សានៅសាលារៀនដែលមានបទពិសោធន៍ក្នុងការងារនេះ។ សកម្មភាពរកមូលនិធិអាចចាប់ផ្តើមពិសេសជាមួយគ្រួសារនៃអ្នកដែល ជាសិស្សសាលារៀននេះ ឬជាមួយអ្នកមាននៅមូលដ្ឋាន និងអ្នកដែលមានប្រជាប្រិយភាព។

**ខ-ធ្វើឱ្យសកម្មភាពរកមូលនិធិជាទម្លាប់នៃការអភិវឌ្ឍ**

បង្ហាញលទ្ធផល បង្ហាញប្រព័ន្ធតម្លាភាព និងគម្លាតថវិកាត្រូវការសម្រាប់អនុវត្តផែនការនៅឆ្នាំក្រោយ។

ពង្រីកសកម្មភាពរកមូលនិធិនៅក្នុងផែនការសកម្មភាពរកចំណូលនៅឆ្នាំក្រោយ។

**គ-សារៈប្រយោជន៍ក្នុងការអភិវឌ្ឍបទពិសោធន៍ពីការរកមូលនិធិ**

ការផ្សារភ្ជាប់ការអនុវត្តជាមួយគោលការណ៍រកមូលនិធិ និងចែករំលែកបទពិសោធន៍នេះ ជាមួយសាលារៀនផ្សេងទៀត ទាំងឯកជន និងរដ្ឋ ដែលជាកិច្ចការមានតម្លៃគប្បីធ្វើ។

### ២ របៀបធ្វើផែនការ និងគ្រប់គ្រងថវិកាសាលារៀន

គណៈកម្មការគ្រប់គ្រងសាលារៀនសម្រេចលើ i) ផលសម្រេច និងក្រុមគោលដៅផលសម្រេច សម្រាប់សាលារៀនរយៈពេល៣ឆ្នាំដែលស្តង់ដាទី១៖ គោលនយោបាយសាលារៀន នៃសាលារៀនមានប្រសិទ្ធភាព

និង ii) ផែនការកែលម្អសាលារៀន និងថវិកាប្រចាំឆ្នាំ។ គណៈកម្មការគ្រប់គ្រងសាលារៀនផលិតផែនការ តែមួយ ថវិកាតែមួយ និងរបាយការណ៍តែមួយដែលគ្របដណ្តប់គ្រប់ប្រភពមូលនិធិ។

គណៈកម្មការគ្រប់គ្រងសាលារៀនអនុម័តលើការកែសម្រួលផែនការ និងថវិកាក្នុងឆ្នាំដោយផ្អែកលើអាទិភាពថ្មីដែលបានរកឃើញពីការពិនិត្យឡើងវិញនៅក្នុងឆ្នាំ។ ការគ្រោងថវិកាត្រូវមានមូលដ្ឋានលើអាទិភាពសាលារៀន។ ខ្លឹមសារលម្អិតពីមុខចំណាយមានរៀបរាប់នៅក្នុងជំពូកការគ្រប់គ្រងហិរញ្ញវត្ថុ។

ខ្លឹមសារខាងក្រោមអធិប្បាយពីចំណងជើងចំនួន៣៖ ១. ការរកមូលនិធិសាលារៀន ២. ការធ្វើផែនការ និងការគ្រោងថវិកា និង ៣. ការរៀបចំ និងការដាក់ស្នើគម្រោងសុំថវិកា។

### ក.ការធ្វើផែនការកែលម្អសាលារៀន

ផែនការមាន២ប្រភេទ៖ ១) ផលសម្រេច និងក្រុមគោលដៅរយៈពេល៣ឆ្នាំ និង ២) ផែនការកែលម្អសាលារៀននិងថវិកាប្រចាំឆ្នាំ។

ផលសម្រេច និងក្រុមគោលដៅរយៈពេល៣ឆ្នាំ ត្រូវប្រើជាក្របខ័ណ្ឌសម្រាប់រៀបចំផែនការ កែលម្អសាលារៀនប្រចាំឆ្នាំ។ ទិន្នន័យដែលបានមកពីការធ្វើស្វ័យវាយតម្លៃពីការអនុវត្តរបស់សាលារៀន ការវាយតម្លៃ ឬធ្វើតេស្តសិស្ស ការវាយតម្លៃគ្រូបង្រៀន និងការធ្វើផែនការថ្នាក់រៀន និងសាលារៀននឹងផ្តល់នូវព័ត៌មានសម្រាប់ការធ្វើផែនការកែលម្អសាលារៀនបានសព្វគ្រប់។

#### *ការធ្វើស្វ័យវាយតម្លៃពីការអនុវត្តរបស់សាលារៀន*

នាយកសាលារៀន ត្រូវធ្វើស្វ័យវាយតម្លៃសាលារៀននៅវិស្សមកាលឆ្នាំសិក្សា ២០១៨-២០១៩។ មូលហេតុដោយសារការធ្វើស្វ័យវាយតម្លៃនេះ គឺត្រូវធ្វើដើម្បីវាយតម្លៃពីការរីកចម្រើនក្នុងការអនុវត្តផែនការកែលម្អសាលារៀននៅឆ្នាំសិក្សា ២០១៧-២០១៨។ ដូចនេះនៅក្នុងវិស្សមកាលឆ្នាំសិក្សា២០១៧-២០១៨ សាលារៀនមិនអាចធ្វើស្វ័យវាយតម្លៃបានឡើយ ដោយសារមិនទាន់មានផែនការកែលម្អសាលារៀនឆ្នាំសិក្សា ២០១៦-២០១៧ ហើយការអនុវត្តពុំទាន់បានចាប់ផ្តើមនៅឡើយ។

នៅក្នុងរយៈកាលវិស្សមកាលឆ្នាំសិក្សា ២០១៨-២០១៩ ខែកញ្ញា និងខែតុលា ឆ្នាំ២០១៨ សាលារៀននឹងធ្វើស្វ័យវាយតម្លៃពីការអនុវត្តរបស់សាលារៀនដោយប្រើឧបសម្ព័ន្ធខាងក្រោម។ នាយក ឬ នាយិកា និងគ្រូបង្រៀនដាក់ពិន្ទុ១ ឬ ២ ឬ ៣សម្រាប់សូចនាករនីមួយៗ ហើយសរុបពិន្ទុតាមស្តង់ដានីមួយៗ រួចហើយសរុបពិន្ទុស្តង់ដាទាំងអស់ដែលជាពិន្ទុតំណាងឱ្យពិន្ទុសាលារៀនមានប្រសិទ្ធភាព។ ប្រសិនបើពិន្ទុសរុបនេះមានចំនួន ៦៥%ឡើង នោះមានន័យថាសាលារៀនបំពេញបាននូវស្តង់ដាសាលារៀនមានប្រសិទ្ធភាពកម្រិតអប្បបរមាហើយ។ ដើម្បីឱ្យបានពិន្ទុ ៦៥% មានន័យថាសូចនាករនីមួយៗត្រូវបានពិន្ទុយ៉ាងហោចណាស់ ២ពិន្ទុ។

ពិន្ទុនៃសូចនាករនីមួយៗ និងស្តង់ដានីមួយៗជូនព័ត៌មានដល់នាយក ឬ នាយិកា និងគណៈកម្មការគ្រប់គ្រងសាលារៀន ដើម្បីពិភាក្សា និងឯកភាពពីសកម្មភាពត្រូវធ្វើនៅក្នុងផែនការកែលម្អសាលារៀននៅឆ្នាំសិក្សាបន្ទាប់ ដើម្បីអាចបង្កើនបាននូវពិន្ទុនៃសូចនាករ និងស្តង់ដានៅឆ្នាំបន្ទាប់។

*ការវាយតម្លៃ ឬធ្វើតេស្តសិស្ស*

ក្រុមគ្រប់គ្រងតាមសាលារៀន គ្រូមុខវិជ្ជាបង្គោលថ្នាក់ជាតិ និងក្រុមធានាគុណភាពអប់រំនឹង រៀបចំសៀវភៅលំហាត់សម្រាប់ការធ្វើតេស្តសិស្ស និងរៀបចំឯកសារបង្រៀន។ សៀវភៅលំហាត់សម្រាប់ ការធ្វើតេស្តសិស្ស និងឯកសារបង្រៀននឹងត្រូវយកមកប្រើប្រាស់ក្នុងការបំប៉នគ្រូបង្រៀននៅនឹងកន្លែង។

ការធ្វើតេស្តសិស្សគប្បីធ្វើឡើងនៅចុងចប់មេរៀននីមួយៗ ចុងខែ និងចុងឆមាស។ សិស្សម្នាក់ៗនឹងត្រូវឱ្យបំពេញនូវសំណួរ និងទិន្នន័យទាក់ទងនឹងសាវតារសង្គម និងសេដ្ឋកិច្ចគ្រួសារ។ ក្រុមអនុវិស័យ គ្រូមុខវិជ្ជាបង្គោលថ្នាក់ជាតិ និងក្រុមធានាគុណភាពអប់រំនឹងជួយគ្រូបង្រៀនក្នុងការវិភាគលទ្ធផលតេស្ត និងព័ត៌មាន និងទិន្នន័យនៃគ្រួសារសិស្ស និងពិភាក្សាពីជម្រើសជាសកម្មភាពដើម្បីជួយសិស្សដែលរៀនយឺត។ ថវិកាត្រូវគ្រោងសម្រាប់ជួយសិស្សរៀនយឺត នឹងត្រូវរកឃើញនៅពេលធ្វើផែនការថ្នាក់រៀននៅដើមឆ្នាំសិក្សាដែលជាផ្នែកមួយនៃការរៀបចំផែនការកែលម្អសាលារៀនប្រចាំឆ្នាំ។

ការប្រជុំរវាងគ្រូបង្រៀន សិស្ស និងមាតាបិតាដើម្បីជួយសិស្សរៀនយឺតមានរៀបរាប់នៅក្នុងជំពូកពីការវាយតម្លៃសាលារៀននិងសិស្ស និងប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផល។

*ការវាយតម្លៃគ្រូបង្រៀន*

ក្រុមគ្រប់គ្រងតាមសាលារៀន និងគ្រូមុខវិជ្ជាបង្គោលថ្នាក់ជាតិនឹងធ្វើការវាយតម្លៃ គ្រូបង្រៀនលើសមត្ថភាព និងបំណិនគរុកោសល្យក្នុងការបង្រៀន។ លទ្ធផលបានពីការវាយតម្លៃនឹងត្រូវប្រើប្រាស់ សម្រាប់ធ្វើផែនការបំប៉នគ្រូបង្រៀននៅនឹងកន្លែង និងការកសាងផែនការកែលម្អសាលារៀនផងដែរ។ ការវាយតម្លៃនេះជាផ្នែកមួយនៃការគ្រប់គ្រងការអនុវត្តការងាររបស់គ្រូបង្រៀន ដែលមានរៀបរាប់នៅក្នុង ជំពូកការគ្រប់គ្រងការអនុវត្តការងាររបស់មន្ត្រី។ ការវាយតម្លៃនេះនឹងចាប់ផ្តើមធ្វើនៅពេលចាប់ផ្តើមបវេសនកាល ឆ្នាំសិក្សា ២០១៧-២០១៨ និងនៅឆ្នាំសិក្សាខាងមុខៗទៀត។

*ការធ្វើផែនការថ្នាក់រៀន និងការធ្វើផែនការគ្រប់គ្រងសាលារៀនលម្អិតប្រចាំត្រីមាស*

ឧបករណ៍វាយតម្លៃសាលារៀនមានប្រសិទ្ធភាព នឹងត្រូវយកមកប្រើសម្រាប់ការធ្វើផែនការប្រចាំត្រីមាសនេះ។ របៀបធ្វើផែនការថ្នាក់រៀនដោយគ្រូបង្រៀន សិស្ស និងមាតាបិតា និងការធ្វើផែនការគ្រប់គ្រងសាលារៀនគឺមានរៀបរាប់នៅក្នុងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើលទ្ធផលរបស់អនុវិស័យ។ ក្រុម

ការងារគ្រប់គ្រងតាមសាលារៀន នឹងផ្តល់នូវការបំប៉ននៅនឹងកន្លែង ដល់សាលារៀនដើម្បីធ្វើកិច្ចការនេះ។ ការធ្វើផែនការថ្នាក់រៀនសំដៅលើ ការធ្វើផែនការសម្រាប់ស្តង់ដាទី២ ការបង្រៀននិងរៀន ស្តង់ដាទី៣ សហគមន៍ និងមាតាបិតាជួយសិស្សក្នុងការរៀនសូត្រ និងស្តង់ដាទី៤ សិស្ស និងសេវាជួយសិស្ស។ ការធ្វើផែនការគ្រប់គ្រងសាលារៀនគឺសំដៅលើ ការធ្វើផែនការសម្រាប់ស្តង់ដាទី៥ ការគ្រប់គ្រងសាលារៀន ស្តង់ដាទី៦ ធនធានមនុស្ស ស្តង់ដាទី៧ សម្ភារៈបង្រៀននិងរៀន ស្តង់ដាទី៨ ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន និងស្តង់ដាទី៩ ហិរញ្ញប្បទាននិងការគ្រប់គ្រងហិរញ្ញវត្ថុ។

*ការធ្វើផែនការរបស់គណៈកម្មការគ្រប់គ្រងសាលារៀនប្រចាំឆ្នាំ*

គ្រូបង្រៀន និងនាយកសាលាប្រើទិន្នន័យពីឆ្នាំសិក្សាមុនសម្រាប់កំណត់ជាតួលេខមូលដ្ឋាន និងក្រុមគោលដៅនៃគ្រប់សូចនាករនីមួយៗនៅឆ្នាំសិក្សាបន្ទាប់។ បើទោះជាទិន្នន័យរបស់ឆ្នាំសិក្សាដំបូង មិនមានភាពពិតច្បាស់លាស់ក៏ដោយ ប៉ុន្តែទិន្នន័យទាំងនោះត្រូវតែយកមកប្រើប្រាស់។ ការកំណត់ក្រុមគោលដៅ គ្រូបង្រៀនមិនគប្បីមានបំណងដាក់ឱ្យទាបពេកដែលនាំឱ្យងាយស្រួលពេកក្នុងការសម្រេច។ ក្រុមគោលដៅគប្បីកំណត់ផ្អែកលើ៖ ភាពច្បាស់លាស់នៃទិន្នន័យ សមត្ថភាពធ្វើឱ្យសម្រេចបានធាតុចូល ដែលត្រូវការ និងយន្តការគាំទ្រដែលត្រូវផ្តល់ឱ្យ។

*ការធ្វើផែនការកែលម្អសាលារៀន និងថវិកាប្រចាំឆ្នាំ*

ក្នុងការកំណត់ផលសម្រេចនិងក្រុមគោលដៅរយៈពេល៣ឆ្នាំ ក្រុមគោលដៅផលសម្រេចថ្នាក់ជាតិដូចជាការចូលរៀន ឡើងថ្នាក់ ត្រួតថ្នាក់ បោះបង់ រៀនចប់ឆ្លងភូមិសិក្សា ជាកម្រិតផលសម្រេចជាមធ្យមដែលមាននៅក្នុងផែនការយុទ្ធសាស្ត្រអប់រំ និងគ្រប់បទដ្ឋានដែលទាក់ទងដូចជាផលធៀបសិស្ស-គ្រូ ផលធៀបសិស្ស -ថ្នាក់ ផលធៀបសិស្ស-សៀវភៅសិក្សា។ល។ ត្រូវយកមកប្រើប្រាស់ជារង្វាស់ដែលបញ្ជាក់ពីភាពខ្វះចន្លោះ នៃផលសម្រេច និងភាពខ្វះខាតធាតុចូលនៅសាលារៀន។ សាលារៀន ការិយាល័យអប់រំ ក្រុង ស្រុក ខណ្ឌ និងមន្ទីរអប់រំនីមួយៗត្រូវធ្វើផែនការដើម្បីសម្រេចបាននូវក្រុមគោលដៅ និងបទដ្ឋានទាំងនេះនៅក្នុងផែនការ យុទ្ធសាស្ត្រអប់រំ។

ទិន្នន័យ និងព័ត៌មានដែលបានមកពី ១) ការវាយតម្លៃសាលារៀន ការវាយតម្លៃសិស្ស និងការវាយតម្លៃគ្រូបង្រៀន ២) ការធ្វើផែនការថ្នាក់រៀន និងការធ្វើផែនការគ្រប់គ្រងសាលារៀនលម្អិតប្រចាំត្រីមាស នឹងត្រូវផ្តុំបញ្ចូលគ្នាទៅក្នុងផែនការកែលម្អសាលារៀនប្រចាំឆ្នាំ ដែលគ្របដណ្តប់ស្តង់ដាទាំង៩នៃសាលារៀន មានប្រសិទ្ធភាព។ ខ្លឹមសារលម្អិតមាននៅក្នុងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើលទ្ធផលរបស់ អនុវិស័យ។

**ខ. ការធ្វើផែនការរបស់មន្ទីរអប់រំរាជធានី ខេត្ត និងការិយាល័យអប់រំក្រុង ស្រុក ខណ្ឌ**

ដំណើរនៃការរៀបចំផែនការរបស់មន្ទីរអប់រំខេត្ត និងការិយាល័យអប់រំស្រុកគឺមានរៀបរាប់នៅក្នុងប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃរបស់អនុវិស័យ។ មន្ទីរអប់រំរាជធានី ខេត្ត និងការិយាល័យអប់រំក្រុង ស្រុក ខណ្ឌ ត្រូវដាក់ស្នើ ឯកសារខាងក្រោមដល់ក្រុមការងារគ្រប់គ្រងតាមសាលារៀនរបស់ក្រសួងសម្រាប់ស្នើសុំថវិកាកែលម្អសាលារៀនៈ

១. របាយការណ៍វាយតម្លៃការអនុវត្តរបស់មន្ទីរអប់រំរាជធានី ខេត្ត និងការិយាល័យអប់រំក្រុង ស្រុក ខណ្ឌ

២. ផែនការសកម្មភាព និងថវិកាគ្រោងប្រចាំឆ្នាំ។

## ២.២.៣ ការគ្រោងថវិកា ការរៀបចំ និងការដាក់ស្នើគម្រោងសុំថវិកា

### ១ ការគ្រោងថវិកា

ការគ្រោងថវិកាគឺផ្អែកលើលទ្ធផល ឬ អាទិភាពដែលបានរកឃើញនៅពេលរៀបចំផែនការកែលម្អសាលារៀនប្រចាំឆ្នាំ។ អាទិភាពខ្ពស់បំផុតគឺស្តង់ដាទី២ គុណភាពនៃការបង្រៀននិងរៀន។ ស្តង់ដាដ៏ទៃទៀតជាស្តង់ដាជំនួយឱ្យស្តង់ដាទី២នេះ។ មិនមែនគ្រប់លទ្ធផល ឬ អាទិភាពត្រូវការថវិកាដើម្បីអនុវត្តនោះទេ។ នាយក ឬនាយិកាសាលារៀន និងគ្រូបង្រៀនជួបគ្នា និងពិភាក្សាពីការគ្រោងថវិកា ដោយធ្វើការវិភាគ លទ្ធផល (សូចនាករ) ម្តងមួយៗ និងពិភាក្សាថវិកាត្រូវការដោយប្រើបញ្ជីមុខចំណាយដែលអាចចាយបាន។ បញ្ជីនេះមាននៅក្នុងជំពូកការគ្រប់គ្រងហិរញ្ញវត្ថុ។ នាយក ឬនាយិកាសាលារៀនកត់ត្រានូវមុខទំនិញ ឬឧបករណ៍ត្រូវទិញនៅក្នុងបញ្ជីមុខទំនិញ ហើយប៉ាន់ស្មានតម្លៃវា។

ក្រោយការគ្រោងផែនការថវិកាសម្រាប់លទ្ធផលនីមួយៗហើយ នាយក ឬ នាយិកាសាលារៀន និងគ្រូបង្រៀនបញ្ចូលតួលេខថវិកា ទៅក្នុងកូឡោនចុងក្រោយនៃផែនការកែលម្អសាលារៀន។ ក្នុងករណីថវិកាគ្រោងមានចំនួនលើសពីថវិកាដែលមាន។ នាយក ឬនាយិកាសាលារៀន និងគ្រូបង្រៀនអាចមានការពិភាក្សា លើអាទិភាពដែលអាចរក្សាទុក សម្រាប់អនុវត្តឆ្នាំសិក្សាបន្ទាប់ បើព្រមព្រៀងហើយត្រូវដកវាចេញពីផែនការថវិកាឆ្នាំនេះ។ សូមចងចាំថាលទ្ធផលដែលទាក់ទងនឹង សូចនាករស្តង់ដាទី២គប្បីរក្សាទុកហើយសរុបថវិកា គ្រោងយ៉ាងហោចណាស់ ៦០% ត្រូវប្រើប្រាស់សម្រាប់ធ្វើឱ្យប្រសើរ គុណភាពបង្រៀន និងរៀន។ សូមរក្សាការភ្ញាក់រឭកថា សហគមន៍មានថាមពលខ្លាំងក្លាណាស់ ក្នុងការរួមចំណែកអនុវត្តផែនការថវិកានេះ ប្រសិនបើគេបានចូលរួមត្រឹមត្រូវ ក្នុងដំណើរនៃការធ្វើផែនការ និងដំណើរប្រតិបត្តិការសាលារៀន។

## ២ ការរៀបចំ និងការដាក់ស្នើគម្រោងសុំថវិកា

ខាងក្រោមនេះជាលំហូរនៃការអភិវឌ្ឍគម្រោងសុំថវិកាសម្រាប់ការគ្រប់គ្រងតាមសាលារៀន៖




គម្រោងស្នើសុំថវិកាសម្រាប់សាលារៀនមានឯកសារចំនួន៥ដែលត្រូវរៀបចំ៖

១. ពាក្យស្នើសុំថវិកាកែលម្អសាលារៀន

២. ផលសម្រេច និងក្រុមគោលដៅរយៈពេល៣ឆ្នាំ

៣. ផែនការកែលម្អសាលារៀនប្រចាំឆ្នាំ និងថវិកា

៤. ផែនការថ្នាក់រៀននិងការគ្រប់គ្រងសាលារៀនលម្អិតប្រចាំត្រីមាស៖

ឧបករណ៍វាយតម្លៃសម្រាប់សាលារៀន

៥. របាយការណ៍វាយតម្លៃការបំពេញស្តង់ដាសាលារៀនមានប្រសិទ្ធភាព ។

### ៣ ស្វ័យភាពក្នុងការគ្រប់គ្រងបៀវត្សបុគ្គលិកបង្រៀន និងបុគ្គលិកមិនបង្រៀន

ក្រសួងអប់រំ យុវជន និងកីឡាកំណត់នូវប្រាក់បៀវត្ស។ នាយកសាលារៀន គ្រប់គ្រងការអនុវត្តការងាររបស់បុគ្គលិកបង្រៀន និងបុគ្គលិកមិនបង្រៀន និងស្នើសុំវិធានការរដ្ឋបាលដល់គណៈកម្មការគ្រប់គ្រងសាលារៀន ដើម្បីសម្រេចបញ្ជូនទៅការិយាល័យអប់រំស្រុក ធ្វើការសម្រេចចិត្តចំពោះមន្ត្រីមិនធ្វើការ ។ ប្រព័ន្ធគ្រប់គ្រងការអនុវត្តការងាររបស់មន្ត្រី មានគោលបំណងផ្តល់ការគាំទ្រដល់មន្ត្រី និងគ្រូបង្រៀនឱ្យមានសមត្ថភាព អនុវត្តកិច្ចការរបស់ខ្លួនប្រកបដោយវិជ្ជាជីវៈ។ គ្រូបង្រៀនដែលអនុវត្តការងារបានប្រសើរនឹងទទួលរង្វាន់ ពីគណៈកម្មការគ្រប់គ្រងសាលារៀន តាមការណែនាំរបស់ក្រសួង។ របៀបអនុវត្តប្រព័ន្ធគ្រប់គ្រងការងារ របស់មន្ត្រីមានរៀបរាប់នៅក្នុងជំពូកការគ្រប់គ្រងការអនុវត្តរបស់មន្ត្រី។

## គំរូពាក្យស្នើសុំថវិកាកែលម្អសាលារៀន

សាលារៀន..........................................................................................................

**សូមគោរពជូន**

........**ប្រធានគណៈកម្មការគ្រប់គ្រងតាមសាលារៀនថ្នាក់ជាតិ**

**កម្មវត្ថុ៖** សំណើសុំមូលនិធិកែលម្អសាលារៀនសម្រាប់ឆ្នាំ២០..........- ២០..........

**យោង៖** គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងតាមសាលារៀន

សាលារៀនបានអនុវត្តកិច្ចការតាមសេចក្តីណែនាំ និងមានជូនភ្ជាប់មកជាមួយនូវឯកសារខាងក្រោមនេះសម្រាប់ស្នើសុំមូលនិធិកែលម្អសាលារៀន៖

១. ពាក្យស្នើសុំថវិកាកែលម្អសាលារៀន
២. ផែនការសកម្មភាពសាលារៀនប្រចាំឆ្នាំ និងថវិកា
៣. ផែនការកែលម្អសាលារៀនប្រចាំឆ្នាំ៖ ឧបករណ៍វាយតម្លៃសម្រាប់សាលារៀនមធ្យមសិក្សា
៤. ផែនការថ្នាក់រៀននិងការគ្រប់គ្រងសាលារៀនលម្អិតប្រចាំត្រីមាស៖ ឧបករណ៍វាយតម្លៃសម្រាប់សាលារៀន
៥. របាយការណ៍វាយតម្លៃការបំពេញស្តង់ដាសាលារៀនមានប្រសិទ្ធភាព។

អាស្រ័យហេតុនេះសូម ..............ប្រធានគណៈកម្មការគ្រប់គ្រងមូលនិធិកែលម្អសាលារៀនថ្នាក់ជាតិ មេត្តាពិនិត្យ និងអនុម័តផ្តល់មូលនិធិកែលម្អសាលារៀនដោយអនុគ្រោះ។

ធ្វើនៅ.............ថ្ងៃទី ខែ ឆ្នាំ២០.........

គណៈកម្មការគ្រប់គ្រងសាលារៀន

បានឃើញនិងបញ្ជូនមក
លោក/លោកស្រីប្រធានមន្ទីរអេយក
ដើម្បីពិនិត្យ
ធ្វើនៅថ្ងៃទី ខែ ឆ្នាំ ២០......
ការិយាល័យអប់រំក្រុង ស្រុក ខណ្ឌ

បានឃើញនិងបញ្ជូនមក
ប្រធានគណៈកម្មការគ្រប់គ្រងសាលារៀនថ្នាក់ជាតិ
ដើម្បីពិនិត្យនិងសម្រេច
ធ្វើនៅថ្ងៃទី ខែ ឆ្នាំ ២០.........
មន្ទីរអេបរំ យុវជន និងកីឡា

*ផលសម្រេច និងក្រុមគោលដៅរយៈពេល៣ឆ្នាំ*

| # | សូចនាករ | | **ឆ្នាំ0**<br>**2016-2017**<br>មូលដ្ឋាន | **ឆ្នាំទី១**<br>**2017-018**<br>ក្រុមគោលដៅ | **ឆ្នាំទី២**<br>**2018-2019**<br>ក្រុមគោលដៅ | **ឆ្នាំទី៣**<br>**2019-2020**<br>ក្រុមគោលដៅ |
|---|---|---|---|---|---|---|
| 1.1 | ចូលរៀន ត្រួតថ្នាក់ បោះបង់ និង ឡើងថ្នាក់ (ចំនួនសិស្ស) | *ចូលរៀន* | | | | |
| | | *ត្រួតថ្នាក់* | | | | |
| | | *បោះបង់* | | | | |
| | | *ឡើងថ្នាក់* | | | | |
| 1.2 | ភាគរយសិស្សសម្រេចផលសិក្សាចុងឆ្នាំសិក្សាជាពិន្ទុច្រើនជាង ៦០%នៃពិន្ទុសរុបលើមុខវិជ្ជាគោលនីមួយៗ | *ភាសាខ្មែរ* | | | | |
| | | *គណិតវិទ្យា* | | | | |
| | | *ភាសាបរទេស* | | | | |
| 1.3 | ភាគរយសិស្សសម្រេចផលសិក្សាចុងឆ្នាំសិក្សាជាពិន្ទុច្រើនជាង ៦០%នៃពិន្ទុសរុបលើមុខវិជ្ជាគោលនីមួយៗ(មុខវិជ្ជាវិទ្យាសាស្រ្ត និងវិទ្យាសាស្រ្តសង្គម (ប្រវត្តិវិទ្យា) | *រូបវិទ្យា* | | | | |
| | | *គីមីវិទ្យា* | | | | |
| | | *ជីវវិទ្យា* | | | | |
| | | *ផែនដីវិទ្យា* | | | | |
| | | *ប្រវត្តិវិទ្យា* | | | | |
| | | *ICT* | | | | |
| 1.4 | ភាគរយសិស្សថ្នាក់ទី៩សម្រេចបានល្បឿនអានភាសាខ្មែរក្នុង១នាទីនិងយល់ភាសា | | | | | |
| 1.5 | ភាគរយសិស្សថ្នាក់ទី៩ប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ | | | | | |

*សម្គាល់៖ ក្រុមគោលដៅឆ្នាំសិក្សា នឹងត្រូវយកទៅប្រើសម្រាប់ធ្វើផែនការកែលម្អសាលារៀន ប្រចាំឆ្នាំដែលមាននៅក្នុងស្តង់ដាទី១ វត្ថុបំណងគោលនយោបាយសាលារៀន*

## ឧបសម្ព័ន្ធ: ទម្រង់ផែនការកែលម្អសាលារៀន និងថវិកា

ឈ្មោះសាលារៀន៖.......................................................... លេខកូដ៖...................................................................................

ភូមិ៖.................................  ឃុំ/សង្កាត់៖............................ក្រុង/ស្រុក/ខណ្ឌ៖............................. រាជធានី/ខេត្ត៖........................

| ស្តង់ដានិងសូចនាករ៖ លទ្ធផល | សកម្មភាព | ពេលវេលាជាត្រីមាស | ថវិកា |
|---|---|---|---|
| ស្តង់ដា២៖ ការបង្រៀន និងរៀន | | | |
| | | | |
| ស្តង់ដា៣៖ មាតាបិតា និងសហគមន៍ជួយដល់ការរៀនសូត្រ | | | |
| | | | |
| ស្តង់ដា៤៖ សិស្ស និងសេវាជួយសិស្ស | | | |
| | | | |
| ស្តង់ដា៥៖ ការដឹកនាំនិងការគ្រប់គ្រង | | | |
| | | | |
| ស្តង់ដា៦៖ ធនធានមនុស្ស | | | |
| | | | |
| ស្តង់ដា៧៖ សម្ភារៈបង្រៀន និងរៀន | | | |
| | | | |
| ស្តង់ដា៨៖ ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន | | | |
| | | | |
| ស្តង់ដា៩៖ ការគ្រោងថវិកា និងការគ្រប់គ្រងហិរញ្ញវត្ថុ | | | |
| | | | |

## ឧបសម្ព័ន្ធ: ឧបករណ៍វាយតម្លៃការអនុវត្តសាលារៀនផ្អែកតាមស្តង់ដាសាលារៀនមានប្រសិទ្ធភាព

ឈ្មោះសាលារៀន៖........................ លេខកូដ៖.......................... ឃុំ/សង្កាត់៖...........................

ក្រុង/ស្រុក/ខណ្ឌ៖............................ រាជធានី/ខេត្ត៖.....................................................................

| **#** | **ស្តង់ដានិងសូចនាករ** | | **ពិន្ទុសម្រេចបានធៀបនឹងក្រុមគោលដៅ** | | |
|---|---|---|---|---|---|
| | | | ពិន្ទុ ១ | ពិន្ទុ ២ | ពិន្ទុ ៣ |
| **ស្តង់ដា ១ វត្ថុបំណងគោលនយោបាយសាលារៀន** | | | | | |
| # | សូចនាករ | | សម្រេចតិចជាងផែនការ = ១ | សម្រេចដូចផែនការ = ២ | សម្រេចលើសផែនការ = ៣ |
| 1.1 | ចូលរៀន ត្រួតថ្នាក់ បោះបង់ និងឡើងថ្នាក់ (ចំនួនសិស្ស) | *ចូលរៀន* | | | |
| | | *ត្រួតថ្នាក់* | | | |
| | | *បោះបង់* | | | |
| | | *ឡើងថ្នាក់* | | | |
| 1.2 | ភាគរយសិស្សសម្រេចផលសិក្សាចុងឆ្នាំសិក្សាជាពិន្ទុច្រើនជាង៦០%នៃពិន្ទុសរុបលើមុខវិជ្ជាគោលនីមួយៗ | *ភាសាខ្មែរ* | | | |
| | | *គណិតវិទ្យា* | | | |
| | | *ភាសាបរទេស* | | | |
| 1.3 | ភាគរយសិស្សសម្រេចផលសិក្សាចុងឆ្នាំសិក្សាជាពិន្ទុច្រើនជាង៦០%នៃពិន្ទុសរុបលើមុខវិជ្ជាគោលនីមួយៗ(លើមុខវិជ្ជាវិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម ប្រវត្តិវិទ្យា) | *រូបវិទ្យា* | | | |
| | | *គីមីវិទ្យា* | | | |
| | | *ជីវវិទ្យា* | | | |
| | | *ផែនដីវិទ្យា* | | | |
| | | *ប្រវត្តិវិទ្យា* | | | |
| | | *ICT* | | | |
| 1.4 | ភាគរយសិស្សថ្នាក់ទី៩សម្រេចបានល្បឿនអានភាសាខ្មែរក្នុង១នាទីនិងយល់ភាសា | | | | |
| 1.5 | ភាគរយសិស្សថ្នាក់ទី៩ប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ | | | | |
| **ពិន្ទុសរុបស្តង់ដាទី១** | | | 14 | 28 | 42 |
| សម្គាល់៖ ពិន្ទុស្តង់ដាអប្បបរមាគឺ៦៥% មានន័យថាស្តង់ដានេះត្រូវមានពិន្ទុយ៉ាងតិច២៧ ដើម្បីបំពេញបាននូវ ស្តង់ដាអប្បបរមា | | | | | |

| ស្តង់ដា ២៖ ការបង្រៀន និងការរៀន | | | | |
|---|---|---|---|---|
| 2.1 | មានបំណែងចែកកម្មវិធីសិក្សាតាមមុខវិជ្ជា(ឆ្នាំ) | ១ទៅ៤មុខវិជ្ជា មានកម្មវិធី សិក្សា | ៥ទៅ៨មុខវិជ្ជា មានកម្មវិធី សិក្សា | លើ៨មុខវិជ្ជាមាន មានកម្មវិធីសិក្សា |
| 2.2.1 | ចំនួនកិច្ចតែងការបង្រៀនបានរៀបចំតាមមុខវិជ្ជា គោល (ភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ និង វិទ្យាសាស្ត្រសង្គម / ប្រវត្តិវិទ្យា) ថ្នាក់ទី៧ ទៅតាម ក្រុមគោលដៅឆ្នាំ | ២មុខវិជ្ជា សម្រេចបាន តាមផែនការ | ៣ទៅ៤មុខវិជ្ជា សម្រេចបាន តាមផែនការ | លើ៤មុខវិជ្ជា សម្រេចបាន តាមផែនការ |
| 2.2.2 | ចំនួនកិច្ចតែងការបង្រៀនបានរៀបចំតាមមុខវិជ្ជា គោល (ភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ និង វិទ្យាសាស្ត្រសង្គម / ប្រវត្តិវិទ្យា) ថ្នាក់ទី៨ ទៅតាម ក្រុមគោលដៅឆ្នាំ | ២មុខវិជ្ជា សម្រេចបាន តាមផែនការ | ៣ទៅ៤មុខវិជ្ជា សម្រេចបាន តាមផែនការ | លើ៤មុខវិជ្ជា សម្រេចបានតាម ផែនការ |
| 2.2.3 | ចំនួនកិច្ចតែងការបង្រៀនបានរៀបចំតាមមុខវិជ្ជា គោល (ភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ និង វិទ្យាសាស្ត្រសង្គម / ប្រវត្តិវិទ្យា) ថ្នាក់ទី៩ ទៅតាម ក្រុមគោលដៅឆ្នាំ | ២មុខវិជ្ជា សម្រេចបាន តាមផែនការ | ៣ទៅ៤មុខវិជ្ជា សម្រេចបាន តាមផែនការ | លើ៤មុខវិជ្ជា សម្រេចបាន តាមផែនការ |
| 2.3 | ចំនួនសិស្សថ្នាក់ទី៩មានពិនិត្យតេស្តជាប់ស្តង់ដា ល្បឿនអំណាននិងយល់ខ្លឹមសារ (២០០ពាក្យក្នុង មួយនាទី) (ត្រូវពិនិត្យតាមដាននៅចុង ឆមាសទី១ និងទី២) | តិចជាង៦០% នៃសិស្សសរុប មានពិន្ទុជាប់ ស្តង់ដា | ពី៦០%ទៅ ៨០%នៃសិស្ស សរុបមានពិន្ទុ ជាប់ស្តង់ដា | លើ៨០%នៃសិស្ស សរុបមានពិន្ទុជាប់ ស្តង់ដា |
| 2.4.1 | ចំនួនសិស្សថ្នាក់ទី៧មានពិន្ទុតេស្តជាប់លើមុខវិជ្ជា គោលធៀបជាមួយក្រុមគោលដៅគ្រោងទុក (ត្រូវ ពិនិត្យតាមដាននៅចុងឆមាសទី១និងទី២) | តិចជាង៦០% នៃសិស្សសរុប មានពិន្ទុជាប់ ស្តង់ដា | ពី៦០%ទៅ ៨០%នៃសិស្ស សរុបមានពិន្ទុ ជាប់ស្តង់ដា | លើ៨០%នៃសិស្ស សរុបមានពិន្ទុជាប់ ស្តង់ដា |
| 2.4.2 | ចំនួនសិស្សថ្នាក់ទី៨មានពិន្ទុតេស្តជាប់លើមុខវិជ្ជា គោលធៀបជាមួយក្រុមគោលដៅគ្រោងទុក (ត្រូវ ពិនិត្យតាមដាននៅចុងឆមាសទី១និងទី២) | តិចជាង៦០% នៃសិស្សសរុប មានពិន្ទុជាប់ ស្តង់ដា | ពី៦០% ទៅ ៨០%នៃ សិស្សសរុប មានពិន្ទុជាប់ ស្តង់ដា | លើ៨០%នៃសិស្ស សរុបមានពិន្ទុជាប់ ស្តង់ដា |
| 2.4.3 | ចំនួនសិស្សថ្នាក់ទី៩មានពិន្ទុតេស្តជាប់លើមុខវិជ្ជា គោលធៀបជាមួយក្រុមគោលដៅគ្រោងទុក (ត្រូវ ពិនិត្យតាមដាននៅចុងឆមាសទី១ និងទី២) | តិចជាង៦០% នៃសិស្សសរុប មានពិន្ទុជាប់ ស្តង់ដា | ពី៦០%ទៅ ៨០%នៃសិស្ស សរុបមានពិន្ទុ ជាប់ស្តង់ដា | លើ៨០%នៃសិស្ស សរុបមានពិន្ទុជាប់ ស្តង់ដា |
| 2.5 | ភាគរយសិស្សថ្នាក់ទី៩ប្រឡងជាប់ការប្រឡង ឆមាស (ត្រូវពិនិត្យតាមដាននៅចុងឆមាសទី១និង ទី២) | ទាបជាងក្រុម គោលដៅ គ្រោងទុក | ភាគសម្រេច បានតានក្រុម គោលដៅ គ្រោងទុក | សម្រេចបានលើស ក្រុមគោលដៅ គ្រោងទុក |

| | | | | |
|---|---|---|---|---|
| 2.7 | ចំនួនថ្នាក់មានការប្រជុំរវាងគ្រូបង្រៀន មាតាបិតា និង សិស្សរៀនយឺត (សិស្សត្រួតថ្នាក់ពីឆ្នាំមុន សិស្សដែលមាន ពិន្ទុទាបជាង៦០%ពីចុងឆ្នាំសិក្សាមុន និងនៅបំណាច់ខែទី១) ធៀបជាមួយក្រុមគោលដៅ | ចំនួនសិស្សរៀនយឺតក្រោម៣០% ចូលរួមប្រជុំ | ចំនួនសិស្សរៀនយឺតពី ៣០% ទៅ ៦០% ចូលរួមប្រជុំ | ចំនួនសិស្សរៀនយឺតលើ៦០% ចូលរួមប្រជុំ |
| 2.8.1 | កង្វះចំនួនម៉ោងបង្រៀនជាមធ្យមនៃថ្នាក់ទី៧ (ត្រូវពិនិត្យតាមដាននៅចុងឆមាសទី១និងទី២) | កង្វះម៉ោងបង្រៀនច្រើនជាង៥០ម៉ោង | កង្វះម៉ោងបង្រៀនច្រើនពី ៣០ទៅ៥០ ម៉ោង | កង្វះម៉ោងបង្រៀនតិចជាង៣០ ម៉ោង |
| 2.8.2 | កង្វះចំនួនម៉ោងបង្រៀនជាមធ្យមនៃថ្នាក់ទី៨ (ត្រូវពិនិត្យតាមដាននៅចុងឆមាសទី១និងទី២) | កង្វះម៉ោងបង្រៀនច្រើនជាង៥០ម៉ោង | កង្វះម៉ោងបង្រៀនច្រើនពី៣០ទៅ៥០ ម៉ោង | កង្វះម៉ោងបង្រៀនតិចជាង៣០ ម៉ោង |
| 2.8.3 | កង្វះចំនួនម៉ោងបង្រៀនជាមធ្យមនៃថ្នាក់ទី៩ (ត្រូវពិនិត្យតាមដាននៅចុងឆមាសទី១និងទី២) | កង្វះម៉ោងបង្រៀនច្រើនជាង៥០ម៉ោង | កង្វះម៉ោងបង្រៀនច្រើនពី៣០ទៅ៥០ ម៉ោង | កង្វះម៉ោងបង្រៀនតិចជាង៣០ម៉ោង |
| 2.9.1 | ភាគរយសិស្សអវត្តមានតិចជាង៥ដង | ថយចុះ៣០% ទាបជាងត្រីមាសទី១ | ថយចុះ៣០% ទៅ៥០%ទាបជាងត្រីមាសទី១ | ថយចុះលើ ៥០%ទាបជាងត្រីមាសទី១ |
| 2.9.2 | ភាគរយសិស្សអវត្តមានពី៥ទៅ១០ដង | ថយចុះ៣០% ទាបជាងត្រីមាសទី១ | ថយចុះ៣០% ទៅ៥០%ទាបជាងត្រីមាសទី១ | ថយចុះលើ៥០%ទាបជាងត្រីមាសទី១ |
| 2.9.3 | ភាគរយសិស្សអវត្តមានច្រើនជាង១០ដង | ថយចុះ៣០% ទាបជាងត្រីមាសទី១ | ថយចុះ៣០% ទៅ៥០%ទាបជាងត្រីមាសទី១ | ថយចុះលើ៥០%ទាបជាងត្រីមាសទី១ |
| 2.10.1 | ភាគរយសិស្សថ្នាក់ទី៧បានទទួលលំហាត់ឬកិច្ចការផ្ទះដាក់ឱ្យតាមមុខវិជ្ជាគោល(ភាសាខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ) ធៀបជាមួយក្រុមគោលដៅ គ្រោងទុក | ២មុខវិជ្ជាសម្រេចក្រុមគោលដៅតាមផែនការ | ៣ទៅ៤មុខ-វិជ្ជាសម្រេចក្រុមគោលដៅតាមផែនការ | លើ៤មុខវិជ្ជាសម្រេចក្រុមគោលដៅតាមផែនការ |


| | | | | |
|---|---|---|---|---|
| 2.10.1 | ភាគរយសិស្សថ្នាក់ទី៧បានទទួលលំហាត់ឬ | ២មុខវិជ្ជាសម្រេចក្រុម | ៣ទៅ៤មុខ-វិជ្ជាសម្រេច | លើ៤មុខវិជ្ជាសម្រេចក្រុមគោលដៅតាម |

| | | | | |
|---|---|---|---|---|
| | កិច្ចការផ្ទះដាក់ឱ្យតាមមុខវិជ្ជាគោល(ភាសាខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ) ធៀបជាមួយក្រុមគោលដៅ គ្រោងទុក | គោលដៅតាមផែនការ | ក្រុមគោលដៅតាមផែនការ | ផែនការ |
| 2.10.2 | ភាគរយសិស្សថ្នាក់ទី៨បានទទួលលំហាត់ឬកិច្ចការផ្ទះដាក់ឱ្យតាមមុខវិជ្ជាគោល(ភាសាខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ) ធៀបជាមួយក្រុមគោលដៅ គ្រោងទុក | ២មុខវិជ្ជាសម្រេចក្រុមគោលដៅតាមផែនការ | ៣ទៅ៤មុខ-វិជ្ជាសម្រេចក្រុមគោលដៅតាមផែនការ | លើ៤មុខវិជ្ជាសម្រេចក្រុមគោលដៅតាមផែនការ |
| 2.10.3 | ភាគរយសិស្សថ្នាក់ទី៩បានទទួលលំហាត់ឬកិច្ចការផ្ទះដាក់ឱ្យតាមមុខវិជ្ជាគោល(ភាសាខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ) ធៀបជាមួយក្រុមគោលដៅ គ្រោងទុក | ២មុខវិជ្ជាសម្រេចក្រុមគោលដៅតាមផែនការ | ៣ទៅ៤មុខ-វិជ្ជាសម្រេចក្រុមគោលដៅតាមផែនការ | លើ៤មុខវិជ្ជាសម្រេចក្រុមគោលដៅតាមផែនការ |
| 2.11.1 | ភាគរយសិស្សថ្នាក់ទី៧ បានទទួលកិច្ចការផ្ទះជា គម្រោងដាក់ឱ្យតាមមុខវិជ្ជាគោល (ភាសាខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ) ធៀបជាមួយក្រុម គោលដៅគ្រោងទុក | ២មុខវិជ្ជាសម្រេចក្រុមគោលដៅតាមផែនការ | ៣ទៅ៤មុខ-វិជ្ជាសម្រេចក្រុមគោល-ដៅតាមផែនការ | លើ៤មុខវិជ្ជាសម្រេចក្រុមគោលដៅតាមផែនការ |
| 2.11.2 | ភាគរយសិស្សថ្នាក់ទី៨បានទទួលកិច្ចការផ្ទះជា<br>គម្រោងដាក់ឱ្យតាមមុខវិជ្ជាគោល (ភាសាខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ) ធៀបជាមួយក្រុម គោលដៅគ្រោងទុក | ២មុខវិជ្ជាសម្រេចក្រុមគោលដៅតាមផែនការ | ៣ទៅ៤មុខ-វិជ្ជាសម្រេចក្រុមគោលដៅតាមផែនការ | លើ៤មុខវិជ្ជាសម្រេចក្រុមគោលដៅតាមផែនការ |
| 2.11.3 | ភាគរយសិស្សថ្នាក់ទី៩បានទទួលកិច្ចការផ្ទះជាគម្រោងដាក់ឱ្យតាមមុខវិជ្ជាគោល (ភាសាខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ) ធៀបជាមួយក្រុម គោលដៅគ្រោងទុក | ២មុខវិជ្ជាសម្រេចក្រុមគោលដៅតាមផែនការ | ៣ទៅ៤មុខវិជ្ជាសម្រេចក្រុមគោល-ដៅតាមផែនការ | លើ៤មុខវិជ្ជាសម្រេចក្រុមគោលដៅតាមផែនការ |
| 2.12 | ចំនួនគ្រូបង្រៀនក្រោមគោលដៅបានទទួលការ<br>បំប៉ននិងការជួយបង្រៀននៅនឹងកន្លែង | តិចជាង១ភាគ៣គ្រូក្រុមគោល-ដៅបានទទួលការបំប៉ន | រវាង១ភាគ៣ទៅ២ភាគ៣គ្រូក្រុមគោលដៅបានទទួលការបំប៉ន | ច្រើនជាង២ភាគ៣គ្រូក្រុមគោលដៅបានទទួលការបំប៉ន |
| 2.13 | ចំនួនថ្នាក់រៀនបានបំពេញរដ្ឋបាលថ្នាក់រៀន | តិចជាង | រវាង១ភាគ៣ | ច្រើនជាង២ភាគ៣ |

| | | | | |
|---|---|---|---|---|
| | តាមការណែនាំរបស់ក្រសួងធៀបជាមួយក្រុមគោលដៅ | ១ភាគ៣នៃថ្នាក់រៀនបានបំពេញរដ្ឋបាលថ្នាក់រៀន | ទៅ២ភាគ៣នៃថ្នាក់រៀនបានបំពេញរដ្ឋបាលថ្នាក់រៀន | នៃថ្នាក់រៀនបានបំពេញរដ្ឋបាលថ្នាក់រៀន |
| 2.14 | ភាគរយគ្រូបង្រៀនបើកថ្នាក់យឺតនិងបិទថ្នាក់មុនម៉ោងបានថយចុះធៀបជាមួយក្រុមគោលដៅ | មានទិន្ន-ន័យគ្រូបើកថ្នាក់យឺតនិងបិទថ្នាក់មុនម៉ោង | មានទិន្នន័យគ្រូបើកថ្នាក់យឺតនិងបិទថ្នាក់មុនម៉ោងនិងបាន ថយចុះធៀបជាមួយក្រុមគោលដៅ | មានទិន្នន័យគ្រូបើកថ្នាក់យឺតនិងបិទថ្នាក់មុនម៉ោងនិងមិនមានថ្នាក់បើកយឺតនិងបិទមុនម៉ោងទេ |
| 2.15 | ចំនួនមុខវិជ្ជាអប់រំកាយ កីឡា និងសិល្បៈបានបង្រៀនតាមគ្រុមគោលដៅគ្រោង (សរុប១៨មុខវិជ្ជា) | ៥មុខវិជ្ជាបានបង្រៀន | រវាង៦ទៅ១០មុខវិជ្ជាបានបង្រៀន | លើ១០មុខវិជ្ជាបានបង្រៀន |
| ពិន្ទុសរុបស្តង់ដាទី២ | | ២៦ | ៥២ | ៧៨ |
| សម្គាល់៖ ពិន្ទុស្តង់ដាអប្បបរមាគឺ៦៥% មានន័យថាស្តង់ដានេះត្រូវមានពិន្ទុយ៉ាងតិច ៥១ ដើម្បីបំពេញ បាននូវស្តង់ដាអប្បបរមា | | | | |

| | | | | |
|---|---|---|---|---|
| **ស្តង់ដាទី៣៖ មាតាបិតា និងសហគមន៍ជួយការសិក្សាសិស្ស** | | | | |
| 3.1 | ភាគរយថ្នាក់រៀនបានប្រជុំប្រឹក្សាយោបល់រវាងគ្រូបង្រៀន មាតាបិតា និងសិស្ស (នៅដើមឆ្នាំសិក្សា និងតាមត្រីមាស) | ៥០%នៃថ្នាក់ចុះក្រោមមានប្រជុំ | ពី៥០%ទៅ៨០%នៃថ្នាក់ចុះក្រោមមានប្រជុំ | ច្រើនជាង៨០%នៃថ្នាក់ចុះក្រោមមានប្រជុំ |
| 3.2 | ចំនួនប្រជុំគណៈកម្មការគ្រប់គ្រងសាលារៀន តាមការណែនាំ (ពេលបើកបវេសនកាល ចុងឆមាសទី១ និងទី២) | ប្រជុំតែពេលបើកបវេសនកាល | ប្រជុំពេលបើកបវេសនកាលនិងចុងឆមាសទី១ | ប្រជុំពេលបើកបវេសនកាលចុងឆមាសទី១និងទី២ |
| 3.3 | ភាគរយសិស្សមករៀនយឺត | ថយចុះ៥០%ធៀបនឹងត្រីមាសមុន | ថយចុះពី៥០%ទៅ៧៥%ធៀបនឹងត្រីមាស | ថយចុះលើ៧៥%ធៀបនឹងត្រីមាសមុន |

| | | | | |
|---|---|---|---|---|
| | | | មុន | |

| | | | | |
|---|---|---|---|---|
| 3.4 | ភាគរយសិស្សបានធ្វើកិច្ចការផ្ទះឬកិច្ចការគម្រោង | ៥០%សិស្សបានធ្វើ | ពី៥១%ដល់ ៧៥%សិស្សបានធ្វើ | លើ៧៥% សិស្សបានធ្វើ |
| **ពិន្ទុសរុបស្តង់ដាទី៣** | | ៤ | ៨ | ១២ |
| សម្គាល់៖ ពិន្ទុស្តង់ដាអប្បបរមាគឺ៦៥% មានន័យថាស្តង់ដានេះត្រូវមានពិន្ទុយ៉ាងតិច ៨ ដើម្បីបំពេញបាននូវស្តង់ដាអប្បបរមា | | | | |

| | | | | |
|---|---|---|---|---|
| **ស្តង់ដាទី៤៖ សិស្សនិងសេវាជួយសិស្ស** | | | | |
| 4.1 | ភាគរយសិស្សប្រើបណ្ណាល័យ (ពិនិត្យតាមដានរាល់ត្រីមាស) | គ្មានបណ្ណា-ល័យ ឬ តិច ជាង៣០% សិស្សប្រើ បណ្ណាល័យ | ពី៣០%ទៅ ៦០%សិស្សប្រើ បណ្ណាល័យ | ច្រើនជាង ៦០%សិស្ស ប្រើ បណ្ណាល័យ |
| 4.2 | ភាគរយសិស្សប្រើបន្ទប់ពិសោធន៍ | គ្មានបន្ទប់ពិសោធ-ន៍ឬតិចជាង៣០% សិស្សប្រើបន្ទប់ ពិសោធន៍ | ពី៣០% ទៅ ៦០%សិស្សប្រើ បន្ទប់ពិសោធន៍ | ច្រើនជាង ៦០%សិស្ស ប្រើ បន្ទប់ពិសោធន៍ |
| 4.3 | ភាគរយសិស្សប្រើកុំព្យូទ័រ | គ្មានកុំព្យូទ័រឬតិច ជាង៣០% សិស្ស ប្រើកុំព្យូទ័រ | ពី៣០% ទៅ ៦០%សិស្ស ប្រើកុំព្យូទ័រ | ច្រើនជាង ៦០%ភាគរយ សិស្សប្រើកុំព្យូទ័រ |
| 4.4 | ភាគរយថ្នាក់មានដំណើរការ (តាមការណែនាំរបស់ក្រសួង) ក្លឹបសិក្សាសិស្ស | ក្រោម៥០%នៃថ្នាក់ មានក្លឹបសិក្សាមាន ដំណើរការ | ពី៥០% ទៅ ៧៥%នៃថ្នាក់ មានក្លឹបសិក្សា មានដំណើរការ | កលើ៧៥%នៃ ថ្នាក់មានក្លឹប សិក្សាមាន ដំណើរការ |
| 4.5 | ភាគរយសិស្សខ្សោយគំហើញនិងខ្សោយស្តាប់បានទទួលការគាំទ្រដើម្បីរៀនបានប្រសើរ | មិនមានព័ត៌មាន ឬ៣០%នៃសិស្ស បានទទួលការការ គាំទ្រនិងជាប់ពិន្ទុ តេស្ត | ពី៣០%ទៅ ៥០%នៃសិស្ស បានទទួលការ ការគាំទ្រ និង ជាប់ ពិន្ទុតេស្ត | លើ៥០%នៃ សិស្សបាន ទទួលការការ គាំទ្រ និងជាប់ ពិន្ទុតេស្ត |
| 4.6 | ភាគរយសិស្សអាហារូបករណ៍បោះបង់ការសិក្សា | ច្រើនជាង១០% បោះបង់ | ៥%ទៅ១០% បោះបង់ | តិចជាង៥% បោះបង់ |

| | | | | |
|---|---|---|---|---|
| 4.7 | ចំនួនទស្សនកិច្ចសិក្សារបស់គ្រូបង្រៀន | ផែនការទស្សនកិច្ចបានរៀបចំតាមការណែនាំ | ផែនការទស្សនកិច្ចបានរៀបចំតាមការណែនាំ និងធ្វើទស្សនកិច្ចបាន១ដង | ផែនការទស្សនកិច្ចបានរៀបចំតាមការណែនាំ និងធ្វើទស្សនកិច្ចបាន២ដងឡើង |
| **ពិន្ទុសរុបស្តង់ដាទី៤** | | ៧ | ១៤ | ២១ |
| **សម្គាល់៖** ពិន្ទុស្តង់ដាអប្បបរមាគឺ៦៥% មានន័យថាស្តង់ដានេះត្រូវមានពិន្ទុយ៉ាងតិច ១៤ ដើម្បីបំពេញបាននូវស្តង់ដាអប្បបរមា | | | | |

| **ស្តង់ដាទី៥៖ ការដឹកនាំ និងការគ្រប់គ្រងសាលារៀន** | | | | |
|---|---|---|---|---|
| 5.1 | ចំនួនសូចនាកររដ្ឋបាលសាលារៀនបានបំពេញតាមការណែនាំរបស់ក្រសួង (សរុប១០សូចនាករ) | សម្រេចបានតែ៥ | សម្រេចបានពី ៦ ដល់ ៨ | សម្រេចបានពី ៩ ដល់ ១០ |
| 5.2 | ការអនុវត្តផែនការអធិការកិច្ចរបស់នាយក ឬនាយិកាឬនាយករងឬនាយិការង | មានផែនការអធិការកិច្ចនិងបានធ្វើអធិការកិច្ចតាមផែនការនៅត្រីមាសទី១ | មានផែនការអធិការកិច្ចនិងបានធ្វើអធិការកិច្ចតាមផែនការនៅត្រីមាសទី១ និងទី២ | មានផែនការអធិការកិច្ចនិងបានធ្វើអធិការ-កិច្ចតាមផែនការទាំង៣ត្រីមាស |
| 5.3 | ចំនួនការប្រជុំបច្ចេកទេសប្រចាំខែតាមការណែនាំរបស់ក្រសួង (សរុប៧ដងក្នុង១ឆ្នាំ) | បានប្រជុំតិចជាង៤ដង | បានប្រជុំពី៤ទៅ៥ដង | បានប្រជុំពី៦ទៅ៧ដង |
| 5.4 | ចំនួនដងបំប៉ននិងដឹកដៃធ្វើការងារនៅនឹងកន្លែងដល់នាយក និងគណៈកម្មការគ្រប់គ្រងសាលារៀន ដោយមន្ត្រីក្រសួង ដើម្បីកែលម្អសូចនាករគ្រប់គ្រងសាលារៀន | តិចជាង៥០% ចំនួនដងបំប៉នបានធ្វើធៀបនឹងក្រុមគោលដៅ | ពី៥០%ទៅ ៨០%ចំនួនដងបំប៉នបានធ្វើធៀបនឹងក្រុមគោលដៅ | លើ៨០%ចំនួនដងបំប៉នបានធ្វើធៀបនឹងក្រុមគោលដៅ |
| 5.5 | ចំនួនគ្រូបង្រៀនបានបំពេញការងារប្រសើរជាងមុនតាមរយៈការវាយតម្លៃការអនុវត្តការងារប្រចាំឆ្នាំ | តិចជាង៣០% គ្រូបង្រៀនបានបំពេញការងារប្រសើរជាងមុន | ពី៣០%ទៅ ៧០%គ្រូបង្រៀនបានបំពេញការងារប្រសើរជាងមុន | ច្រើនជាង៧០% គ្រូបង្រៀនបានបំពេញការងារប្រសើរជាងមុន |

| | | | | |
|---|---|---|---|---|
| 5.5 | ចំនួនគ្រូបង្រៀនបានបំពេញការងារប្រសើរជាងមុនតាមរយៈការវាយតម្លៃការអនុវត្តការងារប្រចាំឆ្នាំ | តិចជាង៣០% គ្រូបង្រៀនបានបំពេញការងារប្រសើរជាងមុន | ពី៣០%ទៅ៧០%គ្រូបង្រៀនបានបំពេញការងារប្រសើរជាងមុន | ច្រើនជាង៧០% គ្រូបង្រៀនបានបំពេញការងារប្រសើរជាងមុន |
| 5.6 | ការបន្ថយភាពមិនប្រក្រតីនៅសាលារៀន (សរុប៩ភាពមិនប្រក្រតី) | តិចជាង៦ បានបន្ថយ | ពី៦ ទៅ៨ បានបន្ថយ | មិនមានភាពមិនប្រក្រតីទាំង៩ |
| 5.7 | ចំនួនដងពិនិត្យតាមដាននិងគាំទ្រពីថ្នាក់ស្រុក មន្ទីរ និងក្រសួង | សាលាបានទទួលការគាំទ្រដូចក្នុងផែនការនៅត្រីមាសទី១ | សាលាបានទទួលការគាំទ្រដូចក្នុងផែនការនៅត្រីមាសទី១ និងទី២ | សាលាបានទទួលការគាំទ្រដូចក្នុងផែនការទាំង៣ត្រីមាស |
| **សរុបពិន្ទុស្តង់ដាទី៥** | | **៧** | **១៤** | **២១** |
| **សម្គាល់៖** ពិន្ទុស្តង់ដាអប្បបរមាគឺ៦៥% មានន័យថាស្តង់ដានេះត្រូវមានពិន្ទុយ៉ាងតិច ១៤ ដើម្បីបំពេញបាននូវស្តង់ដាអប្បបរមា | | | | |

| **ស្តង់ដាទី៦៖ ធនធានមនុស្ស** | | | | |
|---|---|---|---|---|
| 6.1 | គុណវុឌ្ឍិគ្រូបង្រៀនធៀបជាមួយផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន | សាលាមានស្ថិតិមន្ត្រី និងក្រោម៦០% មានគុណវុឌ្ឍិតាមផែនការ | កពី៦០% ទៅ ៧៥% មានគុណវុឌ្ឍិតាមផែនការ | លើ៧៥%មានគុណវុឌ្ឍិតាមផែនការ |
| 6.3 | ចំនួនគ្រូខ្វះមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម (ប្រវត្តិវិទ្យា) ចុះថយធៀបជាមួយបទដ្ឋាន | ចំនួនគ្រូខ្វះថយចុះ៤០% | ចំនួនគ្រូខ្វះថយចុះពី ៤០%ទៅ៧៥% | ចំនួនគ្រូខ្វះថយចុះលើ ៧៥% |
| 6.4 | គុណវុឌ្ឍិនាយក ឬនាយិកាសាលារៀនធៀបជាមួយផែនការក្រសួង | នាយក ឬនាយិកាមិនបានទទួលការចាត់តាំងជាផ្លូវការ តែមិនទាន់បានដំឡើងគុណវុឌ្ឍិ | នាយក ឬនាយិកាបានទទួលការចាត់តាំងជាផ្លូវការ តែមិនទាន់បានដំឡើងគុណវុឌ្ឍិ | នាយក ឬនាយិកាបានទទួលការចាត់តាំងជាផ្លូវការ និងបានដំឡើងគុណវុឌ្ឍិ |

| | | | | |
|---|---|---|---|---|
| **ពិន្ទុសរុបស្តង់ដាទី៦** | | ៣ | ៦ | ៩ |
| **សម្គាល់៖** ពិន្ទុស្តង់ដាអប្បបរមាគឺ៦៥% មានន័យថាស្តង់ដានេះត្រូវមានពិន្ទុយ៉ាងតិច ៦ ដើម្បីបំពេញបាននូវស្តង់ដាអប្បបរមា | | | | |

| | | | | |
|---|---|---|---|---|
| **ស្តង់ដាទី៧៖ សៀវភៅសិក្សាគោល និងសម្ភារៈរៀន និងបង្រៀន** | | | | |
| 7.1 | ភាគរយសិស្សមានសៀវភៅសិក្សាគោលតាមមុខវិជ្ជានិងតាមកម្រិតថ្នាក់តាមបទដ្ឋាន | តិចជាង៥០% សិស្សមានសៀវភៅសិក្សាគោលតាមបទដ្ឋាន | ពី៥០%ទៅ៨០%សិស្សមានសៀវភៅសិក្សាគោលតាមបទដ្ឋាន | ច្រើនជាង៨០% សិស្សមានសៀវភៅសិក្សាគោលតាមបទដ្ឋាន |
| 7.2 | ចំនួនគ្រូបង្រៀនមុខវិជ្ជាគោលបានបំប៉នពីការប្រើប្រាស់សៀវភៅលំហាត់ | តិចជាង៤០% គ្រូបង្គោលបានបំប៉ន | ពី៤០%ទៅ៧៥%គ្រូបង្គោលបានបំប៉ន | លើ៧៥%គ្រូបង្គោលបានបំប៉ន |
| 7.3 | បណ្ណាល័យបានបង្កើត និងមានស្តង់ដា | បណ្ណាល័យមិនមានសៀវភៅនិងសង្ហារឹមតាមស្តង់ដា | បណ្ណាល័យមានសៀវភៅនិងសង្ហារឹមតាមស្តង់ដា | បណ្ណាល័យមានសៀវភៅ និង សង្ហារឹមនិងបើកប្រប្រាស់តាមស្តង់ដា |
| **ពិន្ទុសរុបស្តង់ដាទី៧** | | ៣ | ៦ | ៩ |
| **សម្គាល់៖** ពិន្ទុស្តង់ដាអប្បបរមាគឺ៦៥% មានន័យថាស្តង់ដានេះត្រូវមានពិន្ទុយ៉ាងតិច ៦ ដើម្បីបំពេញបាននូវស្តង់ដាអប្បបរមា | | | | |

| | | | | |
|---|---|---|---|---|
| **ស្តង់ដាទី៨៖ ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន** | | | | |
| 8.1 | កង្វះបន្ទប់រៀនថយចុះរហូតមានចំនួនសិស្សក្នុងបន្ទប់រៀនតាមបទដ្ឋាន | កង្វះបន្ទប់រៀនដូចឆ្នាំមុន | បានទទួលអគារសិក្សាថ្មីតែបន្ទប់រៀននៅតែខ្វះ | បានទទួល អគារសិក្សាថ្មីបំពេញបានបទដ្ឋានសិស្សក្នុងបន្ទប់រៀន |
| 8.2 | បន្ទប់ស្នាក់នៅរបស់គ្រូបង្រៀនបានសាងសង់តាមតម្រូវការ | សំណើបន្ទប់ស្នាក់នៅសម្រាប់គ្រូបង្រៀនបានដាក់ស្នើ | បន្ទប់ស្នាក់នៅសម្រាប់គ្រូបង្រៀនបានផ្តល់តែនៅមិនទាន់គ្រប់ | បន្ទប់ស្នាក់នៅសម្រាប់គ្រូបង្រៀនបានផ្តល់គ្រប់គ្រាន់ |

| | | | | |
|---|---|---|---|---|
| 8.3 | បន្ទប់រដ្ឋបាលសាលារៀននិងសង្ហារឹមបានផ្តល់តាមតម្រូវការ | មានបន្ទប់សម្រាប់នាយកនិងនាយករង | មានបន្ទប់សម្រាប់នាយកនាយករង និងគ្រូបង្រៀន | មានបន្ទប់សម្រាប់នាយកនាយករងបុគ្គលិកបង្រៀននិងបុគ្គលិកមិនបង្រៀន |
| 8.4 | បន្ទប់ទឹកបានសាងសង់តាមស្តង់ដា និងគ្រប់គ្រាន់តាមបទដ្ឋានសម្រាប់សិស្សទាំងស្រីទាំងប្រុស | បន្ទប់ទឹកមានតែមិនតាមបទដ្ឋានសម្រាប់សិស្សស្រី និងប្រុស | បន្ទប់ទឹកមានតាមបទដ្ឋានសម្រាប់សិស្សស្រី និងប្រុស | បន្ទប់ទឹកមាន តែមិនតាមបទដ្ឋានសម្រាប់សិស្សស្រី និងប្រុស និងមានស្តង់ដា |
| 8.5 | សូចនាករបរិស្ថានសាលារៀនបានបំពេញ (សរុប១៦សូចនាករ) | មានតិចជាង ១០សូចនាករបានបំពេញ | មាន១០ទៅ១២សូចនាករបានបំពេញ | មាន១៣ទៅ១៦សូចនាករបានបំពេញ |
| **ពិន្ទុស្តង់ដាទី៨** | | ៥ | ១០ | ១៥ |
| **សម្គាល់៖** ពិន្ទុស្តង់ដាអប្បបរមាគឺ៦៥% មានន័យថាស្តង់ដានេះត្រូវមានពិន្ទុយ៉ាងតិច ១០ ដើម្បីបំពេញបាននូវស្តង់ដាអប្បបរមា | | | | |

| | | | | |
|---|---|---|---|---|
| **ស្តង់ដាទី៩៖ ហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ** | | | | |
| 9.1 | ថវិកាសាលារៀន ពីប្រភពផ្សេងៗ បានទទួលជាក់ស្តែងតាមត្រីមាស មានភាពប្រសើរឡើង | បរិមាណថវិកាទទួលតិចជាងគ្រោងនិងមិនទាន់ពេល | បរិមាណថវិកាទទួលតាមគ្រោងតែមិនទាន់ពេល | បរិមាណថវិកាទទួលតាមគ្រោងនិងទាន់ពេល |
| 9.2 | ការចាត់ចែង ការប្រើប្រាស់ និតម្លាភាពថវិកាសាលារៀនបានប្រសើរ (សរុប៥សូចនាករ) | មានតែ២សូចនាករបានបំពេញ | ៣ទៅ៤សូចនាករបានបំពេញ | សូចនាករទាំង៥បានបំពេញ |
| 9.3 | ការរាយការណ៍ការចំណាយតាមខ្ទង់ចំណាយធំៗ (រដ្ឋបាល ការបង្រៀននិងរៀន និង បរិស្ថាន) បានប្រសើរដោយផ្តោតការចំណាយលើការបង្រៀននិងរៀន | ចំណាយតិចជាង៥០%លើការបង្រៀននិងរៀន | ចំណាយតិចជាង៥០%ទៅ៥៥%លើការបង្រៀន-រៀន | ចំណាយច្រើនជាង៥៥%លើការបង្រៀននិងរៀន |
| **ពិន្ទុសរុបស្តង់ដាទី៩** | | ៣ | ៦ | ៩ |
| **សម្គាល់៖** ពិន្ទុស្តង់ដាអប្បបរមាគឺ៦៥% មានន័យថាស្តង់ដានេះត្រូវមានពិន្ទុយ៉ាងតិច ៦ ដើម្បីបំពេញបាននូវ ស្តង់ដាអប្បបរមា | | | | |
| **សម្គាល់៖** ពិន្ទុស្តង់ដាអប្បបរមាគឺ៦៥% មានន័យថាស្តង់ដាទាំង៩នេះ ត្រូវមានពិន្ទុយ៉ាងតិច១៥០ពិន្ទុ ដើម្បីបំពេញ បាននូវស្តង់ដាអប្បបរមាសាលារៀនមានប្រសិទ្ធភាព | | | | |

ទម្រង់៖ សំណើរបស់មន្ទីរ/ការិយាល័យអប់រំ យុវជន និងកីឡា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

មន្ទីរ/ការិយាល័យអប់រំ យុវជន និងកីឡា
លេខ:..................................

**ប្រធានមន្ទីរ/ការិយាល័យអប់រំ យុវជន និងកីឡា** ..........................
**សូមគោរព**
**ឯកឧត្តមនាយកគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា**

**តាមរយៈ៖** សំណើសុំថវិកាកែលម្អសាលារៀនចំនួន....................(........................)
**កម្មវត្ថុ៖** សំណើសុំថវិកាកែលម្អសាលារៀនចំនួន....................(........................)
**យោង៖** សេចក្តីណែនាំពីការគ្រប់គ្រងតាមសាលារៀន

មន្ទីរ/ការិយាល័យអប់រំ យុវជន និងកីឡាបានរៀបចំសំណើ និងសូមដាក់ជូនសំណើដូច ខាងក្រោមនេះដល់គណៈកម្មការគ្រប់គ្រងអនុវិស័យពិនិត្យ និងសម្រេច។

**ឯកសារសំណើមាន៖**

១. របាយការណ៍វាយតម្លៃការអនុវត្តការងាររបស់មន្ទីរ/ការិយាល័យអប់រំ យុវជន និងកីឡា
២. ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់មន្ទីរ/ការិយាល័យអប់រំ យុវជន និងកីឡា

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើសូមឯកឧត្តមមេត្តាពិនិត្យ និងសម្រេចដោយសេចក្តីអនុគ្រោះ។

សូមឯកឧត្តមនាយកគម្រោងមេត្តាទទួលនូវសេចក្តីគោរពអំពីខ្ញុំ

ធ្វើនៅ........................... ថ្ងៃទី......ខែ.............ឆ្នាំ២០....

ប្រធានមន្ទីរ/ប្រធានការិយាល័យ

# ឧបសម្ព័ន្ធ៖ ឧបករណ៍វាយតម្លៃរបស់ថ្នាក់ជាតិប្រើប្រាស់វាយតម្លៃការបំពេញការងាររបស់មន្ទីរអប់រំ យុវជន និងកីឡា

## រាជធានី ខេត្ត ………………………………………………ឆ្នាំ………………..

| កិច្ចការចម្បងៗ | ពិន្ទុរីកចម្រើន | | | | |
|---|---|---|---|---|---|
| | ទាបខ្លាំង= ១ | ទាប= ២ | មធ្យម=៣ | ល្អ=៤ | ល្អប្រសើរ=៥ |
| ១. ការធ្វើផែនការយុទ្ធ-សាស្រ្តថវិកា ផែនការ ប្រតិបត្តិឆ្នាំ និង ការអនុវត្ត ផែនការ | មិនមានផែនការយុទ្ធសាស្រ្តថវិកា ឬផែនការប្រតិបត្តិឆ្នាំ ឬមួយមាន តែមិនតាមប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផល | ផែនការបានរៀបចំតាមប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផលតេស្តកម្មភាពចំនួនពី០ទៅ២៥%បានអនុវត្ត | ផែនការបានរៀបចំតាមប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផលតេស្តកម្មភាពចំនួនពី២៥%ទៅ៥០%បានអនុវត្ត | ផែនការបានរៀបចំតាមប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផលតេស្តកម្មភាពចំនួនពី៥១%ទៅ៧៥%បានអនុវត្ត | ផែនការបានរៀបចំតាមប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផលតេស្តកម្មភាពចំនួនពី៧៦%ឡើងបានអនុវត្ត |
| **សម្គាល់៖** សរសេរពិន្ទុវាយតម្លៃនៅទីនេះ..................... ហើយអធិប្បាយពីស្ថានភាពនៃកិច្ចការតាមការវាយតម្លៃ និងកំណត់ពិន្ទុក្រុមគោលដៅ និងស្ថានភាពនៃកិច្ចការជាផែនការសម្រាប់ឆ្នាំសិក្សាបន្ទាប់.................................................................................................................................................................................... | | | | | |
| ២.ការគ្រប់គ្រងមន្ត្រី (ការពង្រាយគ្រូ) | មិនមានទិន្នន័យពីគ្រូខ្វះ ឬលើស ឬមួយមានតែមិនមាន បច្ចុប្បន្នភាព | មានទិន្នន័យបច្ចុប្បន្នភាពពីគ្រូខ្វះឬលើស តែមិនមានផែនការសកម្មភាពដោះស្រាយ | មានទិន្នន័យបច្ចុប្បន្នភាពពីគ្រូខ្វះ ឬ លើស មានផែនការសកម្មភាពនិងចាប់ផ្តើមដោះស្រាយ | មានទិន្នន័យបច្ចុប្បន្នភាពពីគ្រូខ្វះ ឬ លើស មានផែនការសកម្មភាពនិង ហើយគ្រូខ្វះ ឬ លើសថយចុះ | មានទិន្នន័យបច្ចុប្បន្នភាពពីគ្រូខ្វះ ឬ លើស មានផែនការសកម្មភាពនិង មិនមានបញ្ហាពីគ្រូខ្វះឬលើយ |

| | | | | | |
|---|---|---|---|---|---|
| **សម្គាល់៖** សរសេរពិន្ទុវាយតម្លៃនៅទីនេះ..................... ហើយអធិប្បាយពីស្ថានភាពនៃកិច្ចការតាមការវាយតម្លៃ និងកំណត់ពិន្ទុក្រុមគោលដៅ និងស្ថានភាពនៃកិច្ចការជាផែនការសម្រាប់ឆ្នាំសិក្សាបន្ទាប់............................................................................................................................................................................................................ | | | | | |
| ៣. ការគ្រប់គ្រងសៀវភៅសិក្សាគោល | មិនមានទិន្នន័យពីសៀវភៅសិក្សាគោលត្រូវការ ឬមួយមានតែមិនមានបច្ចុប្បន្នភាព | មានទិន្នន័យបច្ចុប្បន្នភាពពីសៀវភៅសិក្សាគោលត្រូវការ តែមិនមានផែនការសកម្មភាពដោះស្រាយ | មានទិន្នន័យបច្ចុប្បន្នភាពពីសៀវភៅសិក្សាគោលត្រូវការ មានផែនការសកម្មភាពនិងចាប់ផ្ដើមដោះស្រាយ | មានទិន្នន័យបច្ចុប្បន្នភាពពីសៀវភៅសិក្សាគោលត្រូវការ មានផែនការសកម្មភាពនិងសៀវភៅលើសឬខ្វះថយចុះ | មានទិន្នន័យបច្ចុប្បន្នភាពពីសៀវភៅសិក្សាគោលត្រូវការ មានផែនការសកម្មភាពនិងមិនមានបញ្ហាសៀវភៅលើស |
| **សម្គាល់៖** សរសេរពិន្ទុវាយតម្លៃនៅទីនេះ..................... ហើយអធិប្បាយពីស្ថានភាពនៃកិច្ចការតាមការវាយតម្លៃ និងកំណត់ពិន្ទុក្រុមគោលដៅ និងស្ថានភាពនៃកិច្ចការជាផែនការសម្រាប់ឆ្នាំសិក្សាបន្ទាប់............................................................................................................................................................................................................ | | | | | |
| ៤. ការគ្រប់គ្រង និងហេដ្ឋារចនាសម្ព័ន្ធសាលារៀន | មិនមានទិន្នន័យពីតម្រូវការអគារសិក្សា ឬ មួយមានតែមិនមានបច្ចុប្បន្នភាព | មានទិន្នន័យមានបច្ចុប្បន្នភាពបានប្រើទិន្នន័យស្នើសុំអគារសិក្សាដល់ក្រសួង | មានទិន្នន័យមានបច្ចុប្បន្នភាពបានប្រើទិន្នន័យស្នើសុំអគារសិក្សាដល់មន្ទីរ និងបានប្រើទិន្នន័យកសាងផែនការសាងសង់របស់ការិយាល័យ | មានទិន្នន័យមានបច្ចុប្បន្នភាពបានប្រើទិន្នន័យស្នើសុំអគារសិក្សាដល់មន្ទីរ និងបានប្រើទិន្នន័យកសាងផែនការសាងសង់របស់ការិយាល័យ និងបានទាក់ទងសហគមន៍និងដៃគូសម្រាប់រកមូលនិធិ | មានទិន្នន័យមានបច្ចុប្បន្នភាពបានប្រើទិន្នន័យស្នើសុំអគារសិក្សាដល់មន្ទីរ និងបានប្រើទិន្នន័យកសាងផែនការសាងសង់របស់ការិយាល័យ និងបានទាក់ទងសហគមន៍និងដៃគូសម្រាប់រកមូលនិធិ ហើយ កង្វះអគារសិក្សាថយចុះ |
| **សម្គាល់៖** សរសេរពិន្ទុវាយតម្លៃនៅទីនេះ..................... ហើយអធិប្បាយពីស្ថានភាពនៃកិច្ចការតាមការវាយតម្លៃ និងកំណត់ពិន្ទុក្រុមគោលដៅ និងស្ថានភាពនៃកិច្ចការជាផែនការសម្រាប់ឆ្នាំសិក្សាបន្ទាប់............................................................................................................................................................................................................ | | | | | |

| | | | | | |
|---|---|---|---|---|---|
| ៥.ការពិនិត្យតាមដាន និងវាយតម្លៃ | មិនមានផែនការពិនិត្យតាមដាន ឬមួយមានតែមិនតាមប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើលទ្ធផល | មានផែនការតាមប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផល ពិនិត្យតាមដាន២ដងក្នុងមួយឆ្នាំក្នុងមួយក្រុង ស្រុក ខណ្ឌបានចំនួន២៥%នៃចំនួនក្រុង ស្រុក ខណ្ឌសរុប | មានផែនការតាមប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផល ពិនិត្យតាមដាន២ដងក្នុងមួយឆ្នាំក្នុងមួយក្រុង ស្រុក ខណ្ឌបានចំនួន២៦%ទៅ៥០% នៃចំនួនក្រុង ស្រុក ខណ្ឌសរុប | មានផែនការតាមប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផល ពិនិត្យតាមដាន២ដងក្នុងមួយឆ្នាំក្នុងមួយក្រុង ស្រុក ខណ្ឌបានចំនួន៥១%ទៅ៧០% នៃចំនួនក្រុង ស្រុក ខណ្ឌសរុប | មានផែនការតាមប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផល ពិនិត្យតាមដាន២ដងក្នុងមួយឆ្នាំក្នុងមួយស្រុកបានចំនួនលើ៧០%នៃចំនួនក្រុង ស្រុក ខណ្ឌសរុប |
| **សម្គាល់៖** សរសេរពិន្ទុវាយតម្លៃនៅទីនេះ..................... ហើយអធិប្បាយពីស្ថានភាពនៃកិច្ចការតាមការវាយតម្លៃ និងកំណត់ពិន្ទុក្រុមគោលដៅ និងស្ថានភាពនៃកិច្ចការជាផែនការសម្រាប់ឆ្នាំសិក្សាបន្ទាប់........................................................................................................................................................................................ | | | | | |
| ៦. ការគ្រប់គ្រងហិរញ្ញវត្ថុ | ថវិកាគ្រោងមិនបានរៀបចំពេញលេញទៅតាមសៀវភៅណែនាំពីការគ្រប់គ្រងហិរញ្ញ-វត្ថុរបស់ក្រសួងអប់រំ យុវជន និងកីឡា | ថវិកាគ្រោងបានរៀបចំពេញលេញទៅតាមសៀវភៅណែនាំពីការគ្រប់គ្រងតាមសាលារៀនរបស់ក្រសួង និងផ្អែកលើផែនការប្រតិបត្តិឆ្នាំរបស់មន្ទីរ | ថវិកាគ្រោងបានរៀបចំពេញលេញទៅតាមសៀវភៅណែនាំពីការគ្រប់គ្រងតាមសាលារៀនរបស់ក្រសួង និងផ្អែកលើផែនការប្រតិបត្តិឆ្នាំរបស់មន្ទីរ ហើយប្រាក់កែលម្អ សាលារៀននិងអាហារូបករណ៍បើកផ្តល់ទាន់ពេលនៅត្រីមាសទី១ និង ទី២ | ថវិកាគ្រោងបានរៀបចំពេញលេញទៅតាមសៀវភៅណែនាំពីការគ្រប់គ្រងតាមសាលារៀនរបស់ក្រសួង និងផ្អែកលើផែនការប្រតិបត្តិឆ្នាំរបស់មន្ទីរ ហើយប្រាក់កែលម្អ សាលារៀននិងអាហារូបករណ៍បើកផ្តល់ទាន់ពេលនៅត្រីមាសទី១ ទី២ និងទី៣ | ថវិកាគ្រោងបានរៀបចំពេញលេញទៅតាមសៀវភៅណែនាំពីការគ្រប់គ្រងតាមសាលារៀនរបស់ក្រសួង និងផ្អែកលើផែនការប្រតិបត្តិឆ្នាំរបស់មន្ទីរ ហើយប្រាក់កែលម្អ សាលារៀននិងអាហារូបករណ៍បើកផ្តល់ទាន់ពេលនៅគ្រប់ត្រីមាស |
| **សម្គាល់៖** សរសេរពិន្ទុវាយតម្លៃនៅទីនេះ..................... ហើយអធិប្បាយពីស្ថានភាពនៃកិច្ចការតាមការវាយតម្លៃ និងកំណត់ពិន្ទុក្រុមគោលដៅ និងស្ថានភាពនៃកិច្ចការជាផែនការសម្រាប់ឆ្នាំសិក្សាបន្ទាប់........................................................................................................................................................................................ | | | | | |

| | | | | | |
|---|---|---|---|---|---|
| ៧. ការពិនិត្យតាមដានការអនុវត្តរបស់ការិ.អប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ពិសេសលើផលសម្រេចការសិក្សារបស់សិស្ស | មិនមានទិន្ន័យពីផលសម្រេចការសិក្សារបស់សិស្ស | មានទិន្ន័យពីផលសម្រេចការសិក្សារបស់សិស្ស | មិនមានទិន្ន័យពីផលសម្រេចការសិក្សារបស់សិស្ស និងបានប្រើសម្រាប់កសាងផែនការ-សកម្មភាពជួយដល់ការិ.យអក ក្រុង ស្រុក ខណ្ឌ | មិនមានទិន្ន័យពីផលសម្រេចការសិក្សារបស់សិស្ស និងបានប្រើសម្រាប់កសាងផែនការ-សកម្មភាពជួយដល់ការិ.យអក ក្រុង ស្រុក ខណ្ឌ និងបោះ-ផ្សាយព័ត៌មានដល់ការិ.យអក ក្រុង ស្រុក ខណ្ឌ | មិនមានទិន្ន័យពីផលសម្រេចការសិក្សារបស់សិស្ស និងបានប្រើសម្រាប់កសាងផែនការសកម្មភាពជួយដល់ការិ.យអក ក្រុង ស្រុក ខណ្ឌ និងបោះផ្សាយព័ត៌មានដល់ការិ.យអក ក្រុង ស្រុក ខណ្ឌ និង បានប្រើសម្រាប់កសាងផែនការឆ្នាំបន្ទាប់ |
| **សម្គាល់៖** សរសេរពិន្ទុវាយតម្លៃនៅទីនេះ..................... ហើយអធិប្បាយពីស្ថានភាពនៃកិច្ចការតាមការវាយតម្លៃ និងកំណត់ពិន្ទុក្រុមគោលដៅ និងស្ថានភាពនៃកិច្ចការជាផែនការសម្រាប់ឆ្នាំសិក្សាបន្ទាប់........................................................................................................................................................ | | | | | |
| ៨.ការប្រើប្រាស់ថវិកាសាលារៀនតាមសៀវភៅណែនាំពីការគ្រប់គ្រងមានមូលដ្ឋាននៅសាលារៀន | សាលារៀនមានផែនការកែលម្អសាលារៀនប្រចាំឆ្នាំ តែមិនធ្វើតាមសៀវភៅណែនាំពីការគ្រប់គ្រងតាមសាលារៀន | ៣០% ទៅ ៥០% សាលារៀនមានផែនការកែលម្អសាលា-រៀនប្រចាំឆ្នាំ និងធ្វើតាមសៀវភៅណែនាំពីការគ្រប់គ្រងតាមសាលារៀន | ៥១% ទៅ ៧០% សាលារៀនមានផែនការកែលម្អសាលារៀនប្រចាំឆ្នាំ និងធ្វើតាមសៀវភៅណែនាំពីការគ្រប់គ្រងតាមសាលារៀន ហើយសហគមន៍ចូលរួមក្នុងការធ្វើផែនការនិងគ្រោងថវិកា | ៥១% ទៅ ៧០% សាលារៀនមានផែនការកែលម្អសាលារៀនប្រចាំឆ្នាំ និងធ្វើតាមសៀវភៅណែនាំពីការគ្រប់គ្រងតាមសាលារៀន ហើយសហគមន៍ចូលរួមក្នុងការធ្វើផែនការនិងគ្រោងថវិកា តិចជាង៥០%នៃថវិកាចំណាយលើការបង្រៀន និងរៀន និង៧០%នៃសាលារៀន បិទផ្សាយទិន្នន័យថវិកានិងការចំណាយជាសាធារណៈ | ៥១% ទៅ ៧០% សាលារៀនមានផែនការកែលម្អសាលារៀនប្រចាំឆ្នាំ និងធ្វើតាមសៀវភៅណែនាំពីការគ្រប់គ្រងតាមសាលារៀន ហើយសហគមន៍ចូលរួមក្នុងការធ្វើផែនការនិងគ្រោងថវិកា តិចជាង៥០%នៃថវិកាចំណាយលើការបង្រៀននិងរៀន និងសាលាទាំងអស់រៀនបិទផ្សាយទិន្នន័យថវិកានិងការចំណាយជាសាថារណៈ |

| | | | | | |
|---|---|---|---|---|---|
| **សម្គាល់៖** សរសេរពិន្ទុវាយតម្លៃនៅទីនេះ...................... ហើយអធិប្បាយពីស្ថានភាពនៃកិច្ចការតាមការវាយតម្លៃ និងកំណត់ពិន្ទុក្រុមគោលដៅ និងស្ថានភាពនៃកិច្ចការជាផែនការសម្រាប់ឆ្នាំសិក្សាបន្ទាប់...................................................................................................................................................................................................................... | | | | | |
| ពិន្ទុស្តង់ដាសរុប | ៨ | ១៦ | ២៤ | ៣២ | ៤០ |
| **សរុបពិន្ទុជាក់ស្តែងឆ្នាំនេះ៖ ??** | | | | | |
| **សម្គាល់៖ មន្ទីរអប់រំដែលមានដំណើរការមានពិន្ទុសរុប ៨ទៅ ២២។ ពិន្ទុសរុបដែលមានដំណើរការគឺ ២៣ ទៅ ៣២ ។ ពិន្ទុសរុបដែលមានដំណើរការល្អប្រសើរគឺ ៣៣ ទៅ ៤០។** | | | | | |

**ឧបសម្ព័ន្ធ: ឧបករណ៍វាយតម្លៃរបស់មន្ទីរអប់រំប្រើប្រាស់វាយតម្លៃការបំពេញការងាររបស់ការិយាល័យអប់រំយុវជន និងកីឡា**

**រាជធានី ខេត្ត ……………………………………………ឆ្នាំ………………..**

| កិច្ចការចម្បងៗ | **ពិន្ទុរីកចម្រើន** | | | | |
|---|---|---|---|---|---|
| | ទាបខ្លាំង៖ ១ | ទាប៖ ២ | មធ្យម៖ ៣ | ល្អ៖ ៤ | ល្អប្រសើរ៖ ៥ |
| **១. ផលសម្រេចការសិក្សារបស់សិស្ស** | មិនមានទិន្នន័យពីផលសម្រេចការសិក្សារបស់សិស្ស | មានទិន្នន័យពីផលសម្រេចការសិក្សារបស់សិស្ស តែមិនប្រើ សម្រាប់រៀបចំ ផែនការសកម្មភាព | មានទិន្នន័យពីផលសម្រេចការសិក្សារបស់សិស្ស បានប្រើសម្រាប់រៀបចំផែនការសកម្មភាព និងផលសិក្សាសម្រេច បានក្រោម៥០%ធៀបនឹងក្រុមគោលដៅ | មានទិន្នន័យពីផលសម្រេចការសិក្សារបស់សិស្សបានប្រើសម្រាប់រៀបចំផែនការសកម្មភាព បិទផ្សាយនៅការិយាល័យ និងសាលារៀន និងផលសិក្សា សម្រេចបានពី៥០%ទៅ៧០%ធៀបនឹងក្រុមគោលដៅ | មានទិន្នន័យពីផលសម្រេចការសិក្សារបស់សិស្ស បានប្រើសម្រាប់រៀបចំផែនការសកម្មភាព បិទផ្សាយនៅការិយាល័យ និងសាលារៀន និងផលសិក្សាសម្រេចបានលើ៧០%ធៀបនឹងក្រុមគោលដៅ |
| **សម្គាល់៖** សរសេរពិន្ទុវាយតម្លៃនៅទីនេះ.................. ហើយអធិប្បាយពីស្ថានភាពនៃកិច្ចការតាមការវាយតម្លៃ និងកំណត់ពិន្ទុក្រុមគោលដៅ និងស្ថានភាពនៃកិច្ចការជាផែនការសម្រាប់ឆ្នាំសិក្សាបន្ទាប់........................................................................................................................................................................................... | | | | | |
| **២. ការធ្វើផែនការប្រតិបត្តិឆ្នាំ និងការ អនុវត្ត** | មិនមានផែនការប្រតិបត្តិប្រចាំឆ្នាំ ឬមួយមានតែមិនធ្វើតាមប្រព័ន្ធពិនិត្យតាម-ដាននិងវាយតម្លៃផ្អែកលើលទ្ធផល | ផែនការប្រតិបត្តិប្រចាំឆ្នាំធ្វើតាមប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផលសកម្មភាពគ្រោង០%ទៅ២៥% បានអនុវត្ត | ផែនការប្រតិបត្តិប្រចាំឆ្នាំធ្វើតាមប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផលសកម្មភាពគ្រោង២៦% ទៅ៥០%បានអនុវត្ត | ផែនការប្រតិបត្តិប្រចាំឆ្នាំធ្វើតាមប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផលសកម្មភាពគ្រោង៥១% ទៅ៧៥%បានអនុវត្ត | ផែនការប្រតិបត្តិប្រចាំឆ្នាំធ្វើតាមប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផលសកម្មភាពគ្រោងលើ៧៥% បានអនុវត្ត |
| **សម្គាល់៖** សរសេរពិន្ទុវាយតម្លៃនៅទីនេះ.................. ហើយអធិប្បាយពីស្ថានភាពនៃកិច្ចការតាមការវាយតម្លៃ និងកំណត់ពិន្ទុក្រុមគោលដៅ និងស្ថានភាពនៃកិច្ចការជាផែនការសម្រាប់ឆ្នាំសិក្សាបន្ទាប់........................................................................................................................................................................................... | | | | | |

| | | | | | |
|---|---|---|---|---|---|
| **៣. ការគ្រប់គ្រងបុគ្គលិក (ការពង្រាយគ្រូ)** | មិនមានទិន្នន័យពីគ្រូខ្វះ ឬលើស ឬមួយមានតែមិនមាន បច្ចុប្បន្នភាព | មានទិន្នន័យបច្ចុប្បន្នភាពពីគ្រូខ្វះឬលើស តែមិនមានផែនការសកម្មភាពដោះស្រាយ | មានទិន្នន័យបច្ចុប្បន្នភាពពីគ្រូខ្វះ ឬ លើស មានផែនការសកម្មភាពនិងចាប់ផ្តើម ដោះស្រាយ | មានទិន្នន័យបច្ចុប្បន្នភាពពីគ្រូខ្វះ ឬ លើស មានផែនការសកម្មភាពនិង ហើយគ្រូខ្វះ ឬលើសថយចុះ | មានទិន្នន័យបច្ចុប្បន្នភាពពីគ្រូខ្វះ ឬលើស មានផែនការ សកម្មភាពនិងមិនមានបញ្ហាពី គ្រូខ្វះឬលើយ |
| **សម្គាល់៖** សរសេរពិន្ទុវាយតម្លៃនៅទីនេះ.................. ហើយអធិប្បាយពីស្ថានភាពនៃកិច្ចការតាមការវាយតម្លៃ និងកំណត់ពិន្ទុក្រុមគោលដៅ និងស្ថានភាពនៃកិច្ចការជាផែនការសម្រាប់ឆ្នាំសិក្សាបន្ទាប់.................................................................................................................................................................................................... | | | | | |
| **៤. ការគ្រប់គ្រងសៀវភៅសិក្សាគោល** | មិនមានទិន្នន័យពីសៀវភៅសិក្សាគោលត្រូវការ ឬមួយមានតែមិនមានបច្ចុប្បន្នភាព | មានទិន្នន័យបច្ចុប្បន្នភាពពីសៀវភៅសិក្សាគោលត្រូវការ តែមិនមានផែនការសកម្មភាពដោះស្រាយ | មានទិន្នន័យបច្ចុប្បន្នភាពពីសៀវភៅសិក្សាគោលត្រូវការ មានផែនការសកម្មភាពនិងចាប់ផ្តើមដោះស្រាយ | មានទិន្នន័យបច្ចុប្បន្នភាពពីសៀវភៅសិក្សាគោលត្រូវការ មានផែនការសកម្មភាពនិង សៀវភៅលើសឬខ្វះ ថយចុះ | មានទិន្នន័យបច្ចុប្បន្នភាពពីសៀវភៅសិក្សាគោលត្រូវការ មានផែនការសកម្មភាពនិងមិនមានបញ្ហាសៀវភៅលើស |
| **សម្គាល់៖** សរសេរពិន្ទុវាយតម្លៃនៅទីនេះ.................. ហើយអធិប្បាយពីស្ថានភាពនៃកិច្ចការតាមការវាយតម្លៃ និងកំណត់ពិន្ទុក្រុមគោលដៅ និងស្ថានភាពនៃកិច្ចការជាផែនការសម្រាប់ឆ្នាំសិក្សាបន្ទាប់.................................................................................................................................................................................................... | | | | | |
| **៥. ការគ្រប់គ្រងនិង ហេដ្ឋារចនាសម្ព័ន្ធសាលារៀន** | មិនមានទិន្នន័យពីតម្រូវការអគារសិក្សា ឬមួយមានតែមិនមានបច្ចុប្បន្នភាព | មានទិន្នន័យមានបច្ចុប្បន្នភាពបានប្រើទិន្នន័យស្នើសុំអគារសិក្សាដល់ក្រសួង | មានទិន្នន័យមានបច្ចុប្បន្នភាពបានប្រើទិន្នន័យស្នើសុំអគារសិក្សាដល់ក្រសួង និងបានប្រើទិន្នន័យកសាងផែនការសាងសង់របស់មន្ទីរ | មានទិន្នន័យមានបច្ចុប្បន្នភាពបានប្រើទិន្នន័យស្នើសុំអគារសិក្សាដល់ក្រសួង និងបានប្រើទិន្នន័យកសាងផែនការសាងសង់របស់មន្ទីរ និងបានទាក់-ទងសហគមន៍និងដៃគូសម្រាប់រកមូលនិធិ | មានទិន្នន័យមានបច្ចុប្បន្នភាព បានប្រើទិន្នន័យស្នើសុំអគារសិក្សាដល់ក្រសួង និងបានប្រើទិន្នន័យ កសាងផែនការសាងសង់របស់ក្រសួង និងបានទាក់ទងសហគមន៍និងដៃគូសម្រាប់រកមូលនិធិ ហើយកង្វះអគារសិក្សាថយចុះ |
| **សម្គាល់៖** សរសេរពិន្ទុវាយតម្លៃនៅទីនេះ.................. ហើយអធិប្បាយពីស្ថានភាពនៃកិច្ចការតាមការវាយតម្លៃ និងកំណត់ពិន្ទុក្រុមគោលដៅ និងស្ថានភាពនៃកិច្ចការជាផែនការសម្រាប់ឆ្នាំសិក្សាបន្ទាប់.................................................................................................................................................................................................... | | | | | |

| | | | | | |
|---|---|---|---|---|---|
| **៦. ការគ្រប់គ្រងហិរញ្ញវត្ថុ** | ថវិកាគ្រោងមិនបានរៀបចំពេញលេញទៅតាមសៀវភៅណែនាំពីការគ្រប់គ្រងតាមសាលារៀនរបស់ក្រសួង | ថវិកាគ្រោងបានរៀបចំពេញលេញទៅតាមសៀវភៅណែនាំពីការគ្រប់គ្រងតាមសាលារៀនរបស់ក្រសួង និងផ្អែកលើផែនការប្រតិបត្តិឆ្នាំរបស់ការិយាល័យ | ថវិកាគ្រោងបានរៀបចំពេញលេញទៅតាមសៀវភៅណែនាំពីការគ្រប់គ្រងតាមសាលារៀនរបស់ក្រសួង និងផ្អែកលើផែនការប្រតិបត្តិឆ្នាំរបស់ការិយាល័យ ហើយប្រាក់ កែលម្អសាលារៀននិងអាហារូបករណ៍បើកផ្តល់ទាន់ពេលនៅត្រីមាសទី១និងទី២ | ថវិកាគ្រោងបានរៀបចំពេញលេញទៅតាមសៀវភៅណែនាំពីការគ្រប់គ្រងតាមសាលារៀនរបស់ក្រសួង និងផ្អែកលើផែនការប្រតិបត្តិឆ្នាំរបស់ការិយាល័យ ហើយប្រាក់ កែលម្អសាលារៀននិងអាហារូ-បករណ៍បើកផ្តល់ទាន់ពេលនៅត្រីមាសទី១ ទី២ និងទី៣ | ថវិកាគ្រោងបានរៀបចំពេញលេញទៅតាមសៀវភៅណែនាំពីការគ្រប់គ្រងតាមសាលារៀនរបស់ក្រសួង និងផ្អែកលើ ផែនការប្រតិបត្តិឆ្នាំរបស់ការិយា-ល័យ ហើយប្រាក់កែលម្អសាលា រៀន និងអាហារូបករណ៍បើកផ្តល់ទាន់ពេលនៅគ្រប់ត្រីមាស |
| **សម្គាល់៖** សរសេរពិន្ទុវាយតម្លៃនៅទីនេះ.................. ហើយអធិប្បាយពីស្ថានភាពនៃកិច្ចការតាមការវាយតម្លៃ និងកំណត់ពិន្ទុក្រុមគោលដៅ និងស្ថានភាពនៃកិច្ចការជាផែនការសម្រាប់ឆ្នាំសិក្សាបន្ទាប់.......................................................................................................................................................................................................... | | | | | |
| **៧. ការពិនិត្យតាមដានការអនុវត្តរបស់ក្រុងស្រុក ខណ្ឌពិសេសលើផលសម្រេចការសិក្សារបស់សិស្ស** | មិនមានទិន្នន័យពីផលសម្រេចការសិក្សារបស់សិស្ស | មានទិន្នន័យពីផលសម្រេចការសិក្សារបស់សិស្ស | មិនមានទិន្នន័យពីផលសម្រេចការសិក្សារបស់សិស្ស និងបានប្រើសម្រាប់កសាងផែនការសកម្មភាពជួយដល់សាលារៀន | មិនមានទិន្នន័យពីផលសម្រេចការសិក្សារបស់សិស្ស និងបានប្រើសម្រាប់កសាងផែនការសកម្មភាពជួយដល់សាលារៀន និងបោះផ្សាយព័ត៌មានដល់សាលារៀន | មិនមានទិន្នន័យពីផលសម្រេចការសិក្សារបស់សិស្ស និងបានប្រើសម្រាប់កសាងផែនការសកម្មភាពជួយដល់សាលារៀន និងបោះផ្សាយព័ត៌មានដល់សាលារៀន និងបានប្រើសម្រាប់កសាងផែនការឆ្នាំបន្ទាប់ |
| **សម្គាល់៖** សរសេរពិន្ទុវាយតម្លៃនៅទីនេះ.................. ហើយអធិប្បាយពីស្ថានភាពនៃកិច្ចការតាមការវាយតម្លៃ និងកំណត់ពិន្ទុក្រុមគោលដៅ និងស្ថានភាពនៃកិច្ចការជាផែនការសម្រាប់ឆ្នាំសិក្សាបន្ទាប់.......................................................................................................................................................................................................... | | | | | |

| | | | | | |
|---|---|---|---|---|---|
| **៨. ការប្រើប្រាស់ថវិកាសាលារៀនតាមសៀវ-ភៅណែនាំពីការគ្រប់-គ្រងតាមសាលារៀន** | សាលារៀនមានផែនការកែលម្អសាលារៀនប្រចាំឆ្នាំ តែមិនធ្វើតាមសៀវភៅណែនាំពីការគ្រប់គ្រងតាមសាលារៀន | ៣០% ទៅ ៥០% សាលារៀនមានផែនការកែលម្អសាលា-រៀនប្រចាំឆ្នាំ និងធ្វើតាមសៀវ-ភៅណែនាំពីការគ្រប់គ្រងតាមសាលារៀន | ៥១%ទៅ ៧០% សាលារៀនមានផែនការកែលម្អសាលា-រៀនប្រចាំឆ្នាំ និងធ្វើតាមសៀវភៅណែនាំពីការគ្រប់គ្រងតាមសាលារៀន ហើយ សហគមន៍ចូលរួមក្នុងការធ្វើ ផែនការនិងគ្រោងថវិកា | ៥១%ទៅ ៧០% សាលារៀនមានផែនការកែលម្អសាលា-រៀនប្រចាំឆ្នាំ និងធ្វើតាមសៀវភៅណែនាំពីការគ្រប់គ្រងតាមសាលារៀន ហើយ សហគមន៍ចូលរួមក្នុងការធ្វើផែនការនិងគ្រោងថវិកាតិច ជាង៥០%នៃថវិកាចំណាយ លើការបង្រៀននិងរៀននិង ៧០%នៃសាលារៀនបិទផ្សាយទិន្នន័យថវិកា និងការ ចំណាយជាសាធារណៈ | ៥១%ទៅ៧០% សាលារៀនមានផែនការកែលម្អសាលារៀនប្រចាំឆ្នាំ និងធ្វើតាមសៀវភៅណែនាំ ពីការគ្រប់គ្រងតាមសាលារៀន ហើយសហគមន៍ ចូលរួមក្នុងការធ្វើផែនការនិង គ្រោងថវិកា តិចជាង៥០%នៃថវិកាចំណាយលើការបង្រៀននិងរៀន និងសាលាទាំងអស់រៀន បិទផ្សាយទិន្នន័យថវិកានិង ការចំណាយជាសាធារណៈ |
| **សម្គាល់៖** សរសេរពិន្ទុវាយតម្លៃនៅទីនេះ.................. ហើយអធិប្បាយពីស្ថានភាពនៃកិច្ចការតាមការវាយតម្លៃ និងកំណត់ពិន្ទុក្រុមគោលដៅ និងស្ថានភាពនៃកិច្ចការជាផែនការសម្រាប់ឆ្នាំសិក្សាបន្ទាប់...................................................................................................................................................................................................... | | | | | |
| ពិន្ទុស្តង់ដាសរុប | ៨ | ១៦ | ២៤ | ៣២ | ៤០ |
| **សរុបពិន្ទុជាក់ស្តែងឆ្នាំនេះ៖ ??** | | | | | |
| **សម្គាល់៖ មន្ទីរអប់រំដែលមានដំណើរការមានពិន្ទុសរុប ៨ទៅ ២២។ ពិន្ទុសរុបដែលមានដំណើរការគឺ ២៣ ទៅ ៣២ ។ ពិន្ទុសរុបដែលមានដំណើរការល្អប្រសើរគឺ ៣៣ ទៅ ៤០។** | | | | | |

## ឧបសម្ព័ន្ធ៖ ទម្រង់ផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់មន្ទីរអប់រំ

| សកម្មភាពចម្បង | ពិន្ទុក្រុមគោលដៅ | សកម្មភាព គ្រោង | ពេលអនុវត្ត | ថវិកា |
|---|---|---|---|---|
| ១. ការធ្វើផែនការយុទ្ធសាស្ត្រថវិកា ផែនការប្រតិបត្តិឆ្នាំ និងការអនុវត្តផែនការ | | | | |
| ២. ការគ្រប់គ្រងមន្ត្រី (ការពង្រាយគ្រូ) | | | | |
| ៣. ការគ្រប់គ្រងសៀវភៅសិក្សាគោល | | | | |
| ៤. ការគ្រប់គ្រង និងហេដ្ឋារចនាសម្ព័ន្ធសាលារៀន | | | | |
| ៥. ការពិនិត្យតាមដាននិងវាយតម្លៃ | | | | |
| ៦. ការគ្រប់គ្រងហិរញ្ញវត្ថុ | | | | |
| ៧. ការពិនិត្យតាមដានការអនុវត្តរបស់ក្រុងស្រុក ខណ្ឌ ពិសេសលើផលសម្រេច ការសិក្សារបស់សិស្ស | | | | |
| ៨. ការប្រើប្រាស់ថវិកាសាលារៀនតាមសៀវភៅណែនាំពីការគ្រប់គ្រងតាមសាលារៀន | | | | |
| **ពិន្ទុស្តង់ដាក្រុមគោលដៅសរុប** | | | | |

ថ្ងៃទី......................................................... ប្រធានការិយាល័យផែនការ...........................................

ថ្ងៃទី......................................................... ប្រធានមន្ទីរអប់រំ.............................................................

## ឧបសម្ព័ន្ធៈ ទម្រង់ផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់ការិយាល័យអប់រំ

| សកម្មភាពចម្បង | ពិន្ទុក្រុមគោលដៅ | សកម្មភាព គ្រោង | ពេលអនុវត្ត | ថវិកា |
|---|---|---|---|---|
| . ផលសម្រេចការសិក្សារបស់សិស្ស | | | | |
| . ការធ្វើផែនការប្រតិបត្តិឆ្នាំ និងការអនុវត្ត | | | | |
| . ការគ្រប់គ្រងបុគ្គលិក(ការពង្រាយគ្រូ) | | | | |
| . ការគ្រប់គ្រងសៀវភៅសិក្សាគោល | | | | |
| . ការគ្រប់គ្រងនិងហេដ្ឋារចនាសម្ព័ន្ធសាលារៀន | | | | |
| . ការគ្រប់គ្រងហិរញ្ញវត្ថុ | | | | |
| . ការពិនិត្យតាមដានការអនុវត្តរបស់ក្រុង ស្រុក ខណ្ឌ ពិសេសលើផលសម្រេចការសិក្សា របស់សិស្ស | | | | |
| . ការប្រើប្រាស់ថវិកាសាលារៀនតាមសៀវភៅ ណែនាំ ពីការគ្រប់គ្រងមានមូលដ្ឋាននៅ សាលារៀន | | | | |
| ពិន្ទុក្រុមគោលដៅស្តង់ដាសរុប | | | | |

ថ្ងៃទី........................................................ ប្រធានការិយាល័យផែនការ.......................................

ថ្ងៃទី........................................................ ប្រធានមន្ទីរអប់រំ.........................................................

## ២.៣ ការគ្រប់គ្រងបុគ្គលិក

### ២.៣.១ វត្ថុបំណង និងដំណើរការអនុវត្ត

ដូចបានរៀបរាប់ខាងលើអំពីសកម្មភាពចម្បងៗដែលត្រូវធ្វើការសម្រេចចិត្តគឺ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិទទួលខុសត្រូវលើការជ្រើសរើស និងការបញ្ឈប់មន្ត្រី។ នាយកសាលា និងគណៈកម្មការគ្រប់គ្រងសាលារៀនទទួលខុសត្រូវលើការគ្រប់គ្រងការអនុវត្តរបស់មន្ត្រី លើកសំណើសុំគ្រូឬមន្ត្រីបន្ថែម ដើម្បីបំពេញការខ្វះខាតគ្រូបង្រៀនឬមន្ត្រី និងស្នើសុំថ្នាក់ក្រោមជាតិអនុវត្តវិធានការរដ្ឋបាលចំពោះ មន្ត្រីដែលមិនអនុវត្តការងារ។

វត្ថុបំណងរបស់ប្រព័ន្ធគឺ ១) គាំទ្រដល់ការអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់បុគ្គលិកអប់រំ ២) ផ្តល់ការគាំទ្រទាន់ពេលវេលាដល់គ្រូបង្រៀនដើម្បីកែលម្អចំណេះដឹងមុខវិជ្ជាឯកទេស និងគរុកោសល្យបង្រៀន និង ៣) ផ្តល់រង្វាន់លើកទឹកចិត្តដល់គ្រូមានស្នាដៃក្នុងឆ្នាំសិក្សា។

ដំណើរការនៃការអនុវត្តការគ្រប់គ្រង ការអនុវត្តការងារនឹងត្រូវបញ្ជ្រាបចូលគ្នាជាមួយនឹងដំណើរការសាលារៀន។ ដំណើរការសកម្មភាពអនុវត្តប្រព័ន្ធមានៈ

| |
|---|
| 1. មន្ត្រីម្នាក់ៗព្រាងកិច្ចសន្យាលទ្ធផលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍវិជ្ជាជីវៈ |
| 2. មន្ត្រីម្នាក់ៗ និងនាយកសាលាពិភាក្សា និងឯកភាពលើកិច្ចសន្យាលទ្ធផលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍវិជ្ជាជីវៈ |
| 3. មន្ត្រីម្នាក់ៗ និងនាយកសាលាពិភាក្សាពីការពិនិត្យឡើងវិញពាក់កណ្តាលឆ្នាំ |
| 4. មន្ត្រីម្នាក់ៗ និងនាយកសាលាពិភាក្សានិងឯកភាពថាតើមន្ត្រីណាជាដៃគូពិនិត្យឡើងវិញ |
| 5. មន្ត្រីម្នាក់ៗ ព្រាងនូវលទ្ធផលសម្រេចបានប្រចាំឆ្នាំធៀបជាមួយកិច្ចសន្យាលទ្ធផលប្រចាំឆ្នាំនិងផែនការ អភិវឌ្ឍវិជ្ជាជីវៈ និងបញ្ជូនវាទៅដៃគូពិនិត្យឡើងវិញ |
| 6. ដៃគូពិនិត្យឡើងវិញពិនិត្យ និងផ្តល់នូវការយល់ឃើញជាលាយលក្ខអក្សរទៅនាយកសាលារៀន តែមិនផ្តល់ឱ្យមន្ត្រីទេ |
| 7. នាយកសាលាពិភាក្សាជាមួយមន្ត្រីកំណត់ថ្ងៃប្រជុំ |
| 8. នាយកសាលាពិភាក្សាជាមួយមន្ត្រីដើម្បីវាយតម្លៃការអនុវត្តរបស់មន្ត្រី ដោយផ្អែកលើការយល់ឃើញដែលបានពីដៃគូពិនិត្យឡើងវិញ និងព្រាងលទ្ធផលវាយតម្លៃរបស់មន្ត្រី |
| 9. នាយកសាលារៀនផ្តល់ពិន្ទុវាយតម្លៃដល់មន្ត្រីម្នាក់ៗ |
| 10. នាយកសាលាដាក់ស្នើលទ្ធផលពីការវាយតម្លៃដល់គណៈកម្មការគ្រប់គ្រងសាលារៀនដើម្បីអនុម័ត |
| 11. ការផ្តល់រង្វាន់ ឬការស្នើវិធានការរដ្ឋបាលនឹងត្រូវបានអនុវត្ត |

ដំណាក់ការដំបូងនៃប្រព័ន្ធគ្រប់គ្រងបុគ្គលិកដែលត្រូវអនុវត្តមាន គោលការណ៍ «ការប្តេជ្ញាចិត្តរបស់បុគ្គលិក» ចូលរួមអនុវត្តប្រព័ន្ធ និងគោលការណ៍ «រក្សាការសម្ងាត់» ត្រូវរក្សាឱ្យបាន។

## ២.៣.២ កិច្ចសន្យាលទ្ធផលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍសមត្ថភាព

### ១ គ្រូបង្រៀន និងមន្ត្រី៖ ការរៀបចំកិច្ចសន្យាលទ្ធផលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍសមត្ថភាព

នៅឆ្នាំ២០១៧ នាយក ឬ នាយិកាសាលារៀនរៀបចំការប្រជុំជាមួយបុគ្គលិកអប់រំទាំងអស់ ជូនព័ត៌មានពីប្រព័ន្ធគ្រប់គ្រង ការអនុវត្តការងារ និងគោលការណ៍ចំនួន២ដែលត្រូវអនុវត្ត ដោយមានការជួយគាំទ្រពីក្រុមការងារគ្រប់គ្រងតាមសាលារៀនថ្នាក់ជាតិ និងគ្រូបង្គោលតាមមុខវិជ្ជា។

ខ្លឹមសារនៃការប្រជុំមាន៖ ទិសដៅរបស់ប្រព័ន្ធ ដំណើរការអនុវត្តប្រព័ន្ធ និង គោលការណ៍២ ក្នុងការអនុវត្ត។ រួចហើយនាយកសាលាជ្រើសរើសបុគ្គលិកដែលស្ម័គ្រចិត្តចូលរួមអនុវត្តប្រព័ន្ធ និងកត់ឈ្មោះមន្ត្រីទុកក្នុងបញ្ជី។ ដំណើរការអនុវត្តចាប់ផ្តើមដូចខាងក្រោម៖

- មន្ត្រីម្នាក់ៗព្រាងកិច្ចសន្យាលទ្ធផលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍវិជ្ជាជីវៈដោយមានការណែនាំ ពីក្រសួងអប់រំ យុវជន និងកីឡា ឬនាយកសាលារៀន។
- មន្ត្រីម្នាក់ៗ និងនាយកសាលាពិភាក្សា និងឯកភាពលើកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍវិជ្ជាជីវៈ។ មន្ត្រីកែតម្រូវកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍវិជ្ជាជីវៈតាមការឯកភាព ពីការប្រជុំ។
- នាយកសាលាអនុម័តលើកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍវិជ្ជាជីវៈ។

*ទម្រង់កិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍវិជ្ជាជីវៈសម្រាប់គ្រូបង្រៀន*

ឈ្មោះគ្រូបង្រៀន.......................................... ☐ ប្រុស ☐ ស្រី មុខវិជ្ជា..................................

ឈ្មោះនាយក/នាយិកាសាលារៀន...................................................... ☐ ប្រុស ☐ ស្រី

ថ្ងៃខែឆ្នាំអនុម័ត.....................................................................................

សំណុំទី១

វត្ថុបំណង (ស្តង់ដាទី២៖ ការបង្រៀន និងរៀន)

លទ្ធផល៖.........................................................................................................................................

សកម្មភាព៖......................................................................................................................................

សំណុំទី២

វត្ថុបំណង (ស្តង់ដាទី៣៖ សហគមន៍ និងមាតាបិតាជួយដល់ការរៀនសូត្ររបស់សិស្ស)

លទ្ធផល៖.........................................................................................................................................

សកម្មភាព៖......................................................................................................................................

សំណុំទី៣

វត្ថុបំណង (ស្តង់ដាទី៤៖ សិស្ស និងសេវាជួយសិស្ស)

លទ្ធផល៖.........................................................................................................................................

សកម្មភាព៖......................................................................................................................................

សំណុំទី៤

វត្ថុបំណង (ផែនការអភិវឌ្ឍវិជ្ជាជីវៈមាន ចំណេះដឹង សីលធម៌ ការរៀនសូត្រ និងការអនុវត្ត)

លទ្ធផល៖..............................................................................................................................................

សកម្មភាព៖...........................................................................................................................................

## ២ នាយក ឬ នាយិកាសាលារៀន៖ កិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍវិជ្ជាជីវៈ

នៅឆ្នាំ២០១៨ ក្រសួង អយក. មន្ទីរ អយក. និងការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ រៀបចំការប្រជុំជាមួយនាយក ឬ នាយិកាសាលារៀន និងគណៈកម្មការគ្រប់គ្រងសាលារៀនដើម្បីពិភាក្សាពីប្រព័ន្ធគ្រប់គ្រងការអនុវត្តការងាររបស់នាយកសាលារៀន។ មន្ទីរ អយក. និងការិយាល័យ អយក. ចូលរួមដំណើរការនៅឆ្នាំដំបូងដើម្បីរៀនសូត្រ។

- នាយកសាលារៀនព្រាងកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍវិជ្ជាជីវៈដោយមានការគាំទ្រពីក្រសួង។
- នាយកសាលារៀនពិភាក្សា និងឯកភាពជាមួយគណៈកម្មការគ្រប់គ្រងសាលារៀនលើកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍវិជ្ជាជីវៈ។ នាយកសាលារៀនកែតម្រូវកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍវិជ្ជាជីវៈតាមការឯកភាពពីការប្រជុំ។
- គណៈកម្មការគ្រប់គ្រងសាលារៀនអនុម័តលើកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍវិជ្ជាជីវៈរបស់នាយកសាលារៀន។

***ទម្រង់កិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍវិជ្ជាជីវៈសម្រាប់នាយកសាលារៀន***

ឈ្មោះគ្រូបង្រៀន................................................ ☐ ប្រុស ☐ ស្រី មុខវិជ្ជា.......................................

ឈ្មោះប្រធានគណៈកម្មការគ្រប់គ្រងសាលារៀន.....................................................................................

ថ្ងៃ ខែ ឆ្នាំអនុម័ត.....................................................................................

---

សំណុំទី១

វត្ថុបំណង (ស្តង់ដាទី៥៖ ការដឹកនាំ និងការគ្រប់គ្រងសាលារៀន)

លទ្ធផល៖.....................................................................................................................................

សកម្មភាព៖..................................................................................................................................

---

សំណុំទី២

វត្ថុបំណង (ស្តង់ដាទី៩៖ ហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ)

លទ្ធផល៖.....................................................................................................................................

សកម្មភាព៖..................................................................................................................................

---

សំណុំទី៣

វត្ថុបំណង (ការគ្រប់គ្រងការអនុវត្តរបស់មន្ត្រី និងស្តង់ដាទី៦ ៧ និង៨ ពីធាតុចូល (គ្រូ សៀវភៅសិក្សាគោល និងហេដ្ឋារចនាសម្ព័ន្ធ) សម្រាប់សាលារៀន)

លទ្ធផល៖.....................................................................................................................................

សកម្មភាព៖..................................................................................................................................

---

សំណុំទី៤

វត្ថុបំណង (ផែនការអភិវឌ្ឍវិជ្ជាជីវៈមាន ចំណេះដឹង សីលធម៌ ការរៀនសូត្រ និងបំណិនការងារ)

លទ្ធផល៖.....................................................................................................................................

សកម្មភាព៖..................................................................................................................................

## ២. ៣. ៣. ការពិនិត្យឡើងវិញពាក់កណ្ដាលឆ្នាំ

សម្រាប់នាយកសាលារៀនគឺ គណៈកម្មការគ្រប់គ្រងសាលារៀនកំណត់ថ្ងៃជួបពិភាក្សាជាមួយនាយកសាលា សម្រាប់ការពិនិត្យឡើងវិញពាក់កណ្ដាលឆ្នាំ។ សម្រាប់គ្រូបង្រៀន ឬ មន្ត្រី នាយកសាលារៀនកំណត់ថ្ងៃជួប ពិភាក្សាជាមួយគ្រូបង្រៀន ឬមន្ត្រី សម្រាប់ការពិនិត្យឡើងវិញពាក់កណ្ដាលឆ្នាំ។

ការប្រជុំគឺផ្ដោតលើការរីកចម្រើនការអនុវត្តលទ្ធផលមាននៅក្នុងកិច្ចព្រមព្រៀងលទ្ធផល និងផែនការអភិវឌ្ឍវិជ្ជាជីវៈប្រចាំឆ្នាំ បញ្ហាដែលត្រូវការយកចិត្តទុកដាក់ និងសកម្មភាពដែលបានឯកភាពនឹងត្រូវអនុវត្តដើម្បីធានាថាលទ្ធផល និងសកម្មភាពដែលមិនទាន់សម្រេចនឹងត្រូវអនុវត្តឱ្យបាននៅមុនដំណាច់ឆ្នាំ។

គណៈកម្មការគ្រប់គ្រងសាលារៀន ឬ នាយក និងគ្រូបង្រៀន ឬ មន្ត្រីចុះហត្ថលេខាលើកំណត់ហេតុប្រជុំ។

***ទម្រង់កំណត់ហេតុប្រជុំ៖***

| |
|---|
| ឈ្មោះគ្រូបង្រៀន/មន្ត្រី៖........................................... ឈ្មោះនាយក/គគស.........................................<br><br>(ហត្ថលេខា)................................................... (ហត្ថលេខា) ........................................................<br><br>ថ្ងៃខែឆ្នាំប្រជុំ៖........................................................ |
| ការរីកចម្រើនបញ្ជាក់ថាលទ្ធផល និងសកម្មភាពដែលបានសម្រេច៖.............................................<br><br>លទ្ធផល និងសកម្មភាពដែលមិនទាន់បានសម្រេច៖...................................................................... |
| បញ្ហាដែលត្រូវការនូវការយកចិត្តទុកដាក់ដោយ៖.......................................................................<br><br>គ្រូបង្រៀនឬមន្ត្រី៖.........................................................................................................<br><br>នាយកសាលាឬគគស៖...................................................................................................... |
| សកម្មភាពដែលត្រូវធ្វើដោយ៖...........................................................................................<br><br>គ្រូបង្រៀនឬមន្ត្រី៖.........................................................................................................<br><br>នាយកសាលាឬគគស៖...................................................................................................... |

## ២. ៣. ៤. ការវាយតម្លៃដំណើរការអនុវត្តនៅដំណាច់ឆ្នាំ

ក្រុមការងារថ្នាក់ជាតិនឹងជួយដល់នាយកសាលារៀន និង គគស ក្នុងការអនុវត្តការវាយតម្លៃ នៅដំណាច់ឆ្នាំនីមួយៗ។

នាយកសាលារៀនរៀបចំការប្រជុំ នៅក្នុងពេលវិស្សមកាលផ្សព្វផ្សាយពី ការអនុវត្តការវាយតម្លៃនៅដំណាច់ឆ្នាំដល់មន្ត្រី។ ក្រសួងនឹងជួយមន្ត្រីសាលារៀន ក្នុងការរៀបចំកិច្ចព្រមព្រៀងលទ្ធផល និងផែនការអភិវឌ្ឍសមត្ថភាពសម្រាប់ឆ្នាំបន្ទាប់។ លទ្ធផលមិនគប្បីដាក់ហួសសមត្ថភាព ឬមួយងាយស្រួលពេកសម្រាប់អនុវត្ត និងត្រូវសាងសង់បន្តពីឆ្នាំមុន។

ការជួយនេះត្រូវបន្តអនុវត្តដោយមន្ទីរ អយក. ឬការិយាល័យ អយក. ក្រុង ស្រុក ខណ្ឌ នៅឆ្នាំបន្ទាប់។ ដំណើរការ និងកាលវិភាគនៃការវាយតម្លៃប្រចាំឆ្នាំមានដូចខាងក្រោម៖

| សកម្មភាព | ពេលវេលា |
|---|---|
| 1. មន្ត្រីម្នាក់ៗ និងនាយកសាលាពិភាក្សា និងឯកភាពថាតើមន្ត្រីណាជាដៃគូពិនិត្យឡើងវិញ | ១ ដល់ ៣០ កញ្ញា |
| 2. មន្ត្រីម្នាក់ៗ ព្រាងនូវលទ្ធផលសម្រេចបានប្រចាំឆ្នាំធៀបជាមួយកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំនិងផែនការអភិវឌ្ឍវិជ្ជាជីវៈ និងបញ្ជូនវាទៅដៃគូពិនិត្យឡើងវិញ | |
| 3. ដៃគូពិនិត្យឡើងវិញពិនិត្យ និងផ្តល់នូវការយល់ឃើញជាលាយលក្ខអក្សរទៅ នាយកសាលារៀន តែមិនផ្តល់ឱ្យមន្ត្រីទេ | |
| 4. នាយកសាលាពិភាក្សាជាមួយមន្ត្រីកំណត់ថ្ងៃប្រជុំ | ១ ដល់ ៣១តុលា |
| 5. នាយកសាលាពិភាក្សាជាមួយមន្ត្រីដើម្បីវាយតម្លៃការអនុវត្តរបស់មន្ត្រីដោយ ផ្អែកលើការយល់ឃើញបានពីដៃគូពិនិត្យឡើងវិញ និងពង្រាងលទ្ធផលវាយតម្លៃរបស់មន្ត្រី | |
| 6. នាយកសាលារៀនផ្តល់ពិន្ទុវាយតម្លៃដល់មន្ត្រីម្នាក់ៗ | |
| 7. នាយកសាលាដាក់ស្នើលទ្ធផលពីការវាយតម្លៃដល់គណៈកម្មការគ្រប់គ្រងសាលារៀនដើម្បីអនុម័ត | |
| 8. ការផ្តល់រង្វាន់ ឬការស្នើវិធានការណ៍រដ្ឋបាលនឹងត្រូវបានអនុវត្ត | |

ដែគូផ្តល់ចម្លើយតបសម្រាប់គ្រូបង្រៀនអាចជាមន្ត្រី ដែលមានទំនាក់ទំនងការងារជាមួយគ្រូដែលទទួលការវាយតម្លៃដូចជា គ្រូបង្រៀន បុគ្គលិកមិនបង្រៀន ប្រធានក្រុមបច្ចេកទេស មាតាបិតា ឬ តំណាងសិស្ស និងនាយករង។ សម្រាប់ការវាយតម្លៃនាយកសាលារៀនវិញ អាចជាមន្ត្រីការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ នាយករង គ្រូបង្រៀន បុគ្គលិកមិនបង្រៀន និងមាតាបិតា/អ្នកអាណាព្យាបាលសិស្ស។

បន្ថែមលើការវាយតម្លៃ ប្រអប់យោបល់អាចត្រូវដាក់នៅក្នុងបរិវេណសាលារៀន ហើយអាចទទួលក្រដាសយោបល់ ឬព័ត៌មានពីគ្រប់មជ្ឈដ្ឋាន ហើយនាយកសាលារៀន និងគគស អាចប្រើយោបល់ និងព័ត៌មាន ទាំងនេះសម្រាប់កែលម្អសាលារៀន។

## *របៀបកំណត់កម្រិតពិន្ទុនៃការវាយតម្លៃ*

ពិន្ទុមានពី១ដែលជាពិន្ទុទាបទៅ៥ ដែលជាពិន្ទុខ្ពស់បំផុត។ នាយកសាលា ឬ គគសមិនចាំបាច់ប្រាប់មន្ត្រីឬនាយកសាលា នូវលទ្ធផលភ្លាមក្រោយពេលប្រជុំឡើយ តែអាចប្រាប់មន្ត្រីឬនាយកសាលានៅដំណាក់ ចុងក្រោយនៃការវាយតម្លៃ។

| **លទ្ធផល** | **កម្រិតពិន្ទុ** |
|---|---|
| សម្រេចគ្រប់លទ្ធផលគ្រោង និងលើសផែនការ | ៥ |
| សម្រេចគ្រប់លទ្ធផលគ្រោង | ៤ |
| សម្រេចលើ៥០%ទៅ៧០%នៃលទ្ធផលគ្រោង | ៣ |
| សម្រេចពី៣០%ទៅ៥០%នៃលទ្ធផលគ្រោង | ២ |
| សម្រេចទាបជាង៣០%នៃលទ្ធផលគ្រោង | ១ |

យ៉ាងច្រើនណាស់ចំនួន១០% នៃមន្ត្រីជាអ្នកដែលអាចទទួលបានកម្រិតពិន្ទុ ៥ នៃឆ្នាំនីមួយៗ។ កម្រិត ពិន្ទុ៣ ជាកម្រិតនៃការអនុវត្តការងាររបស់មន្ត្រីដែលអាចទទួលយកបាន។ មន្ត្រី ឬនាយកសាលាដែលទទួល បានតែកម្រិត១ ឬ ២ ពីការវាយតម្លៃប្រចាំឆ្នាំចំនួន២ឆ្នាំជាប់គ្នា នាយកសាលា ឬ គគស. អាចស្នើសុំវិធានការ រដ្ឋបាលទៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិសម្រាប់មន្ត្រីនោះ។

គគស និងនាយកសាលានៃសាលារៀនដែលមានគ្រូលើសនិយាមអាចមិនទទួលយកគ្រូបន្ថែមដែលសាលារៀនមិនត្រូវការ។ គគស និងនាយកសាលាអាចស្នើសុំទៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិនូវចំនួនគ្រូខ្វះ។

## ២. ៣. ៥. ការអភិវឌ្ឍវិជ្ជាជីវៈ៖ ការបំប៉ននៅនឹងកន្លែង

### ១. កម្មវិធីបំប៉ននៅនឹងកន្លែង និងទិន្នផលបាន

សម្រាប់គ្រូបង្រៀន ក្រុមការងារក្រសួង និងគ្រូមុខវិជ្ជាថ្នាក់ជាតិនឹងរៀបចំកម្មវិធីបំប៉ននៅនឹងកន្លែង ដោយផ្អែកលើកិច្ចព្រមព្រៀងលទ្ធផល ផែនការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូបង្រៀន និងលទ្ធផលបានពីការធ្វើតេស្តសមត្ថភាពគ្រូបង្រៀន។ ក្រុមការងារថ្នាក់ជាតិនឹងចងក្រងកម្មវិធីបំប៉នតាមតំបន់ឱ្យទៅជាកម្មវិធីបំប៉នថ្នាក់ជាតិ រួចរៀបចំគ្រោងថវិកាប្រចាំឆ្នាំដើម្បីដាក់ជូនក្រុមគ្រប់គ្រងគម្រោងអនុម័ត។

សម្រាប់នាយកសាលារៀន ក្រុមការងារថ្នាក់ជាតិនឹងចងក្រងផែនការអភិវឌ្ឍសមត្ថភាពរបស់នាយកសាលារៀនទាំងអស់ឱ្យទៅជាកម្មវិធីបំប៉នថ្នាក់ជាតិសម្រាប់គ្រប់នាយកសាលារៀនទាំងអស់។ ក្រុមការងារក្រសួងនឹងរៀបចំគ្រោងថវិកាដាក់ស្នើដល់ក្រុមគ្រប់គ្រងគម្រោងដើម្បីអនុម័ត។

**ទម្រង់នៃកម្មវិធីបំប៉ននៅនឹងកន្លែង**

| មុខវិជ្ជាឬកិច្ចការ និងអនុខ្លឹមសារមុខវិជ្ជា (ចំណេះដឹង កិច្ចការ ការសិក្សា និងសីលធម៌) | វិធីសាស្ត្របង្រៀន (បុគ្គល ឬ រួមគ្នា) | ផលិតផលបានផលិត (ចំនួន) | ពេលវេលា |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |

### ២ ប្រតិទិនបំប៉ន សៀវភៅលំហាត់ សម្ភារៈបង្រៀន (មេរៀនសិក្សា) និងការបង្រៀនតាមកម្មសិក្សា

គ្រូបង្គោលតាមមុខវិជ្ជាថ្នាក់ជាតិនឹងរៀបចំប្រតិទិនបំប៉ន និងសេចក្តីណែនាំស្តីពីការអនុវត្តកិច្ចការផ្ទះ សៀវភៅលំហាត់ សម្ភារៈបង្រៀន (មេរៀនសិក្សា មេរៀនលម្អិត) និងការបង្រៀនតាមកម្មសិក្សា។ សៀវភៅណែនាំធានានូវការផ្សារភ្ជាប់គ្នារវាងកម្មវិធីសិក្សា ប្រតិទិនបំប៉ន សៀវភៅលំហាត់ សម្ភារៈបង្រៀន (មេរៀន

សិក្សា មេរៀនលម្អិត) និងការបង្រៀនតាមកម្មសិក្សា ហើយទាំងអស់នេះគ្របដណ្តប់យ៉ាងពេញលេញនូវគំលាតចំណេះដឹងនៃមុខវិជ្ជា និងបំណិនគរុកោសល្យធៀបនឹងតម្រូវការនៃខ្លឹមសារកម្មវិធីសិក្សាថ្នាក់ជាតិ ដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា។

ផលិតផលដែលផលិតបានដោយគ្រូបង្រៀនត្រូវពិនិត្យមើលដោយក្រុមគ្រូបង្គោលថ្នាក់ជាតិហើយ ផលិតផលដែលមានគុណភាពប្រសើរនឹងត្រូវផ្សព្វផ្សាយក្នុងគេហទំព័ររបស់ក្រសួងអប់រំ យុវជន និងកីឡា។

## ៣ ការវាយតម្លៃចុងឆ្នាំនិងការធ្វើផែនការឆ្នាំបន្ទាប់

ក្នុងអំឡុងខែកញ្ញា ក្រុមគ្រូបង្គោលថ្នាក់ជាតិ និងគ្រូបង្រៀនជួបប្រជុំ ដើម្បីពិនិត្យពីការរីកចម្រើនការអនុវត្តកម្មវិធីបំប៉ន ហើយពិភាក្សា និងឯកភាពលើខ្លឹមសារនៅក្នុងផែនការបំប៉ននៅនឹងកន្លែងសម្រាប់ឆ្នាំបន្ទាប់។ កិច្ចការនេះត្រូវធ្វើក្នុងពេលស្របគ្នាជាមួយនឹងការវាយតម្លៃការអនុវត្តការងារចុងឆ្នាំរបស់គ្រូបង្រៀន ឬនាយកសាលា ព្រោះថាផែនការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀននឹងត្រូវប្រើសម្រាប់រៀបចំកម្មវិធីបំប៉ននេះ។

*តារាងវាយតម្លៃលទ្ធផលពីការបំប៉ន*

| ផលិតផលបានគ្រោង (ចំនួន) | ផលិតផលបានផលិត (ចំនួន) | ផលិតផលជាផែនការបន្ទាប់(ចំនួន) |
|---|---|---|
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |

**ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន** (**សូមមើលឧបសម្ព័ន្ធ**)

**សេចក្តីព្រាងស្តង់ដាវិជ្ជាជីវៈនាយកសាលារៀនចំណេះទូទៅ**(**សូមមើលឧបសម្ព័ន្ធ**)

## ២. ៤. តួនាទីសហគមន៍ និងអភិបាលកិច្ចសាលារៀន

ជំពូកនេះអធិប្បាយពីនីតិវិធី និងរបៀបអនុវត្តសកម្មភាពនូវតួនាទីសហគមន៍ និងអភិបាលកិច្ចសាលារៀន។

### ២.៤.១. ការចូលរួមរបស់សហគមន៍

សហគមន៍នៅទីនេះជាមាតាបិតាសិស្ស រដ្ឋអំណាចមូលដ្ឋាន និងតំណាងសហគមន៍ដែលជាសមាជិកគណៈកម្មការគ្រប់គ្រងសាលារៀន។

#### ១ ការចូលរួមក្នុងការគ្រប់គ្រង ការអនុវត្តការងាររបស់មន្ត្រី និងការពិនិត្យតាមដានសាលារៀន

ការចូលរួមនេះមានប្រយោជន៍ធ្វើឱ្យមានការធានានូវគណនេយ្យភាពរបស់សាលារៀន និងគ្រូបង្រៀន។ សហគមន៍អាចពិនិត្យតាមដានម៉ោងបង្រៀន ដូចជាអវត្តមានគ្រូបង្រៀន សិស្សអវត្តមាន ថ្នាក់រៀនបើកយឺត-បិទមុនម៉ោង និងសាលារៀនបើក-បិទមិនខុសប្រតិទិនសិក្សា។ សហគមន៍នឹងទទួលការបំប៉នដើម្បីអនុវត្តការងារនេះ។

តំណាងសហគមន៍ ត្រូវបានចូលរួមក្នុងការអនុវត្តការគ្រប់គ្រងមន្ត្រីដូចមានរៀបរាប់នៅក្នុងជំពូកការគ្រប់គ្រងការអនុវត្តរបស់មន្ត្រី។

#### ២ ការធ្វើផែនការ ការគ្រោងថវិកា និងការពិនិត្យថវិកាសាលារៀន

សារៈប្រយោជន៍នៃការចូលរួមរបស់សហគមន៍គឺបង្កើនការទុកចិត្តគ្នារវាងសហគមន៍ គ្រូបង្រៀន និងសាលារៀន។ ការទុកចិត្តនេះអាចធ្វើឱ្យមានការចូលរួម និងការបរិចាករបស់សហគមន៍ជួយដល់សាលារៀន ហើយសាលារៀន និងគ្រូបង្រៀនត្រូវតែឆ្លើយតបទៅនឹងតម្រូវរបស់សហគមន៍ និងមាតាបិតាតាមគោលការណ៍គណនេយ្យភាព។ មានន័យថាគ្រប់ធនធានដែលសាលារៀនបានទទួលពីរដ្ឋាភិបាល ដៃគូអភិវឌ្ឍ វិស័យឯកជន និងសហគមន៍ត្រូវបានប្រើប្រាស់ក្នុងការអនុវត្តសកម្មភាពអាទិភាពដែលបានរកឃើញពេលធ្វើផែនការ និងគ្រោងថវិកា។

នាយកសាលាអញ្ជើញសហគមន៍ និងមាតាបិតាចូលរួមក្នុងការធ្វើផែនការ និងគ្រោងថវិកាសាលារៀនតាមការណែនាំនៅក្នុងប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផលនិងសេចក្តីណែនាំពីការគ្រប់គ្រងតាមសាលារៀន។

គ្រប់មូលនិធិដែលបានទទួលត្រូវកត់ត្រានៅក្នុងស្តង់ដាទី៩ នៃស្តង់ដាសាលារៀនមានប្រសិទ្ធភាព និង ទៅតាមការណែនាំក្នុងជំពូកពីការគ្រប់គ្រងហិរញ្ញវត្ថុ នៃសៀវភៅណែនាំពីការគ្រប់គ្រងតាមសាលារៀន។

## ៣ ការចូលរួមក្នុងសកម្មភាពសាលារៀន

សហគមន៍អាចអនុវត្តសកម្មភាពដែលមានការឯកភាពនៅក្នុងផែនការកែលម្អសាលារៀនប្រចាំឆ្នាំ ឬដោយមានការប្តេជ្ញាចិត្តពីសហគមន៍នៅក្នុងឆ្នាំសិក្សា។

សកម្មភាពមានដូចជា ជួយសិស្សមករៀនទៀងទាត់ គ្រប់គ្រងការសាងសង់សាលារៀន ជាសមាជិកគណៈកម្មការថ្នាក់រៀន ចូលរួមក្នុងការរៀបចំព្រឹត្តិការឬពិធីផ្សេងៗនៅសាលារៀន ជាអ្នកជំនាញបង្ហាញប្រធានបទអ្វីមួយដល់សិស្ស ជួយរកមូលនិធិសាលារៀន សង្កេតសកម្មភាពបង្រៀនក្នុងថ្នាក់ ធានាថាសិស្ស(ជាកូនរបស់ខ្លួន)ធ្វើកិច្ចការផ្ទះជាលំហាត់ឬជាគម្រោងដែលគ្រូដាក់ឱ្យជួយសិស្សឱ្យអាន និងសិក្សានៅផ្ទះទៀងទាត់ និងថែរក្សាហេដ្ឋារចនាសម្ព័ន្ធសាលារៀន។ល។

*របៀបអនុវត្តសកម្មភាពទាំងនេះមានរៀបរាប់នៅខាងក្រោម៖*

**ជួយសិស្សមករៀននៅសាលារៀនទៀងទាត់ពេលវេលា**

១. មាតាបិតាគប្បីផ្តល់ព័ត៌មាន និងសុំច្បាប់ពីគ្រូបង្រៀន ឬនាយកសាលាប្រសិនបើគាត់ចង់ឱ្យកូនគាត់ឈប់សម្រាកពីថ្នាក់រៀន

២. គ្រូបង្រៀន ឬសាលារៀនទូរស័ព្ទផ្តល់ព័ត៌មានទៅមាតាបិតា ប្រសិនបើមិនឃើញសិស្សមករៀនក្នុងថ្នាក់ទាន់ពេល ឬ អវត្តមានពីថ្នាក់រៀន

៣. គ្រូបង្រៀន ឬសាលារៀនគប្បីអញ្ជើញ មាតាបិតានៃសិស្សដែលអវត្តមានចំនួន៣ដង ឬច្រើនដងជាងនេះដោយមិនមានច្បាប់មកប្រជុំដើម្បីពិភាក្សារកបញ្ហា និងកំណត់សកម្មភាពដោះស្រាយដែលត្រូវអនុវត្ត

៤. គ្រូបង្រៀន ឬសាលារៀនគប្បីចុះសួរសុខទុក្ខគ្រួសារដល់ផ្ទះសិស្ស ប្រសិនបើមាតាបិតា និងសិស្ស មកសាលារៀនដើម្បីប្រជុំតាមការណាត់របស់គ្រូបង្រៀនឬសាលាទេ។ ក្នុងពេលសួរសុខទុក្ខនៅផ្ទះ គ្រូបង្រៀនឬសាលាគប្បីជូនព័ត៌មានពីស្ថានភាពបញ្ហា "អវត្តមានដោយមិនមានព័ត៌មាន និងផលប៉ះពាល់របស់វាដល់ការសិក្សារបស់សិស្ស" សួរមាតាបិតា និងសិស្សអំពីការលំបាកដែលគេជួបប្រទះ និងមិនត្រូវស្តីបន្ទោសមាតាបិតា និងសិស្សទេ រួចហើយពិភាក្សាពីសកម្មភាពដែលអាចធ្វើបាន ដោយគ្រូបង្រៀនឬសាលាដើម្បីនាំសិស្សមករៀនវិញ។

## ៤ គ្រប់គ្រងការសាងសង់សាលារៀន

របៀបអនុវត្តសកម្មភាពនេះមានអធិប្បាយនៅក្នុងសៀវភៅពីការសាងសង់ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធរបស់សាលារៀនដោយសហគមន៍។ សមាជិកគណៈកម្មការសហគមន៍នឹងទទួលការបង្រៀនដើម្បីអនុវត្តការងារនេះ។

## ៥ ជាសមាជិកគណៈកម្មការថ្នាក់រៀន .

របៀបអនុវត្តសកម្មភាពនេះមានរៀបរាប់នៅក្នុងចំណងជើងខាងក្រោមស្តីពី ការអប់រំមាតាបិតាពីការពិនិត្យតាមដានសាលារៀននិងថ្នាក់រៀន។

## ៦ ចូលរួមក្នុងការរៀបចំព្រឹត្តិការណ៍ ឬពិធីផ្សេងៗនៅសាលារៀន

មានព្រឹត្តិការណ៍ ឬ ពិធីផ្សេងៗដូចបានរៀបរាប់ក្នុងជំពូក៣ ស្តីពីការធ្វើផែនការ និងការគ្រប់គ្រងថវិកាសាលារៀន អនុចំណងជើងស្តីពីសកម្មភាពក្នុងការរកមូលនិធិសាលារៀន។ ជាទូទៅជំហាននៃការអនុវត្តសកម្មភាពនេះមានរៀបរាប់ដូចខាងក្រោម៖

១. គណៈកម្មការគ្រប់គ្រងសាលារៀន និងនាយកសាលាពិភាក្សាពីការអនុវត្តព្រឹត្តិការណ៍ឬពិធីនេះ។ ព្រឹត្តិការណ៍ ឬ ពិធីគប្បីមានបញ្ចូលទៅក្នុងផែនការកែលម្អសាលារៀន។

២. ជំហាននៃការប្រជុំមាន៖

- ពិភាក្សា និងឯកភាពលើវត្ថុបំណងនៃព្រឹត្តិការណ៍ឬពិធី
- ពិភាក្សា និងឯកភាពថាត្រូវធ្វើសកម្មភាពអ្វីនៅមុនពេល ក្នុងពេល និងក្រោយពេលមានព្រឹត្តិការណ៍ឬពិធី
- ពិភាក្សា និងឯកភាពថាអ្នកណាជាអ្នកអនុវត្តសកម្មភាពអ្វី និងនៅពេលណា

៣. ពិនិត្យឡើងវិញនូវការសម្រេចបានពីព្រឹត្តិការណ៍ឬពិធីក្រោយពីបានរៀបចំហើយ។ សំណួរត្រូវសួរ សម្រាប់ការពិនិត្យឡើងវិញមាន៖

- តើវត្ថុបំណងបានសម្រេចឬទេ ហើយតើសំអាងលើភស្តុតាងអ្វី?
- តើអ្នកចូលរួមបានអនុវត្តសកម្មភាព ដែលបានឯកភាពដោយមានគុណភាពតាមការគ្រោងទុក និងទាន់ពេលឬទេ?
- ប្រសិនបើវត្ថុបំណង ឬសកម្មភាពមិនបានធ្វើឱ្យសម្រេចឬមិនបានអនុវត្តទេ តើមកពីអ្វី និងតើ ត្រូវដោះស្រាយតាមវិធីណា?

គំរូពីជំហានសកម្មភាពព្រឹត្តិការណ៍ឬពិធីសាមញ្ញមួយ

| វត្ថុបំណង | សកម្មភាព | អ្នកទទួលអនុវត្ត | ថ្ងៃទីខែឆ្នាំ |
|---|---|---|---|
| អាចមានៈ កសាងទំនុកចិត្ត ឬ រកមូលនិធិ ឬ ផ្តល់រង្វាន់ដល់សិស្ស ឬ គ្រូពូកែ | **មុនពេលព្រឹត្តិការណ៍** | | |
| | ក. រៀបចំផែនការសកម្មភាព | | |
| | ខ. ផលិតសម្ភារៈសម្រាប់ប្រើក្នុងព្រឹត្តិការណ៍ | | |
| | គ. ជូនព័ត៌មានមាតាបិតានិងសហគមន៍ចូលរួមកម្មវិធី | | |
| | **ក្នុងពេលមានព្រឹត្តិការណ៍** | | |
| | ក. ប្រជុំជូនព័ត៌មានពីកម្មវិធី | | |
| | ខ. រៀបចំការធ្វើទស្សនៈកិច្ចអគារសិក្សា ឬផលិតផលស្នាដៃសិស្ស ឬសកម្មភាពក្នុងថ្នាក់រៀន | | |
| | គ. ប្រជុំបិទកម្មវិធី និងជូនព័ត៌មានពីការសម្រេចបាននូវ វត្ថុបំណងរបស់ព្រឹត្តិការណ៍ | | |
| | **ក្រោយពេលព្រឹត្តិការណ៍** | | |
| | ក. ប្រជុំពិនិត្យឡើងវិញ | | |
| | ខ. ជូនសំបុត្រសាលារៀនជាព័ត៌មានអំពីព្រឹត្តិការណ៍ ចំណូល ឬការបរិច្ចាគដែលសាលារៀនបានទទួល ព្រមទាំងថ្លែងអំណរគុណមាតាបិតានិងសហគមន៍ | | |

## ៧ ជាអ្នកជំនាញបង្ហាញប្រធានបទអ្វីមួយដល់សិស្ស

ប្រធានបទអាចមានដូចជាៈ បំណិនរកចំណូល ច្បាប់ទាក់ទងនឹងបញ្ហាមាននៅសាលារៀន (ដូចជាហឹង្សា) ការថែទាំកូន ការរកមូលនិធិឬចំណូលសាលារៀន ការជួយសិស្សធ្វើលំហាត់ឬគម្រោងនៅផ្ទះដែលគ្រូដាក់ឱ្យ ការជួយមាតាបិតាសិស្សដើម្បីជួយកូនខ្លួនឯង និងសិស្សជួយសិស្សជាបណ្តាញឬដៃគូ ។ល។

ក. គគស និងនាយកសាលាអាចចាប់ផ្តើមបង្កើតសកម្មភាព ដោយធ្វើការពិភាក្សាពីវត្ថុបំណងនៃបទបង្ហាញ ប្រធានបទដោយអ្នកជំនាញ កំណត់ប្រធានបទអាទិភាព ស្វែងរកនិងអញ្ជើញអ្នកមានជំនាញលើប្រធានបទនីមួយៗមកធ្វើបទបង្ហាញចែករំលែកពិសោធន៍។

ខ. រៀបចំការប្រជុំដោយអញ្ជើញអ្នកជំនាញ និងសមាជិកចូលរួមស្តាប់ទៅតាមប្រធានបទនីមួយៗ

គ. ប្រតិទិននៃការប្រជុំអាចមាន៖

១. នាយកសាលារៀន ឬ ប្រធានគគសជំរាបជូននូវវត្ថុបំណងនៃការប្រជុំ និងណែនាំសមាជិក ប្រជុំឱ្យស្គាល់អ្នកជំនាញ

២. អ្នកជំនាញចែករំលែកពិសោធន៍តាមមាត់ឬមានការបង្ហាញ

៣. នាយកសាលាឬប្រធានគគស.សម្រួលការពិភាក្សា ដោយការភ្ញោចសំណួរ រក្សាការឆ្លងឆ្លើយ និងពិភាក្សាគ្នា

៤. នាយកសាលាឬប្រធានគគស.បិទការប្រជុំដោយបង្ហាញពីលទ្ធផលប្រជុំ ឬខ្លឹមសារបូកសរុប (ការប្តេជ្ញាចិត្តបន្តធ្វើតាមពិសោធន៍បានទទួល ឬកំណត់សកម្មភាពត្រូវធ្វើបន្ត) និងថ្លែងអំណរគុណដល់អ្នកជំនាញ និងសមាជិកចូលរួមប្រជុំ។

## ៨ ជួយរកមូលនិធិសាលារៀន

ខ្លឹមសារមានរៀបរាប់នៅក្នុងជំពូកការធ្វើផែនការ និងការគ្រប់គ្រងមូលនិធិសាលារៀន ការរកមូលនិធិសាលារៀនហើយ និងនៅក្នុងប្រធានបទខាងលើស្តីពីការចូលរួមជួយរៀបចំព្រឹត្តិការណ៍ ឬពិធីនៅសាលារៀន។

## ៩ សង្កេតសកម្មភាពបង្រៀនក្នុងថ្នាក់

ខ្លឹមសារមានរៀបរាប់នៅក្នុងសេចក្តីណែនាំពីការគ្រប់គ្រងតាមសាលារៀន ការពិនិត្យតាមដានសាលារៀននិងថ្នាក់រៀន។

**ធានាថាសិស្ស (ជាកូនរបស់ខ្លួន) ធ្វើកិច្ចការផ្ទះជាលំហាត់ឬជាគម្រោងដែលគ្រូដាក់ឱ្យ**

សិស្ស មាតាបិតា និងគ្រូបង្រៀនជាជនគន្លឹះក្នុងការអនុវត្តសកម្មភាពនេះ៖

- ➪ គ្រូបង្រៀនត្រូវដាក់កិច្ចការជាលំហាត់ឬជាគម្រោងដល់សិស្ស និងណែនាំសិស្សឱ្យច្បាស់លាស់ពីរបៀបធ្វើលំហាត់។ គ្រូបង្រៀនអាចរៀបសិស្សជាក្រុមដើម្បីធ្វើលំហាត់ជាគម្រោង និងរៀបសិស្ស ជាដៃគូពីរនាក់ដែលរស់នៅក្បែរខាងគ្នាក្នុងការជួយគ្នាធ្វើកិច្ចការជាលំហាត់។ ការរៀបឱ្យមានសិស្សពូកែនិងសិស្សរៀនយឺតជាក្រុមនឹងផ្តល់តម្លៃបន្ថែមដល់កិច្ចការនេះ។ សម្រាប់សាលាដែលមានសិស្សមានចិត្តចង់ជួយគ្នាជាដៃគូ ឬជាក្រុម ការរៀបចំនេះគឺសិស្សគេធ្វើ ដោយខ្លួនគេប្រកបដោយការភ្ញាក់រលឹក។ គ្រូបង្រៀនត្រូវកែកិច្ចការផ្ទះជាលំហាត់ និងជាគម្រោង ព្រមទាំងត្រូវផ្តល់ចម្លើយតបដល់សិស្សវិញ។

➪ សិស្សត្រូវមានការទទួលខុសត្រូវក្នុងការធ្វើកិច្ចការផ្ទះ។ សិស្សអាចរៀបចំការជួបជុំគ្នាធ្វើកិច្ចការនៅសាលារៀន ឬ នៅផ្ទះ ឬ មួយគេអាចប្រើបច្ចេកវិទ្យាបង្រៀននិងរៀនតាមប្រព័ន្ធអ៊ីនធើណែតដែលភ្ជាប់ពីផ្ទះមួយទៅផ្ទះផ្សេងទៀត។ សិស្សត្រូវមានពេលទទួលចម្លើយតបពីគ្រូបង្រៀននូវលទ្ធផលនៃលំហាត់របស់គេ។

➪ មាតាបិតាគប្បីចំណាយពេលនៅជាមួយកូនរាល់ពេលល្ងាចនៃថ្ងៃនីមួយៗ និងលើកទឹកចិត្តកូនរបស់ខ្លួនឱ្យធ្វើកិច្ចការផ្ទះដែលគ្រូដាក់ឱ្យ។ ប្រសិនបើមាតាបិតាជាអ្នកបានរៀនសូត្រ គេអាចជួយសម្របសម្រួលសិស្សក្នុងការសិក្សានៅផ្ទះនេះ តែមិនមែនធ្វើកិច្ចការផ្ទះជំនួសកូនឡើយ។.

## ១០ ជួយសិស្សឱ្យអាននិងសិក្សានៅផ្ទះទៀងទាត់

➪ មាតាបិតាគប្បីរក្សាទុកពេលឱ្យកូនសិក្សានៅផ្ទះ និងកំណត់ម៉ោងជាក់លាក់ប្រចាំថ្ងៃដូចជាកាលវិភាគរៀននៅផ្ទះជាដើម។ ការធ្វើបែបនេះនឹងជួយសិស្សបង្កើតបាននូវចរិយារៀនសូត្រនិងការទទួលខុសត្រូវបានល្អ។ ម៉ោងសិក្សាទៀងទាត់ប្រចាំថ្ងៃគប្បីចាប់ផ្តើមដោយការអានអក្សរឮៗ ឱ្យបានមួយម៉ោង រួចហើយធ្វើលំហាត់មុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រ បន្ទាប់មកសិក្សា និងសរសេរលំហាត់ជាគម្រោង (វិទ្យាសាស្ត្រ ឬ វិទ្យាសាស្ត្រសង្គម) ដោយប្រើព័ត៌មានវិទ្យាស្រាវជ្រាវពីឯកសារយោងក្នុងប្រព័ន្ធអ៊ីនធើណែត ឬសៀវភៅដែលខ្ចីពីបណ្ណាល័យសាលារៀន។

➪ ការអានគឺជាអាទិភាពខ្ពស់បំផុតសម្រាប់សិស្ស ប្រសិនបើសិស្សមិនអាចអានបានទេ សិស្សមិនអាចរៀនមុខវិជ្ជាផ្សេងទៀតបាននោះទេ។ មាតាបិតាបើទោះជាមិនចេះអក្សរក៏អាចជួយកូនឱ្យអានអក្សរបានដែរ។ មាតាបិតាគប្បីនៅជាមួយកូន និងស្តាប់ភាសាដែលកូនអាន (ភាសាខ្មែរ ឬ បរទេស) រយៈពេល១ម៉ោងក្នុងមួយថ្ងៃ។ ប្រសិនបើកូនអានអក្សរខុស នាំឱ្យមាតាបិតា (ទោះមិនចេះអក្សរ) ស្តាប់មិនយល់នូវអ្វីដែលកូនអាន នោះមាតាបិតាអាចនិយាយជាមួយកូនដើម្បីស្វែងយល់ពីបញ្ហា។ វាជាការសំខាន់ដែលមាតាបិតាគប្បីវាស់ល្បឿនអំណានរបស់កូន «ចំនួនពាក្យអានត្រូវក្នុងមួយនាទី និងសួរកូនឱ្យនិយាយសង្ខេបប្រាប់ថាអត្ថបទមួយកថាខ័ណ្ឌដែលបានអានរៀបរាប់ពីអ្វីឬមានន័យយ៉ាងណា»។ ការនិយាយសង្ខេបនូវអត្ថន័យនៃអត្ថបទមួយកថាខ័ណ្ឌនេះបង្ហាញពីកម្រិតនៃសមត្ថភាពយល់ដឹងរបស់កូនលើមុខវិជ្ជាភាសា។ គ្រូបង្រៀនអាចផ្តល់ការណែនាំសាមញ្ញដល់ មាតាបិតាក្នុងការធ្វើកិច្ចការនេះ។ ការណែនាំមានដូចខាងក្រោម៖

- ជ្រើសរើសយកកថាខ័ណ្ឌមួយពីសៀវភៅសិក្សាគោល និងរាប់ចំនួនពាក្យនៅក្នុងកថាខ័ណ្ឌនោះ។ កថាខ័ណ្ឌគប្បីមានចំនួនពាក្យយ៉ាងតិចៈ ៨០ពាក្យ សម្រាប់សិស្សថ្នាក់ទី៣ ១៣០ពាក្យ សម្រាប់ថ្នាក់ទី៦ និង ២៥០ពាក្យសម្រាប់ថ្នាក់ទី៩។
- មាតាបិតាប្រាប់សិស្សត្រូវធ្វើអ្វីនៅនាទីបន្ទាប់ដូចជា «កូនត្រូវអានឱ្យឮៗ ការអានកូនអាចរំលងពាក្យណាដែលមិនចេះ ហើយកូនត្រូវឈប់អានពេលដែលប្រាប់ថាឈប់អាន»។
- មាតាបិតាប្រើនាឡិកាដែលបង្ហាញវិនាទី ដល់ទ្រនិចនាឡិកាចង្អុលលេខ១២ ត្រូវប្រាប់ឱ្យកូនអាន គូសក្រោមពាក្យដែលអានត្រូវ និងប្រាប់ឱ្យកូនឈប់អានពេលទ្រនិចនាឡិកាចង្អុលលេខ១២វិញ។
- មាតាបិតាប្រាប់ឱ្យសិស្សនិយាយសង្ខេបថាតើអត្ថបទដែលអាននិយាយពីអ្វី និងកត់ត្រាអ្វីដែលកូននិយាយ។
- មាតាបិតារាប់ចំនួនពាក្យដែលបានគូសពីក្រោម ប្រសិនបើកូនអានបានតាមចំនួនស្តង់ដា (ថ្នាក់ទី៣ ចំនួន៤៥ ទៅ៦០ពាក្យ ថ្នាក់ទី៦ ចំនួន១០០ ទៅ ១២០ពាក្យ ថ្នាក់ទី៩ ចំនួន ២០០ ទៅ២៥០ពាក្យ) នោះមាតាបិតាសិស្សនឹងដឹងពីសមត្ថភាពកូនលើមុខវិជ្ជាភាសាខ្មែរ ឬ បរទេស។ ជាទូទៅបើសិស្សអាចអានតាមចំនួនស្តង់ពាក្យក្នុងមួយនាទីនោះសិស្សនឹងអាចយល់បានពីន័យរបស់អត្ថបទ ដែលបង្ហាញដោយការនិយាយសង្ខេបនូវអត្ថន័យនៃអត្ថបទនោះ។ ប្រសិនបើកូនមិនចេះអាន មាតាបិតាគប្បីពិភាក្សាជាមួយកូនស្វែងរកបញ្ហា និងជួយកូនអានពាក្យដែលមិនចេះ (ពាក្យអានរំលងឬអានមិនត្រូវ) ដោយសារការប្រកបអក្សរមិនត្រូវ។ ប្រសិនបើមាតាបិតា មិនចេះអក្សរ មាតាបិតាគប្បីទាក់ទងជួបជាមួយគ្រូបង្រៀនដើម្បីពិភាក្សា និងផ្តល់ការគាំទ្រសិស្សពីគ្រូបង្រៀន។

## ១១ ថែរក្សាហេដ្ឋារចនាសម្ព័ន្ធសាលារៀន

គោលបំណងនៃសកម្មភាពនេះគឺ រក្សាការប្រើប្រាស់អគារសិក្សាសម្រាប់ការសិក្សារបស់សិស្សទៅតាមអាយុកាលរបស់អគារសិក្សា។

១. អគារសិក្សានេះមានថ្នាក់រៀន បន្ទប់ពិសោធន៍ រោងជាង សំណង់អនាម័យទឹកស្អាត ការិយាល័យ និងឧបករណ៍ប្រើប្រាស់ ព្រមទាំងអគ្គីសនីនិងឧបករណ៍ ។ល។

២. សហគមន៍អាចសង្កេតពីការប្រើប្រាស់ និងដំណើរការនៃហេដ្ឋារចនាសម្ព័ន្ធខាងលើ ដោយមានការឯកភាពជាមួយនាយកសាលារៀបចំកាលវិភាគទទួលខុសត្រូវតាមថ្ងៃនីមួយៗ។

៣. សហគមន៍អាចផ្តល់ព័ត៌មានដល់នាយកសាលាគ្រប់ពេលនៅពេលណាឃើញថា អគារណាមួយត្រូវការជួសជុលតូច។

៤. នាយកសាលាសម្រេចចិត្តប្រើថវិកាសាលារៀនដើម្បីជួសជុល និងត្រូវអនុវត្តតាមការណែនាំ សម្រាប់ការជួសជុល និងការសាងសង់។

## ១២ ការជួយផ្តល់ធាតុចូលដល់សាលារៀន

សហគមន៍អាចចូលរួមចំណែកជាប្រាក់ដល់សាលារៀន សម្ភារៈសិក្សាដល់សិស្ស ឬ កុមារ ផ្តល់វត្ថុធាតុដើមសម្រាប់ធ្វើសង្ហារឹមឬថ្នាក់រៀន។ល។

## ១៣ ការពង្រឹងតម្លាភាពក្នុងការចូលរួមរបស់សហគមន៍

តម្លាភាពនេះមានន័យថាៈ ១) តម្លាភាពក្នុងការបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន ២) តម្លាភាពក្នុងការធ្វើផែនការសាលារៀន និងការគ្រោងថវិកា ៣) តម្លាភាពក្នុងការចំណាយ ការរកមូលនិធិ និងការផ្សព្វផ្សាយទិន្នន័យហិរញ្ញវត្ថុ ៤) តម្លាភាពពីការអនុវត្តនិងប្រតិបត្តិការសាលារៀន ៥) តម្លាភាពពីលទ្ធផលសិក្សារបស់សិស្ស ៦) តម្លាភាពក្នុងការបង្កើតគណៈកម្មការសាងសង់និងជួសជុលសាលារៀន និង ៧) តម្លាភាពពីថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិពីការផ្តល់ធាតុចូលដល់សាលារៀន និងការកសាងសមត្ថភាពសាលារៀន។

របៀបអនុវត្តតម្លាភាពទាំងនេះមានរៀបរាប់ខាងក្រោមនេះៈ

១). តម្លាភាពក្នុងការបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន មាននៅក្នុងជំពូកស្តីពីស្វ័យភាព និង គណនេយ្យភាពសាលារៀន។

២). តម្លាភាពក្នុងការធ្វើផែនការសាលារៀននិងការគ្រោងថវិកា និងការរកមូលនិធិមាននៅក្នុងជំពូក ស្តីពីការធ្វើផែនការ និងការគ្រប់គ្រងថវិកាសាលារៀន។

៣). តម្លាភាពក្នុងការចំណាយ និងការផ្សព្វផ្សាយទិន្នន័យហិរញ្ញវត្ថុ មាននៅក្នុងជំពូកពីការគ្រប់គ្រងហិរញ្ញវត្ថុ។

៤). តម្លាភាពពីការអនុវត្ត និងប្រតិបត្តិការសាលារៀន មានបង្ហាញនៅក្នុងផែនការកែលម្អសាលារៀន និងថវិកា លទ្ធផលពីការវាយតម្លៃការអនុវត្តការងាររបស់សាលារៀនធៀបជាមួយស្តង់ដាសាលារៀនមានប្រសិទ្ធភាព ។

៥). តម្លាភាពពីលទ្ធផលសិក្សារបស់សិស្ស មាននៅកាតរបាយការណ៍សាលារៀនពីសូចនាករគន្លឹះ និងក្នុងផលសម្រេចនិងក្រុមគោលដៅសូចនាករផលសម្រេចរយៈពេល៣ឆ្នាំ។

៦). តម្លាភាពក្នុងការបង្កើតគណៈកម្មការសាងសង់ និងជួសជុលសាលារៀន មាននៅក្នុងសៀវភៅណែនាំពីសហគមន៍ចូលរួមក្នុងការងារសាងសង់ និងជួសជុលសាលារៀន។

៧). តម្លាភាពពីថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិពីការផ្តល់ធាតុចូលដល់សាលារៀន និងការកសាងសមត្ថភាពសាលារៀនមាននៅក្នុង ផែនការសកម្មភាពរបស់មន្ទីរ និងការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ។

## ២.៤.២. មាតាបិតានិងសិស្សចូលរួមការងារក្នុងវិស័យអប់រំ

ការចូលរួមរបស់មាតាបិតានិងសិស្សក្នុងការពិនិត្យតាមដានសាលារៀន និងថ្នាក់រៀនមានសារៈសំខាន់ ណាស់ដើម្បីបំពេញចន្លោះខ្វះខាតនៃការពិនិត្យតាមដានរបស់នាយកសាលានិងគ្រូបង្រៀន។ មានខ្លឹមសារ៣ ដែលទាក់ទងនឹងការពិនិត្យតាមដានដោយមាតាបិតានិងសិស្សដូចខាងក្រោម៖

១) ខ្លឹមសារសម្រាប់អប់រំមាតាបិតានិងសិស្ស ២) ការបំប៉នមាតាបិតានិងសិស្ស និង ៣) ការអនុវត្តការពិនិត្យតាមដាន។

## ១ ខ្លឹមសារសម្រាប់អប់រំមាតាបិតានិងសិស្ស

### សូចនាករផលសម្រេច និងក្រុមគោលដៅរយៈពេល៣ឆ្នាំ ឆ្នាំសិក្សា២០១៧-២០១៨

| សូចនាករផលសម្រេច | ក្រុមគោលដៅគ្រោងឆ្នាំសិក្សា ២០១៧-២០១៨ | សម្រេចជាក់ស្តែងឆ្នាំសិក្សា ២០១៧-២០១៨ |
|---|---|---|
| ១. ការចូលរៀន | | |
| ចំនួនសិស្សបានចូលរៀន | | |
| ចំនួនសិស្សត្រួតថ្នាក់ | | |
| ចំនួនសិស្សឡើងថ្នាក់ | | |
| ២. ចំនួនសិស្សមានពិន្ទុតេស្តលើ៦០%នៃមុខវិជ្ជាគោល | | |
| ភាសាខ្មែរ | | |
| គណិតវិទ្យា | | |
| ភាសាបរទេស | | |
| ៣. ចំនួនសិស្សមានពិន្ទុតេស្តលើ៦០%នៃមុខវិជ្ជាវិទ្យាសាស្ត្រ | | |
| រូបវិទ្យា | | |
| គីមីវិទ្យា | | |
| ជីវវិទ្យា | | |
| ផែនដីវិទ្យា | | |
| ព័ត៌មាន ទំនាក់ទំនង និងបច្ចេកវិទ្យា | | |
| ៤. ចំនួនសិស្សថ្នាក់ទី៩អានភាសាខ្មែរបានច្រើនជាង ២០០ ពាក្យក្នុងមួយនាទី | | |
| ៥. ចំនួនសិស្សថ្នាក់ទី៩ប្រឡងជាប់ការប្រឡងថ្នាក់ជាតិ | | |

# កាតរបាយការណ៍ប្រៀបធៀបសូចនាករសំខាន់ឆ្នាំសិក្សា ២០១....-២០១.....

| **ព័ត៌មានសាលារៀន** | | | | |
|---|---|---|---|---|
| ឈ្មោះ | កម្រិត | ថ្នាក់ទី..........<br>ដល់<br>ថ្នាក់ទី.......... | លេខកូដ | |
| ឃុំ-សង្កាត់៖ | រាជធានី-ខេត្ត | | លេខទូរស័ព្ទ | |
| **ព័ត៌មានសិស្ស** | | | | |
| សរុបចំនួនសិស្ស៖ | សរុបចំនួនគ្រូបង្រៀន | | សរុបចំនួនមន្ត្រី | |
| សរុបចំនួនថ្នាក់រៀន៖ | ចំនួនម៉ោងបង្រៀនមួយសប្តាហ៍ | | បង្រៀនពេលថ្ងៃ (បាទឬទេ) | |
| **សូចនាករសំខាន់ៗ** | **សាលាខ្ញុំ** | **ស្រុកខ្ញុំ** | **រាជធានី-ខេត្តខ្ញុំ** | **ប្រទេសខ្ញុំ** |
| ១. ផលធៀបសិស្ស-គ្រូ<br>(បទដ្ឋាន៖ ......................) | | | | |
| ២. ផលធៀបសិស្ស-ថ្នាក់<br>(បទដ្ឋាន៖......................) | | | | |
| ៣. ផលធៀបសិស្ស=សៀវភៅសិក្សាគោល<br>(បទដ្ឋាន:......................) | | | | |
| ៤. បរិមាណថវិកាសម្រាប់សិស្សម្នាក់ | | | | |
| ៥. ចំនួនម៉ោងបង្រៀនជាមធ្យម<br>(បទដ្ឋាន:......................) | | | | |
| ៦. ភាគរយសិស្សថ្នាក់ទី៣ ទី៦ ទី៩ អានមានល្បឿនតាមស្តង់ដា (៤៥-៦០ ១០០-១២០ និង២០០ពាក្យក្នុង១នាទី) | | | | |
| ៧. ភាគរយសិស្សថ្នាក់ទី៣ ទី៦ និងទី៩ មានពិន្ទុតេស្តច្រើនជាង៦០% | | | | |
| ៨. ចំនួនសិស្សបោះបង់ការសិក្សា | | | | |

## ថវិកា និងការចំណាយថវិកាសាលារៀនឆ្នាំសិក្សា ២០១....-២០១....

| លរ | ប្រភេទចំណាយ | ថវិការដ្ឋ | | ថវិកាដៃគូ | | ថវិកាអំណោយមនុស្សធម៌ | | ថវិកាសហគមន៍ | | ថវិកាសរុប | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ថវិកាសរុប | ចំណាយសរុប | ថវិកាសរុប | ចំណាយសរុប | ថវិកាសរុប | ចំណាយសរុប | ថវិកាសរុប | ចំណាយសរុប | ថវិកាសរុប | ចំណាយសរុប |
| ១ | រដ្ឋបាល | | | | | | | | | | |
| ២ | ការបង្រៀននិងរៀន | | | | | | | | | | |
| ៣ | បរិស្ថាន | | | | | | | | | | |
| | សរុប | | | | | | | | | | |

*សម្គាល់៖ ថវិកាសម្រាប់ការបង្រៀននិងរៀនគប្បីមានចំនួនយ៉ាងតិច៦៥%នៃថវិកាសរុប*

## ២ ការបំប៉នមាតាបិតានិងសិស្ស

ការស្វែងរកមាតាបិតា និងសិស្សស្ម័គ្រចិត្តៈ គណៈកម្មការគ្រប់គ្រងសាលារៀនអញ្ជើញមាតាបិតាតាមរយៈសិស្ស និងសិស្សមកចូលរួមប្រជុំពីការចូលរួមរបស់សហគមន៍ក្នុងការអប់រំ។

**ប្រតិទិននៃការប្រជុំជ្រើសរើសអ្នកស្ម័គ្រចិត្តមានៈ**

ក. គណៈកម្មការគ្រប់គ្រងសាលារៀនជូនព័ត៌មានពីគោលបំណងនៃការប្រជុំ និងពីកិច្ចការចូលរួមរបស់ សហគមន៍ក្នុងការអប់រំតាមរយៈការពិនិត្យតាមដានការអនុវត្តការងាររបស់សាលារៀន និងថ្នាក់រៀន ដែលជា កិច្ចការមានសារៈសំខាន់ ដើម្បីបំពេញបន្ថែមលើការពិនិត្យតាមដានដែលធ្វើដោយនាយកសាលារៀន និង គ្រូបង្រៀន។ គណៈកម្មការគ្រង់គ្រងសាលារៀនជម្រាបអង្គប្រជុំនូវខ្លឹមសារចំនួន៣ៈ ១) ខ្លឹមសារជាចំណេះដឹង ដែលមាតាបិតានិងសិស្សត្រូវដឹង (តារាង៣ខាងលើ) ២) ការបំប៉នមាតាបិតានិងសិស្សឱ្យមានសមត្ថភាពអនុវត្ត កិច្ចការនេះ (ខ្លឹមសារខាងក្រោម) និង ៣) របៀបធ្វើការពិនិត្យតាមដាន (ឧបករណ៍ខាងក្រោម)។

ខ. គណៈកម្មការគ្រប់គ្រងសាលារៀនសាកសួររកមាតាបិតានិងសិស្សស្ម័គ្រចិត្តចូលរួមសកម្មភាពនេះ និងចុះឈ្មោះនិងលេខទូរស័ព្ទនៅក្នុងបញ្ជី។

គ. គណៈកម្មការគ្រប់គ្រងសាលារៀនពិភាក្សាជាមួយអ្នកស្ម័គ្រចិត្តជាមាតាបិតានិងសិស្សពីការបំប៉ននិងកំណត់ថ្ងៃខែត្រូវធ្វើការបំប៉ន។

**កម្មវិធីបំប៉នមាតាបិតានិងសិស្សស្ម័គ្រចិត្តៈ**

◈ គ្រូបំប៉នជូនព័ត៌មានពីវត្ថុបំណងនៃការបំប៉ន

◈ គ្រូបំប៉នបង្រៀនពីៈ

➪ ខ្លឹមសារដែលត្រូវពិនិត្យតាមដាន (តារាងខាងលើ)

➪របៀបអនុវត្តការពិនិត្យតាមដាន (ឧបករណ៍ខាងក្រោម)

## ៣ ការអនុវត្តការពិនិត្យតាមដាន

**ផែនការពិនិត្យតាមដានបានឯកភាព**

១. ពិនិត្យតាមដានរាល់ថ្ងៃពីៈ សាលារៀនបើកនិងបិទទ្វារ ថ្នាក់រៀនបើកបង្រៀននិងបិទឈប់បង្រៀន និងគ្រូអវត្តមាន។ អាចធ្វើដោយសិស្ស និងម្តងម្កាលដោយមាតាបិតា។

២. ពិនិត្យឡើងវិញប្រចាំត្រីមាសពី៖ ផែនការថ្នាក់រៀននិងការគ្រប់គ្រងសាលារៀនលម្អិតប្រចាំត្រីមាស សូចនាករផលសម្រេច និងកាតរបាយការណ៍សូចនាករសំខាន់ៗ។ អាចធ្វើដោយសិស្សនិងមាតាបិតា។

៣. ពិនិត្យឡើងវិញប្រចាំឆ្នាំ៖ សូចនាករផលសម្រេច និងកាតរបាយការណ៍សូចនាករសំខាន់ៗ និងថវិកានិងការចំណាយ។ អាចធ្វើដោយសិស្សនិងមាតាបិតា។

សកម្មភាពគ្រោងអនុវត្តដែលបានឯកភាពគឺគ្រាន់តែបានដឹងរវាងមាតាបិតានិងសិស្ស និងគណៈកម្មការគ្រប់គ្រងសាលារៀនបានហើយ មិនចាំបាច់ឱ្យគ្រូបង្រៀនដឹងពីឈ្មោះសិស្ស ឬ មាតាបិតាទេ។ គណៈកម្មការ គ្រប់គ្រងសាលារៀនជូនព័ត៌មានគ្រូបង្រៀនទាំងអស់នៅដើមឆ្នាំសិក្សាថា មានសកម្មភាពពិនិត្យតាមដាន ដែល ធ្វើដោយសហគមន៍នេះ។

សិស្សនិងមាតាបិតាអាចពិភាក្សាគ្នាថាតើអ្នកណាធ្វើកិច្ចការនៅអាទិត្យនេះ ឬ អាទិត្យក្រោយ ឬមួយនៅ ខែនេះ ឬ នៅខែក្រោយ។ មិនមានការចាំបាច់សរសេរផែនការនេះនៅក្នុងក្រដាសទេ ដោយសារការសរសេរនៅលើក្រដាសវាមិនជាតម្រូវការចាំបាច់ទេ និងកិច្ចការនេះមិនចាំបាច់ប្រកាសផ្សព្វផ្សាយជាសាធារណៈទេ។

## ការពិនិត្យតាមដាននិងពិនិត្យឡើងវិញ

### *ការពិនិត្យតាមដាន*

សិស្សនិងមាតាបិតាស្ម័គ្រចិត្តអាចប្រើតារាង៣ខាងក្រោមក្នុងការកត់ត្រាទិន្នន័យនិងព័ត៌មាន៖

## ការបើក និងបិទសាលារៀនឆ្នាំសិក្សា២០១....-២០១....

| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ច័ន្ទ | | | | | | | | | | | | | ច័ន្ទ |
| អង្គារ | | | | | | | | | | | | | អង្គារ |
| ពុធ | | | | | | | | | | | | | ពុធ |
| ព្រហ. | | | | | | | | | | | | | ព្រហ. |
| សុក្រ | | | | | | | | | | | | | សុក្រ |
| សៅរ៍ | | | | | | | | | | | | | សៅរ៍ |
| អាទិត្យ | | | | | | | | | | | | | អាទិត្យ |
| ច័ន្ទ | | | | | | | | | | | | | ច័ន្ទ |
| អង្គារ | | | | | | | | | | | | | អង្គារ |
| ពុធ | | | | | | | | | | | | | ពុធ |
| ព្រហ. | | | | | | | | | | | | | ព្រហ. |
| សុក្រ | | | | | | | | | | | | | សុក្រ |
| សៅរ៍ | | | | | | | | | | | | | សៅរ៍ |
| អាទិត្យ | | | | | | | | | | | | | អាទិត្យ |
| ច័ន្ទ | | | | | | | | | | | | | ច័ន្ទ |
| អង្គារ | | | | | | | | | | | | | អង្គារ |
| ពុធ | | | | | | | | | | | | | ពុធ |
| ព្រហ. | | | | | | | | | | | | | ព្រហ. |
| សុក្រ | | | | | | | | | | | | | សុក្រ |
| សៅរ៍ | | | | | | | | | | | | | សៅរ៍ |
| អាទិត្យ | | | | | | | | | | | | | អាទិត្យ |
| ច័ន្ទ | | | | | | | | | | | | | ច័ន្ទ |
| អង្គារ | | | | | | | | | | | | | អង្គារ |
| ពុធ | | | | | | | | | | | | | ពុធ |
| ព្រហ. | | | | | | | | | | | | | ព្រហ. |
| សុក្រ | | | | | | | | | | | | | សុក្រ |
| សៅរ៍ | | | | | | | | | | | | | សៅរ៍ |
| អាទិត្យ | | | | | | | | | | | | | អាទិត្យ |
| ច័ន្ទ | | | | | | | | | | | | | ច័ន្ទ |
| អង្គារ | | | | | | | | | | | | | អង្គារ |
| ពុធ | | | | | | | | | | | | | ពុធ |
| ព្រហ. | | | | | | | | | | | | | ព្រហ. |

***សម្គាល់៖*** *គូសសញ្ញា √នៅថ្ងៃសាលារៀនបើកទ្វារ គូសសញ្ញា X នៅថ្ងៃដែលសាលាបិទ និង សញ្ញា ¥ នៅថ្ងៃឈប់សម្រាក។*

# ការបើកនិងបិទថ្នាក់រៀន

| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ច័ន្ទ | | | | | | | | | | | | | ច័ន្ទ |
| អង្គារ | | | | | | | | | | | | | អង្គារ |
| ពុធ | | | | | | | | | | | | | ពុធ |
| ព្រហ. | | | | | | | | | | | | | ព្រហ. |
| សុក្រ | | | | | | | | | | | | | សុក្រ |
| សៅរ៍ | | | | | | | | | | | | | សៅរ៍ |
| អាទិត្យ | | | | | | | | | | | | | អាទិត្យ |
| ច័ន្ទ | | | | | | | | | | | | | ច័ន្ទ |
| អង្គារ | | | | | | | | | | | | | អង្គារ |
| ពុធ | | | | | | | | | | | | | ពុធ |
| ព្រហ. | | | | | | | | | | | | | ព្រហ. |
| សុក្រ | | | | | | | | | | | | | សុក្រ |
| សៅរ៍ | | | | | | | | | | | | | សៅរ៍ |
| អាទិត្យ | | | | | | | | | | | | | អាទិត្យ |
| ច័ន្ទ | | | | | | | | | | | | | ច័ន្ទ |
| អង្គារ | | | | | | | | | | | | | អង្គារ |
| ពុធ | | | | | | | | | | | | | ពុធ |
| ព្រហ. | | | | | | | | | | | | | ព្រហ. |
| សុក្រ | | | | | | | | | | | | | សុក្រ |
| សៅរ៍ | | | | | | | | | | | | | សៅរ៍ |
| អាទិត្យ | | | | | | | | | | | | | អាទិត្យ |
| ច័ន្ទ | | | | | | | | | | | | | ច័ន្ទ |
| អង្គារ | | | | | | | | | | | | | អង្គារ |
| ពុធ | | | | | | | | | | | | | ពុធ |
| ព្រហ. | | | | | | | | | | | | | ព្រហ. |
| សុក្រ | | | | | | | | | | | | | សុក្រ |
| សៅរ៍ | | | | | | | | | | | | | សៅរ៍ |
| អាទិត្យ | | | | | | | | | | | | | អាទិត្យ |
| ច័ន្ទ | | | | | | | | | | | | | ច័ន្ទ |
| អង្គារ | | | | | | | | | | | | | អង្គារ |
| ពុធ | | | | | | | | | | | | | ពុធ |
| ព្រហ. | | | | | | | | | | | | | ព្រហ. |

***សម្គាល់៖*** *គូសសញ្ញា √ ពេលថ្នាក់បើកនិងបិទត្រូវពេលវេលា  សញ្ញា X ពេលថ្នាក់បើកយឺតនិងបិទមុន*

*ពេលកំណត់ សញ្ញា € ពេលថ្នាក់បើកត្រូវពេលតែបិទមុនម៉ោង ឬ បើកថ្នាក់យឺតតែបិទត្រូវពេលកំណត់ សញ្ញា ¥ នៅថ្ងៃឈប់សម្រាក និងសញ្ញា XX នៅថ្ងៃមានពិធីអ្វីផ្សេងៗឬគ្រោះមហន្តរាយ។*

*សម្រាប់សាលាបឋមសិក្សាបញ្ជី១សន្លឹកប្រើបានសម្រាប់មួយថ្នាក់។ សម្រាប់សាលាមធ្យមសិក្សាបញ្ជី១សន្លឹកប្រើបានតែ១មុខវិជ្ជានៃមួយថ្នាក់។*

**អវត្តមានគ្រូបង្រៀនឆ្នាំសិក្សា២០១....-២០១....**

សាលាមត្តេយ្យសិក្សានិងសាលាបឋមសិក្សាអាចប្រើក្រដាសតែមួយសម្រាប់សាលារៀនទាំងមូល។ សាលាមធ្យមសិក្សាត្រូវប្រើក្រដាសមួយសម្រាប់ថ្នាក់មួយ។ ក្រដាសមួយអាចប្រើសម្រាប់រយៈពេលមួយខែ ឬមួយត្រីមាស ឬមួយឆមាស ឬមួយឆ្នាំ អាស្រ័យលើ ស្ថានភាពអវត្តមាន។

| លរ | ឈ្មោះគ្រូបង្រៀន | ថ្ងៃអវត្តមាន | | ថ្ងៃអវត្តមាន | | ថ្ងៃអវត្តមាន | | ថ្ងៃអវត្តមាន | | ថ្ងៃអវត្តមាន | | ថ្ងៃអវត្តមាន | | សរុបអវត្តមាន |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | មាន | គ្មាន | មាន | គ្មាន | មាន | គ្មាន | មាន | គ្មាន | មាន | គ្មាន | មាន | គ្មាន | |
| 1 | | | ៩/២ | | | | | | | | | | | |
| 2 | | | | | | | | | | | | | | |
| 3 | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| Total | | | | | | | | | | | | | | |

**សម្គាល់៖**

ក. ប្រសិនបើមិនមានអវត្តមានមានន័យថាមិនចាំបាច់កត់ត្រាអ្វីទេ

ខ. មាន៖ មានន័យថា មានគ្រូជំនួស ហើយ គ្មាន៖ មានន័យថា មិនមានគ្រូជំនួស

គ. កត់ត្រាថ្ងៃខែនៅក្នុងកូឡោនមាន ឬ គ្មាន។ មើលឧទាហរណ៍ខាងលើដែលបង្ហាញពីថ្ងៃ និងខែ ៩/២ មានន័យថា ថ្ងៃទី៩ ខែកុម្ភៈ។

ឃ. ក្នុងករណីសាលាធំ ក្រដាសមួយសន្លឹកអាចប្រើសម្រាប់មួយថ្នាក់ បើសាលាមធ្យមក្រដាសមួយសន្លឹកអាចប្រើសម្រាប់កម្រិតថ្នាក់មួយ ប្រសិនបើសាលារៀនតូច ក្រដាសមួយអាចប្រើសម្រាប់មួយសាលាតែម្តង។

*ការពិនិត្យឡើងវិញ*

ក្នុងករណីសាលារៀនមានបញ្ហាអវត្តមានធ្ងន់ធ្ងរ ការប្រជុំប្រចាំខែត្រូវបានរៀបចំឡើងដើម្បីដោះស្រាយបញ្ហា។

*ពិនិត្យឡើងវិញប្រចាំត្រីមាស៖ ផែនការថ្នាក់រៀននិងការគ្រប់គ្រងសាលារៀនលម្អិតប្រចាំត្រីមាស សូចនាករផលសម្រេច និងកាតរបាយការណ៍សូចនាករសំខាន់ៗរបស់សាលារៀន*

ការពិនិត្យឡើងវិញផែនការថ្នាក់រៀន និងការគ្រប់គ្រងសាលារៀនលម្អិតប្រចាំត្រីមាសមានបំណងធានាថាក្រុមគោលដៅនៃគ្រប់សូចនាករប្រចាំត្រីមាសត្រូវបានសម្រេច។ រួមជាមួយនឹងការពិនិត្យឡើងវិញលើការ រីកចម្រើនក្រុមគោលដៅនៃសូចនាករផលសម្រេចសាលារៀននេះ មានបំណងធានាថាពិន្ទុសិស្សគ្រប់មុខវិជ្ជា ប្រចាំខែ មានភាពរីកចម្រើនឆ្ពោះទៅរកភាពជោគជ័យនៃក្រុមគោលដៅគ្រោងនៅក្នុងសូចនាករផលសម្រេច ទាំងអស់ប្រចាំត្រីមាស និងឆ្នាំនៃស្តង់ដាទី១ ស្តីពីវត្តុបំណងគោលនយោបាយសាលារៀន។ ប្រសិនបើ ភាពរីកចម្រើននៃពិន្ទុតេស្តសិស្ស អាចនឹងមិនឈានទៅរកការសម្រេចបាននូវក្រុមគោលដៅគ្រោងប្រចាំត្រីមាសទេនោះ មាតាបិតាសិស្ស និងគ្រូបង្រៀនត្រូវប្រជុំពិភាក្សាជាមួយនាយកសាលារៀនដើម្បីស្វែងរកបញ្ហា និងកំណត់នូវសកម្មភាពជាដំណោះស្រាយ និងអ្នកអនុវត្តសកម្មភាពនីមួយៗ។

ការពិនិត្យឡើងវិញកាតរបាយការណ៍ពីសូចនាករសំខាន់ៗរបស់សាលារៀននេះ មានបំណងធានាថាធាតុចូលត្រូវបានផ្តល់ឱ្យដោយថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ និងសូចនាករសំខាន់ៗចំនួនបី (ល្បឿនអំណាន គណិតវិទ្យា និងវិទ្យាសាស្ត្រ) អាចសម្រេចនូវក្រុមគោលដៅគ្រោង។ ប្រសិនបើក្រុមគោលដៅមិនបានសម្រេច នោះត្រូវមានការប្រជុំពិភាក្សាឬត់ចត់រវាងនាយកសាលា គណៈកម្មការគ្រប់គ្រងសាលារៀន និងថ្នាក់ក្រោម ជាតិនិងថ្នាក់ជាតិដើម្បីស្វែងរកបញ្ហា និងកំណត់សកម្មភាពដោះស្រាយ និងធ្វើដោយអ្នកណា និងពេលណា។

**ប្រតិទិនប្រជុំ៖**

១. នាយកសាលាឬប្រធានគណៈកម្មការគ្រប់គ្រងសាលារៀនបញ្ជាក់ពីវត្ថុបំណងនៃការប្រជុំដូចបានរៀបរាប់ខាងលើ

២. នាយកសាលាបង្ហាញពីតារាងទិន្នន័យ និងព័ត៌មានដែលបានកត់ត្រាអំពី៖ ១). ការរីកចម្រើនសូចនាករផលសម្រេច និង ២). កាតរបាយការណ៍សូចនាករសំខាន់ៗរបស់សាលារៀន។ តំណាងមាតាបិតាបង្ហាញពីទិន្នន័យពីការតាមដានសាលារៀននិងថ្នាក់រៀន

៣. ពិភាក្សា និងកំណត់សកម្មភាព និងអ្នកណាត្រូវធ្វើសកម្មភាពអ្វី និងនៅពេលណា។

*ពិនិត្យឡើងវិញប្រចាំឆ្នាំលើសូចនាករផលសម្រេច កាតរបាយការណ៍សូចនាករសំខាន់ៗរបស់សាលារៀន និង ថវិកាសាលារៀន និងការចំណាយ*

ការពិនិត្យឡើងវិញនេះជាផ្នែកនៃការវាយតម្លៃការអនុវត្តសាលារៀនប្រចាំឆ្នាំ និងការធ្វើផែនការកែលម្អសាលារៀន និងគ្រោងថវិកាប្រចាំឆ្នាំ។ វត្ថុបំណងនៃការវាយតម្លៃគឺដើម្បីវាយតម្លៃការរីកចម្រើនការអនុវត្តធៀបជាមួយក្រុមគោលដៅនៃស្តង់ដានិងសូចនាករនីមួយៗ និងប្រើលទ្ធផលនៃការវាយតម្លៃជូនព័ត៌មានដល់ការធ្វើ ផែនការកែលម្អសាលារៀននិងគ្រោងថវិកានៅឆ្នាំបន្ទាប់។

ជាការសំខាន់ដែលត្រូវសម្គាល់ថា ប្រសិនបើកម្រិតណាមួយនៃប្រព័ន្ធ ឬមន្ត្រីណាបរាជ័យក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួន ដើម្បីជួយសាលារៀនឱ្យមានស្តង់ដាទេនោះ ម្នាក់ៗនឹងដឹងច្បាស់ថា អ្នកណាមិនមានគណនេយ្យភាព និងអ្នកណាមានគណនេយ្យភាព។ តួនាទីរបស់ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិគឺធានានូវការផលិតនិងផ្តល់ធាតុចូលទាំងអស់ទាន់ពេលដល់សាលារៀន និងជួយកសាងសមត្ថភាពដល់សាលារៀន និងគ្រូបង្រៀនឱ្យគេអាចបំពេញកិច្ចការរបស់គេបាន។ គណៈកម្មការគ្រប់គ្រងសាលារៀន នាយកសាលារៀន គ្រូបង្រៀន សិស្ស និងមាតាបិតានឹងបង្កើនការទទួលខុសត្រូវ ឬគណនេយ្យភាពរបស់គេនៅពេលណាគេសង្កេតឃើញចរិយាជាគំរូពីមន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ប្រតិទិនប្រជុំគឺដូចគ្នានឹងខ្លឹមសារខាងលើស្តីពីការធ្វើផែនការកែលម្អសាលារៀន និងគ្រោងថវិកា។

## ២.៥ ការវាយតម្លៃសាលារៀន និងការវាយតម្លៃសិស្ស

### ២.៥.១ ប្រភេទ និងការវាយតម្លៃការអនុវត្តសាលារៀន

ការវាយតម្លៃសាលារៀនមានពីរប្រភេទគឺ ការវាយតម្លៃនៅចុងឆមាសទី១ និងការវាយតម្លៃនៅចុងឆ្នាំ។ ការវាយតម្លៃនៅចុងឆមាសទី១ មានគោលបំណងពិនិត្យការរីកចម្រើននៃក្រុមគោលដៅសូចនាករនៃស្តង់ដា ទី២ ដល់ ទី៩។ គោលបំណងនៃការវាយតម្លៃចុងឆ្នាំគឺពិនិត្យឡើងវិញការរីកចម្រើនសូចនាករនៃស្តង់ដាទាំង៩ និងដាក់ពិន្ទុស្តង់ដាសាលារៀនមានប្រសិទ្ធភាព។

ឧបករណ៍វាយតម្លៃការអនុវត្តសាលារៀន មាននៅក្នុងជំពូកពីការធ្វើផែនការ និងការគ្រោងថវិកាសាលារៀន។ ពិន្ទុទទួលបានត្រូវមានយ៉ាងតិច ចំនួន៦៥%សម្រាប់ស្តង់ដានីមួយៗ និងសម្រាប់សាលារៀនទាំងមូលដើម្បីទទួលបាន នូវការសម្រេចស្តង់ដាអប្បបរមា នៃស្តង់ដាសាលារៀនមានប្រសិទ្ធភាព។ ពិន្ទុស្តង់ដា មួយមិនអាចយកទៅជំនួសឱ្យ ស្តង់ដាមួយផ្សេងទៀតឡើយ។ នេះមានន័យថាប្រសិន បើស្តង់ដាមួយមាន ពិន្ទុទាបជាង៦៥%នោះ ស្តង់ដានេះមិនមានពិន្ទុស្តង់ដាអប្បបរមាបានទេ ហើយសាលារៀននេះក៏មិនអាចរាប់ ថាមានស្តង់ដាអប្បបរមាបានដែរ។ សម្រាប់រយៈពេលមធ្យមទៅរយៈពេលវែង សាលារៀនដែល

មានស្តង់ដាអប្បបរមា អាចត្រូវបានចាត់ទុកថាជាសាលារៀន មានសមត្ថភាពអាចទទួលយកកញ្ចប់ថវិកាពិសេសសម្រាប់ធ្វើឱ្យប្រសើរ នូវសាលារៀនរបស់ខ្លួន និងទៅជួយសាលារៀនផ្សេងទៀត ឱ្យមានស្តង់ដាអប្បបរមាដូចខ្លួនដែរ។

របៀបធ្វើការវាយតម្លៃការអនុវត្តសាលារៀន៖

## ១ ការរៀបចំសម្រាប់ធ្វើការវាយតម្លៃ

ភាពជោគជ័យនៃការវាយតម្លៃ គឺផ្អែកលើសំណួរវាយតម្លៃ គុណភាពទិន្នន័យ និងព័ត៌មានគុណភាពនៃការវាយតម្លៃនិងរបាយការណ៍ និងការចូលរួមរបស់អ្នកពាក់ព័ន្ធ។

តារាងបញ្ជាក់ពីទំនាក់ទំនង នៃការពិនិត្យឡើងវិញប្រចាំត្រីមាស ការវាយតម្លៃចុងឆមាស និងការវាយតម្លៃ ចុងឆ្នាំ

| ឧបករណ៍វាយតម្លៃ | ពិនិត្យឡើងវិញត្រីមាស | វាយតម្លៃឆមាស | វាយតម្លៃឆ្នាំ |
|---|---|---|---|
| ការរីកចម្រើនក្រុមគោលដៅនៃឧបករណ៍សាលារៀនមានប្រសិទ្ធភាពបានគ្រោង | បាទ/ចាស | បាទ/ចាស | ទេ |
| ផែនការកែលម្អសាលារៀននិងថវិកាប្រចាំឆ្នាំ | ទេ | បាទ/ចាស | បាទ/ចាស |
| របាយការណ៍វាយម្លៃការអនុវត្តសាលារៀននៅឆ្នាំមុន | ទេ | ទេ | បាទ/ចាស |
| ការសម្រេចបាននូវផលសម្រេចនិងក្រុមគោលដៅ៣ឆ្នាំ | ទេ | ទេ | បាទ/ចាស |
| កាតរបាយការណ៍ប្រៀបធៀបសូចនាករសាលារៀនសំខាន់ៗ | ទេ | ទេ | បាទ/ចាស |

### *សម្រាប់ការពិនិត្យឡើងវិញចុងត្រីមាស*

ក. តើក្រុមគោលដៅនៃសូចនាករនីមួយៗសម្រាប់ត្រីមាសនេះបានសម្រេចឬទេ?

ខ. ប្រសិនបើមានក្រុមគោលដៅនៃសូចនាករណាមួយមិនបានសម្រេច តើបណ្តាលមកពីមានឧបសគ្គ អ្វី (ស្តង់ដាទី២ដល់ទី៩អំពី ការផ្តល់ធាតុចូល ការប្រើប្រាស់ធាតុចូល។ល។)? តើមកពីហេតុអ្វីបានជា មានឧបសគ្គទាំងនេះ (សមត្ថភាព យន្តការគាំទ្រ ធនធានផ្តល់ឱ្យ ស្វ័យភាព ឬមិនមាន គណនេយ្យភាព)?

គ. តើត្រូវធ្វើសកម្មភាពអ្វីដើម្បីដោះស្រាយឧបសគ្គទាំងនេះ? អ្នកណាជាអ្នកធ្វើសកម្មភាពអ្វី? និងធ្វើនៅពេលណា?

*សម្រាប់ការវាយតម្លៃចុងឆមាសទី១*

សំណួរធំៗចំនួន៤ត្រូវប្រើ តែមិនកម្រិតកំណត់តែចំនួនប៉ុណ្ណឹងទេះ

ក. តើសកម្មភាពគ្រោងទាំងអស់បានអនុវត្តឬទេ?

ខ. តើក្រោមគោលដៅគ្រោងទាំងអស់បានសម្រេចឬទេ (ស្តង់ដាទី២ដល់ទី៩) ?

គ. ប្រសិនបើមិនបានសម្រេច (ជាសកម្មភាព ឬ ក្រុមគោលដៅ) តើបណ្តាលមកពីមានឧបសគ្គអ្វី (ស្តង់ដាទី២ដល់ទី៩អំពី ការផ្តល់ធាតុចូល ការប្រើប្រាស់ធាតុចូល ។ល។)? តើមកពីហេតុអ្វីបាន ជាមានឧបសគ្គទាំងនេះ (សមត្ថភាព យន្តការគាំទ្រ ធនធានផ្តល់ឱ្យ ស្វ័យភាព ឬ មិនមាន គណនេយ្យភាព)?

ឃ. តើត្រូវធ្វើសកម្មភាពអ្វីដើម្បីដោះស្រាយឧបសគ្គទាំងនេះ? អ្នកណាជាអ្នកធ្វើសកម្មភាពអ្វី? និងធ្វើនៅពេលណា?

*សម្រាប់ការវាយតម្លៃដំណាច់ឆ្នាំ*

ក. តើសកម្មភាពគ្រោងទាំងអស់បានអនុវត្តឬទេ?

ខ. តើក្រុមគោលដៅគ្រោងទាំងអស់បានសម្រេចឬទេ (ស្តង់ដាទី២ដល់ទី៩) ?

គ. តើក្រុមគោលដៅនៃសូចនាករស្តង់ដាទី១បានសម្រេចឬទេ?

ឃ. ប្រសិនបើមិនបានសម្រេច (ជាសកម្មភាព ឬ ក្រុមគោលដៅ) តើបណ្តាលមកពីមានឧបសគ្គអ្វី (ស្តង់ដាទី២ដល់ទី៩អំពី ការផ្តល់ធាតុចូល ការប្រើប្រាស់ធាតុចូល ។ល។?) តើមកពីហេតុអ្វីបានជាមានឧបសគ្គទាំងនេះ (សមត្ថភាព យន្តការគាំទ្រ ធនធានផ្តល់ឱ្យ ស្វ័យភាព ឬមិនមាន គណនេយ្យភាព)?

ង. តើត្រូវធ្វើសកម្មភាពអ្វីដើម្បីដោះស្រាយឧបសគ្គទាំងនេះ? អ្នកណាជាអ្នកធ្វើសកម្មភាពអ្វី? និងធ្វើនៅពេលណាសម្រាប់ឆ្នាំក្រោយ?

នាយកសាលាធានាថាមានការរៀបចំដូចខាងក្រោមះ

- គ្រប់ទិន្នន័យ និង ឯកសារពាក់ព័ន្ធត្រូវបានចងក្រងទុកមុនការប្រជុំពិនិត្យឡើងវិញ ឬវាយតម្លៃ
- គ្រប់អ្នកពាក់ព័ន្ធបានអញ្ជើញចូលរួមប្រជុំ។ ការប្រជុំត្រីមាសទី១គឺត្រូវធ្វើនៅក្នុងអំឡុងខែកុម្ភៈ ឬមីនា ចុងឆមាសទី១នៅអំឡុងខែមេសាឬឧសភា ហើយការវាយតម្លៃចុងឆ្នាំត្រូវធ្វើនៅក្នុងអំឡុងខែកញ្ញា ឬ តុលា។ អ្នកពាក់ព័ន្ធមានៈ នាយកសាលា គ្រូបង្រៀន មាតាបិតា សិស្ស និងមាតាបិតា

ឬសិស្សដែលចូលរួមក្នុង ការអប់រំពីការពិនិត្យតាមដានសាលារៀននិងថ្នាក់រៀន និងមន្ត្រីអប់រំក្រុង ស្រុក ខណ្ឌ។

- សម្រាប់ការពិនិត្យឡើងវិញប្រចាំត្រីមាស បង្ហាញតែការរីកចម្រើន ផែនការថ្នាក់រៀន និងការគ្រប់គ្រងសាលារៀន (លម្អិតនៃស្តង់ដាទី២ ដល់ ទី៩)។ សម្រាប់ការវាយតម្លៃចុងឆមាសទី១ ត្រូវរៀបចំការ បង្ហាញចំនួន ៣មាន៖ ការរីកចម្រើនការអនុវត្តផែនការកែលម្អសាលារៀន និងថវិកាប្រចាំឆ្នាំ ការរីកចម្រើនផែនការថ្នាក់រៀននិងការគ្រប់គ្រងសាលារៀន (លម្អិតនៃស្តង់ដាទី២ ដល់ ទី៥) និងការរីកចម្រើនផែនការថ្នាក់រៀននិងការគ្រប់គ្រងសាលារៀន (លម្អិតនៃ ស្តង់ដាទី៦ ដល់ ទី៩)។
- សម្រាប់ការវាយតម្លៃដំណាច់ឆ្នាំ ត្រូវរៀបចំការបង្ហាញចំនួន៥មាន៖ ការបង្ហាញទាំង៣ខាងលើដូចគ្នានឹង ការវាយតម្លៃឆមាស និង ការបង្ហាញពីការរីកចម្រើនផលសម្រេចនិងសូចនាករ៣ឆ្នាំ កាតរបាយការណ៍ ប្រៀបធៀបសូចនាករសំខាន់ៗ និងការរីកចម្រើននៃស្តង់ដាសាលារៀនមានប្រសិទ្ធភាពដោយធៀបនឹងឆ្នាំមុន។

នាយកសាលាត្រូវរៀបចំការប្រជុំទាំងអស់ខាងលើជាមួយគណៈកម្មការគ្រប់គ្រងសាលារៀន ដើម្បីបង្ហាញនូវលទ្ធផលនៃការវាយតម្លៃប្រចាំត្រីមាស ឆមាស និងឆ្នាំ ពិភាក្សាបញ្ហា និងស្នើសុំការឯកភាព ឬអនុម័តពីគណៈកម្មការគ្រប់គ្រងសាលារៀន។

## ២ ការវាយតម្លៃការអនុវត្តការងារសាលារៀន

របៀបប្រជុំវាយតម្លៃគឺមាននៅក្នុងប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃរបស់អនុវិស័យរួចហើយ។ ខាងក្រោមនេះជាកម្មវិធីប្រជុំរវាងនាយកសាលានិងគណៈកម្មការគ្រប់គ្រងសាលារៀន។

ការប្រជុំ៖ ការវាយតម្លៃប្រចាំត្រីមាស ឆមាស ឬ ឆ្នាំ

វត្ថុបំណង៖ ដូចមានចែងនៅខាងលើ

ថ្ងៃ ខែ ឆ្នាំ៖…………………………………………………………………………………………………

ទីកន្លែង៖…………………………………………………………………………………………………..

កម្មវិធីប្រជុំ៖………………………………………………………………………………………………

| ម៉ោង | ប្រធានបទពិភាក្សា | អ្នកទទួលខុសត្រូវ |
|---|---|---|
| **កម្មវិធីប្រជុំត្រីមាស** | | |
| **7:00** | អ្នកចូលរួមមកដល់ | មន្ត្រីរដ្ឋបាល |
| **7:30-** | ជំរាបជូនពីកម្មវិធីប្រជុំ | មន្ត្រីរដ្ឋបាល |

| | | |
|---|---|---|
| **7:35** | បញ្ជាក់ពីគោលបំណងប្រជុំ | ប្រធានគគស |
| **7:40** | បង្ហាញពីការរីកចម្រើនស្តង់ដាទី២ដល់ទី៥ | នាយកសាលា |
| **8:40** | បង្ហាញពីការរីកចម្រើនស្តង់ដាទី៦ដល់ទី៩ | នាយកសាលា |
| **9:40** | សម្រាក | |
| **10:00** | ពិភាក្សាដោយប្រើសំណួរខាងលើ | ប្រធានគគស |
| **11:00** | បូកសរុបនិងបិទអង្គប្រជុំ | ប្រធានគគស |
| **ការវាយតម្លៃចុងឆមាសទី១** | | |
| **7:00-730am** | អ្នកចូលរួមមកដល់ | មន្ត្រីរដ្ឋបាល |
| **7:30am** | ជំរាបជូនពីកម្មវិធីប្រជុំ | មន្ត្រីរដ្ឋបាល |
| **7:35am** | បញ្ជាក់ពីគោលបំណងប្រជុំ | ប្រធានគគស |
| **7:45am** | បង្ហាញពីការរីកចំរើនការអនុវត្តផែនការកែលម្អសាលារៀន និងថវិកាប្រចាំឆ្នាំ | នាយកសាលា |
| **8:15am** | បង្ហាញពីការរីកចម្រើនស្តង់ដាទី២ដល់ទី៥ | នាយកឬនាយករង<br>បច្ចេកទេស |
| **9:00am** | សម្រាក | |
| **9:20am** | បង្ហាញពីការរីកចម្រើនស្តង់ដាទី៦ដល់ទី៩ | នាយកឬនាយករងរដ្ឋបាល |
| **10:00am** | ពិភាក្សាដោយប្រើបញ្ជីសំណួរខាងលើ | ប្រធានគគស |
| **11:00am** | សម្រាក | |
| **14:00pm** | បន្តពិភាក្សា | ប្រធានគគស |
| **15:00pm** | បូកសរុបលទ្ធផលប្រជុំ និងបិទអង្គប្រជុំ | |
| **កម្មវិធីបន្ថែមសម្រាប់ការវាយតម្លៃចុងឆ្នាំសិក្សា** | | |
| **7:00** | អ្នកចូលរួមមកដល់ | មន្ត្រីរដ្ឋបាល |
| **7:30** | ជំរាបជូនពីកម្មវិធីប្រជុំ | មន្ត្រីរដ្ឋបាល |
| **7:35** | បញ្ជាក់ពីគោលបំណងប្រជុំ | ប្រធានគគស |
| **7:40** | ការបង្ហាញពីការរីកចម្រើនផលសម្រេចនិងក្រុមគោលដៅ និងកាតរបាយការណ៍ប្រៀបធៀបសូចនាករសំខាន់ៗរបស់សាលារៀន | នាយកសាលា |
| **8:40** | ការបង្ហាញពីរបាយការណ៍វាយតម្លៃការអនុវត្តសាលារៀន | នាយកសាលា |
| **9:40** | សម្រាក | |
| **10:00** | ពិភាក្សា | ប្រធានគគស |
| **11:00** | បូកសរុបលទ្ធផល និងការសម្រេចឯកភាពឬអនុម័តលើរបាយការណ៍ | ប្រធានគគស |

**បញ្ជីសមាជិកអង្គប្រជុំ**

| ល.រ | ឈ្មោះ | តួនាទី | ហត្ថលេខា |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |

## ៣ របាយការណ៍ពីលទ្ធផលនៃការវាយតម្លៃ

ខាងក្រោមនេះជាប្រភេទរបាយការណ៍៖

១. របាយការណ៍រីកចម្រើនត្រីមាសប្រៀបធៀបផែនការថ្នាក់រៀន និងការគ្រប់គ្រងសាលារៀនលម្អិត (ឧបករណ៍វាយតម្លៃប្រសិទ្ធភាពសាលារៀន)

២. របាយការណ៍រីកចម្រើនធៀបនឹងផែនការកែលម្អសាលារៀននិងថវិកាប្រចាំឆ្នាំ

៣.របាយការណ៍រីកចម្រើនពីការវាយតម្លៃការអនុវត្តការងាររបស់សាលារៀន និង

៤. របាយការណ៍ពីការរីកចម្រើនផលសម្រេច និងក្រុមគោលដៅសូចនាករផលសម្រេច

៥. កាតរបាយការណ៍ប្រៀបធៀបសូចនាករសំខាន់ឆ្នាំសិក្សា២០១៧-២០១៨

១. របាយការណ៍រីកចម្រើនត្រីមាសប្រៀបធៀបផែនការថ្នាក់រៀននិងការគ្រប់គ្រងសាលារៀនលម្អិត (ឧបករណ៍វាយតម្លៃប្រសិទ្ធភាពសាលារៀន) គឺមាននៅក្នុងប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃអនុវិស័យរួច ហើយ។ ឧបករណ៍មានកូឡេទ្បានអំពីក្រុមគោលដៅគ្រោង និងការរាយការណ៍ពីការសម្រេចបានក្រុមគោលដៅ ហើយ។

២. របាយការណ៍រីកចម្រើនធៀបនឹងផែនការកែលម្អសាលារៀននិងថវិកាប្រចាំឆ្នាំ

| ស្តង់ដានិងសូចនាករ | សកម្មភាពគ្រោង | ការរីកចម្រើនចុងឆមាសទី១ | ការរីកចម្រើនចុងឆមាសទី២ | ឧបសគ្គ |
|---|---|---|---|---|
| ស្តង់ដាទី២ ការបង្រៀននិងរៀន | | | | |
| | | | | |
| | | | | |
| ស្តង់ដាទី៣ មាតាបិតា និងសហគមន៍ជួយការសិក្សារបស់សិស្ស | | | | |
| | | | | |
| | | | | |
| ស្តង់ដាទី៤ សិស្ស និងសេវាជួយសិស្ស | | | | |
| | | | | |
| | | | | |
| ស្តង់ដាទី៥ ការដឹកនាំ និងការគ្រប់គ្រង | | | | |
| | | | | |
| | | | | |
| ស្តង់ដាទី៦ ធនធានមនុស្ស | | | | |
| | | | | |
| | | | | |
| ស្តង់ដាទី៧ សៀវភៅសិក្សា សម្ភារៈបង្រៀន និងរៀន | | | | |
| | | | | |
| | | | | |
| ស្តង់ដាទី៨ ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន | | | | |
| | | | | |
| | | | | |
| ស្តង់ដាទី៩ ការគ្រោងថវិកា និងការគ្រប់គ្រងហិរញ្ញវត្ថុ | | | | |
| | | | | |
| | | | | |

## ៣. របាយការណ៍រីកចម្រើនពីការវាយតម្លៃការអនុវត្តការងាររបស់សាលារៀន

## ឧបសម្ព័ន្ធ: ឧបករណ៍វាយតម្លៃការអនុវត្តសាលារៀនផ្អែកតាមស្តង់ដាសាលារៀនមានប្រសិទ្ធភាព

## ៤. របាយការណ៍ពីការរីកចម្រើនផលសម្រេចនិងក្រុមគោលដៅសូចនាករផលសម្រេច

### សូចនាករផលសម្រេច និងក្រុមគោលដៅរយៈពេល៣ឆ្នាំ ឆ្នាំសិក្សា២០១៧-២០១៨

| សូចនាករផលសម្រេច | ក្រុមគោលដៅគ្រោងឆ្នាំសិក្សា ២០១៧-២០១៨ | សម្រេចជាក់ស្តែងឆ្នាំសិក្សា ២០១៧-២០១៨ |
|---|---|---|
| ១. ការចូលរៀន | | |
| ចំនួនសិស្សបានចូលរៀន | | |
| ចំនួនសិស្សត្រួតថ្នាក់ | | |
| ចំនួនសិស្សឡើងថ្នាក់ | | |
| ២. ចំនួនសិស្សមានពិន្ទុតេស្តលើ៦០%នៃមុខវិជ្ជាគោល | | |
| ភាសាខ្មែរ | | |
| គណិតវិទ្យា | | |
| ភាសាបរទេស | | |
| ៣. ចំនួនសិស្សមានពិន្ទុតេស្តលើ៦០%នៃមុខវិជ្ជាវិទ្យាសាស្ត្រ | | |
| រូបវិទ្យា | | |
| គីមីវិទ្យា | | |
| ជីវវិទ្យា | | |
| ផែនដីវិទ្យា | | |
| ព័ត៌មាន ទំនាក់ទំនង និងបច្ចេកវិទ្យា | | |
| ៤. ចំនួនសិស្សថ្នាក់ទី៩អានភាសាខ្មែរបានច្រើនជាង ២០០ ពាក្យក្នុងមួយនាទី | | |
| ៥. ចំនួនសិស្សថ្នាក់ទី៩ប្រឡងជាប់ការប្រឡងថ្នាក់ជាតិ | | |

## ៥ កាតរបាយការណ៍ប្រៀបធៀបសូចនាករសំខាន់ឆ្នាំសិក្សា ២០១...-២០១...

| **ព័ត៌មានសាលារៀន** | | | | |
|---|---|---|---|---|
| ឈ្មោះ | កម្រិត | ថ្នាក់ទី.........<br>ដល់<br>ថ្នាក់ទី......... | លេខកូដ | |
| **ឃុំ-សង្កាត់៖** | **រាជធានី-ខេត្ត** | | **លេខទូរស័ព្ទ** | |
| **ព័ត៌មានសិស្ស** | | | | |
| សរុបចំនួនសិស្ស៖ | សរុបចំនួនគ្រូបង្រៀន | | សរុបចំនួនមន្ត្រី | |
| សរុបចំនួនថ្នាក់រៀន៖ | ចំនួនម៉ោងបង្រៀនមួយអាទិត្យ | | បង្រៀនពេលថ្ងៃ (បាទឬទេ) | |
| **សូចនាករសំខាន់ៗ** | **សាលាខ្ញុំ** | **ស្រុកខ្ញុំ** | **រាជធានី-ខេត្តខ្ញុំ** | **ប្រទេសខ្ញុំ** |
| ១. ផលធៀបសិស្ស-គ្រូ<br>(បទដ្ឋាន៖ ....................) | | | | |
| ២. ផលធៀបសិស្ស-ថ្នាក់<br>(បទដ្ឋាន៖....................) | | | | |
| ៣. ផលធៀបសិស្ស/សៀវភៅសិក្សាគោល<br>(បទដ្ឋាន:....................) | | | | |
| ៤. បរិមាណថវិកាសម្រាប់សិស្សម្នាក់ | | | | |
| ៥. ចំនួនម៉ោងបង្រៀនជាមធ្យម<br>(បទដ្ឋាន:....................) | | | | |
| ៦. ភាគរយសិស្សថ្នាក់ទី៣ ទី៦ ទី៩ អានមានល្បឿនតាមស្តង់ដា (៤៥-៦០ ១០០-១២០ និង២០០ពាក្យក្នុង១នាទី) | | | | |
| ៧. ភាគរយសិស្សថ្នាក់ទី៣ ទី៦ និងទី៩ មានពិន្ទុតេស្តច្រើនជាង៦០% | | | | |
| ៨. ចំនួនសិស្សបោះបង់ការសិក្សា | | | | |

## ២.៥. ២ ការប្រើប្រាស់លទ្ធផលវាយតម្លៃធ្វើឱ្យប្រសើរការអនុវត្តសាលារៀន

លទ្ធផលបានពីការវាយតម្លៃត្រីមាស និងឆមាសនឹងត្រូវយកទៅប្រើប្រាស់សម្រាប់កែតម្រូវការអនុវត្តនៅត្រីមាស និងឆមាសក្រោយ រីឯលទ្ធផលបានពីការវាយតម្លៃនៅចុងឆ្នាំសិក្សានឹងត្រូវយកទៅប្រើសម្រាប់កសាងផែនការឆ្នាំសិក្សាបន្ទាប់។

ការវាយតម្លៃត្រីមាស និងឆមាសនឹងធៀបទិន្នន័យពីការរីកចម្រើនជាមួយនឹងក្រុមគោលដៅនីមួយៗ ប្រសិនបើការរីកចម្រើនទាបជាងក្រុមគោលដៅ នោះត្រូវធ្វើការតម្រូវផែនការដោយស្វែងរកបញ្ហា (ការលំបាកនិងឧបសគ្គ) និងសកម្មភាពដែលត្រូវធ្វើ ដោយអ្នកណា និងនៅពេលណា។ ការកែតម្រូវក្នុងឆ្នាំមាន: ក) បន្ថែមសកម្មភាពចាំបាច់ដើម្បីសម្រេចក្រុមគោលដៅ ខ) កែតម្រូវសកម្មភាពគ្រោងពីរបៀបអនុវត្តសកម្មភាព គ) កែតម្រូវថវិកាគ្រោងពីសកម្មភាពមួយទៅសកម្មភាពមួយ ។ ការកែតម្រូវមិនចាំបាច់សុំការអនុញ្ញាតិពីថ្នាក់លើទេ និង ឃ) ស្នើទៅថ្នាក់ជាតិនិងក្រោមជាតិនូវការប្រឹងប្រែង និងគាំទ្រនូវអ្វីដែលបានប្តេជ្ញាចិត្ត (ការផ្តល់ធាតុចូលឬការកសាងសមត្ថភាព) ឬសកម្មភាពថ្មី។

លទ្ធផលពីការវាយតម្លៃចុងឆ្នាំសិក្សានឹងត្រូវយកទៅប្រើសម្រាប់ធ្វើផែនការឆ្នាំក្រោយ និងផ្សព្វផ្សាយជាសាធារណ:នូវទិន្នន័យ និងព័ត៌មានដូចមានចែងនៅក្នុងជំពូកពីតួនាទីសហគមន៍ និងអភិបាលកិច្ចសាលារៀន។

### ២.៥.៣ ការវាយតម្លៃសិស្ស និងពេលវេលាវាយតម្លៃ

ការវាយតម្លៃការសិក្សារបស់សិស្សមានបីប្រភេទ៖

#### ១ ដំណើរនៃការបង្រៀនមេរៀននីមួយៗ

ជាទូទៅពេលបង្រៀនមេរៀននីមួយៗគឺមានជំហានបី ដូចជា ក) ការបង្ហាញពីគោលគំនិត ខ) ការយល់ពីគោលគំនិត (ការងារសិស្សជាក្រុម ពី៥ទៅ៦នាក់) និងគ) ការអនុវត្តគោលគំនិត (ការងារសិស្សជាដៃគូ២នាក់) សូមមើលរូបខាងក្រោម។

**ឧទាហរណ៍ពីក្រុងសៀងហៃ៖**

**នៅក្នុងប្រអប់ខ្មៅនៃប្រព័ន្ធសាលារៀនសៀងហៃ ពីទស្សន:កិច្ចសិក្សា**

មានសញ្ញាជាក់ច្បាស់ពីប្រសិទ្ធភាពនៃការបង្រៀន និងរៀន៖

- ឧទាហរណ៍ នៅក្នុងការបង្រៀនមេរៀនគណិតវិទ្យានៅសាលារៀនមួយ គ្រូបង្រៀនបានបង្រៀនដោយមានភាពស៊ីជម្រៅលើគោលគំនិតនៃមេរៀនអំពីពីរ៉ាមីត ដោយប្រើជំហានបន្តបន្ទាប់ដើម្បីសាងសង់នូវគ្រឹះយល់ដឹងពីគោលគំនិត និងបន្ទាប់មកប្រើបច្ចេកទេសទំនើបក្នុងការប្រើរូបពីរ៉ាមីតខុសៗគ្នា និងសរុបយោបល់រួមចុងក្រោយ។
- មេរៀនមានការចូលរួម និងការប្រាស្រ័យទាក់ទងខ្ពស់ពីសិស្ស ហើយគ្រូប្រើវិធីបង្រៀនច្រើនបែបដោយរលូនពីការបង្រៀន អោយសិស្សធ្វើការជាក្រុម និងជាដៃគូ។ មិនមានពេលណាបន្តិចដែលខាតបង់ឡើយ។
- គ្រូប្រើវិធីផ្សេងៗ ដូចជាបង្ហាញលើក្តារខៀននូវចម្លើយសិស្សបានធ្វើជាក្រុម និងជាដៃគូដល់សិស្សទាំងអស់ក្នុងថ្នាក់។ មេរៀន ដែលមានការផ្សាភ្ជាប់គ្នារវាងខ្លឹមសារ ការប្រាស្រ័យទាក់ទង និងការអនុវត្តការបង្រៀន និងរៀន ដោយមានជំនួយពីបច្ចេកវិទ្យាព័ត៌មាន បានផ្តល់នូវពិសោធន៍មួយនៅក្នុងការសម្រេចផលសិក្សារបស់សិស្សនៅក្រុងសៀងហៃ។

### ២ ការធ្វើតេស្តនៅចុងខែនីមួយៗ

តេស្តត្រូវបានធ្វើសម្រាប់គ្រប់មុខវិជ្ជានៅខែនីមួយៗ។ ពិន្ទុសរុបគឺបានមកពីពិន្ទុពីការធ្វើតេស្ត ការធ្វើកិច្ចការផ្ទះ សៀវភៅសិក្សារបស់សិស្ស និងផ្សេងៗទៀត។

គោលបំណងនៃការធ្វើតេស្តគឺវាយតម្លៃសមត្ថភាពរបស់សិស្សសម្រាប់ខែនីមួយៗ។ សិស្សដែលមានពិន្ទុទាប ជាពិសេសលើភាសាខ្មែរ គណិតវិទ្យា និងមុខវិជ្ជាវិទ្យាសាស្ត្រ នឹង បានទទួលការជួយនៅខែបន្ទាប់។

### ៣ តេស្តនៅចុងឆមាសនីមួយៗ

តេស្តគឺធ្វើសម្រាប់គ្រប់មុខវិជ្ជានៅចុងឆមាសនីមួយៗ។

គោលបំណងនៃការធ្វើតេស្តគឺដើម្បីវាយតម្លៃសមត្ថភាពសិស្សនៅក្នុងឆមាស។ សិស្សដែលមានពិន្ទុទាបជាពិសេសលើភាសាខ្មែរ គណិតវិទ្យា និងមុខវិជ្ជាវិទ្យាសាស្ត្រ នឹង បានទទួលការជួយនៅឆមាសបន្ទាប់។

ពិន្ទុសរុបឆមាសទី១ និងទី២ នឹងត្រូវប្រើសម្រាប់កំណត់ថាសិស្សជាប់ឬធ្លាក់ថ្នាក់សម្រាប់ឆ្នាំសិក្សា។

នៅពេលបវេសនកាល សិស្សមានពិន្ទុទាបលើមុខវិជ្ជាណានឹងត្រូវបានទទួលការជួយបន្ថែម ហើយសិស្សដែលមានពិន្ទុត្រូវធ្លាក់ថ្នាក់នឹងបានធ្វើតេស្តឡើងវិញមុនពេលចូលរៀន។ ប្រសិនបើសិស្សធ្វើតេស្តជាប់ គេនឹងត្រូវឡើងថ្នាក់ទៅថ្នាក់បន្ទាប់។

## ២.៥.៤ ការប្រើលទ្ធផលតេស្តសិស្ស

គោលបំណងនៃការធ្វើតេស្តគឺដើម្បីកែលម្អគរុកោសល្យបង្រៀន និងការអនុវត្តរបស់គ្រូបង្រៀន ។

លទ្ធផលវាយតម្លៃសិស្សនៅពេលបង្រៀនមេរៀននីមួយៗ នឹងត្រូវប្រើសម្រាប់ជួយសិស្សរៀនយឺត។ ការជួយសិស្សរៀនយឺតជាដំណើរជាប់ជាប្រចាំដែលធានាថាសិស្សបានរៀនជាប់ជាបន្តពីមេរៀនមួយទៅមេរៀនមួយ។ វិធីជួយសិស្សនៅក្នុងពេលបង្រៀនឬក្រោយពេលបង្រៀនមេរៀនមួយមាន៖ ១. រៀបសិស្សជាក្រុមមានសិស្សពូកែ និងសិស្សរៀនយឺតដែលនាំឱ្យសិស្សពូកែជួយសិស្សរៀនយឺតបាននៅក្នុងពេលរៀនឬក្រោយពេលរៀនឬនៅផ្ទះ ២. រៀបជាដៃគូមានសិស្សពូកែនិងសិស្សរៀនយឺតដើម្បីអនុវត្តលំហាត់មេរៀន នីមួយៗ។ ភស្តុតាងនៃការជួយសិស្សគប្បីឃើញមានគ្រោងនៅក្នុងកិច្ចតែងការបង្រៀន។ កាលវិភាគបង្រៀនកម្មវិធីសិក្សាបន្ថែមគប្បីមានសម្រាប់សកម្មភាពក្រៅថ្នាក់។ ក្រុមសិស្សគប្បីត្រូវបានរៀបចំសម្រាប់សម្រាប់ធ្វើកិច្ចការគម្រោង។ ក្រុមជាដៃគូគប្បីរៀបចំសម្រាប់សិស្សពូកែអាចជួយសិស្សរៀនយឺតលើមេរៀនមួយៗ។ សិស្សពូកែដែលបានជួយសិស្សរៀនយឺតគប្បីបានទទួលរង្វាន់ពីគគស.ជាការទទួលស្គាល់នូវស្នាដៃសិស្ស។

លទ្ធផលពីការវាយតម្លៃប្រចាំខែត្រូវប្រើសម្រាប់៖ ១. ជួយសិស្សរៀនយឺតអាចចាប់យកបាននូវខ្លឹមសារកម្មវិធីសិក្សានៅកម្រិតថ្នាក់រៀនជាក់លាក់ ២. ធ្វើការសម្រេចចិត្តថាតើប្រធានបទអ្វីជាអាទិភាពសម្រាប់ការប្រជុំបច្ចេកទេសប្រចាំខែ ៣. ជូនព័ត៌មានដល់មាតាបិតាពីលទ្ធផលនៃការសិក្សារបស់សិស្សតាមរយៈសៀវភៅទំនាក់ទំនងមាតាបិតា និងរៀបចំប្រជុំពិភាក្សាពីសកម្មភាពអ្វីដែលមាតាបិតា សិស្សខ្លួនឯង និងគ្រូបង្រៀនត្រូវធ្វើដើម្បីជួយសិស្សរៀនយឺត និង ៤. បញ្ចូលទៅក្នុងកម្មវិធីបំប៉នគ្រូនៅនឹងកន្លែងដែលបង្រៀនដោយគ្រូបង្គោលតាមមុខវិជ្ជាថ្នាក់ជាតិ។ គ្រូមានបទពិសោធន៍នៅសាលារៀនអាចជួយគ្រូខ្សោយក្រោមការឧបត្ថម្ភហិរញ្ញវត្ថុពី សាលារៀន។ មុខវិជ្ជាគោលសម្រាប់រៀនថ្នាក់បន្ថែមមានភាសាខ្មែរ គណិតវិទ្យា និងមុខវិជ្ជាវិទ្យាសាស្ត្រ។ ការប្រជុំបច្ចេកទេសប្រចាំខែ គប្បីប្រើសម្រាប់រំលែកបទពិសោធន៍ដោយឱ្យគ្រូបង្រៀនមានពិសោធន៍អនុវត្តការបង្រៀនមេរៀនដែលពិបាកសម្រាប់គ្រូខ្សោយ ឬមួយឱ្យគ្រូខ្សោយហាត់អនុវត្តនូវការបង្រៀនមេរៀនជាក់លាក់ណាមួយដែលគេត្រូវការនូវការសង្កេត និងពិភាក្សាលើវិធីសាស្ត្របង្រៀនពីគ្រូមានពិសោធន៍។ ភស្តុតាងនៃការបង្រៀនបន្ថែម មានផែនការបង្រៀនបន្ថែម សម្ភារៈបង្រៀន ឯកសារប្រជុំបច្ចេកទេសប្រចាំខែ កំណត់ហេតុប្រជុំជាមួយមាតាបិតាគ្រូ និងសិស្ស សៀវភៅទំនាក់ទំនងសិស្សនិងមាតាបិតាគប្បីមានសម្រាប់ការពិនិត្យតាមដាន។

លទ្ធផលជាពិន្ទុពីការវាយតម្លៃឆមាសត្រូវប្រើសម្រាប់ឱ្យសិស្សឡើងថ្នាក់ ឬ ត្រួតថ្នាក់ដដែល។ សម្រាប់សិស្សដែលឡើងថ្នាក់តែពិន្ទុរបស់គេមានត្រឹម៥០% ទៅ ៦០%បង្ហាញថា ជាសិស្សដែលត្រូវការនូវការយកចិត្តទុកដាក់ពីគ្រូបង្រៀនតាំងពីដើមឆ្នាំសិក្សា។ ដូចនេះព័ត៌មានពីពិន្ទុសិស្សសម្រាប់ឆ្នាំបច្ចុប្បន្ននឹងត្រូវបញ្ជូនទៅឱ្យគ្រូនៅថ្នាក់បន្ទាប់។ គ្រូបង្រៀននៅថ្នាក់បន្ទាប់អាចប្រើព័ត៌មានទាំងនេះសម្រាប់គ្រូបង្រៀនធ្វើផែនការថ្នាក់រៀនដែលមាននៅក្នុងស្តង់ដាទី២ ដល់ ទី៥ និងសម្រាប់នាយកសាលាធ្វើផែនការស្តង់ដាទី៥។ ភស្តុតាងពីការធ្វើផែនការថ្នាក់រៀន ទិន្នន័យសិស្សពីការត្រួតថ្នាក់ ការឡើងថ្នាក់ និងការបោះបង់គប្បីមាននៅក្នុងសាលា។

**ទម្រង់ជាផែនការអនុវត្តថ្នាក់រៀនបន្ថែម៖ ថ្នាក់ទី ............... (អាចបញ្ចូលថ្នាក់ច្រើនក្នុងទម្រង់តែមួយ)**

| ថ្នាក់ទី | មុខវិជ្ជា | មេរៀន | ចំនួនសិស្ស | ថ្ងៃខែបង្រៀន | ថ្ងៃខែបង្រៀនជាក់ស្តែង | ថវិកា |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

**ទម្រង់ពីការប្រជុំបច្ចេកទេសប្រចាំខែ**

| មុខវិជ្ជា | មេរៀន | ឈ្មោះគ្រូ | ថ្ងៃគ្រោងប្រជុំ | ថ្ងៃប្រជុំជាក់ស្តែង | ថវិកា |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

*ឈ្មោះប្រធានក្រុមបច្ចេកទេស៖*

ភស្តុតាងនៃការប្រជុំមាន៖ របាយការណ៍ប្រជុំ សម្ភារៈបានប្រើ បញ្ជីឈ្មោះអ្នកចូលរួម ។ល។

**ទម្រង់ពីការកត់ត្រាការធ្វើផែនការនិងការរាយការណ៍ពីការប្រជុំរវាងមាតាបិតា សិស្ស និងគ្រូបង្រៀន**

ការប្រជុំនេះគប្បីធ្វើរាល់ត្រីមាស។ ក្នុងករណីមានបញ្ហាធ្ងន់ធ្ងរ ការប្រជុំត្រូវរៀបចំប្រចាំខែ។

<table>
<tr><td>ថ្ងៃខែប្រជុំ</td><td>កន្លែង</td></tr>
<tr><td>អ្នកចូលរួម៖</td><td>គ្រូ៖<br>ប្រធានគគស</td></tr>
<tr><td colspan="2">បញ្ហា៖ (អាចជាពិន្ទុសិស្សទាប អវត្តមានសិស្ស ឬ គ្រូ កិច្ចការផ្ទះ ហិង្សា ។ល។)</td></tr>
<tr><td colspan="2">សកម្មភាពឯកភាពគ្នាត្រូវធ្វើនៅ៣ខែបន្ទាប់ដោយ</td></tr>
<tr><td>គ្រូបង្រៀន<br>១.<br>២.<br>៣.</td><td>មាតាបិតា<br>១.<br>២.<br>៣.</td></tr>
<tr><td>សិស្ស<br>១.<br>២.<br>៣.</td><td>នាយកសាលា ឬ គគស<br>១.<br>២.<br>៣.</td></tr>
</table>

| របាយការណ៍ពីការអនុវត្តរយៈពេល៣ខែកន្លងមកដោយ | |
|---|---|
| គ្រូបង្រៀន<br>១.<br>២.<br>៣. | មាតាបិតា<br>១.<br>២.<br>៣. |

| សិស្ស<br>១.<br>២.<br>៣. | នាយកសាលា ឬ គគស<br>១.<br>២.<br>៣. |
|---|---|

**ទម្រង់ពីការធ្វើផែនការថ្នាក់រៀន និងការគ្រប់គ្រងសាលារៀនលម្អិតត្រីមាសសម្រាប់ឆ្នាំសិក្សា**

ទម្រង់នេះជាឧបករណ៍វាយតម្លៃសាលារៀនមានប្រសិទ្ធភាព ដែលមាននៅក្នុងប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃហើយ។

## ២.៦. គណនេយ្យភាពសាលារៀន

គណនេយ្យភាពសាលារៀនជាផ្នែកសំខាន់ទី៣នៃប្រព័ន្ធ ៣អា បិទជិត។ វាមានគណនេយ្យភាពពីដំណើរការសាលារៀន គណនេយ្យភាពសិក្សា និងគណនេយ្យភាពហិរញ្ញវត្ថុ។

### ២.៦.១ ប្រភេទគណនេយ្យភាព

#### ១ គណនេយ្យពីដំណើរការសាលារៀន

លទ្ធផលបានពីការវាយតម្លៃសិស្ស និងសាលារៀន ដូចមានរៀបរាប់នៅក្នុងជំពូក៦ ពីការវាយតម្លៃសិស្ស និងសាលារៀន ត្រូវតែយកមកប្រើប្រាស់ដើម្បីបញ្ជាក់គណនេយ្យភាពពីប្រតិបត្តិការណ៍សាលារៀន។

ភស្តុតាងជាតារាងទិន្ន័យចំនួនពីរបិទផ្សាយជាសាធារណៈនៅដើមឆ្នាំសិក្សា ដែលបញ្ជាក់នូវគណនេយ្យភាពសាលារៀន៖ ១ ផែនការកែលម្អសាលារៀននិងថវិកាប្រចាំឆ្នាំ និង២ ចំណូលរបស់សាលារៀនពីគ្រប់ប្រភេទធនធាន។

### ២ គណនេយ្យភាពសិក្សា

គណនេយ្យភាពសិក្សាមានបីកម្រិត៖ កម្រិតទី១ មានគ្រូបង្រៀន មាតាបិតា និងសិស្ស កម្រិតទី២ មានគណៈកម្មការគ្រប់គ្រងសាលារៀន និងមន្ត្រីអប់រំស្រុក និង កម្រិតទី៣ មានក្រុមការងារគ្រប់គ្រងតាមសាលារៀន និងមន្ត្រីអប់រំរាជធានីនិងខេត្ត។

ភស្តុតាងគណនេយ្យភាពសិក្សាបង្ហាញដោយតារាងទិន្នន័យចំនួន៣ ដែលត្រូវបិទផ្សាយជាសាធារណៈនៅដំណាច់ឆ្នាំសិក្សា៖

កម្រិតទី១ តារាងពិន្ទុតេស្តប្រចាំត្រីមាសប្រចាំថ្នាក់ និងតាមមុខវិជ្ជាគោល (សូចនាករស្តង់ដាទី២)

កម្រិតទី២ តារាងទិន្នន័យនៅដំណាច់ឆ្នាំសិក្សាពីស្តង់ដាទី១ វត្ថុបំណងគោលនយោបាយសាលារៀន និងផលសម្រេច និងក្រុមគោលដៅរយៈពេល៣ឆ្នាំ.

កម្រិតទី៣ តារាងទិន្នន័យពីកាតរបាយការណ៍ប្រៀបធៀបសូចនាករសំខាន់ៗរបស់សាលារៀន (ប្រចាំឆ្នាំ)។

### ៣ គណនេយ្យភាពហិរញ្ញវត្ថុ

តារាងទិន្នន័យហិរញ្ញវត្ថុមាននៅក្នុងសូចនាករ ៩.២ និង ៩.៣ នៃស្តង់ដាទី៩ ថវិកាសាលារៀន និងការគ្រប់គ្រងហិរញ្ញវត្ថុ ដែលត្រូវបិទផ្សាយជាសាធារណៈនៅចុងឆ្នាំសិក្សានីមួយៗ។

## ២.៦.២ ការវិភាគការអនុវត្តការងាររបស់សាលារៀន

ការវិភាគនឹងត្រូវបង្ហាញដោយក្រាហ្វទិន្នន័យនៅថ្នាក់ជាតិ ដែលមាន៖

ក. ពិន្ទុស្តង់ដាសាលារៀនមានប្រសិទ្ធភាពរវាងសាលារៀននៅក្នុងក្រុង ស្រុក ខណ្ឌ ឬ រាជធានី ខេត្ត ទំនោរពីការរីកចម្រើននៃពិន្ទុសាលារៀនមានប្រសិទ្ធភាពពី២ឬ៣ឬ៤ឆ្នាំកន្លងមក នៃសាលារៀននៅក្នុងក្រុង ស្រុក ខណ្ឌ ឬ រាជធានី ខេត្ត សាលារៀននៅទីប្រជុំជន និង ជនបទ ឬធៀបជាមួយនឹងកម្រិតជាមធ្យមនៅថ្នាក់ជាតិ ។ល។

ខ. ពិន្ទុតេស្តសិស្សនៃសាលារៀននៅក្នុងស្រុកឬខេត្ត សាលារៀនទីប្រជុំជននិងជនបទ ឬធៀបជាមួយថ្នាក់ជាតិ ។ល។

ការវិភាគនឹងត្រូវបង្ហាញដោយក្រាហ្វទិន្នន័យនៅសាលារៀន ដែលមាន៖

ក. ពិន្ទុវាយតម្លៃការអនុវត្តការងារសាលារៀនតាមស្តង់ដានីមួយៗនៃឆ្នាំសិក្សាបច្ចុប្បន្នធៀបជាមួយឆ្នាំមុនៗ

ខ. ពិន្ទុតេស្តសិស្សតាមមុខវិជ្ជាគោលនៃឆ្នាំសិក្សាបច្ចុប្បន្នធៀបជាមួយឆ្នាំសិក្សាមុនៗ។

ប្រព័ន្ធទិន្នន័យទន់របស់ប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃអាចជួយសាលារៀននីមួយៗក្នុងការបង្កើតក្រាហ្វទិន្នន័យបាន។ ថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់ស្រុកអាចផលិតតារាងទិន្នន័យនិងរបាយការណ៍ទាំងអស់នៅចុងឆ្នាំសិក្សា ដើម្បីបង្ហាញនូវការរីកចម្រើនការអនុវត្តការងាររបស់សាលារៀនពីគុណភាពនិងសមធម៌នៃការអប់រំដែលបានផ្តល់នូវឆ្នាំសិក្សាបច្ចុប្បន្ន ហើយធៀបជាមួយឆ្នាំសិក្សាមុនៗ។

## ២.៦.៣ ការគ្រប់គ្រងហិរញ្ញវត្ថុ (មានលម្អិតក្នុងសៀវភៅប្រតិបត្តិមូលនិធិកែលម្អសាលារៀន)

## ២.៦.៤ សូចនាករពិនិត្យតាមដានផលប៉ះពាល់នៃមូលនិធិកែលម្អសាលារៀន

ផលប៉ះពាល់នៃមូលនិធិត្រូវបានបង្ហាញនូវការប្រែប្រួលនៃផលសម្រេចសិក្សារបស់សិស្ស និងការអនុវត្តរបស់សាលារៀន។ ផលសម្រេចសិក្សារបស់សិស្សត្រូវបានវាស់វែងដោយសារទិន្នន័យពីពិន្ទុតេស្ត ការឡើងថ្នាក់ ការត្រួតថ្នាក់ និងការបោះបង់ការសិក្សា។ ការអនុវត្តរបស់សាលារៀនត្រូវបានវាស់វែងដោយទិន្នន័យពីស្តង់ដាសាលារៀនមានប្រសិទ្ធភាព។ តារាង២ខាងក្រោមរៀបរាប់គ្រប់សូចនាករដើម្បីពិនិត្យតាមដានផលប៉ះពាល់នៃមូលនិធីលើសិស្សនិងសាលារៀន។

## ១. សូចនាករផលសម្រេច និងក្រុមគោលដៅរយៈពេល៣ឆ្នាំ ឆ្នាំសិក្សា២០១៧-២០១៨

| សូចនាករផលសម្រេច | ក្រុមគោលដៅគ្រោងឆ្នាំសិក្សា ២០១៧-២០១៨ | សម្រេចជាក់ស្តែងឆ្នាំសិក្សា ២០១៧-២០១៨ |
|---|---|---|
| ១. ការចូលរៀន | | |
| ចំនួនសិស្សបានចូលរៀន | | |
| ចំនួនសិស្សត្រួតថ្នាក់ | | |
| ចំនួនសិស្សឡើងថ្នាក់ | | |
| ២. ចំនួនសិស្សមានពិនិទ្ទុតេស្តលើ៦០%នៃមុខវិជ្ជាគោល | | |
| ភាសាខ្មែរ | | |
| គណិតវិទ្យា | | |
| ភាសាបរទេស | | |
| ៣. ចំនួនសិស្សមានពិនិទ្ទុតេស្តលើ៦០%នៃមុខវិជ្ជាវិទ្យាសាស្ត្រ | | |
| រូបវិទ្យា | | |
| គីមីវិទ្យា | | |
| ជីវវិទ្យា | | |
| ផែនដីវិទ្យា | | |
| ព័ត៌មាន ទំណាក់ទំនង និងបច្ចេកវិទ្យា | | |
| ៤. ចំនួនសិស្សថ្នាក់ទី៩អានភាសាខ្មែរបានច្រើនជាង២០០ពាក្យក្នុងមួយនាទី | | |
| ៥. ចំនួនសិស្សថ្នាក់ទី៩ប្រឡងជាប់ការប្រឡងថ្នាក់ជាតិ | | |

## ២ របាយការរីកចម្រើនពីការវាយតម្លៃការអនុវត្តការងាររបស់សាលារៀន

**ឧបសម្ព័ន្ធ៖ ឧបករណ៍វាយតម្លៃការអនុវត្តសាលារៀនផ្អែកតាមស្តង់ដាសាលារៀនមានប្រសិទ្ធភាព**

# ជំពូក៣៖

# ផែនការអនុវត្ត និងថវិកា

## ៣.១ ផែនការអនុវត្ត

ផែនការសកម្មភាពខាងក្រោមគ្រប់ដណ្តប់រយៈពេល១៨ខែ គិតចាប់ពីខែ សីហាឆ្នាំ២០១៧ ដល់ខែ មករាឆ្នាំ២០១៩។

| Activities | Date |
|---|---|
| **Sub-component 1.1 Strengthen School Based Management** | |
| Launching of the project | August 10 |
| Develop workbooks by core subjects | Aug - Sept |
| Develop STEM equipment standards | Aug - Sept |
| DLI1: SBM manual – final review meeting | Sept. 14 |
| DLI2: PoE, DoE and school training manual – final review meeting | Sept. 15 |
| SBM orientation workshop for national trainers | Sept. 27-29 |
| SBM national workshop for PoE, DoE and school | Oct 11-12 |
| On-job training: establish SMC, school planning and budgeting, staff performance management, assessment of G7 students on Khmer and math subjects and develop teacher on-job training program | Oct 16 – Nov 24 |
| On-job training: PoE and DoE monitoring planning and budgeting | Dec 4 - 15 |
| **On-job training: core subject teachers by subject** | |
| School year quarter 1 and 2: monthly monitoring on progress of supporting slow learners including G7 students and students who have scores below 65% : provide hands on support monitoring to core subject teachers: provide guidance on extra classes for slow learners, support teachers on the analysis of socio-economic issues of vulnerable students that impact learning, | Monthly |
| School year quarterly monitoring on progress of teacher performance including classroom observations and feedback, provide guidance on Thursday technical meeting/demonstration practices and annual teacher performance evaluation and appraisal | Quarterly |
| Quarterly monitoring on progress of school improvement plan and PoE and DoE plan implement | 2018, Jan 1 – 15 |
| On-job training: community role and school governance and parental/student education on class monitoring | 2018, Feb 1 – 15 |
| Quarterly monitoring on progress of school improvement plan and PoE and DoE plan implement | 2018, Late April-early May |
| On-job training: school and student evaluation and school accountability (preparation) | 2018, June 4 – 15 |
| On-job training: financial management | ??? |
| End year monitoring | 2018, July 1 – 30 |
| On-job training: conduct school performance evaluation, and use data for following year planning and budgeting | 2018, Sept 3 - 14 |
| On-job training: conduct PoE and DoE performance evaluation, and use data/inf for following year planning and budgeting | 2018, Sept 17 – 28 |

| | |
|---|---|
| Develop SBM annual report | 2018, October 15 – 31 |
| **Sub-component 1.2 Upgrading teachers** | |
| DLI3 adopted and orientation (TUP WG) | August |
| DLI3: chapter on FM and procurement to be produced by FM and PU of MoEYS together with RUPP/PMT | August 15 |
| DLI3: Final TUP manual reviewed and adopted | Sept 15 |
| Orientation of DLI3 to possible training providers: RUPP and RTTC/PTTC | Sept 25 |
| **Teacher Selection (TUP WG/SBM WG)** | |
| Select target teachers for TUP based on the set criteria | Oct 16 – Nov 24 |
| Share the list of selected teachers with RUPP | Nov 28 |
| **Training Providers Selection** | |
| ***Prepare Training Institutions for TUP Program Provision from Second Year*** | |
| TUP WG: assess RTTCs (Battambang and Phnom Penh) capacity for program provision and make decision on which RTTC will start program provision in second year | 2017 - 2018 |
| Selected RTTCs will do self-assessment on its institutional capacity and produce assessment report with support from TUP WG | |
| Selected RRTCs prepare proposal to offer program in second year and submit to TUP WG for review | |
| TUP WG review the proposal and submit it to Project Director for approval | |
| Prepare RTTCs institution for TUP program provision with support from TUP WG and RUPP (MOU between RTTC and RUPP) | |
| **Training Providers Selection** | |
| ***RUPP Preparation for TUP Program Provision in First Year Onward*** | |
| RUPP self-assess its institution against TEPS, produce assessment report | 2017 - 2018 |
| RUPP prepare proposal and submit proposal include self-assessment report to TUP WG for review | |
| TUP WG review the proposal and submit to Project Director for approval | |
| Develop facilities development plan with support from PMT | |
| Rehabilitate and prepare RUPP classrooms / labs for program provision | |

| | |
|---|---|
| **TUP Program Provision** | |
| Conduct entry tests among selected teachers | 2017 - 2018 |
| Conduct training courses | |
| Assign practicum program for teachers | |
| Provide onsite monitoring supports to teachers | |
| Conduct term exams and final exam | |
| Provide certificates to graduated teachers | |

| | |
|---|---|
| **DLI7: LUP Manual (SBM/TUP WG)** | |
| Develop first draft LUP manual: 2 workshops | 2017 - 2018 |
| Arrange consultation sessions of the draft | |
| Finalize the LUP Manual and submit it to Project Director for approval | |
| Conduct orientation session of LUP Manual for potential training providers | |
| RUPP prepare proposal and submit it to TUP WG for review | |
| TUP WG review the proposal and submit it to Project Director for approval | |
| RUPP prepares implementation plan and submit it to PMT | |
| SBM/RUPP select school directors for first round training program | |
| RUPP conduct training courses | |
| Conduct term exams and final exam | |
| Provide certificates to graduated school directors | |
| Other potential training providers could prepare proposals with the endorsement and supports from TUP WG | |
| **Sub-component 1.3: Improving school facilities** | |
| Establish project committee to establish Community Committee | 2017, Aug 10 |
| Finalize and submit community participation manual to WB | 2017, Aug 4 |
| Finalize first lists for school facilities construction | 2017, Aug 10 |
| Establish central engineers' division of responsibility by target provinces | 2017, Aug 10 |

| | |
|---|---|
| Establish community committees | 2017, Sep 1 – 30 |
| Site engineers recruited | 2017, end Sept. |
| Training community committees | 2017, Oct 1 – 30 |
| Start construction activities | 2017, November – May 2018 |
| Central engineers monitoring | Regular |
| **PISA for development** | |
| PISA-D Capacity Building | 2017 |
| Preparing and Conducting PISA-D | 2017 |
| Prepare jointly with the OECD analysis of the PISA-D data | 2018 |
| PISA-D Test Result Dissemination | 2018 |

## ៣.២ ថវិកា

ថវិកាខាងក្រោមគ្របដណ្តប់គម្រោងទាំងមូល។

| | | Y1 | Y2 | Y3 | Y4 | Y5 | Sub-total | Ratio |
|---|---|---|---|---|---|---|---|---|
| I. | **DLI** | **4,973,500** | **5,499,000** | **6,549,000** | **5,004,000** | **797,000** | **22,822,500** | |
| 1 | **Earmark** | **1,938,524** | **2,548,108** | **3,626,021** | **2,867,908** | **362,000** | **11,342,561** | 50% |
| | C1.1: Strengthening School Based Management (DLI) | 1,401,400 | 1,296,400 | 1,060,400 | 578,900 | 332,000 | 4,669,100 | |
| | C1.2: Upgrading Teachers (DLI) | 537,124 | 1,251,708 | 2,565,621 | 2,289,008 | 30,000 | 6,673,461 | |
| 2 | **None Earmark** | 3,034,976 | 2,950,892 | 2,922,979 | 2,136,092 | 435,000 | 11,479,939 | 50% |
| II. | **IPF** | **6,916,500** | **7,035,000** | **2,122,000** | **1,622,000** | **482,000** | **18,177,500** | |
| | C1.3: Improving School Facilities (IPF) | 5,709,000 | 6,631,000 | 1,568,000 | 1,268,000 | 168,000 | 15,344,000 | |
| | C2: Project Management and Monitoring and Eavaluation (IPF) | **1,207,500** | **404,000** | **554,000** | **354,000** | **314,000** | **2,833,500** | |
| Grand Total | | **11,890,000** | **12,534,000** | **8,671,000** | **6,626,000** | **1,279,000** | **41,000,000** | |

# ជំពូក៤៖

# ស្ថាប័ន និងអ្នកទទួលខុសត្រូវ

# ក្រុមគ្រប់គ្រងគម្រោង



## ៤.១. ក្រុមគ្រប់គ្រងគម្រោង

រដ្ឋលេខាធិការម្នាក់មានតួនាទីជានាយកគម្រោងជាអ្នកដឹកនាំក្រុម រួមជាមួយនិងប្រធានគម្រោង ដែលជាអគ្គនាយករងម្នាក់នៃអគ្គលេខាធិការដ្ឋានអបរំ។

សមាជិកក្រុមជាមន្ត្រីមកពីនាយកដ្ឋានពាក់ព័ន្ធដូចជាមធ្យមសិក្សា ផែនការពិនិត្យតាមដាន និង វាយតម្លៃ ធានាគុណភាពសំណង់ ប្រព័ន្ធគ្រប់គ្រងទិន្នន័យអប់រំ កម្មវិធីសិក្សា បណ្តុះបណ្តាលគ្រូ ហិរញ្ញវត្ថុ និងអង្គភាពលទ្ធកម្ម។

## ៤.២. ក្រុមការងារការគ្រប់គ្រងតាមសាលារៀន

អគ្គនាយករងម្នាក់នៃអគ្គលេខាធិការដ្ឋានគោលនយោបាយ និងផែនការជាប្រធានក្រុម។ សមាជិកក្រុមនឹងគមានតួនាទីជាគ្រូបង្គោលថ្នាក់ជាតិសម្រាប់ការងារគ្រប់គ្រងតាមសាលារៀន។

ក្រុមនឹងផ្តល់ការណែនាំរួម និងបំប៉ននៅនឹងកន្លែងសម្រាប់មន្ត្រីថ្នាក់ក្រោមជាតិ និងសាលារៀន ដើម្បីអនុវត្តសេចក្តីណែនាំពីការគ្រប់គ្រងតាមសាលារៀន និងប្រព័ន្ធពិនិត្យតាមដាមនិងវាយតម្លៃផ្អែក លើលទ្ធផលសម្រាប់អនុវិស័យ។ គ្រូបង្គោលថ្នាក់ជាតិនឹងផ្តល់ការបំប៉ននៅឆ្នាំទីមួយ ២០១៧ និង ២០១៨ ហើយប្តូរតួនាទីជាអ្នកសម្របសម្រួលវិញនៅឆ្នាំទីពីរពី២០១៨ និង២០១៩។ ក្នុងករណីថ្នាក់ ក្រោមជាតិណាដែលនៅមានសមត្ថភាពខ្សោយ គ្រូបង្គោលថ្នាក់ជាតិអាចជួយតែនៅឆ្នាំទីពីរប៉ុណ្ណោះ។

នាយកសាលារៀនដែលមានសមត្ថភាពជាក់លាក់លើប្រធានបទណាមួយ នឹងត្រូវបានអញ្ជើញ មកជួយបង្រៀនផ្ទាល់ដល់វគ្គបំប៉ននៅនឹងកន្លែងនេះ។

## ៤.៣. ក្រុមការងារបង្កើនគុណវុឌ្ឍិគ្រូបង្រៀន

អគ្គនាយករងម្នាក់នៃអគ្គលេខាធិការដ្ឋានគោលនយោបាយនិងផែនការជាប្រធានក្រុម។ សមាជិកក្រុមនឹងមានតួនាទីជាគ្រូបង្គោលថ្នាក់ជាតិសម្រាប់មុខវិជ្ជា។

ក្រុមនឹងផ្តល់ការណែនាំរួម និងបំប៉ននៅនឹងកន្លែងសម្រាប់មន្ត្រីថ្នាក់ក្រោមជាតិ និងសាលារៀន ដើម្បីអនុវត្តការបង្រៀនឱ្យមានប្រសិទ្ធភាព ស្របតាមសេចក្តីណែនាំពីការគ្រប់គ្រងតាមសាលារៀន និង ប្រព័ន្ធពិនិត្យតាមដាមនិងវាយតម្លៃផ្អែកលើលទ្ធផលសម្រាប់អនុវិស័យ។ គ្រូបង្គោលថ្នាក់ជាតិនឹងផ្តល់ ការបំប៉ននៅពីរទៅបីឆ្នាំដំបូង ដើម្បីធានាថាគ្រូបង្រៀនមានពេញលេញនូវចំណេះដឹង

មុខវិជ្ជា និងសមត្ថភាពគរុកោសល្យ។

### ៤.៤ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត

មន្ត្រីចំនួន៥រូប ត្រូវបានចាត់តាំងឱ្យទទួលខុសត្រូវលើការងារគ្រប់គ្រងសាលារៀនមានប្រសិទ្ធភាពនេះ។ មន្ត្រីនឹងចូលរួមការបំប៉ននៅនឹងកន្លែងដែលរៀបចំដោយគ្រូបង្គោលថ្នាក់ជាតិនៅឆ្នាំ២០១៧ និង២០១៨។ មន្ត្រីថ្នាក់រាជធានីឬខេត្តនឹងទទួលខុសត្រូវក្នុងការជួយសាលារៀនពីថ្នាក់ជាតិនៅឆ្នាំទីពីរតទៅ។ ក្នុងករណីដែលខេត្តណានៅមានសមត្ថភាពមិនពេញលេញ ថ្នាក់ជាតិអាចជួយនៅឆ្នាំទីពីរតែប៉ុណ្ណោះ។

### ៤.៥ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ

មន្ត្រីចំនួន២ ទៅ ៣រូប ត្រូវបានចាត់តាំងឱ្យទទួលខុសត្រូវលើការងារគ្រប់គ្រងសាលារៀនមានប្រសិទ្ធភាពនេះ។ មន្ត្រីនឹងចូលរួមការបំប៉ននៅនឹងកន្លែងដែលរៀបចំដោយគ្រូបង្គោលថ្នាក់ជាតិនៅឆ្នាំ ២០១៧ និង ២០១៨។ មន្ត្រីថ្នាក់ស្រុកនឹងទទួលខុសត្រូវក្នុងការជួយសាលារៀនពីថ្នាកជាតិនៅឆ្នាំទីបីតទៅ។ ក្នុងករណីដែលស្រុកណានៅមានសមត្ថភាពមិនពេញលេញ ថ្នាក់ខេត្តអាចជួយនៅឆ្នាំទីបីតែប៉ុណ្ណោះ។

### ៤.៦. គណៈកម្មការគ្រប់គ្រងសាលារៀន

គណៈកម្មការគ្រប់គ្រងសាលារៀននៃសាលារៀនគោលដៅទាំង១០០ នឹងត្រូវបង្កើតឡើងនៅឆ្នាំទីមួយ។ ជាទូទៅក្រសួងនឹងមិនអាចរំពឹងថាសាលារៀនទាំង១០០ អាចបង្កើតនូវគណៈកម្មការគ្រប់គ្រងសាលារៀនទាំង១០០បានទេ។ សាលារៀនដែលមាននាយកសាលារឹងមាំ អាចនឹងមិនត្រូវការគណៈកម្មការគ្រប់គ្រងសាលារៀននៅឆ្នាំដំបូងៗ។ សាលារៀនខ្លះអាចនឹងមិនប្ដេជ្ញាបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀនតែម្ដង។ បើជួបស្ថានភាពនេះ ក្រុមការងារគ្រប់គ្រងតាមសាលារៀន អាចពិចារណាផ្ដល់ដល់សាលារៀននូវឱកាសអនុវត្តនៅឆ្នាំទីមួយដោយគ្មាន គណៈកម្មការគ្រប់គ្រងសាលារៀន ឬមួយផ្លាស់ប្ដូរសាលារៀនគោលដៅទៅសាលារៀនបម្រុងផ្សេងទៀត។

គណៈកម្មការគ្រប់គ្រងសាលារៀនមានបញ្ជីតួនាទី និងភារកិច្ចច្បាស់លាស់នៅក្នុងសៀវភៅណែនាំពីការគ្រប់គ្រងតាមសាលារៀនហើយ។ សមាជិកគណៈកម្មការនឹងទទួលការបំប៉នលើប្រធានបទទាក់ទងដើម្បីគេអាចអនុវត្តនូវតួនាទីនិងភារកិច្ចរបស់គេ។

### ៤.៧. នាយកសាលា

នាយកសាលានឹងដើរតួនាទីជាមន្ត្រីដឹកនាំកិច្ចការប្រតិបត្តិរបស់សាលារៀន ដូចមានចែងនៅក្នុងបញ្ជីតួនាទី និងភារកិច្ចនៅក្នុងសៀវភៅណែនាំពីការគ្រប់គ្រងតាមសាលារៀន។

នាយកសាលានឹងទទួលការបំប៉នលើប្រធានបទទាក់ទងដើម្បីគេអាចអនុវត្តនូវតួនាទី និងភារកិច្ចរបស់គេ។ នាយកសាលា និងគណៈកម្មការគ្រប់គ្រងសាលារៀននឹងទទួលខុសត្រូវពេញលេញលើការងារគ្រប់គ្រងតាមសាលារៀនពីឆ្នាំទី៤ គឺពីឆ្នាំ២០២០ និង២០២១ តទៅ។

ជូនភ្ជាប់នូវឧបសម្ព័ន្ធជាប្រកាសចាត់តាំងមន្ត្រី សម្រាប់កិច្ចការពង្រឹងការគ្រប់គ្រងតាមសាលារៀនសម្រាប់ក្រុមគោលដៅ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តទាំង២៥ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ៩៩ និងសាលារៀន១០០។

# ជំពូក៥៖

# គោលនយោបាយការពារសុវត្ថិភាពរបស់ធនាគារដែលត្រូវយកមកអនុវត្តចំពោះគម្រោង

SEIP ដែលត្រូវបានស្នើឡើង នឹងបានទទួលហិរញ្ញវត្ថុតាមរយៈ IDA ដែលជាភ្នាក់ងារកណ្តាលសម្រាប់ធនាគារ ហើយគម្រោងតាមការដ្ឋានជាក់លាក់ អាចមានផលប៉ះពាល់ផ្នែកបរិស្ថាន និងផ្នែកសង្គម គួរជាទីកត់សម្គាល់ ឬជាសក្តានុពល ដែលយើងនៅពុំទាន់ដឹងនៅឡើយ។ ជាលទ្ធផល ឧបករណ៍ការពារសុវត្ថិភាពសមស្រប គឺ ESMF។ ESMF ជាឯកសារផ្តល់ការណែនាំផ្នែកគោលនយោបាយការពារសុវត្ថិភាពមួយ ដែលអភិបាលលើគោលវិធីដំណើរការ និងឧបករណ៍ជាក់លាក់ ដែលត្រូវយកមកប្រើប្រាស់ក្នុងអំឡុងពេលការវាយតម្លៃតាមទីតាំងជាក់លាក់ និងដាក់បញ្ចូលនូវចំណាត់ប្រភេទគោលនយោបាយការពារសុវត្ថិភាពណាមួយ ក្នុងចំណោមចំណាត់ប្រភេទទាំងបី (រួមមានចំណាត់ប្រភេទ ក ខ ឬ គ)។

## ៥.១ គោលនយោបាយការពារសុវត្ថិភាពរបស់ធនាគារដែលត្រូវយកមកអនុវត្តចំពោះគម្រោង

**គោលនយោបាយការពារសុវត្ថិភាពបរិស្ថាន (OP/BP4.01) នឹងត្រូវយកមកប្រើប្រាស់។** យើងមិនរំពឹងថាគម្រោងនឹងមានផលប៉ះពាល់ផ្នែកបរិស្ថានធំធេងនោះទេ ហេតុនេះហើយ គម្រោងត្រូវបានចាត់ចូលក្នុងចំណាត់ប្រភេទគម្រោង "ខ"។ OP/BP 4.01 នឹងត្រូវយកមកប្រើប្រាស់ ហើយនឹងតម្រូវឱ្យមានការវាយតម្លៃជាផ្នែកប៉ុណ្ណោះ។ ក្រសួងអប់រំ យុវជន និងកីឡាយ បានរៀបចំ ESMF, EMP ទូទៅ, IPPF និង RPF សម្រាប់គម្រោងនេះ។ ការអនុវត្តគម្រោងនឹងត្រូវធ្វើឡើងនៅទូទាំងប្រទេស ហើយទីតាំងជាក់លាក់សម្រាប់ការសាងសង់សាលាមធ្យមសិក្សាបឋមភូមិ បន្ទប់រៀនបន្ថែម និងបរិក្ខារជាកន្លែងស្នាក់នៅរបស់គ្រូ នឹងត្រូវទាញចេញចេញពីលំហាត់ធ្វើផែនទីសាលារៀន ដោយផ្អែកលើភាពតំណាងនៃចរិតលក្ខ

ណៈពិសេសដាច់ដោយឡែក នៃជនជាតិដើមភាគតិច បរិយាកាសផ្នែកនយោបាយ សង្គម វប្បធម៌ សាសនា និងបរិស្ថានរបស់តំបន់អនុគម្រោងដែលត្រូវបានស្នើឡើង។ មានការរំពឹងទុកថា ៩០% នៃទីតាំងគម្រោង នឹងស្ថិតនៅក្នុងបរិវេណសាលារៀនដែលមានស្រាប់។ ក្នុងករណីត្រូវការដីថ្មីសម្រាប់ការសាងសង់សាលារៀន អាជ្ញាធរ មូលដ្ឋាន (ជាពិសេសគឺអាជ្ញាធរឃុំ សង្កាត់) ឬគណៈកម្មាធិការគ្រប់គ្រងដីធ្លី និងនគររូបនីយកម្មរាជធានី ខេត្ត ក្រសួងអប់រំ យុវជន និងកីឡា តាមរយៈមន្ទីរអបរំ យុវជន និងកីឡារាជធានី ខេត្ត នឹងផ្តល់ចំណារអនុម័ត។ ពេលកំណត់ទីតាំងបានហើយ និងរំពឹងថាទំនងជាមានផលប៉ះពាល់អវិជ្ជមានកើតឡើង ឧបករណ៍ជាក់លាក់ដូចជា EMP, IPP និង RPP នឹងត្រូវបង្កើតឡើង។ ដោយឡែក ដំណើរការនេះអាចមានដូចខាងក្រោម៖ (i) ពេលកំណត់ទីតាំងថ្មីបានហើយ នាយកសាលា គណៈកម្មការគ្រប់គ្រងសាលារៀន និងអាជ្ញាធរឃុំ សង្កាត់ នឹងរួមគ្នាធ្វើការពិនិត្យជ្រើសរើសទូលំទូលាយមួយ ដើម្បីបញ្ជាក់អះអាងថា ទីតាំងដែលបានកំណត់ មានសុវត្ថិភាពផ្នែកបរិស្ថាន និងសង្គម និងមានលក្ខណៈសម្បត្តិអាចធ្វើការសាងសង់បាន និង (ii) ក្នុងករណីមិនមានប័ណ្ណកម្មសិទ្ធិលើដីសម្រាប់ការសាងសង់អនុគម្រោងដែលត្រូវបានស្នើឡើងទេ អាជ្ញាធរឃុំ សង្កាត់ (ឬថ្នាក់ក្រុង ស្រុក ខណ្ឌ) នឹងត្រូវផ្តល់ចំណារយល់ព្រមលើលទ្ធផលនៃការពិនិត្យជ្រើសរើស និងចេញលិខិតផ្លូវការ ដើម្បីបញ្ជាក់ការប្រើប្រាស់ដី។ EMP នឹងត្រូវដាក់បញ្ចូលនៅក្នុងឯកសារដេញថ្លៃ ដើម្បីជម្រាបប្រាប់ដល់អ្នកម៉ៅការ/សហគមន៍ អំពីតួនាទី និងការទទួលខុសត្រូវរបស់ពួកគេក្នុងការអនុវត្តតាមឧបករណ៍ការពារ សុវត្ថិភាព។

**គោលនយោបាយជនជាតិដើមភាគតិច** (OP/BP**4.10**) **នឹងត្រូវយកមកប្រើប្រាស់។** ដូចគ្នានេះដែរ SEIP អាចមានផលប៉ះពាល់ជាសក្តានុពលលើជនជាតិដើមភាគតិច និងសហគមន៍របស់ពួកគាត់ អាស្រ័យដោយការសាងសង់សាលារៀនថ្មី ហើយបរិក្ខារសាលារៀនទាំងនោះអាចមានវត្តមាននៅក្នុងសហគមន៍របស់ពួកគាត់ ព្រមទាំងឱកាសផ្តល់ជំនួយ "អាហារូបករណ៍សម្រាប់គ្រូបង្រៀន"។ ក្របខណ្ឌការងារការធ្វើផែនការជនជាតិដើមភាគតិច (IPPF) ត្រូវបានរៀបចំឡើងផ្អែកលើលទ្ធផល ESIA និងជាផ្នែកមួយនៃ ESMF នេះ។ នៅដំណាក់កាលក្រោយទៀត នៅពេលសាលារៀនត្រូវបានជ្រើសរើសរួច ហើយវិសាលភាពនៃផលប៉ះពាល់ត្រូវបានកំណត់ច្បាស់លាស់ហើយ ផែនការជនជាតិដើមភាគតិច (**IPP**) នឹងត្រូវបង្កើតឡើង។

**គោលនយោបាយការដោះស្រាយផលប៉ះពាល់ដោយមិនស្ម័គ្រចិត្ត (OP/BP4.12)** នឹងត្រូវយកមកប្រើប្រាស់។ SEIP អាចមានសក្តានុពលក្នុងការធ្វើលទ្ធកម្មដីធ្លី មិនថាជាការធ្វើលទ្ធកម្មដោយស្ម័គ្រចិត្ត ឬមិនស្ម័គ្រចិត្តក្តី ព្រមទាំងអាចមានផលប៉ះពាល់ផ្នែករូបវន្ត និងសេដ្ឋកិច្ចដទៃទៀតលើប្រជាពលរដ្ឋកំពុងរស់នៅក្នុង ឬ ក្បែរសាលារៀន។ ក្របខណ្ឌការងារគោលនយោបាយការដោះស្រាយផលប៉ះពាល់ (RPF) ត្រូវបានរៀបចំឡើងដោយផ្អែកលើលទ្ធផលរបស់ ESIA និងជាផ្នែកមួយនៃ ESMF នេះ។ ដូចគ្នានេះដែរ ផលប៉ះពាល់ផ្នែកការដោះស្រាយផលប៉ះពាល់ជាយថាហេតុ អាចកើតមានក្នុងអំឡុងពេលការសាងសង់បរិក្ខារសាលារៀន។ នៅដំណាក់កាលក្រោយទៀត នៅពេលសាលារៀនត្រូវបានជ្រើសរើស

រួច ហើយរចនាបទបច្ចេកទេស និងចំណុចតម្រូវដាក់លាក់ត្រូវបានសម្រេចជាស្ថាពរហើយ ផែនការសកម្មភាពសម្រាប់ការដោះស្រាយផលប៉ះពាល់ (RAP) សម្រាប់សាលារៀនគោលដៅទាំងឡាយណាដែលទទួលផលប៉ះពាល់ទាក់ទងនឹងការដោះស្រាយផលប៉ះពាល់ នឹងត្រូវបង្កើតឡើង។

## ៥.២ ផលប៉ះពាល់បរិស្ថាន និងសង្គមជាសក្តានុពល

នៅដំណាក់កាលនេះវិសាលភាពនៃផលប៉ះពាល់ផ្នែកបរិស្ថាន និង សង្គមគឺយើងនៅមិនទាន់ដឹងនៅឡើយ ព្រោះថាសាលាគោលដៅទាំង ១៣០ នៅពុំទាន់ត្រូវបានអនុម័តដោយក្រសួងអប់រំ យុវជន និងកីឡា ហេតុនេះការពិនិត្យជ្រើសរើសលើផលប៉ះពាល់ផ្នែកសង្គមនៅពុំទាន់ត្រូវបានធ្វើឡើងនៅឡើយ។ បន្ថែមលើនេះទៀត វិសាលភាពនៃការសាងសង់សាលារៀនគោលដៅនីមួយៗក៏នៅពុំទាន់ដឹងផងដែរ។ ផលប៉ះពាល់ជាសក្តានុពលផ្នែកបរិស្ថាន និងសង្គមកើតចេញពីគម្រោងត្រូវបានកំណត់តាមរយៈការប្រៀបធៀបការផ្តួចផ្តើមគំនិតសាលារៀនគោលដៅ និង/ឬសកម្មភាពនានាជុំវិញបរិបទបរិស្ថាន និងសង្គម និងផ្អែកលើគម្រោងអនុវត្តកន្លងមករបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា ពោលគឺ SESSP (P144715)។ ព័ត៌មានផ្នែកភូមិសាស្ត្រ និងប្រជាសាស្ត្រក៏ត្រូវបានដកចេញមកពីប្រភពទិន្នន័យចម្បង និងប្រភពទិន្នន័យបន្ទាប់បន្សំ ក៏ដូចជាពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធនានាផងដែរ។ ខាងក្រោមនេះគឺជាផលប៉ះពាល់បរិស្ថាន និងសង្គមជាសក្តានុពល ព្រមជាមួយវិធានការកាត់បន្ថយផលប៉ះពាល់ទាំងនោះ។

### ផលប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយ

គម្រោងត្រូវបានចាត់ចូលក្នុងចំណាត់ប្រភេទបរិស្ថាន "B" ដែលពាក់ព័ន្ធជាមួយគោលនយោបាយបីគឺ៖ OP/BP 4.01; OP/BP 4.12 និង OP/BP 4.10។ ការវាយតម្លៃផ្នែកបរិស្ថាន និងសង្គមឯករាជ្យមួយធ្វើឡើងដោយអ្នកពិគ្រោះយោបល់របស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងខែ មេសា និងខែ ឧសភា ឆ្នាំ ២០១៦ បានស្នើឡើងថា ពុំរំពឹងថាមានតម្រូវការការពារសង្គម និងបរិស្ថានគួរឲ្យកត់សម្គាល់នោះឡើយ ហើយពុំមានការធ្វើលទ្ធកម្មដីធ្លី ការបាត់បង់ និង/ឬកង្វល់ផ្នែកការដោះស្រាយផលប៉ះពាល់នោះឡើយ។ ភាគច្រើននៃសំណង់សាលារៀននឹងត្រូវធ្វើឡើងក្នុងបរិវេណសាលាដែលមានស្រាប់។ ក្នុងករណីទីតាំងខ្លះជាទីតាំងថ្មី (៣០ ស្រុក) ក្រសួងអប់រំ យុវជន និងកីឡា នឹងសុំការអនុម័ត (ផ្នែកច្បាប់) លើដីពីអាជ្ញាធរ មូលដ្ឋាន/ ឬអាជ្ញាធរពាក់ព័ន្ធ។ គម្រោងនឹងធានាឲ្យមានការប្រើប្រាស់ដីទំនេរ និងដីមិនប្រើប្រាស់ដែលជាកម្មសិទ្ធិរាជរដ្ឋាភិបាលដែលពុំមានម្ចាស់កម្មសិទ្ធិ អ្នកតាំងលំនៅ វិវាទ ឬមតិចម្រូងចម្រាស់។

**ទិដ្ឋភាពផ្នែកបរិស្ថាន** ផលប៉ះពាល់ជាសក្តានុពលរបស់គម្រោងលើបរិស្ថានមើលទៅហាក់ដូចជាតិចតួច ផ្តោតតែចំពោះទីតាំងជាក់លាក់ ហើយមានលក្ខណៈអាចប្រសើរឡើងវិញនៅពេលក្រោយ ហើយផលប៉ះពាល់ទាំងអស់នោះអាចមានវិធានការតាក់តែងដើម្បីកាត់បន្ថយបានរួចជាស្រេច។ លទ្ធផលនេះបានទទួលការគាំទ្រពីការវាយតម្លៃផ្នែកបរិស្ថាន (EA) ធ្វើឡើងដោយក្រសួងអប់រំ យុវជន និងកីឡា ក្នុងខែ មេសា ឆ្នាំ ២០១៦។ អាស្រ័យដោយធម្មជាតិ និងទ្រង់ទ្រាយតូចនៃសំណង់ស៊ីវិលដែលត្រូវបានស្នើឡើងក្រោមគម្រោងនេះ របាយការណ៍វាយតម្លៃបរិស្ថានពេញលេញមិនត្រូវបានចាត់ទុកថាត្រូវធ្វើនោះឡើយ។ ទោះយ៉ាងនេះក្តីទំនងជាមានកង្វល់មួយចំនួនទាក់ទងជាមួយការបង្កភាពមិនងាយស្រួល ឬការរំខានដល់បរិវេណជុំវិញក្នុងអំឡុងពេលការសាងសង់។ សម្រាប់គោលបំណងដើម្បីពង្រឹងវិធានការអំណោយផលដល់បរិស្ថាន និងកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមានដែលអាចបង្កឡើងដោយសកម្មភាពការសាងសង់ ក្របខណ្ឌការងារផ្នែកបរិស្ថាន និងសង្គម (ESMF) រួមទាំងផែនការគ្រប់គ្រងបរិស្ថានទូទៅ (EMP និង ECOPSs) ត្រូវបានរៀបចំឡើង។ EMP (ECOPSs) នឹងត្រូវដាក់បញ្ចូលនៅក្នុងឯកសារដេញថ្លៃជាការតម្រូវ។ ចំពោះទីតាំងគម្រោងជាក់លាក់នៅក្នុងអនុគម្រោងទាំងឡាយណាដែលយើងបានដឹងរួចហើយ ហើយដែលទំនងជាមានផលប៉ះពាល់បរិស្ថានជាអវិជ្ជមានត្រូវបានរំពឹងទុក EMPs ជាក់លាក់តាមទីតាំងនឹងត្រូវបានរៀបចំឡើងសម្រាប់ទីតាំងក្នុងអនុគម្រោងនោះ។

**ESMF ស្នើឲ្យមានទម្រង់ពិនិត្យជ្រើសរើសកែសម្រួលឡើងវិញ (ដោយផ្អែកលើឯកសាររបស់ក្រសួងអប់រំ យុវជន និងកីឡា**) សម្រាប់អនុគម្រោង ហើយដាក់បញ្ចូលព័ត៌មានពាក់ព័ន្ធស្តីពីការគ្រប់គ្រងបរិស្ថាន និងបញ្ហាសង្គមនៅក្នុងគម្រោង។ EMP គ្របដណ្តប់លើវិធានការកាត់បន្ថយសម្រាប់ផលប៉ះពាល់ទូទៅលើសំណង់សាលារៀន និងប្រតិបត្តិការទាក់ទងជាមួយសកម្មភាពនានា និងបទបញ្ញត្តិសម្រាប់ឱកាសរកនីតិវិធីដើម្បីឆ្លើយតបជាមួយធនធានវប្បធម៌រូបវន្តក្នុងអំឡុងពេលការអនុវត្ត។ ESMF និង EMP មានចំណុចតម្រូវលម្អិតសម្រាប់អ្នកម៉ៅការសាងសង់ដើម្បីឆ្លើយតបជាមួយបញ្ហារួមទាំងការគ្រប់គ្រងធូលី និងសម្លេងដែលបង្កឡើងពីការសាងសង់ ការគ្រប់គ្រងកាកសំណល់ ការគ្រប់គ្រងការដ្ឋាន ការគ្រប់គ្រងសុវត្ថិភាព ការផ្តល់ទឹកស្អាត និងបរិក្ខារអនាម័យ ការបោសសម្អាតគ្រាប់មិនទាន់ផ្ទុះ និងការគ្រប់គ្រងលើកំទេចសម្ភារៈមានផ្ទុកជាតិអាបេតូស (asbestos)។ ESMF និង EMP ត្រូវបានពិនិត្យឡើងវិញដោយក្រុមធនាគារ និងចែករំលែកជាមួយគណៈកម្មាការដោះស្រាយផលប៉ះពាល់អន្តរក្រសួង (IRC) ដើម្បីសុំយោបល់ត្រឡប់។ ដូចគ្នានេះដែរ ឧបករណ៍នានាត្រូវបានពិនិត្យឡើងវិញ និងសម្អាតដោយលេខាធិការដ្ឋានការពារសុវត្ថិភាពថ្នាក់តំបន់ (RSS) ក្នុងខែ វិច្ឆិកា ឆ្នាំ ២០១៦។ ឧបករណ៍ត្រូវបានបង្ហាញជាសាធារណៈ នៅថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៦ នៅក្រុងភ្នំពេញលើក្តារខៀនព័ត៌មានសាធារណៈរបស់ក្រសួងអប់រំ យុវជន និងកីឡា (ជាភាសាខ្មែរ) ក៏ដូចជានៅលើគេហទំព័រ InfoShop របស់ធានាគារនៅថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ។

**ទិដ្ឋភាពផ្នែកសង្គម OP/BP 4.10 របស់ធនាគារស្តីពីជនជាតិដើមភាគតិច និង OP/BP 4.12** ត្រូវបានលើកឡើង។ ទីតាំងសាងសង់ដែលត្រូវបានស្នើឡើងនៅក្រោមគម្រោងត្រូវបានកំណត់ឡើង និងរួមមានតំបន់មួយចំនួនដែលមានប្រជាជនពុំមែនជាជាតិពិន្ទុខ្មែរ ឬ "ជនជាតិដើមភាគតិច" ឬរស់នៅដូចមានកំណត់ក្នុង OP/BP 4.10។ ពុំមានការធ្វើលទ្ធកម្មដីធ្លីពាក់ព័ន្ធទេ ប៉ុន្តែទំនងជាស្ថិតក្នុងទម្រង់នៃការបរិច្ចាគដីដោយស្ម័គ្រចិត្ត។ ការវាយតម្លៃផ្នែកសង្គម (SA) ត្រូវបានធ្វើឡើងក្នុងខែ មេសា ឆ្នាំ ២០១៦ ដើម្បីវាយតម្លៃលើផលប៉ះពាល់ជាវិជ្ជមាន និងអវិជ្ជមានជាសក្តានុពលរបស់គម្រោងលើសហគមន៍ជនជាតិដើមភាគតិច និងដើម្បីពិនិត្យលើជម្រើសជំនួសដែលគម្រោងអាចមាន។ ការទស្សនកិច្ចទៅមូលដ្ឋានក្នុងខេត្តគំរូ (កំពត កំពង់ស្ពឺ បន្ទាយមានជ័យ និងរតនគិរី) ត្រូវបានធ្វើឡើង ហើយការពិគ្រោះយោបល់ដោយសេរី ជាមុន និងមានព័ត៌មានត្រឹមត្រូវជាមួយឃុំមួយចំនួនរបស់ជនជាតិដើមភាគតិច ត្រូវបានធ្វើឡើងក្នុងអំឡុងពេលលំហាត់ការវាយតម្លៃផ្នែកសង្គមនេះ។ ក្របខណ្ឌការងារការធ្វើផែនការរបស់ជនជាតិដើមភាគតិច (IPPF) ត្រូវបានរៀបចំឡើង ហើយដាក់បង្ហាញនៅថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៦ នៅក្រុងភ្នំពេញលើក្តារខៀនព័ត៌មានសាធារណៈរបស់ក្រសួងអប់រំ យុវជន និងកីឡា (ជាភាសាខ្មែរ) និងនៅថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៦ នៅទីក្រុងវ៉ាស៊ីនតោន ឌីស៊ី នៅលើគេហទំព័រ។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ៖ ឧបករណ៍វាយតម្លៃការអនុវត្តសាលារៀនផ្អែកតាមស្តង់ដាសាលារៀនមានប្រសិទ្ធភាព

ឈ្មោះសាលារៀន៖....................... លេខកូដ៖......................... ឃុំ/សង្កាត់៖..........................

ក្រុង/ស្រុក/ខណ្ឌ៖............................ រាជធានី/ខេត្ត៖...............................................................

| # | ស្តង់ដានិងសូចនាករ | | ពិន្ទុសម្រេចបានធៀបនឹងក្រុមគោលដៅ | | |
|---|---|---|---|---|---|
| | | | ពិន្ទុ ១ | ពិន្ទុ ២ | ពិន្ទុ ៣ |
| **ស្តង់ដា ១ វត្តុបំណងគោលនយោបាយសាលារៀន** | | | | | |
| # | សូចនាករ | | សម្រេចតិចជាងផែនការ = ១ | សម្រេចដូចផែនការ = ២ | សម្រេចលើសផែនការ = ៣ |
| 1.1 | ចូលរៀន ត្រួតថ្នាក់ បោះបង់ និងឡើងថ្នាក់ (ចំនួនសិស្ស) | *ចូលរៀន* | | | |
| | | *ត្រួតថ្នាក់* | | | |
| | | *បោះបង់* | | | |
| | | *ឡើងថ្នាក់* | | | |
| 1.2 | ភាគរយសិស្សសម្រេចផលសិក្សាចុងឆ្នាំសិក្សាជាពិន្ទុច្រើនជាង៦០%នៃពិន្ទុសរុបលើមុខវិជ្ជាគោលនីមួយៗ | *ភាសាខ្មែរ* | | | |
| | | *គណិតវិទ្យា* | | | |
| | | *ភាសាបរទេស* | | | |
| 1.3 | ភាគរយសិស្សសម្រេចផលសិក្សាចុងឆ្នាំសិក្សាជាពិន្ទុច្រើនជាង៦០%នៃពិន្ទុសរុបលើមុខវិជ្ជាគោលនីមួយៗ(លើមុខវិជ្ជាវិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម ប្រវត្តិវិទ្យា) | *រូបវិទ្យា* | | | |
| | | *គីមីវិទ្យា* | | | |
| | | *ជីវវិទ្យា* | | | |
| | | *ផែនដីវិទ្យា* | | | |
| | | *ប្រវត្តិវិទ្យា* | | | |
| | | *ICT* | | | |
| 1.4 | រភាគរយសិស្សថ្នាក់ទី៩សម្រេចបានល្បឿនអានភាសាខ្មែរក្នុង១នាទីនិងយល់ភាសា | | | | |
| 1.5 | ភាគរយសិស្សថ្នាក់ទី៩ប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ | | | | |
| **ពិន្ទុសរុបស្តង់ដាទី១** | | | 14 | 28 | 42 |
| សម្គាល់៖ ពិន្ទុស្តង់ដាអប្បបរមាគឺ៦៥% មានន័យថាស្តង់ដានេះត្រូវមានពិន្ទុយ៉ាងតិច២៧ ដើម្បីបំពេញ បាននូវ ស្តង់ដាអប្បបរមា | | | | | |

| ស្តង់ដា ២៖ ការបង្រៀន និងការរៀន | | | | |
|---|---|---|---|---|
| 2.1 | មានបំណែងចែកកម្មវិធីសិក្សាតាមមុខវិជ្ជា(ឆ្នាំ) | ១ទៅ៤មុខវិជ្ជាមានកម្មវិធីសិក្សា | ៥ទៅ៨មុខវិជ្ជាមានកម្មវិធីសិក្សា | លើ៨មុខវិជ្ជាមានមានកម្មវិធីសិក្សា |
| 2.2.1 | ចំនួនកិច្ចតែងការបង្រៀនបានរៀបចំតាមមុខវិជ្ជាគោល (ភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម / ប្រវត្តិវិទ្យា) ថ្នាក់ទី៧ ទៅតាមក្រុមគោលដៅឆ្នាំ | ២មុខវិជ្ជាសម្រេចបានតាមផែនការ | ៣ទៅ៤មុខវិជ្ជាសម្រេចបានតាមផែនការ | លើ៤មុខវិជ្ជាសម្រេចបានតាមផែនការ |
| 2.2.2 | ចំនួនកិច្ចតែងការបង្រៀនបានរៀបចំតាមមុខវិជ្ជាគោល (ភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម / ប្រវត្តិវិទ្យា) ថ្នាក់ទី៨ ទៅតាមក្រុមគោលដៅឆ្នាំ | ២មុខវិជ្ជាសម្រេចបានតាមផែនការ | ៣ទៅ៤មុខវិជ្ជាសម្រេចបានតាមផែនការ | លើ៤មុខវិជ្ជាសម្រេចបានតាមផែនការ |
| 2.2.3 | ចំនួនកិច្ចតែងការបង្រៀនបានរៀបចំតាមមុខវិជ្ជាគោល (ភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម / ប្រវត្តិវិទ្យា) ថ្នាក់ទី៩ ទៅតាមក្រុមគោលដៅឆ្នាំ | ២មុខវិជ្ជាសម្រេចបានតាមផែនការ | ៣ទៅ៤មុខវិជ្ជាសម្រេចបានតាមផែនការ | លើ៤មុខវិជ្ជាសម្រេចបានតាមផែនការ |
| 2.3 | ចំនួនសិស្សថ្នាក់ទី៩មានពិនិត្ទុតេស្តជាប់ស្តង់ដាល្បឿនអំណាននិងយល់ខ្លឹមសារ (២០០ពាក្យក្នុងមួយនាទី) (ត្រូវពិនិត្យតាមដាននៅចុង ឆមាសទី១ និងទី២) | តិចជាង៦០%នៃសិស្សសរុបមានពិន្ទុជាប់ស្តង់ដា | ពី៦០%ទៅ៨០%នៃសិស្សសរុបមានពិន្ទុជាប់ស្តង់ដា | លើ៨០%នៃសិស្សសរុបមានពិន្ទុជាប់ស្តង់ដា |
| 2.4.1 | ចំនួនសិស្សថ្នាក់ទី៧មានពិន្ទុតេស្តជាប់លើមុខវិជ្ជាគោលធៀបជាមួយក្រុមគោលដៅគ្រោងទុក (ត្រូវពិនិត្យតាមដាននៅចុងឆមាសទី១និងទី២) | តិចជាង៦០%នៃសិស្សសរុបមានពិន្ទុជាប់ស្តង់ដា | ពី៦០%ទៅ៨០%នៃសិស្សសរុបមានពិន្ទុជាប់ស្តង់ដា | លើ៨០%នៃសិស្សសរុបមានពិន្ទុជាប់ស្តង់ដា |
| 2.4.2 | ចំនួនសិស្សថ្នាក់ទី៨មានពិន្ទុតេស្តជាប់លើមុខវិជ្ជាគោលធៀបជាមួយក្រុមគោលដៅគ្រោងទុក (ត្រូវពិនិត្យតាមដាននៅចុងឆមាសទី១និងទី២) | តិចជាង៦០%នៃសិស្សសរុបមានពិន្ទុជាប់ស្តង់ដា | ពី៦០% ទៅ ៨០%នៃសិស្សសរុបមានពិន្ទុជាប់ស្តង់ដា | លើ៨០%នៃសិស្សសរុបមានពិន្ទុជាប់ស្តង់ដា |
| 2.4.3 | ចំនួនសិស្សថ្នាក់ទី៩មានពិន្ទុតេស្តជាប់លើមុខវិជ្ជាគោលធៀបជាមួយក្រុមគោលដៅគ្រោងទុក (ត្រូវពិនិត្យតាមដាននៅចុងឆមាសទី១ និងទី២) | តិចជាង៦០%នៃសិស្សសរុបមានពិន្ទុជាប់ស្តង់ដា | ពី៦០%ទៅ៨០%នៃសិស្សសរុបមានពិន្ទុជាប់ស្តង់ដា | លើ៨០%នៃសិស្សសរុបមានពិន្ទុជាប់ស្តង់ដា |
| 2.5 | ភាគរយសិស្សថ្នាក់ទី៩ប្រឡងជាប់ការប្រឡងឆមាស (ត្រូវពិនិត្យតាមដាននៅចុងឆមាសទី១និងទី២) | ទាបជាងក្រុមគោលដៅគ្រោងទុក | ភាគសម្រេចបានតានក្រុមគោលដៅគ្រោងទុក | សម្រេចបានលើសក្រុមគោលដៅគ្រោងទុក |

| | | | | |
|---|---|---|---|---|
| 2.7 | ចំនួនថ្នាក់មានការប្រជុំរវាងគ្រូបង្រៀន មាតាបិតា និង សិស្សរៀនយឺត (សិស្សត្រួតថ្នាក់ពីឆ្នាំមុន សិស្សដែលមាន ពិន្ទុទាបជាង៦០%ពីចុងឆ្នាំសិក្សាមុន និងនៅបំណាច់ខែទី១) ធៀបជាមួយក្រុមគោលដៅ | ចំនួនសិស្សរៀនយឺតក្រោម៣០% ចូលរួមប្រជុំ | ចំនួនសិស្សរៀនយឺតពី ៣០% ទៅ ៦០% ចូលរួមប្រជុំ | ចំនួនសិស្សរៀនយឺតលើ៦០% ចូលរួមប្រជុំ |
| 2.8.1 | កង្វះចំនួនម៉ោងបង្រៀនជាមធ្យមនៃថ្នាក់ទី៧ (ត្រូវពិនិត្យតាមដាននៅចុងឆមាសទី១និងទី២) | កង្វះម៉ោងបង្រៀនច្រើនជាង៥០ម៉ោង | កង្វះម៉ោងបង្រៀនច្រើនពី៣០ទៅ៥០ម៉ោង | កង្វះម៉ោងបង្រៀនតិចជាង៣០ម៉ោង |
| 2.8.2 | កង្វះចំនួនម៉ោងបង្រៀនជាមធ្យមនៃថ្នាក់ទី៨ (ត្រូវពិនិត្យតាមដាននៅចុងឆមាសទី១និងទី២) | កង្វះម៉ោងបង្រៀនច្រើនជាង៥០ម៉ោង | កង្វះម៉ោងបង្រៀនច្រើនពី៣០ទៅ៥០ម៉ោង | កង្វះម៉ោងបង្រៀនតិចជាង៣០ម៉ោង |
| 2.8.3 | កង្វះចំនួនម៉ោងបង្រៀនជាមធ្យមនៃថ្នាក់ទី៩ (ត្រូវពិនិត្យតាមដាននៅចុងឆមាសទី១និងទី២) | កង្វះម៉ោងបង្រៀនច្រើនជាង៥០ម៉ោង | កង្វះម៉ោងបង្រៀនច្រើនពី៣០ទៅ៥០ម៉ោង | កង្វះម៉ោងបង្រៀនតិចជាង៣០ម៉ោង |
| 2.9.1 | ភាគរយសិស្សអវត្តមានតិចជាង៥ដង | ថយចុះ៣០% ទាបជាងត្រីមាសទី១ | ថយចុះ៣០% ទៅ៥០%ទាបជាងត្រីមាសទី១ | ថយចុះលើ៥០%ទាបជាងត្រីមាសទី១ |
| 2.9.2 | ភាគរយសិស្សអវត្តមានពី៥ទៅ១០ដង | ថយចុះ៣០% ទាបជាងត្រីមាសទី១ | ថយចុះ៣០% ទៅ៥០%ទាបជាងត្រីមាសទី១ | ថយចុះលើ៥០%ទាបជាងត្រីមាសទី១ |
| 2.9.3 | ភាគរយសិស្សអវត្តមានច្រើនជាង១០ដង | ថយចុះ៣០% ទាបជាងត្រីមាសទី១ | ថយចុះ៣០% ទៅ៥០%ទាបជាងត្រីមាសទី១ | ថយចុះលើ៥០%ទាបជាង ត្រីមាសទី១ |
| 2.10.1 | ភាគរយសិស្សថ្នាក់ទី៧បានទទួលលំហាត់ឬកិច្ចការផ្ទះដាក់ឱ្យតាមមុខវិជ្ជាគោល(ភាសាខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ) ធៀបជាមួយក្រុមគោលដៅ គ្រោងទុក | ២មុខវិជ្ជាសម្រេចក្រុមគោលដៅតាមផែនការ | ៣ទៅ៤មុខ-វិជ្ជាសម្រេចក្រុមគោលដៅតាមផែនការ | លើ៤មុខវិជ្ជាសម្រេចក្រុមគោលដៅតាមផែនការ |



| | | | | |
|---|---|---|---|---|
| 2.10.1 | ភាគរយសិស្សថ្នាក់ទី៧បានទទួលលំហាត់ឬ | ២មុខវិជ្ជា | ៣ទៅ៤មុខ- | លើ៤មុខវិជ្ជាសម្រេច |

| | | | | |
|---|---|---|---|---|
| | កិច្ចការផ្ទះដាក់ឱ្យតាមមុខវិជ្ជាគោល(ភាសាខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ) ធៀបជាមួយក្រុមគោលដៅ គ្រោងទុក | សម្រេចក្រុមគោលដៅតាមផែនការ | វិជ្ជាសម្រេចក្រុមគោលដៅតាមផែនការ | ក្រុមគោលដៅតាមផែនការ |
| 2.10.2 | ភាគរយសិស្សថ្នាក់ទី៨បានទទួលលំហាត់ឬកិច្ចការផ្ទះដាក់ឱ្យតាមមុខវិជ្ជាគោល(ភាសាខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ) ធៀបជាមួយក្រុមគោលដៅ គ្រោងទុក | ២មុខវិជ្ជាសម្រេចក្រុមគោលដៅតាមផែនការ | ៣ទៅ៤មុខ-វិជ្ជាសម្រេចក្រុមគោលដៅតាមផែនការ | លើ៤មុខវិជ្ជាសម្រេចក្រុមគោលដៅតាមផែនការ |
| 2.10.3 | ភាគរយសិស្សថ្នាក់ទី៩បានទទួលលំហាត់ឬកិច្ចការផ្ទះដាក់ឱ្យតាមមុខវិជ្ជាគោល(ភាសាខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ) ធៀបជាមួយក្រុមគោលដៅ គ្រោងទុក | ២មុខវិជ្ជាសម្រេចក្រុមគោលដៅតាមផែនការ | ៣ទៅ៤មុខ-វិជ្ជាសម្រេចក្រុមគោលដៅតាមផែនការ | លើ៤មុខវិជ្ជាសម្រេចក្រុមគោលដៅតាមផែនការ |
| 2.11.1 | ភាគរយសិស្សថ្នាក់ទី៧ បានទទួលកិច្ចការផ្ទះជា គម្រោងដាក់ឱ្យតាមមុខវិជ្ជាគោល (ភាសាខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ) ធៀបជាមួយក្រុម គោលដៅគ្រោងទុក | ២មុខវិជ្ជាសម្រេចក្រុមគោលដៅតាមផែនការ | ៣ទៅ៤មុខ-វិជ្ជាសម្រេចក្រុមគោល-ដៅតាមផែនការ | លើ៤មុខវិជ្ជាសម្រេចក្រុមគោលដៅតាមផែនការ |
| 2.11.2 | ភាគរយសិស្សថ្នាក់ទី៨បានទទួលកិច្ចការផ្ទះជា<br>គម្រោងដាក់ឱ្យតាមមុខវិជ្ជាគោល (ភាសាខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ) ធៀបជាមួយក្រុម គោលដៅគ្រោងទុក | ២មុខវិជ្ជាសម្រេចក្រុមគោលដៅតាមផែនការ | ៣ទៅ៤មុខ-វិជ្ជាសម្រេចក្រុមគោលដៅតាមផែនការ | លើ៤មុខវិជ្ជាសម្រេចក្រុមគោលដៅតាមផែនការ |
| 2.11.3 | ភាគរយសិស្សថ្នាក់ទី៩បានទទួលកិច្ចការផ្ទះជាគម្រោងដាក់ឱ្យតាមមុខវិជ្ជាគោល (ភាសាខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ) ធៀបជាមួយក្រុម គោលដៅគ្រោងទុក | ២មុខវិជ្ជាសម្រេចក្រុមគោលដៅតាមផែនការ | ៣ទៅ៤មុខវិជ្ជាសម្រេចក្រុមគោល-ដៅតាមផែនការ | លើ៤មុខវិជ្ជាសម្រេចក្រុមគោលដៅតាមផែនការ |
| 2.12 | ចំនួនគ្រូបង្រៀនក្រោមគោលដៅបានទទួលការ<br>បំប៉ននិងការជួយបង្រៀននៅនឹងកន្លែង | តិចជាង១ភាគ៣គ្រូក្រុមគោល-ដៅបានទទួលការបំប៉ន | រវាង១ភាគ៣ទៅ២ភាគ៣គ្រូក្រុមគោលដៅបានទទួលការបំប៉ន | ច្រើនជាង២ភាគ៣គ្រូក្រុមគោលដៅបានទទួលការបំប៉ន |
| 2.13 | ចំនួនថ្នាក់រៀនបានបំពេញរដ្ឋបាលថ្នាក់រៀន | តិចជាង | រវាង១ភាគ៣ | ច្រើនជាង២ភាគ៣ |

| | | | | |
|---|---|---|---|---|
| | តាមការណែនាំរបស់ក្រសួងធៀបជាមួយក្រុមគោលដៅ | ១ភាគ៣នៃថ្នាក់រៀនបានបំពេញរដ្ឋបាលថ្នាក់រៀន | ទៅ២ភាគ៣នៃថ្នាក់រៀនបានបំពេញរដ្ឋបាលថ្នាក់រៀន | នៃថ្នាក់រៀនបានបំពេញរដ្ឋបាលថ្នាក់រៀន |
| 2.14 | ភាគរយគ្រូបង្រៀនបើកថ្នាក់យឺតនិងបិទថ្នាក់មុនម៉ោងបានថយចុះធៀបជាមួយក្រុមគោលដៅ | មានទិន្ន-ន័យគ្រូបើកថ្នាក់យឺតនិងបិទថ្នាក់មុនម៉ោង | មានទិន្នន័យគ្រូបើកថ្នាក់យឺតនិងបិទថ្នាក់មុនម៉ោងនិងបាន ថយចុះធៀបជាមួយក្រុមគោលដៅ | មានទិន្នន័យគ្រូបើកថ្នាក់យឺតនិងបិទថ្នាក់មុនម៉ោងនិងមិនមានថ្នាក់បើកយឺតនិងបិទមុនម៉ោងទេ |
| 2.15 | ចំនួនមុខវិជ្ជាអប់រំកាយ កីឡា និងសិល្បៈបានបង្រៀនតាមក្រុមគោលដៅគ្រោង (សរុប១៨មុខវិជ្ជា) | ៥មុខវិជ្ជាបានបង្រៀន | រវាង៦ទៅ១០មុខវិជ្ជាបានបង្រៀន | លើ១០មុខវិជ្ជាបានបង្រៀន |
| ពិន្ទុសរុបស្តង់ដាទី២ | | ២៦ | ៥២ | ៧៨ |
| សម្គាល់៖ ពិន្ទុស្តង់ដាអប្បបរមាគឺ៦៥% មានន័យថាស្តង់ដានេះត្រូវមានពិន្ទុយ៉ាងតិច ៥១ ដើម្បីបំពេញ បាននូវស្តង់ដាអប្បបរមា | | | | |

| **ស្តង់ដាទី៣៖ មាតាបិតា និងសហគមន៍ជួយការសិក្សាសិស្ស** | | | | |
|---|---|---|---|---|
| 3.1 | ភាគរយថ្នាក់រៀនបានប្រជុំប្រឹក្សាយោបល់រវាងគ្រូបង្រៀន មាតាបិតា និងសិស្ស (នៅដើមឆ្នាំសិក្សានិងតាមត្រីមាស) | ៥០%នៃថ្នាក់ចុះក្រោមមានប្រជុំ | ពី៥០%ទៅ៨០%នៃថ្នាក់ចុះក្រោមមានប្រជុំ | ច្រើនជាង៨០%នៃថ្នាក់ចុះក្រោមមានប្រជុំ |
| 3.2 | ចំនួនប្រជុំគណៈកម្មការគ្រប់គ្រងសាលារៀន តាមការណែនាំ (ពេលបើកបវេសនកាល ចុងឆមាសទី១ និងទី២) | ប្រជុំតែពេលបើកបវេសនកាល | ប្រជុំពេលបើកបវេសនកាលនិងចុងឆមាសទី១ | ប្រជុំពេលបើកបវេសនកាលចុងឆមាសទី១ និងទី២ |
| 3.3 | ភាគរយសិស្សមករៀនយឺត | ថយចុះ៥០%ធៀបនឹងត្រីមាសមុន | ថយចុះពី៥០%ទៅ៧៥%ធៀបនឹងត្រីមាស | ថយចុះលើ៧៥%ធៀបនឹងត្រីមាសមុន |

| | | | | |
|---|---|---|---|---|
| | | | មុន | |

| | | | | |
|---|---|---|---|---|
| 3.4 | ភាគរយសិស្សបានធ្វើកិច្ចការផ្ទះឬកិច្ចការគម្រោង | ៥០%សិស្សបានធ្វើ | ពី៥១%ដល់៧៥%សិស្សបានធ្វើ | លើ៧៥%សិស្សបានធ្វើ |
| **ពិន្ទុសរុបស្តង់ដាទី៣** | | ៨ | ៨ | ១២ |
| សម្គាល់៖ ពិន្ទុស្តង់ដាអប្បបរមាគឺ៦៥% មានន័យថាស្តង់ដានេះត្រូវមានពិន្ទុយ៉ាងតិច ៨ ដើម្បីបំពេញបាននូវស្តង់ដាអប្បបរមា | | | | |

| **ស្តង់ដាទី៤៖ សិស្សនិងសេវាជួយសិស្ស** | | | | |
|---|---|---|---|---|
| 4.1 | ភាគរយសិស្សប្រើបណ្ណាល័យ (ពិនិត្យតាមដានរាល់ត្រីមាស) | គ្មានបណ្ណា-ល័យ ឬ តិច ជាង៣០% សិស្សប្រើ បណ្ណាល័យ | ពី៣០%ទៅ ៦០%សិស្សប្រើ បណ្ណាល័យ | ច្រើនជាង ៦០%សិស្ស ប្រើ បណ្ណាល័យ |
| 4.2 | ភាគរយសិស្សប្រើបន្ទប់ពិសោធន៍ | គ្មានបន្ទប់ពិសោធ-ន៍ឬតិចជាង៣០% សិស្សប្រើបន្ទប់ ពិសោធន៍ | ពី៣០% ទៅ ៦០%សិស្សប្រើ បន្ទប់ពិសោធន៍ | ច្រើនជាង ៦០%សិស្ស ប្រើ បន្ទប់ពិសោធន៍ |
| 4.3 | ភាគរយសិស្សប្រើកុំព្យូទ័រ | គ្មានកុំព្យូទ័រឬតិច ជាង៣០% សិស្ស ប្រើកុំព្យូទ័រ | ពី៣០% ទៅ ៦០%សិស្ស ប្រើកុំព្យូទ័រ | ច្រើនជាង ៦០%ភាគរយ សិស្សប្រើកុំព្យូទ័រ |
| 4.4 | ភាគរយថ្នាក់មានដំណើរការ (តាមការណែនាំរបស់ក្រសួង) ក្លឹបសិក្សាសិស្ស | ក្រោម៥០%នៃថ្នាក់ មានក្លឹបសិក្សាមាន ដំណើរការ | ពី៥០% ទៅ ៧៥%នៃថ្នាក់ មានក្លឹបសិក្សា មានដំណើរការ | កលើ៧៥%នៃ ថ្នាក់មានក្លឹប សិក្សាមាន ដំណើរការ |
| 4.5 | ភាគរយសិស្សខ្សោយគំហើញនិងខ្សោយស្តាប់បានទទួលការគាំទ្រដើម្បីរៀនបានប្រសើរ | មិនមានព័ត៌មាន ឬ៣០%នៃសិស្ស បានទទួលការការ គាំទ្រនិងជាប់ពិន្ទុ តេស្ត | ពី៣០%ទៅ ៥០%នៃសិស្ស បានទទួលការ ការគាំទ្រ និង ជាប់ ពិន្ទុតេស្ត | លើ៥០%នៃ សិស្សបាន ទទួលការការ គាំទ្រ និងជាប់ ពិន្ទុតេស្ត |
| 4.6 | ភាគរយសិស្សអាហារូបករណ៍បោះបង់ការសិក្សា | ច្រើនជាង១០% បោះបង់ | ៥%ទៅ១០% បោះបង់ | តិចជាង៥% បោះបង់ |

| | | | | |
|---|---|---|---|---|
| 4.7 | ចំនួនទស្សនកិច្ចសិក្សារបស់គ្រូបង្រៀន | ផែនការទស្សនកិច្ចបានរៀបចំតាមការណែនាំ | ផែនការទស្សនកិច្ចបានរៀបចំតាមការណែនាំ និងធ្វើទស្សនកិច្ចបាន១ដង | ផែនការទស្សនកិច្ចបានរៀបចំតាមការណែនាំ និងធ្វើទស្សនកិច្ចបាន២ដងឡើង |
| **ពិន្ទុសរុបស្តង់ដាទី៤** | | ៧ | ១៤ | ២១ |
| **សម្គាល់៖** ពិន្ទុស្តង់ដាអប្បបរមាគឺ៦៥% មានន័យថាស្តង់ដានេះត្រូវមានពិន្ទុយ៉ាងតិច ១៤ ដើម្បីបំពេញបាននូវស្តង់ដាអប្បបរមា | | | | |

| **ស្តង់ដាទី៥៖ ការដឹកនាំ និងការគ្រប់គ្រងសាលារៀន** | | | | |
|---|---|---|---|---|
| 5.1 | ចំនួនសូចនាកររដ្ឋបាលសាលារៀនបានបំពេញតាមការណែនាំរបស់ក្រសួង (សរុប១០សូចនាករ) | សម្រេចបានតែ៥ | សម្រេចបានពី ៦ ដល់ ៨ | សម្រេចបានពី ៩ ដល់ ១០ |
| 5.2 | ការអនុវត្តផែនការអធិការកិច្ចរបស់នាយក ឬនាយិកាឬនាយករងឬនាយិការង | មានផែនការអធិការកិច្ចនិងបានធ្វើអធិការកិច្ចតាមផែនការនៅត្រីមាសទី១ | មានផែនការអធិការកិច្ចនិងបានធ្វើអធិការកិច្ចតាមផែនការនៅត្រីមាសទី១ និងទី២ | មានផែនការអធិការកិច្ចនិងបានធ្វើអធិការ-កិច្ចតាមផែនការទាំង៣ត្រីមាស |
| 5.3 | ចំនួនការប្រជុំបច្ចេកទេសប្រចាំខែតាមការណែនាំរបស់ក្រសួង (សរុប៧ដងក្នុង១ឆ្នាំ) | បានប្រជុំតិចជាង៤ដង | បានប្រជុំពី៤ទៅ៥ដង | បានប្រជុំពី៦ទៅ៧ដង |
| 5.4 | ចំនួនដងបំប៉ននិងដឹកដៃធ្វើការងារនៅនឹងកន្លែងដល់នាយក និងគណៈកម្មការគ្រប់គ្រងសាលារៀន ដោយមន្ត្រីក្រសួង ដើម្បីកែលម្អសូចនាករគ្រប់គ្រងសាលារៀន | តិចជាង៥០%ចំនួនដងបំប៉នបានធ្វើធៀបនឹងក្រុមគោលដៅ | ពី៥០%ទៅ៨០%ចំនួនដងបំប៉នបានធ្វើធៀបនឹងក្រុមគោលដៅ | លើ៨០%ចំនួនដងបំប៉នបានធ្វើធៀបនឹងក្រុមគោលដៅ |
| 5.5 | ចំនួនគ្រូបង្រៀនបានបំពេញការងារប្រសើរជាងមុនតាមរយៈការវាយតម្លៃការអនុវត្តការងារប្រចាំឆ្នាំ | តិចជាង៣០%គ្រូបង្រៀនបានបំពេញការងារប្រសើរជាងមុន | ពី៣០%ទៅ៧០%គ្រូបង្រៀនបានបំពេញការងារប្រសើរជាងមុន | ច្រើនជាង៧០%គ្រូបង្រៀនបានបំពេញការងារប្រសើរជាងមុន |

| | | | | |
|---|---|---|---|---|
| 5.5 | ចំនួនគ្រូបង្រៀនបានបំពេញការងារប្រសើរជាងមុនតាមរយៈការវាយតម្លៃការអនុវត្តការងារប្រចាំឆ្នាំ | តិចជាង៣០% គ្រូបង្រៀនបានបំពេញការងារប្រសើរជាងមុន | ពី៣០%ទៅ ៧០%គ្រូបង្រៀន បានបំពេញការងារប្រសើរជាងមុន | ច្រើនជាង៧០% គ្រូបង្រៀនបានបំពេញការងារប្រសើរជាងមុន |
| 5.6 | ការបន្ថយភាពមិនប្រក្រតីនៅសាលារៀន (សរុប៩ភាពមិនប្រក្រតី) | តិចជាង៦ បានបន្ថយ | ពី៦ ទៅ៨ បានបន្ថយ | មិនមានភាពមិនប្រក្រតីទាំង៩ |
| 5.7 | ចំនួនដងពិនិត្យតាមដាននិងគាំទ្រពីថ្នាក់ស្រុក មន្ទីរ និងក្រសួង | សាលាបានទទួលការគាំទ្រដូចក្នុងផែនការនៅត្រីមាសទី១ | សាលាបានទទួលការគាំទ្រដូចក្នុងផែនការនៅត្រីមាសទី១ និងទី២ | សាលាបានទទួលការគាំទ្រដូចក្នុងផែនការទាំង៣ត្រីមាស |
| **សរុបពិន្ទុស្តង់ដាទី៥** | | **៧** | **១៤** | **២១** |
| **សម្គាល់៖** ពិន្ទុស្តង់ដាអប្បបរមាគឺ៦៥% មានន័យថាស្តង់ដានេះត្រូវមានពិន្ទុយ៉ាងតិច ១៤ ដើម្បីបំពេញបាននូវស្តង់ដាអប្បបរមា | | | | |

| | | | | |
|---|---|---|---|---|
| **ស្តង់ដាទី៦៖ ធនធានមនុស្ស** | | | | |
| 6.1 | គុណវុឌ្ឍិគ្រូបង្រៀនធៀបជាមួយផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន | សាលាមានស្ថិតិមន្ត្រី និងក្រោម៦០% មានគុណវុឌ្ឍិតាមផែនការ | កពី៦០% ទៅ ៧៥% មានគុណវុឌ្ឍិតាមផែនការ | លើ៧៥%មានគុណវុឌ្ឍិតាមផែនការ |
| 6.3 | ចំនួនគ្រូខ្វះមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម (ប្រវត្តិវិទ្យា) ចុះថយធៀបជាមួយបទដ្ឋាន | ចំនួនគ្រូខ្វះថយចុះ៤០% | ចំនួនគ្រូខ្វះថយចុះពី ៤០%ទៅ ៧៥% | ចំនួនគ្រូខ្វះថយចុះលើ ៧៥% |
| 6.4 | គុណវុឌ្ឍិនាយក ឬនាយិកាសាលារៀនធៀបជាមួយផែនការក្រសួង | នាយក ឬ នាយិកាមិនបានទទួលការចាត់តាំងជាផ្លូវការ តែមិនទាន់បានដំឡើងគុណវុឌ្ឍិ | នាយក ឬ នាយិកាបានទទួលការចាត់តាំងជាផ្លូវការ តែមិនទាន់បានដំឡើងគុណវុឌ្ឍិ | នាយក ឬ នាយិកាបានទទួលការចាត់តាំងជាផ្លូវការ និងបានដំឡើងគុណវុឌ្ឍិ |

| | | | |
|---|---|---|---|
| **ពិន្ទុសរុបស្តង់ដាទី៦** | **៣** | **៦** | **៩** |

**សម្គាល់៖** ពិន្ទុស្តង់ដាអប្បបរមាគឺ៦៥% មានន័យថាស្តង់ដានេះត្រូវមានពិន្ទុយ៉ាងតិច ៦ ដើម្បីបំពេញបាននូវស្តង់ដាអប្បបរមា

| **ស្តង់ដាទី៧៖ សៀវភៅសិក្សាគោល និងសម្ភារៈរៀន និងបង្រៀន** | | | | |
|---|---|---|---|---|
| 7.1 | ភាគរយសិស្សមានសៀវភៅសិក្សាគោលតាមមុខវិជ្ជានិងតាមកម្រិតថ្នាក់តាមបទដ្ឋាន | តិចជាង៥០%សិស្សមានសៀវភៅសិក្សាគោលតាមបទដ្ឋាន | ពី៥០%ទៅ៨០%សិស្សមានសៀវភៅសិក្សាគោលតាមបទដ្ឋាន | ច្រើនជាង៨០%សិស្សមានសៀវភៅសិក្សាគោលតាមបទដ្ឋាន |
| 7.2 | ចំនួនគ្រូបង្រៀនមុខវិជ្ជាគោលបានបំប៉នពីការប្រើប្រាស់សៀវភៅលំហាត់ | តិចជាង៤០%គ្រូបង្គោលបានបំប៉ន | ពី៤០%ទៅ៧៥%គ្រូបង្គោលបានបំប៉ន | លើ៧៥%គ្រូបង្គោលបានបំប៉ន |
| 7.3 | បណ្ណាល័យបានបង្កើត និងមានស្តង់ដា | បណ្ណាល័យមិនមានសៀវភៅនិងសង្ហារឹមតាមស្តង់ដា | បណ្ណាល័យមានសៀវភៅនិងសង្ហារឹមតាមស្តង់ដា | បណ្ណាល័យមានសៀវភៅ និង សង្ហារឹមនិងបើកប្រប្រាស់តាមស្តង់ដា |
| **ពិន្ទុសរុបស្តង់ដាទី៧** | | **៣** | **៦** | **៩** |

**សម្គាល់៖** ពិន្ទុស្តង់ដាអប្បបរមាគឺ៦៥% មានន័យថាស្តង់ដានេះត្រូវមានពិន្ទុយ៉ាងតិច ៦ ដើម្បីបំពេញបាននូវស្តង់ដាអប្បបរមា

| **ស្តង់ដាទី៨៖ ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន** | | | | |
|---|---|---|---|---|
| 8.1 | កង្វះបន្ទប់រៀនថយចុះរហូតមានចំនួនសិស្សក្នុងបន្ទប់រៀនតាមបទដ្ឋាន | កង្វះបន្ទប់រៀនដូចឆ្នាំមុន | បានទទួលអគារសិក្សាថ្មីតែបន្ទប់រៀននៅតែខ្វះ | បានទទួល អគារសិក្សាថ្មីបំពេញបានបទដ្ឋានសិស្សក្នុងបន្ទប់រៀន |
| 8.2 | បន្ទប់ស្នាក់នៅរបស់គ្រូបង្រៀនបានសាងសង់តាមតម្រូវការ | សំណើបន្ទប់ស្នាក់នៅសម្រាប់គ្រូបង្រៀនបានដាក់ស្នើ | បន្ទប់ស្នាក់នៅសម្រាប់គ្រូបង្រៀនបានផ្តល់តែនៅមិនទាន់គ្រប់ | បន្ទប់ស្នាក់នៅសម្រាប់គ្រូបង្រៀនបានផ្តល់គ្រប់គ្រាន់ |

| | | | | |
|---|---|---|---|---|
| 8.3 | បន្ទប់រដ្ឋបាលសាលារៀននិងសង្ហារឹមបានផ្តល់តាមតម្រូវការ | មានបន្ទប់សម្រាប់នាយកនិងនាយករង | មានបន្ទប់សម្រាប់នាយកនាយករង និងគ្រូបង្រៀន | មានបន្ទប់សម្រាប់នាយកនាយករងបុគ្គលិកបង្រៀននិងបុគ្គលិកមិនបង្រៀន |
| 8.4 | បន្ទប់ទឹកបានសាងសង់តាមស្តង់ដា និងគ្រប់គ្រាន់តាមបទដ្ឋានសម្រាប់សិស្សទាំងស្រីទាំងប្រុស | បន្ទប់ទឹកមានតែមិនតាមបទដ្ឋានសម្រាប់សិស្សស្រី និងប្រុស | បន្ទប់ទឹកមានតាមបទដ្ឋានសម្រាប់សិស្សស្រី និងប្រុស | បន្ទប់ទឹកមាន តែមិនតាមបទដ្ឋានសម្រាប់សិស្សស្រី និងប្រុស និងមានស្តង់ដា |
| 8.5 | សូចនាករបរិស្ថានសាលារៀនបានបំពេញ (សរុប១៦សូចនាករ) | មានតិចជាង១០សូចនាករបានបំពេញ | មាន១០ទៅ១២សូចនាករបានបំពេញ | មាន១៣ទៅ១៦សូចនាករបានបំពេញ |
| **ពិន្ទុស្តង់ដាទី៨** | | ៥ | ១០ | ១៥ |
| **សម្គាល់៖** ពិន្ទុស្តង់ដាអប្បបរមាគឺ៦៥% មានន័យថាស្តង់ដានេះត្រូវមានពិន្ទុយ៉ាងតិច ១០ ដើម្បីបំពេញបាននូវស្តង់ដាអប្បបរមា | | | | |

| | | | | |
|---|---|---|---|---|
| **ស្តង់ដាទី៩៖ ហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ** | | | | |
| 9.1 | ថវិកាសាលារៀន ពីប្រភពផ្សេងៗ បានទទួលជាក់ស្តែងតាមត្រីមាស មានភាពប្រសើរឡើង | បរិមាណថវិកាទទួលតិចជាងគ្រោងនិងមិនទាន់ពេល | បរិមាណថវិកាទទួលតាមគ្រោងតែមិនទាន់ពេល | បរិមាណថវិកាទទួលតាមគ្រោងនិងទាន់ពេល |
| 9.2 | ការចាត់ចែង ការប្រើប្រាស់ និតម្លាភាពថវិកាសាលារៀនបានប្រសើរ (សរុប៥សូចនាករ) | មានតែ២សូចនាករបានបំពេញ | ៣ទៅ៤សូចនាករបានបំពេញ | សូចនាករទាំង៥បានបំពេញ |
| 9.3 | ការរាយការណ៍ការចំណាយតាមខ្ទង់ចំណាយធំៗ (រដ្ឋបាល ការបង្រៀននិងរៀន និង បរិស្ថាន) បានប្រសើរដោយផ្តោតការចំណាយលើការបង្រៀននិងរៀន | ចំណាយតិចជាង៤០%លើការបង្រៀននិងរៀន | ចំណាយតិចជាង៤០%ទៅ៥៥%លើការបង្រៀន-រៀន | ចំណាយច្រើនជាង៥៥%លើការបង្រៀននិងរៀន |
| **ពិន្ទុសរុបស្តង់ដាទី៩** | | ៣ | ៦ | ៩ |
| **សម្គាល់៖** ពិន្ទុស្តង់ដាអប្បបរមាគឺ៦៥% មានន័យថាស្តង់ដានេះត្រូវមានពិន្ទុយ៉ាងតិច ៦ ដើម្បីបំពេញបាននូវ ស្តង់ដាអប្បបរមា | | | | |
| **សម្គាល់៖** ពិន្ទុស្តង់ដាអប្បបរមាគឺ៦៥% មានន័យថាស្តង់ដាទាំង៩នេះ ត្រូវមានពិន្ទុយ៉ាងតិច១៤០ពិន្ទុ ដើម្បីបំពេញ បាននូវស្តង់ដាអប្បបរមាសាលារៀនមានប្រសិទ្ធភាព | | | | |

## ទម្រង់៖ សំណើរបស់មន្ទីរ/ការិយាល័យអប់រំ យុវជន និងកីឡា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

មន្ទីរ/ការិយាល័យអប់រំ យុវជន និងកីឡា
លេខ:.................................

**ប្រធានមន្ទីរ/ការិយាល័យអប់រំ យុវជន និងកីឡា** …………………………..
**សូមគោរព**
**ឯកឧត្តមនាយកគម្រោងកែលម្អការអប់រំមធ្យមសិក្សា**

**តាមរយៈ៖** សំណើសុំថវិកាកែលម្អសាលារៀនចំនួន...................(........................)
**កម្មវត្ថុ៖** សំណើសុំថវិកាកែលម្អសាលារៀនចំនួន...................(........................)
**យោង៖** សេចក្តីណែនាំពីការគ្រប់គ្រងតាមសាលារៀន

មន្ទីរ/ការិយាល័យអប់រំ យុវជន និងកីឡាបានរៀបចំសំណើ និងសូមដាក់ជូនសំណើដូច ខាងក្រោមនេះដល់គណ:កម្មការគ្រប់គ្រងអនុវិស័យពិនិត្យ និងសម្រេច។

**ឯកសារសំណើមាន៖**
១. របាយការណ៍វាយតម្លៃការអនុវត្តការងាររបស់មន្ទីរ/ការិយាល័យអប់រំ យុវជន និងកីឡា
២. ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់មន្ទីរ/ការិយាល័យអប់រំ យុវជន និងកីឡា

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើសូមឯកឧត្តមមេត្តាពិនិត្យ និងសម្រេចដោយសេចក្តីអនុគ្រោះ។

សូមឯកឧត្តមនាយកគម្រោងមេត្តាទទួលនូវសេចក្តីគោរពអំពីខ្ញុំ

ធ្វើនៅ........................... ថ្ងៃទី……ខែ.............ឆ្នាំ២០....

ប្រធានមន្ទីរ/ប្រធានការិយាល័យ

## ឧបសម្ព័ន្ធ៖ ឧបករណ៍វាយតម្លៃរបស់ថ្នាក់ជាតិប្រើប្រាស់វាយតម្លៃការបំពេញការងាររបស់មន្ទីរអប់រំ យុវជន និងកីឡា

**រាជធានី ខេត្ត ……………………………………………ឆ្នាំ……………….**

| កិច្ចការចម្បងៗ | ពិន្ទុរីកចម្រើន | | | | |
|---|---|---|---|---|---|
| | ទាបខ្លាំង= ១ | ទាប= ២ | មធ្យម=៣ | ល្អ=៤ | ល្អប្រសើរ=៥ |
| ១. ការធ្វើផែនការយុទ្ធ-សាស្ត្រថវិកា ផែនការ ប្រតិបត្តិឆ្នាំ និង ការអនុវត្ត ផែនការ | មិនមានផែនការយុទ្ធសាស្ត្រថវិកា ឬផែនការប្រតិបត្តិឆ្នាំ ឬមួយមាន តែមិនតាមប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផល | ផែនការបានរៀបចំតាមប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផលតែសកម្មភាពចំនួនពី០ទៅ២៥%បានអនុវត្ត | ផែនការបានរៀបចំតាមប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផលតែសកម្មភាពចំនួនពី២៥%ទៅ៥០%បានអនុវត្ត | ផែនការបានរៀបចំតាមប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផលតែសកម្មភាពចំនួនពី៥១%ទៅ៧៥%បានអនុវត្ត | ផែនការបានរៀបចំតាមប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផលតែសកម្មភាពចំនួនពី៧៦%ឡើងបានអនុវត្ត |
| **សម្គាល់៖** សរសេរពិន្ទុវាយតម្លៃនៅទីនេះ..................... ហើយអធិប្បាយពីស្ថានភាពនៃកិច្ចការតាមការវាយតម្លៃ និងកំណត់ពិន្ទុក្រុមគោលដៅ និងស្ថានភាពនៃកិច្ចការជាផែនការសម្រាប់ឆ្នាំសិក្សាបន្ទាប់................................................................................................................................................................ | | | | | |
| ២.ការគ្រប់គ្រងមន្ត្រី (ការពង្រាយគ្រូ) | មិនមានទិន្នន័យពីគ្រូខ្វះ ឬលើស ឬមួយមានតែមិនមាន បច្ចុប្បន្នភាព | មានទិន្នន័យបច្ចុប្បន្នភាពពីគ្រូខ្វះឬលើស តែមិនមានផែនការសកម្មភាពដោះស្រាយ | មានទិន្នន័យបច្ចុប្បន្នភាពពីគ្រូខ្វះ ឬ លើស មានផែនការសកម្មភាពនិងចាប់ផ្តើមដោះស្រាយ | មានទិន្នន័យបច្ចុប្បន្នភាពពីគ្រូខ្វះ ឬ លើស មានផែនការសកម្មភាពនិង ហើយគ្រូខ្វះ ឬលើសថយចុះ | មានទិន្នន័យបច្ចុប្បន្នភាពពីគ្រូខ្វះ ឬ លើស មានផែនការសកម្មភាពនិង មិនមានបញ្ហាពីគ្រូខ្វះឬលើយ |
| **សម្គាល់៖** សរសេរពិន្ទុវាយតម្លៃនៅទីនេះ..................... ហើយអធិប្បាយពីស្ថានភាពនៃកិច្ចការតាមការវាយតម្លៃ និងកំណត់ពិន្ទុក្រុមគោលដៅ និងស្ថានភាពនៃកិច្ចការជាផែនការសម្រាប់ឆ្នាំសិក្សាបន្ទាប់................................................................................................................................................................ | | | | | |

| | | | | | |
|---|---|---|---|---|---|
| ៣. ការគ្រប់គ្រងសៀវភៅសិក្សាគោល | មិនមានទិន្នន័យពីសៀវភៅសិក្សាគោលត្រូវការ ឬមួយមានតែមិនមានបច្ចុប្បន្នភាព | មានទិន្នន័យបច្ចុប្បន្នភាពពីសៀវភៅសិក្សាគោលត្រូវការតែមិនមានផែនការសកម្មភាពដោះស្រាយ | មានទិន្នន័យបច្ចុប្បន្នភាពពីសៀវភៅសិក្សាគោលត្រូវការមានផែនការសកម្មភាពនិងចាប់ផ្តើមដោះស្រាយ | មានទិន្នន័យបច្ចុប្បន្នភាពពីសៀវភៅសិក្សាគោលត្រូវការមានផែនការសកម្មភាពនិងសៀវភៅលើសឬខ្វះថយចុះ | មានទិន្នន័យបច្ចុប្បន្នភាពពីសៀវភៅសិក្សាគោលត្រូវការមានផែនការសកម្មភាពនិងមិនមានបញ្ហាសៀវភៅលើស |
| **សម្គាល់៖** សរសេរពិន្ទុវាយតម្លៃនៅទីនេះ..................... ហើយអធិប្បាយពីស្ថានភាពនៃកិច្ចការតាមការវាយតម្លៃ និងកំណត់ពិន្ទុក្រុមគោលដៅ និងស្ថានភាពនៃកិច្ចការជាផែនការសម្រាប់ឆ្នាំសិក្សាបន្ទាប់........................................................................................................................................................................................................ | | | | | |
| ៤. ការគ្រប់គ្រង និងហេដ្ឋា-រចនាសម្ព័ន្ធសាលារៀន | មិនមានទិន្នន័យពីតម្រូវការអគារសិក្សា ឬ មួយមានតែមិនមានបច្ចុប្បន្នភាព | មានទិន្នន័យមានបច្ចុប្បន្នភាពបានប្រើទិន្នន័យស្នើសុំអគារសិក្សាដល់ក្រសួង | មានទិន្នន័យមានបច្ចុប្បន្នភាពបានប្រើទិន្នន័យស្នើសុំអគារសិក្សាដល់មន្ទីរ និងបានប្រើទិន្នន័យកសាងផែនការសាងសង់របស់ការិយាល័យ | មានទិន្នន័យមានបច្ចុប្បន្នភាពបានប្រើទិន្នន័យស្នើសុំអគារសិក្សាដល់មន្ទីរ និងបានប្រើទិន្នន័យកសាងផែនការសាងសង់របស់ការិយាល័យ និងបានទាក់ទងសហគមន៍និងដៃគូសម្រាប់រកមូលនិធិ | មានទិន្នន័យមានបច្ចុប្បន្នភាពបានប្រើទិន្នន័យស្នើសុំអគារសិក្សាដល់មន្ទីរ និងបានប្រើទិន្នន័យកសាងផែនការសាងសង់របស់ការិយាល័យ និងបានទាក់ទងសហគមន៍និងដៃគូសម្រាប់រកមូលនិធិ ហើយ កង្វះអគារសិក្សាថយចុះ |
| **សម្គាល់៖** សរសេរពិន្ទុវាយតម្លៃនៅទីនេះ..................... ហើយអធិប្បាយពីស្ថានភាពនៃកិច្ចការតាមការវាយតម្លៃ និងកំណត់ពិន្ទុក្រុមគោលដៅ និងស្ថានភាពនៃកិច្ចការជាផែនការសម្រាប់ឆ្នាំសិក្សាបន្ទាប់........................................................................................................................................................................................................ | | | | | |
| ៥.ការពិនិត្យតាមដាន និងវាយតម្លៃ | មិនមានផែនការពិនិត្យតាមដាន ឬមួយមានតែមិនតាមប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើលទ្ធផល | មានផែនការតាមប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផល ពិនិត្យតាមដាន២ដងក្នុងមួយឆ្នាំក្នុងមួយក្រុង ស្រុក ខណ្ឌបានចំនួន២៥%នៃចំនួនក្រុង ស្រុក ខណ្ឌសរុប | មានផែនការតាមប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផល ពិនិត្យតាមដាន២ដងក្នុងមួយឆ្នាំក្នុងមួយក្រុង ស្រុក ខណ្ឌបានចំនួន២៦%ទៅ៥០%នៃចំនួនក្រុង ស្រុក ខណ្ឌសរុប | មានផែនការតាមប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផល ពិនិត្យតាមដាន២ដងក្នុងមួយឆ្នាំក្នុងមួយក្រុង ស្រុក ខណ្ឌបានចំនួន៥១%ទៅ៧០%នៃចំនួនក្រុង ស្រុក ខណ្ឌសរុប | មានផែនការតាមប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផល ពិនិត្យតាមដាន២ដងក្នុងមួយឆ្នាំក្នុងមួយស្រុកបានចំនួនលើ៧០%នៃចំនួនក្រុង ស្រុក ខណ្ឌសរុប |

| | | | | | |
|---|---|---|---|---|---|
| **សម្គាល់៖** សរសេរពិន្ទុវាយតម្លៃនៅទីនេះ..................... ហើយអធិប្បាយពីស្ថានភាពនៃកិច្ចការតាមការវាយតម្លៃ និងកំណត់ពិន្ទុក្រុមគោលដៅ និងស្ថានភាពនៃកិច្ចការជាផែនការសម្រាប់ឆ្នាំសិក្សាបន្ទាប់.................................................................................................................................................................................................................................................................................... | | | | | |
| ៦. ការគ្រប់គ្រងហិរញ្ញវត្ថុ | ថវិកាគ្រោងមិនបានរៀបចំពេញលេញទៅតាមសៀវភៅណែនាំពីការគ្រប់គ្រងហិរញ្ញ-វត្ថុរបស់ក្រសួងអប់រំ យុវជន និងកីឡា | ថវិកាគ្រោងបានរៀបចំពេញលេញទៅតាមសៀវភៅណែនាំពីការគ្រប់គ្រងតាមសាលារៀនរបស់ក្រសួង និងផ្អែកលើផែនការប្រតិបត្តិឆ្នាំរបស់មន្ទីរ | ថវិកាគ្រោងបានរៀបចំពេញលេញទៅតាមសៀវភៅណែនាំពីការគ្រប់គ្រងតាមសាលារៀនរបស់ក្រសួង និងផ្អែកលើផែនការប្រតិបត្តិឆ្នាំរបស់មន្ទីរ ហើយប្រាក់កែលម្អ សាលារៀននិងអាហារូបករណ៍បើកផ្តល់ទាន់ពេលនៅត្រីមាសទី១ និង ទី២ | ថវិកាគ្រោងបានរៀបចំពេញលេញទៅតាមសៀវភៅណែនាំពីការគ្រប់គ្រងតាមសាលារៀនរបស់ក្រសួង និងផ្អែកលើផែនការប្រតិបត្តិឆ្នាំរបស់មន្ទីរ ហើយប្រាក់កែលម្អ សាលារៀននិងអាហារូបករណ៍បើកផ្តល់ទាន់ពេលនៅត្រីមាសទី១ ទី២ និងទី៣ | ថវិកាគ្រោងបានរៀបចំពេញលេញទៅតាមសៀវភៅណែនាំពីការគ្រប់គ្រងតាមសាលារៀនរបស់ក្រសួង និងផ្អែកលើផែនការប្រតិបត្តិឆ្នាំរបស់មន្ទីរ ហើយប្រាក់កែលម្អ សាលារៀននិងអាហារូបករណ៍បើកផ្តល់ទាន់ពេលនៅគ្រប់ត្រីមាស |
| **សម្គាល់៖** សរសេរពិន្ទុវាយតម្លៃនៅទីនេះ..................... ហើយអធិប្បាយពីស្ថានភាពនៃកិច្ចការតាមការវាយតម្លៃ និងកំណត់ពិន្ទុក្រុមគោលដៅ និងស្ថានភាពនៃកិច្ចការជាផែនការសម្រាប់ឆ្នាំសិក្សាបន្ទាប់.................................................................................................................................................................................................................................................................................... | | | | | |
| ៧. ការពិនិត្យតាមដានការអនុវត្តរបស់ការិ.អប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ពិសេសលើផលសម្រេចការសិក្សារបស់សិស្ស | មិនមានទិន្នន័យពីផលសម្រេចការសិក្សារបស់សិស្ស | មានទិន្នន័យពីផលសម្រេចការសិក្សារបស់សិស្ស | មិនមានទិន្នន័យពីផលសម្រេចការសិក្សារបស់សិស្ស និងបានប្រើសម្រាប់កសាងផែនការ-សកម្មភាពជួយដល់ការិ.យអក ក្រុង ស្រុក ខណ្ឌ | មិនមានទិន្នន័យពីផលសម្រេចការសិក្សារបស់សិស្ស និងបានប្រើសម្រាប់កសាងផែនការ-សកម្មភាពជួយដល់ការិ. យអក ក្រុង ស្រុក ខណ្ឌ និងបោះ-ផ្សាយព័ត៌មានដល់ការិ. យអក ក្រុង ស្រុក ខណ្ឌ | មិនមានទិន្នន័យពីផលសម្រេចការសិក្សារបស់សិស្ស និងបានប្រើសម្រាប់កសាងផែនការឥសកម្មភាពជួយដល់ការិ. យអក ក្រុង ស្រុក ខណ្ឌ និងបោះ ផ្សាយព័ត៌មានដល់ការិ. យអក ក្រុង ស្រុក ខណ្ឌ និងបានប្រើ សម្រាប់កសាងផែនការឆ្នាំបន្ទាប់ |

| | | | | | |
|---|---|---|---|---|---|
| **សម្គាល់៖** សរសេរពិន្ទុវាយតម្លៃនៅទីនេះ..................... ហើយអធិប្បាយពីស្ថានភាពនៃកិច្ចការតាមការវាយតម្លៃ និងកំណត់ពិន្ទុក្រុមគោលដៅ និងស្ថានភាពនៃកិច្ចការជាផែនការសម្រាប់ឆ្នាំសិក្សាបន្ទាប់.................................................................................................................................................................................. | | | | | |
| ៨.ការប្រើប្រាស់ថវិកាសាលារៀនតាមសៀវភៅណែនាំពីការគ្រប់គ្រងមានមូលដ្ឋាននៅសាលារៀន | សាលារៀនមានផែនការកែលម្អសាលារៀនប្រចាំឆ្នាំ តែមិនធ្វើតាមសៀវភៅណែនាំពីការគ្រប់គ្រងមានមូល-ដ្ឋាននៅសាលារៀន | ៣០% ទៅ ៥០% សាលារៀនមានផែនការកែលម្អសាលា-រៀនប្រចាំឆ្នាំ និងធ្វើតាមសៀវភៅណែនាំពីការគ្រប់គ្រងតាមសាលារៀន | ៥១% ទៅ ៧០% សាលារៀនមានផែនការកែលម្អសាលារៀនប្រចាំឆ្នាំ និងធ្វើតាមសៀវភៅណែនាំពីការគ្រប់គ្រងតាមសាលារៀន ហើយសហគមន៍ចូលរួមក្នុង ការធ្វើផែនការនិងគ្រោងថវិកា | ៥១% ទៅ ៧០% សាលារៀនមានផែនការកែលម្អសាលារៀនប្រចាំឆ្នាំ និងធ្វើតាមសៀវភៅណែនាំពីការគ្រប់គ្រងតាមសាលារៀន ហើយសហគមន៍ចូលរួមក្នុងការធ្វើផែនការនិងគ្រោងថវិកា តិចជាង៥០%នៃថវិកាចំណាយលើការបង្រៀននិងរៀន និង៧០%នៃសាលារៀន បិទផ្សាយទិន្នន័យថវិកានិងការចំណាយជាសាធារណៈ | ៥១% ទៅ ៧០% សាលារៀនមានផែនការកែលម្អសាលារៀនប្រចាំឆ្នាំ និងធ្វើតាមសៀវភៅណែនាំពីការគ្រប់គ្រងតាមសាលារៀន ហើយសហគមន៍ចូលរួមក្នុងការធ្វើផែនការនិងគ្រោងថវិកា តិចជាង៥០%នៃថវិកាចំណាយលើការបង្រៀននិងរៀន និងសាលាទាំងអស់រៀនបិទផ្សាយទិន្នន័យថវិកានិងការចំណាយជាសាថារណៈ |

| | | | | | |
|---|---|---|---|---|---|
| **សម្គាល់៖** សរសេរពិន្ទុវាយតម្លៃនៅទីនេះ..................... ហើយអធិប្បាយពីស្ថានភាពនៃកិច្ចការតាមការវាយតម្លៃ និងកំណត់ពិន្ទុក្រុមគោលដៅ និងស្ថានភាពនៃកិច្ចការជាផែនការសម្រាប់ឆ្នាំសិក្សាបន្ទាប់.................................................................................................................................................................................. | | | | | |
| ពិន្ទុស្តង់ដាសរុប | ៨ | ១៦ | ២៤ | ៣២ | ៤០ |
| **សរុបពិន្ទុជាក់ស្តែងឆ្នាំនេះ៖ ??** | | | | | |
| **សម្គាល់៖ មន្ទីរអប់រំដែលមានដំណើរការមានពិន្ទុសរុប ៨ទៅ ២២។ ពិន្ទុសរុបដែលមានដំណើរការគឺ ២៣ ទៅ ៣២ ។ ពិន្ទុសរុបដែលមានដំណើរការល្អប្រសើរគឺ ៣៣ ទៅ ៤០។** | | | | | |

## ឧបសម្ព័ន្ធ: ឧបករណ៍វាយតម្លៃរបស់មន្ទីរអប់រំប្រើប្រាស់វាយតម្លៃការបំពេញការងាររបស់ការិយាល័យអប់រំយុវជន និងកីឡា

**រាជធានី ខេត្ត ………………………………………………ឆ្នាំ………………..**

| កិច្ចការចម្បងៗ | **ពិន្ទុរីកចម្រើន** | | | | |
|---|---|---|---|---|---|
| | ទាបខ្លាំង៖ ១ | ទាប៖ ២ | មធ្យម៖ ៣ | ល្អ៖ ៤ | ល្អប្រសើរ៖ ៥ |
| **១. ផលសម្រេចការសិក្សារបស់សិស្ស** | មិនមានទិន្នន័យពីផលសម្រេចការសិក្សារបស់សិស្ស | មានទិន្នន័យពីផលសម្រេចការសិក្សារបស់សិស្ស តែមិនប្រើ សម្រាប់រៀបចំ ផែនការសកម្មភាព | មានទិន្នន័យពីផលសម្រេចការសិក្សារបស់សិស្ស បានប្រើសម្រាប់រៀបចំផែនការសកម្មភាព និងផលសិក្សាសម្រេច បានក្រោម៤០%ធៀបនឹងក្រុមគោលដៅ | មានទិន្នន័យពីផលសម្រេចការសិក្សារបស់សិស្សបានប្រើសម្រាប់រៀបចំផែនការសកម្មភាព បិទផ្សាយនៅការិយាល័យ ការិយាល័យ និងសាលារៀន និងផលសិក្សាសម្រេចបានពី៤០%ទៅ៧០%ធៀបនឹងក្រុមគោលដៅ | មានទិន្នន័យពីផលសម្រេចការសិក្សារបស់សិស្ស បានប្រើ សម្រាបរៀបចំផែនការសកម្មភាពបិទផ្សាយនៅការិយាល័យ និងសាលារៀន និងផលសិក្សាសម្រេចបានលើ៧០%ធៀបនឹងក្រុមគោលដៅ |
| **សម្គាល់៖** សរសេរពិន្ទុវាយតម្លៃនៅទីនេះ.................. ហើយអធិប្បាយពីស្ថានភាពនៃកិច្ចការតាមការវាយតម្លៃ និងកំណត់ពិន្ទុក្រុមគោលដៅ និងស្ថានភាពនៃកិច្ចការជាផែនការសម្រាប់ឆ្នាំសិក្សាបន្ទាប់.......................................................................................................... | | | | | |
| **២. ការធ្វើផែនការប្រតិបត្តិឆ្នាំ និងការ អនុវត្ត** | មិនមានផែនការប្រតិបត្តិប្រចាំឆ្នាំ ឬមួយមានតែមិនធ្វើតាមប្រព័ន្ធពិនិត្យតាម-ដាននិងវាយតម្លៃផ្អែកលើលទ្ធផល | ផែនការប្រតិបត្តិប្រចាំឆ្នាំធ្វើតាមប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផលសកម្មភាពគ្រោង០%ទៅ២៥%បានអនុវត្ត | ផែនការប្រតិបត្តិប្រចាំឆ្នាំធ្វើតាមប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផលសកម្មភាពគ្រោង២៦% ទៅ៥០%បានអនុវត្ត | ផែនការប្រតិបត្តិប្រចាំឆ្នាំធ្វើតាមប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផលសកម្មភាពគ្រោង៥១% ទៅ៧៥%បានអនុវត្ត | ផែនការប្រតិបត្តិប្រចាំឆ្នាំធ្វើតាមប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផលសកម្មភាពគ្រោងលើ៧៥% បានអនុវត្ត |
| **សម្គាល់៖** សរសេរពិន្ទុវាយតម្លៃនៅទីនេះ.................. ហើយអធិប្បាយពីស្ថានភាពនៃកិច្ចការតាមការវាយតម្លៃ និងកំណត់ពិន្ទុក្រុមគោលដៅ និងស្ថានភាពនៃកិច្ចការជាផែនការសម្រាប់ឆ្នាំសិក្សាបន្ទាប់.......................................................................................................... | | | | | |

| | | | | | |
|---|---|---|---|---|---|
| **៣. ការគ្រប់គ្រងបុគ្គលិក (ការពង្រាយគ្រូ)** | មិនមានទិន្នន័យពីគ្រូខ្វះ ឬលើស ឬមួយមានតែមិនមាន បច្ចុប្បន្នភាព | មានទិន្នន័យបច្ចុប្បន្នភាពពីគ្រូខ្វះឬលើស តែមិនមានផែនការសកម្មភាពដោះស្រាយ | មានទិន្នន័យបច្ចុប្បន្នភាពពីគ្រូខ្វះ ឬ លើស មានផែនការសកម្មភាពនិងចាប់ផ្តើម ដោះស្រាយ | មានទិន្នន័យបច្ចុប្បន្នភាពពីគ្រូខ្វះ ឬ លើស មានផែនការសកម្មភាពនិង ហើយគ្រូខ្វះ ឬលើសថយចុះ | មានទិន្នន័យបច្ចុប្បន្នភាពពីគ្រូខ្វះ ឬលើស មានផែនការ សកម្មភាពនិងមិនមានបញ្ហាពី គ្រូខ្វះឬលើយ |
| **សម្គាល់៖** សរសេរពិន្ទុវាយតម្លៃនៅទីនេះ.................. ហើយអធិប្បាយពីស្ថានភាពនៃកិច្ចការតាមការវាយតម្លៃ និងកំណត់ពិន្ទុក្រុមគោលដៅ និងស្ថានភាពនៃកិច្ចការជាផែនការសម្រាប់ឆ្នាំសិក្សាបន្ទាប់...................................................................................................................................................................... | | | | | |
| **៤. ការគ្រប់គ្រងសៀវភៅសិក្សាគោល** | មិនមានទិន្នន័យពីសៀវភៅសិក្សាគោលត្រូវការ ឬមួយមានតែមិនមានបច្ចុប្បន្នភាព | មានទិន្នន័យបច្ចុប្បន្នភាពពីសៀវភៅសិក្សាគោលត្រូវការ តែមិនមានផែនការសកម្មភាពដោះស្រាយ | មានទិន្នន័យបច្ចុប្បន្នភាពពីសៀវភៅសិក្សាគោលត្រូវការ មានផែនការសកម្មភាពនិងចាប់ផ្តើមដោះស្រាយ | មានទិន្នន័យបច្ចុប្បន្នភាពពីសៀវភៅសិក្សាគោលត្រូវការ មានផែនការសកម្មភាពនិងសៀវភៅលើសឬខ្វះ ថយចុះ | មានទិន្នន័យបច្ចុប្បន្នភាពពីសៀវភៅសិក្សាគោលត្រូវការ មានផែនការសកម្មភាពនិងមិនមានបញ្ហាសៀវភៅលើស |
| **សម្គាល់៖** សរសេរពិន្ទុវាយតម្លៃនៅទីនេះ.................. ហើយអធិប្បាយពីស្ថានភាពនៃកិច្ចការតាមការវាយតម្លៃ និងកំណត់ពិន្ទុក្រុមគោលដៅ និងស្ថានភាពនៃកិច្ចការជាផែនការសម្រាប់ឆ្នាំសិក្សាបន្ទាប់...................................................................................................................................................................... | | | | | |
| **៥. ការគ្រប់គ្រងនិង ហេដ្ឋារចនាសម្ព័ន្ធសាលារៀន** | មិនមានទិន្នន័យពីតម្រូវការអគារសិក្សា ឬមួយមានតែមិនមានបច្ចុប្បន្នភាព | មានទិន្នន័យមានបច្ចុប្បន្នភាព បានប្រើទិន្នន័យស្នើសុំអគារសិក្សាដល់ក្រសួង | មានទិន្នន័យមានបច្ចុប្បន្នភាព បានប្រើទិន្នន័យស្នើសុំអគារសិក្សាដល់ក្រសួង និងបានប្រើទិន្នន័យកសាងផែនការសាងសង់របស់មន្ទីរ | មានទិន្នន័យមានបច្ចុប្បន្នភាព បានប្រើទិន្នន័យស្នើសុំអគារសិក្សាដល់ក្រសួង និងបានប្រើទិន្នន័យកសាងផែនការសាងសង់របស់មន្ទីរ និងបានទាក់-ទងសហគមន៍និងដៃគូសម្រាប់រកមូលនិធិ | មានទិន្នន័យមានបច្ចុប្បន្នភាព បានប្រើទិន្នន័យស្នើសុំអគារសិក្សាដល់ក្រសួង និងបានប្រើទិន្នន័យ កសាងផែនការសាងសង់របស់ក្រសួង និងបានទាក់ទងសហគមន៍និងដៃគូសម្រាប់រកមូលនិធិ ហើយកង្វះអគារសិក្សាថយចុះ |
| **សម្គាល់៖** សរសេរពិន្ទុវាយតម្លៃនៅទីនេះ.................. ហើយអធិប្បាយពីស្ថានភាពនៃកិច្ចការតាមការវាយតម្លៃ និងកំណត់ពិន្ទុក្រុមគោលដៅ និងស្ថានភាពនៃកិច្ចការជាផែនការសម្រាប់ឆ្នាំសិក្សាបន្ទាប់...................................................................................................................................................................... | | | | | |

| | | | | | |
|---|---|---|---|---|---|
| **៦. ការគ្រប់គ្រងហិរញ្ញវត្ថុ** | ថវិកាគ្រោងមិនបានរៀបចំពេញលេញទៅតាមសៀវភៅណែនាំពីការគ្រប់គ្រងតាមសាលារៀនរបស់ក្រសួង | ថវិកាគ្រោងបានរៀបចំពេញលេញទៅតាមសៀវភៅណែនាំពីការគ្រប់គ្រងតាមសាលារៀនរបស់ក្រសួង និងផ្អែកលើផែនការប្រតិបត្តិឆ្នាំរបស់ការិយាល័យ | ថវិកាគ្រោងបានរៀបចំពេញលេញទៅតាមសៀវភៅណែនាំពីការគ្រប់គ្រងតាមសាលារៀនរបស់ក្រសួង និងផ្អែកលើផែនការប្រតិបត្តិឆ្នាំរបស់ការិយាល័យ ហើយប្រាក់ កែលម្អសាលារៀននិងអាហារូបករណ៍បើកផ្តល់ទាន់ពេលនៅត្រីមាសទី១និងទី២ | ថវិកាគ្រោងបានរៀបចំពេញលេញទៅតាមសៀវភៅណែនាំពីការគ្រប់គ្រងតាមសាលារៀនរបស់ក្រសួង និងផ្អែកលើផែនការប្រតិបត្តិឆ្នាំរបស់ការិយាល័យ ហើយប្រាក់ កែលម្អសាលារៀននិងអាហារូ-បករណ៍បើកផ្តល់ទាន់ពេលនៅត្រីមាសទី១ ទី២ និងទី៣ | ថវិកាគ្រោងបានរៀបចំពេញលេញទៅតាមសៀវភៅណែនាំពីការគ្រប់គ្រងតាមសាលារៀនរបស់ក្រសួង និងផ្អែកលើ ផែនការប្រតិបត្តិឆ្នាំរបស់ការិយា-ល័យ ហើយប្រាក់កែលម្អសាលា រៀន និងអាហារូបករណ៍បើកផ្តល់ទាន់ពេលនៅគ្រប់ត្រីមាស |
| **សម្គាល់៖** សរសេរពិន្ទុវាយតម្លៃនៅទីនេះ.................. ហើយអធិប្បាយពីស្ថានភាពនៃកិច្ចការតាមការវាយតម្លៃ និងកំណត់ពិន្ទុក្រុមគោលដៅ និងស្ថានភាពនៃកិច្ចការជាផែនការសម្រាប់ឆ្នាំសិក្សាបន្ទាប់.................................................................................................................................................................................... | | | | | |
| **៧. ការពិនិត្យតាមដានការអនុវត្តរបស់ក្រុង ស្រុក ខណ្ឌពិសេសលើផលសម្រេចការសិក្សារបស់សិស្ស** | មិនមានទិន្នន័យពីផលសម្រេចការសិក្សារបស់សិស្ស | មានទិន្នន័យពីផលសម្រេចការសិក្សារបស់សិស្ស | មិនមានទិន្នន័យពីផលសម្រេចការសិក្សារបស់សិស្ស និងបានប្រើសម្រាប់កសាងផែនការសកម្មភាពជួយដល់សាលារៀន | មិនមានទិន្នន័យពីផលសម្រេចការសិក្សារបស់សិស្ស និងបានប្រើសម្រាប់កសាងផែនការសកម្មភាពជួយដល់សាលារៀន និងបោះផ្សាយព័ត៌មានដល់សាលារៀន | មិនមានទិន្នន័យពីផលសម្រេចការសិក្សារបស់សិស្ស និងបានប្រើសម្រាប់កសាងផែនការសកម្មភាពជួយដល់សាលារៀន និងបោះផ្សាយព័ត៌មានដល់សាលារៀន និងបានប្រើសម្រាប់កសាងផែនការឆ្នាំបន្ទាប់ |
| **សម្គាល់៖** សរសេរពិន្ទុវាយតម្លៃនៅទីនេះ.................. ហើយអធិប្បាយពីស្ថានភាពនៃកិច្ចការតាមការវាយតម្លៃ និងកំណត់ពិន្ទុក្រុមគោលដៅ និងស្ថានភាពនៃកិច្ចការជាផែនការសម្រាប់ឆ្នាំសិក្សាបន្ទាប់.................................................................................................................................................................................... | | | | | |

| | | | | | |
|---|---|---|---|---|---|
| **៨. ការប្រើប្រាស់ថវិកាសាលារៀនតាមសៀវ-ភៅណែនាំពីការគ្រប់-គ្រងមានមូលដ្ឋាននៅសាលារៀន** | សាលារៀនមានផែនការកែលម្អសាលារៀនប្រចាំឆ្នាំ តែមិនធ្វើតាមសៀវភៅណែនាំពីការគ្រប់គ្រងមានមូល-ដ្ឋាននៅសាលារៀន | ៣០% ទៅ ៥០% សាលារៀនមានផែនការកែលម្អសាលា-រៀនប្រចាំឆ្នាំ និងធ្វើតាមសៀវ-ភៅណែនាំពីការគ្រប់គ្រងតាមសាលារៀន | ៥១%ទៅ ៧០% សាលារៀនមានផែនការកែលម្អសាលា-រៀនប្រចាំឆ្នាំ និងធ្វើតាមសៀវភៅណែនាំពីការគ្រប់គ្រងតាមសាលារៀនហើយ សហគមន៍ចូលរួមក្នុងការធ្វើ ផែនការនិងគ្រោងថវិកា | ៥១%ទៅ ៧០% សាលារៀនមានផែនការកែលម្អសាលា-រៀនប្រចាំឆ្នាំ និងធ្វើតាមសៀវភៅណែនាំពីការគ្រប់គ្រងមានមូលដ្ឋាន នៅសាលារៀនហើយ សហគមន៍ចូលរួមក្នុងការធ្វើផែនការនិងគ្រោងថវិកាតិច ជាង ៥០%នៃថវិកាចំណាយ លើការបង្រៀននិងរៀននិង ៧០%នៃសាលារៀនបិទផ្សាយទិន្នន័យថវិកានិងការចំណាយជាសាធារណ: | ៥១%ទៅ៧០% សាលារៀនមានផែនការកែលម្អសាលារៀនប្រចាំឆ្នាំ និងធ្វើតាមសៀវភៅណែនាំ ពីការគ្រប់គ្រងតាមសាលារៀនហើយសហគមន៍ ចូលរួមក្នុងការធ្វើផែនការនិងគ្រោងថវិកា តិចជាង៥០%នៃថវិកាចំណាយលើការបង្រៀននិងរៀន និងសាលាទាំងអស់រៀន បិទផ្សាយទិន្នន័យថវិកានិងការចំណាយជាសាថារណ: |
| **សម្គាល់៖** សរសេរពិន្ទុវាយតម្លៃនៅទីនេះ.................. ហើយអធិប្បាយពីស្ថានភាពនៃកិច្ចការតាមការវាយតម្លៃ និងកំណត់ពិន្ទុក្រុមគោលដៅ និងស្ថានភាពនៃកិច្ចការជាផែនការសម្រាប់ឆ្នាំសិក្សាបន្ទាប់...................................................................................................................................................................................... | | | | | |
| ពិន្ទុស្តង់ដាសរុប | ៨ | ១៦ | ២៤ | ៣២ | ៤០ |
| **សរុបពិន្ទុជាក់ស្តែងឆ្នាំនេះ៖** | | | | | |
| **សម្គាល់៖ មន្ទីរអប់រំដែលមានដំណើរការមានពិន្ទុសរុប ៨ទៅ ២២។ ពិន្ទុសរុបដែលមានដំណើរការគឺ ២៣ ទៅ ៣២ ។ ពិន្ទុសរុបដែលមានដំណើរការល្អប្រសើរគឺ ៣៣ ទៅ ៤០។** | | | | | |

# ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន

## ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនជាអ្វី?

តាមពិតការកំណត់បញ្ញត្តិ ឬការឱ្យនិយមន័យស្តង់ដាមានច្រើនណាស់។ ជួនកាលគេសរសេរពាក្យ នៅក្នុងល្បះផ្សេងគ្នាប៉ុន្តែមានន័យដូចគ្នា។ ដូច្នេះយើងកំណត់បញ្ញត្តិធំៗបីនៃស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនគឺ៖

ក- ជាសេចក្តីអធិប្បាយសង្ខេប និងច្បាស់លាស់នូវទិដ្ឋភាពទាំងឡាយណាដែលគ្រូបង្រៀនត្រូវយល់ដឹង និងធ្វើ ។

ខ- ជាការបញ្ជាក់ប្រាប់ពីអំពើ ឬសកម្មភាពរបស់គ្រូបង្រៀនដែលអាចអនុវត្តបាន ហើយមានឥទ្ធិពល ទៅលើសិស្ស។

គ - ជាឧបករណ៍សម្រាប់វាស់សមត្ថភាពដែលស្តែងចេញរបស់គ្រូបង្រៀន។

## គោលបំណង

ការកសាងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន គឺមិនមែនមានបំណងវាយតម្លៃសមត្ថភាពគ្រូបង្រៀន ដើម្បីចាត់ ជាប្រភេទគ្រូល្អ ឬគ្រូខ្សោយនោះទេ ពោលគឺយើងមានបំណងលើកស្ទួយការបង្រៀន និងរៀនរបស់គ្រូបង្រៀន សម្រាប់ជួយសម្រួលការសិក្សារបស់សិស្សឱ្យទទួលបាន លទ្ធផលសិក្សាដែលមានកម្រិតសមស្របអាចទទួល យកបាន បើប្រៀបធៀបទៅនឹងស្តង់ដា កម្មវិធីសិក្សាចំណោះទូទៅ។ ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនជាឧបករណ៍ដ៏ មានសារៈសំខាន់បំផុត និងជាខ្នាតគំរូសម្រាប់អ្នកអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលគ្រូនិងសម្រាប់ធ្វើផែនការ កសាងសមត្ថភាពគ្រូបង្រៀន។ ទៅអនាគតគេនឹងប្រើប្រាស់ស្តង់ដាសម្រាប់ចេញជាអាជ្ញាប័ណ្ណបង្រៀន និងជា លក្ខណៈវិនិច្ឆ័យ សម្រាប់ផ្តល់ប្រាក់បៀវត្សដូចនៅប្រទេសអភិវឌ្ឍមួយចំនួន ។

## ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនមានផលប្រយោជន៍អ្វីខ្លះ?

ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនមានផលប្រយោជន៍សម្រាប់៖

- កែលំអការបង្រៀន និងរៀន
- ផ្តល់ចក្ខុវិស័យសម្រាប់បណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន
- កែលំអកម្មវិធីបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន
- រៀបចំផែនការអភិវឌ្ឍន៍សាលារៀន
- ធ្វើឱ្យគ្រូបង្រៀនមានលទ្ធភាព និងមានឱកាសជាច្រើនក្នុងការស្វែងរកសេវាការងារធ្វើទាំងក្នុង ស្ថាប័នរដ្ឋ និងស្ថាប័នឯកជន
- បង្កើនសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀនឱ្យប្រហាក់ប្រហែលប្រទេសក្នុងតំបន់
- ផ្តល់ជាមូលដ្ឋានគ្រឹះដើម្បីដំឡើងឋានន្តរសក្តិ ។

## ១- ចំណេះដឹងវិជ្ជាជីវៈ

គ្រូបង្រៀនមានចំណេះដឹងវិជ្ជាជីវៈសម្បូរបែប ។ គាត់ត្រូវតែដឹងច្បាស់ពីតម្រូវការសិក្សា សមត្ថភាព សិក្សា ប្រវត្តិសិក្សាច្បាស់លាស់ និងឥរិយាបថរបស់សិស្សម្នាក់ៗហើយក៍យល់ដឹងផង ដែរពីប្រភេទគ្រួសារ និងកត្តាផ្សេងៗ ដែលមានឥទ្ធិពលដល់ការសិក្សារបស់ សិស្ស (យេនឌ័រ ពិការភាព និងក្រុមជនជាតិភាគតិច...) ព្រមទាំងយល់ដឹងពីវិធីដោះស្រាយកត្តាទាំងនេះ។ គ្រូបង្រៀនត្រូវមានការយល់ដឹងពីគោលនយោបាយអប់រំ ជាពិសេសគោលដៅអប់រំជាតិ និងគោលបំណងអប់រំចំណេះទូទៅហើយពេញចិត្តក្នុងការអនុវត្តនៅសាលារៀន។ គ្រូបង្រៀនយល់ពីទ្រឹស្តីក្នុងការរៀបចំកិច្ចតែងការបង្រៀន ដូចជាវត្ថុបំណង វិធីសាស្ត្របង្រៀន និងអាចជ្រើស រើសវិធីវាយតម្លៃលទ្ធផលសិក្សាបានសមស្រប។ គ្រូបង្រៀនយល់ពីខ្លឹមសារកម្មវិធីសិក្សា ហើយមានសមត្ថភាព ពន្យល់មេរៀនបានច្បាស់លាស់ និងយល់ពីរបៀបបញ្ជ្រាបខ្លឹមសារពីមុខវិជ្ជាមួយ ទៅមុខវិជ្ជាមួយផ្សេងទៀត ក្នុងន័យឱ្យសិស្សទទួលបានបំណិនជាច្រើន និងមានចិត្តកាន់តែចង់រៀន។

គ្រូបង្រៀនត្រូវយល់ពីបរិស្ថានអប់រំក្នុងថ្នាក់រៀន និងក្នុងសហគមន៍ ពិសេសយល់ពីរបៀបរៀនរបស់ សិស្ស ភាពខុសគ្នារវាងទេពកោសល្យ ល្បឿន និងរបៀបសិក្សា ដែលមានឥទ្ធិពលដល់ការសិក្សារបស់ សិស្ស។

<table>
<tr><td rowspan="4">ចំណេះដឹងអំពីសិស្ស</td><td>១.១ ស្គាល់សិស្ស (តម្រូវការសិក្សា សមត្ថភាព ប្រវត្តិសិក្សា និងឥរិយាបថសិក្សារបស់សិស្ស)</td></tr>
<tr><td>• ពណ៌នាបានពីតម្រូវការសិក្សារបស់សិស្ស<br>• ពណ៌នាបានពីសមត្ថភាពសិក្សារបស់សិស្ស<br>• ពណ៌នាបានពីប្រវត្តិសិក្សារបស់សិស្ស<br>• ពណ៌នាបានពីឥរិយាបថសិក្សារបស់សិស្ស។</td></tr>
<tr><td>១.២ ដឹងច្បាស់ពីប្រភេទគ្រួសារ និងកត្តាផ្សេងៗ (ឧ.យេនឌ័រ សាវតារសង្គម សេដ្ឋកិច្ច ពិការភាព និងក្រុមជនជាតិភាគតិច...) ដែលមានឥទ្ធិពល ដល់ការសិក្សា របស់សិស្ស និងដឹងពីរបៀបដោះស្រាយកត្តាទាំងនោះ</td></tr>
<tr><td>• ពណ៌នាបានពី យេនឌ័រ ដែលមានឥទ្ធិពលដល់ការសិក្សារបស់សិស្ស<br>• ពណ៌នាបានពីកត្តាសង្គម សេដ្ឋកិច្ច ដែលជះឥទ្ធិពលដល់ការសិក្សារបស់សិស្ស<br>• ពណ៌នាបានពីក្រុមជនជាតិ និងពិការភាពដែលជះឥទ្ធិពលដល់ការសិក្សារបស់សិស្ស<br>• ពណ៌នាបានពីរបៀបដោះស្រាយកត្តាទាំងនោះ។</td></tr>
</table>

ចំណេះដឹងអំពីខ្លឹមសារមេរៀន

**១.៣ យល់ដឹងពីគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ និងគោលបំណងអប់រំចំណេះទូទៅ**

- ពណ៌នាបានពី គោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ និង គោលបំណងអប់រំចំណេះទូទៅ
- ពណ៌នាបានពី វិធីដែលធ្វើឱ្យបានសម្រេចគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ និងគោលបំណងអប់រំចំណេះទូទៅ ។

**១.៤ យល់ដឹងពីទ្រឹស្តីនៃការសរសេរកិច្ចតែងការបង្រៀន**

- ពណ៌នាបានពីវត្ថុបំណង និងធាតុរបស់វាបានត្រឹមត្រូវ
- ពណ៌នាបានពីចំណុចសំខាន់ៗនៃគោលវិធីសិស្សមជ្ឈមណ្ឌល
- ពណ៌នាបានពីយុទ្ធវិធីវាយតម្លៃលទ្ធផលសិក្សារបស់សិស្សបានសមស្រប
- ពណ៌នាបានពីសម្ភារបង្រៀន និងរៀនបានសមស្រប សម្រាប់ប្រើប្រាស់ក្នុងការបង្រៀន មេរៀន។

**១.៥ យល់ដឹងពីខ្លឹមសារកម្មវិធីសិក្សា ហើយមានសមត្ថភាព ពន្យល់ និងបង្រៀនខ្លឹមសារ មុខវិជ្ជាដែលមានក្នុងកម្មវិធីសិក្សាបានល្អ**

- គូសបញ្ជាក់ពីខ្លឹមសារសំខាន់ៗ នៃកម្មវិធីសិក្សាដែលត្រូវបង្រៀនបានច្បាស់លាស់
- បង្រៀនដើម្បីបង្ហាញពីការយល់ខ្លឹមសារច្បាស់លាស់។

**១.៦ យល់ដឹងពីរបៀបបញ្ជ្រាបខ្លឹមសារ ពីមុខវិជ្ជាមួយទៅមុខវិជ្ជាផ្សេងទៀតក្នុងន័យឱ្យសិស្សទទួលបានបំណិនជាច្រើន និងមានចិត្តកាន់តែចង់រៀន**

- ពណ៌នាបានពីវិធីបញ្ជ្រាបខ្លឹមសារពីមុខវិជ្ជាមួយទៅក្នុងមុខវិជ្ជាផ្សេងទៀតដែលអាចជួយឱ្យសិស្ស រៀនកាន់តែប្រសើរឡើង និងចូលចិត្តរៀន។

<table>
<tr><td rowspan="6">ចំណេះដឹងពីរបៀបរៀនរបស់សិស្ស</td><td>១.៧ យល់ដឹងពីបរិស្ថានសិក្សាក្នុងថ្នាក់រៀន និងសហគមន៍</td></tr>
<tr><td>• ពណ៌នាបានពី វិធីដែលធ្វើឱ្យប្រសើរឡើងនូវបរិស្ថានសិក្សាក្នុងថ្នាក់រៀនដើម្បីជួយឱ្យសិស្សរៀនកាន់តែពូកែ<br>• ពណ៌នាបានពី វិធីដែលធ្វើឱ្យសហគមន៍សាលារៀន ចូលរួមជួយសិស្សឱ្យរៀន កាន់តែពូកែ។</td></tr>
<tr><td>១.៨ យល់ដឹងពីរបៀបរៀនរបស់សិស្ស</td></tr>
<tr><td>• ពណ៌នាបានពីទ្រឹស្តីមួយ ឬច្រើននៃរបៀបរៀនរបស់សិស្ស<br>• ប្រាប់បានពីរបៀបរៀនផ្សេងៗគ្នារបស់សិស្ស ។</td></tr>
<tr><td>១.៩ យល់ដឹងពីភាពខុសគ្នានៃសម្បទា ល្បឿន និងរបៀបសិក្សារបស់សិស្ស</td></tr>
<tr><td>• ពន្យល់ពី ភាពខុសគ្នានៃសម្បទាសិក្សារបស់សិស្ស<br>• ពន្យល់ពីភាពខុសគ្នានៃល្បឿនសិក្សារបស់សិស្ស<br>• ពន្យល់ពីភាពខុសគ្នានៃរបៀបសិក្សារបស់សិស្ស។</td></tr>
</table>

## ២ -ការប្រតិបត្តិវិជ្ជាជីវៈ

គ្រូបង្រៀនត្រូវរៀបចំកិច្ចតែងការបង្រៀនឱ្យបានច្បាស់លាស់ប្រកបដោយប្រសិទ្ធភាព ស្របតាម កម្មវិធីសិក្សា ដោយផ្អែកលើ សៀវភៅសិស្ស សៀវភៅគ្រូ និងសម្ភារសិក្សាផ្សេងៗទៀត ដែលអាចរកបាន។ ដើម្បីគាំទ្រដល់កិច្ចតែងការបង្រៀន គ្រូបង្រៀនត្រូវរៀបចំសម្ភារ បង្រៀន និងរៀន ដើម្បីរិះរកមធ្យោបាយសម្រេចការសិក្សា របស់សិស្សប្រកបដោយប្រសិទ្ធភាព។ គ្រូបង្រៀនក៏ប្រើប្រាស់វិធីវាយតម្លៃលទ្ធផលសិក្សា ផ្សេងៗគ្នា ដែលស្របទៅតាមតម្រូវការ និងទេពកោសល្យរបស់សិស្ស។ គ្រូបង្រៀនត្រូវបញ្ជូនព័ត៌មានត្រឡប់ទៅសិស្ស មាតាបិតា ឬអ្នកអាណាព្យាបាលអំពីការអភិវឌ្ឍចំណេះដឹង បំណិន និងឥរិយាបថរបស់សិស្ស។

គ្រូបង្រៀនផ្តល់ឱ្យសិស្សគ្រប់រូបនូវបរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព និងធ្វើឱ្យមានការប្រឹងប្រែងអស់ពីសមត្ថភាព ហើយលើកទឹកចិត្តសិស្សឱ្យកាន់តែមានការទទួលខុសត្រូវចំពោះការសិក្សារបស់ខ្លួន។ គ្រូបង្រៀនត្រូវចូលរួមក្នុងការអភិវឌ្ឍសាលារៀន ដើម្បីគាំទ្រការសិក្សា និងសុខុមាលភាពរបស់សិស្ស និង គ្រូបង្រៀនឯទៀត។

គ្រូបង្រៀនត្រូវចេះប្រើប្រាស់វិធីបង្រៀនឱ្យសម្បូរបែប ដើម្បីសម្រួលដល់ការសិក្សារបស់សិស្ស និងសម្រេច បានវត្ថុបំណងមេរៀន។ ម៉្យាងទៀតគ្រូបង្រៀនគួរមានសមត្ថភាពផ្តល់ជាមធ្យោបាយឱ្យស្របទៅតាមរបៀបសិក្សា និងតម្រូវការផ្សេងៗគ្នារបស់សិស្សតាមរយៈ ការអនុវត្តវិធីបង្រៀនសមស្របសម្បូរបែប

ដោយបង្កឱកាសឱ្យ សិស្សចូលរួមគិតបានល្អិតល្អន់ និងដោយច្នៃប្រឌិត។ លើសពីនេះទៀត គ្រូបង្រៀនត្រូវចេះប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន សារគមនាគមន៍ និងធនធានក្នុងបណ្ណាល័យបើមានលទ្ធភាព ដើម្បីធ្វើឱ្យការបង្រៀន និងរៀន កាន់តែមានប្រសិទ្ធភាព។

**ការធ្វើផែនការ និងការពិនិត្យតាមដាន វាយតម្លៃលទ្ធផលសិក្សា**

**២១. រៀបចំកិច្ចតែងការបង្រៀន កម្មវិធីបង្រៀន និងការវាយតម្លៃ លទ្ធផលសិក្សាបានត្រឹមត្រូវ ហើយមានប្រសិទ្ធភាព**

- កិច្ចតែងការបង្រៀនមានសេចក្តីពណ៌នាបញ្ជាក់ ពីវត្ថុបំណងមេរៀនច្បាស់លាស់
- កិច្ចតែងការបង្រៀនមានសេចក្តីពណ៌នាបញ្ជាក់ពីរបៀបវាយតម្លៃ លទ្ធផលសិក្សាបានច្បាស់លាស់
- កិច្ចតែងការបង្រៀនមានសេចក្តីពណ៌នាបញ្ជាក់ពីសកម្មភាពគ្រូសិស្ស និងខ្លឹមសារមេរៀន ដើម្បី គាំទ្រវត្ថុបំណងមេរៀនបានច្បាស់លាស់ និងត្រឹមត្រូវតាម គោលការណ៍។

**២២. រៀបចំសម្ភារបង្រៀន និងរៀន ដើម្បីធ្វើឱ្យការសិក្សាសម្រេចបានលទ្ធផលល្អ**

- រៀបចំសម្ភាររៀនប្រកបដោយប្រសិទ្ធភាព ដើម្បីសម្រេចបានលទ្ធផលសិក្សា ល្អរបស់សិស្ស
- រៀបចំសម្ភារបង្រៀនប្រកបដោយប្រសិទ្ធភាព ដើម្បីសម្រេចបានលទ្ធផលសិក្សាល្អរបស់សិស្ស។

**២៣. ប្រើប្រាស់វិធីសមស្របសម្បូរបែប សម្រាប់វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស**

- កសាងសំណួរតេស្ត ដោយមានទម្រង់ និងរយៈពេលសមស្របសម្រាប់ សិស្សឆ្លើយ
- ជ្រើសរើសអាយតឹមតេស្ត )Item Test)ពីសៀវភៅផ្សេងៗ ដែលមាន ទម្រង់សំណួរ និងរយៈពេល សមស្របសម្រាប់សិស្សឆ្លើយ
- បង្ហាញប្រាប់ពីអត្រាកំណែតេស្ត និងការកែចម្លើយរបស់សិស្សបានត្រឹមត្រូវ
- កំណត់បានយ៉ាងច្បាស់ពី លទ្ធផលតេស្ត ដើម្បីបង្ហាញពីប្រសិទ្ធភាពនៃ ការសិក្សារបស់សិស្ស។

**២៤. តាមដានការចូលរួម និងថែរក្សាកំណត់ត្រានៃភាពរីកចម្រើនរបស់សិស្ស**

- តាមដានការចូលរួមរបស់សិស្ស តាមរយៈការសង្កេត និងធ្វើកំណត់ត្រា
- ថែរក្សាកំណត់ត្រា ស្តីពីការចូលរួមរបស់សិស្សក្នុងសកម្មភាពសិក្សា។

**២៥. ផ្តល់ព័ត៌មានត្រឡប់ទៅសិស្ស មាតាបិតា ឬអាណាព្យាបាលសិស្ស អំពីការអភិវឌ្ឍចំណេះដឹង បំណិន និងឥរិយាបថរបស់សិស្ស**

| | |
|---|---|
| | • ផ្តល់ព័ត៌មានត្រឡប់ទៅសិស្សតាមរយៈការនិយាយដោយផ្ទាល់ និងដាក់មូលវិចារណ៍សមស្រប ជាលាយលក្ខណ៍អក្សរ នៅលើសន្លឹកកិច្ចការ របស់សិស្ស ពិសេសលើសៀវភៅទំនាក់ទំនង<br>• ផ្តល់ព័ត៌មានត្រឡប់ទៅមាតាបិតាឬអាណាព្យាបាលសិស្សតាមរយៈ របាយការណ៍ប្រចាំខែនិងទៅជួបផ្ទាល់ បើចាំបាច់។ |
| ការគ្រប់គ្រងបរិស្ថានសិក្សា | ២៦. ផ្តល់បរិស្ថានសិក្សាដែលមានសុវត្ថិភាព និងធ្វើឱ្យសិស្សទាំងអស់ខិតខំរៀនអស់ពីលទ្ធភាព |
| | • បង្ហាញឱ្យឃើញពីការគ្រប់គ្រងថ្នាក់រៀនមានប្រសិទ្ធភាព<br>• ជួយសិស្សឱ្យមានអន្តរកម្មវិជ្ជមានជាមួយសិស្សដទៃទៀត<br>• ផ្តល់បរិស្ថានសិក្សាដែលធ្វើឱ្យសិស្សពង្រីកការសិក្សាបានច្រើន។ |
| | ២៧. ជួយសិស្សឱ្យបង្កើនការទទួលខុសត្រូវចំពោះការសិក្សារបស់ខ្លួន |
| | • បង្ហាញពីវិធីដែលអាចជួយសិស្សឱ្យមានការទទួលខុសត្រូវចំពោះការសិក្សារបស់ ខ្លួនកាន់តែខ្លាំង<br>• បង្ហាញកិច្ចការសិស្សជាឧទាហរណ៍ ដែលចង្អុលបង្ហាញការរៀនដោយខ្លួនឯង (កិច្ចការសិស្ស គម្រោងតូចៗ របាយការណ៍ក្រុម។ល។)។ |
| | ២៨. ចូលរួមអភិវឌ្ឍន៍សាលារៀន ដើម្បីទ្រទ្រង់ការសិក្សា និងសុខុមាលភាព របស់សិស្សព្រមទាំង សហសេវិក/មិត្តរួមអាជីព |
| | • ពណ៌នាបានពីសកម្មភាពអភិវឌ្ឍសាលារៀនដែលគាត់បានចូលរួម<br>• លើកជាសំណូមពរពីសកម្មភាពអភិវឌ្ឍន៍សាលារៀន។ |
| វិធីបង្រៀន | ២៩. ប្រើវិធីបង្រៀនផ្សេងៗ ដើម្បីជួយសម្រួលការសិក្សារបស់សិស្ស និងសម្រេចឱ្យបានតាមស្តង់ដាក់ម្មវិធីសិក្សារបស់ក្រសួង |
| | • បង្ហាញពីវិធីបង្រៀនផ្សេងៗ ដូចជាអនុមានរួម អនុមានញែក ការងារក្រុម ពន្យល់បង្ហាញ ពីដំណោះស្រាយបញ្ហា។ល។<br>• ពណ៌នាបានពីវិធីបង្រៀនដែលមានប្រសិទ្ធភាពចំពោះមេរៀននីមួយៗដែលបានប្រើពិសេសអនុវត្ត គោលវិធីសិស្សមជ្ឈមណ្ឌលបានត្រឹមត្រូវ<br>• ពន្យល់បានពីមូលហេតុដែលប្រើវិធីបង្រៀនទាំងនោះ។ |
| | ២១០. ផ្តល់មធ្យោបាយឱ្យស្របទៅតាមរបៀបសិក្សា និងតម្រូវការផ្សេងៗគ្នារបស់សិស្សតាមរយៈការអនុវត្តវិធីបង្រៀនសមស្រប និងសម្បូរបែប |

បង្ហាញពីវិធីបង្រៀនផ្សេងៗដែលផ្តល់ជាមធ្យោបាយឱ្យត្រូវទៅតាមរបៀបសិក្សា របស់សិស្សផ្សេងៗគ្នា (ឧ.ពូកែខាង ភាសា គណិត ចក្ខុ ចលនារាងកាយតន្ត្រី ទាក់ទងរវាងបុគ្គល និងបុគ្គល។ល។) ពន្យល់បានពីវិធីបង្រៀនដែលផ្តល់ជាមធ្យោបាយ ឱ្យត្រូវទៅតាមរបៀបសិក្សាខុសៗគ្នារបស់សិស្ស។

**២១១. រៀបចំ និងផ្តល់ឱ្យសិស្ស នូវឱកាសសិក្សាពី ដំណោះស្រាយបញ្ហា ដើម្បីចូលរួមគិតឱ្យបានល្អិតល្អន់ និងដោយច្នៃប្រឌិត**

- ជួយសិស្សឱ្យប្រើការគិតល្អិតល្អន់ ដើម្បីវិភាគចំណោទបញ្ហា
- ពណ៌នាបានពីរបៀប ដែលគាត់ប្រើការគិតដោយច្នៃប្រឌិត ដើម្បីដោះស្រាយ បញ្ហា។

**២១២. ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ បើមានលទ្ធភាព ដើម្បីធ្វើឱ្យការបង្រៀន និងរៀនកាន់តែមានប្រសិទ្ធភាព**

- ពណ៌នាបានពីរបៀបប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ដើម្បីជួយឱ្យសិស្សមានចិត្តចង់រៀន
- ពណ៌នាបានពីរបៀបដែលគាត់ប្រើប្រាស់ចំណេះដឹង និងបំណិនបច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ ដើម្បីឱ្យសិស្សរៀនកាន់តែមានប្រសិទ្ធភាព។

### ៣- ការសិក្សាវិជ្ជាជីវៈ

យើងបានដឹងហើយថាគ្រូបង្រៀនគឺជាអ្នកលើកទឹកចិត្ត និងជាអ្នកធានាឱ្យសិស្សទទួល បានជោគជ័យ ក្នុងការសិក្សា ។ ដូច្នេះគាត់ត្រូវតែស្វ័យសិក្សា វាយតម្លៃការបង្រៀន ដើម្បី អភិវឌ្ឍខ្លួនឯង និងប្រើប្រាស់ ផែនការសម្រាប់ដឹកនាំស្វ័យសិក្សាមុខវិជ្ជាជីវៈជាប្រចាំស្របតាម ជីវភាពរស់នៅជាក់ស្តែង ។ គ្រូបង្រៀនត្រូវ អភិវឌ្ឍផ្នែកបច្ចេកវិទ្យាព័ត៌មានសារគមនាគមន៍ និងបំណិនផ្សេងៗសម្រាប់អនុវត្តក្នុងការបង្រៀន ហើយធ្វើឱ្យ ប្រសើរឡើងនូវបំណិនទំនាក់ទំនងជាមួយសិស្ស មាតាបិតា មិត្តរួមអាជីព និងជាមួយអ្នកផ្សេងៗទៀត នៅក្នុង សហគមន៍។ គ្រូបង្រៀនត្រូវលើកកម្ពស់កម្រិតសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួនតាមរយៈការអាន និងស្រាវជ្រាវ ប្រភពឯកសារផ្សេងៗ ដើម្បីពង្រីកចំណេះដឹងឱ្យបានទូលំទូលាយក្នុងន័យកែលំអការបង្រៀន និងរៀន ហើយ ត្រូវមានទំនាក់ទំនងល្អជាមួយគ្រូដទៃទៀតក្នុងការសិក្សាវិជ្ជាជីវៈ។

| | |
|---|---|
| ស្វ័យសិក្សា | ៣ ១-វាយតម្លៃការបង្រៀន ការអភិវឌ្ឍខ្លួន និងការប្រើប្រាស់ផែនការសម្រាប់ ដឹកនាំស្វ័យសិក្សាវិជ្ជាជីវៈបានទៀងទាត់ |
| | • កំណត់បានពីចំណុចខ្លាំង ចំណុចដែលត្រូវកែលំអ និងតម្រូវការក្នុងមុខវិជ្ជាជីវៈ ផ្ទាល់ខ្លួន<br>• រៀបចំផែនការអភិវឌ្ឍន៍វិជ្ជាជីវៈផ្ទាល់ខ្លួនប្រកបដោយប្រសិទ្ធភាព<br>• ស្វែងយល់ពីការប្រើប្រាស់សៀវភៅកំណត់ត្រាប្រចាំថ្ងៃ ដើម្បីឆ្លុះបញ្ចាំងការងារ របស់ខ្លួន។ |
| | ៣ ២-អភិវឌ្ឍចំណេះដឹងបច្ចេកវិទ្យាព័ត៌មាន សារគមនាគមន៍ និងបំណិនសម្រាប់ អនុវត្តក្នុងការបង្រៀន និងរៀន |
| | • បង្កើនបំណិនដែលទាក់ទងនឹងវិជ្ជាជីវៈរបស់ខ្លួន ដោយបង្ហាញវិញ្ញាបនបត្រ ជាភស្តុតាង<br>• ពណ៌នាបានពីរបៀបប្រើប្រាស់ បច្ចេកវិទ្យាព័ត៌មាន សារគមនាគមន៍ សម្រាប់ការស្រាវជ្រាវ និងរៀនដោយខ្លួនឯង<br>• មានឆន្ទៈស្វ័យសិក្សាស្រាវជ្រាវបំពេញបន្ថែមទាំងចំណេះដឹងមូលដ្ឋាន ទាំងបច្ចេកទេសបង្រៀនថ្មីៗ តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍។ |
| | ៣ ៣-ធ្វើឱ្យប្រសើរឡើង នូវបំណិនទំនាក់ទំនង ជាមួយសិស្ស មាតាបិតា មិត្តរួមអាជីព និងសហគមន៍ |
| | • បង្ហាញពីបំណិនទំនាក់ទំនងជាមួយសិស្ស<br>• បង្ហាញពីបំណិនទំនាក់ទំនងជាមួយសហការី<br>• បង្ហាញពីបំណិនទំនាក់ទំនងជាមួយមាតាបិតា និងសហគមន៍។ |
| ការចូលរួមកែលំអការបង្រៀន | ៣ ៤-អានអត្ថបទវិជ្ជាជីវៈគ្រូបង្រៀន និងស្រាវជ្រាវ ដើម្បីពង្រីកចំណេះដឹង ឱ្យបានទូលំទូលាយក្នុងន័យធ្វើឱ្យការបង្រៀនកាន់តែប្រសើរឡើង |
| | • ពណ៌នាបានពីអត្ថបទដែលគាត់បានអាន និងស្រាវជ្រាវហើយយកបទពិសោធក្នុងអត្ថបទនោះមកជួយកែលំអការបង្រៀន<br>• ធ្វើថ្នាក់និទស្សន៍ដើម្បីបង្ហាញបទពិសោធដែលទទួលបានពីការអាននិងស្រាវជ្រាវ ឯកសារផ្សេងៗ ដល់មិត្តរួមអាជីព ដើម្បីបង្កើនសមត្ថភាព។ |
| | ៣ ៥-ធ្វើអន្តរកម្មជាមួយគ្រូដទៃទៀតក្នុងសកម្មភាពសិក្សាវិជ្ជាជីវៈផ្សេងៗ |
| | • ធ្វើបញ្ជីឈ្មោះសិក្ខាសាលា ឬវគ្គបំប៉នផ្សេងៗ ដែលបានចូលរួម<br>• ពន្យល់បានពីខ្លឹមសារសិក្ខាសាលា ឬវគ្គបំប៉នដែលបានចូលរួមហើយបានផ្តល់បទពិសោធល្អៗ ដល់ការបង្រៀន និងរៀន។ |

**៤- សីលធម៌វិជ្ជាជីវៈ**

សីលធម៌វិជ្ជាជីវៈ គឺពាក់ព័ន្ធទៅនឹងគ្រប់ទិដ្ឋភាពទាំងអស់ក្នុងវិជ្ជាជីវៈគ្រូបង្រៀនដែលជារួមមានការ ប្តេជ្ញាចិត្ត បង្រៀនសិស្សប្រើប្រាស់មនសិការវិជ្ជាជីវៈប្រកបដោយគតិបណ្ឌិត និង មានចំណេះដឹងគ្រប់គ្រាន់តាមក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន និងច្បាប់ស្តីពីការអប់រំ។

គ្រូបង្រៀនត្រូវគោរពពេលវេលាតាមភារកិច្ច មានវត្តមានជាប្រចាំនៅក្នុងសាលារៀន មានការស្លៀកពាក់ សមរម្យ និងមានឥរិយាបថថ្លៃថ្នូរ។ គាត់គួរតែចូលរួមក្នុងគ្រប់សកម្មភាព ទាំងក្នុងនិងក្រៅម៉ោងទាំងអស់របស់សាលារៀនឱ្យបានសមស្របតាមករណីដែលអាចធ្វើបាន។

គ្រូបង្រៀនមានប្រសិទ្ធភាព គឺមិនរើសអើងសិស្ស ទោះនៅក្នុងកាលៈទេសៈណាក៏ដោយ ដូចជា បញ្ហា យេនឌ័រ ជនជាតិភាគតិច ពិការភាព ក្រីក្រ និងត្រូវចេះថែទាំសិស្ស ផ្តល់លទ្ធភាព ឱ្យសិស្សប្រើប្រាស់ធនធាន ឱ្យអស់ពីលទ្ធភាព ហើយយកចិត្តទុកដាក់ដល់សិស្សឱ្យបានស្មើៗគ្នា រួចបង្ហាញពីភាពយុត្តិធម៌ក្នុងការត្រួតពិនិត្យ លទ្ធផលសិក្សា។ នៅពេលទាក់ទងជាមួយសិស្ស គ្រូបង្រៀនត្រូវមានការគោរពសិស្សដោយមិននិយាយមើលងាយ ឬដាក់ទណ្ឌកម្មពួកគេតាមរបៀបហិង្សាឡើយ។ គ្រូបង្រៀនប្រកាន់ចរិយាសម្បត្តិមានសុជីវធម៌ និងអាកប្បកិរិយាថ្លៃថ្នូរ សម្រាប់ធ្វើការសហការជាមួយសហការី និងមាតាបិតាសិស្ស ដើម្បីផលប្រយោជន៍សិស្សផ្តល់ជាគំរូដល់សិស្ស ក្នុងការរស់នៅ និងរៀនសូត្របានល្អ ពិសេសចេះលើកកម្ពស់ស្មារតីសិស្សឱ្យ រឹងប៉ឹង និងវិជ្ជមានហើយបង្កើត ស្មារតីលះបង់ និងការរួមចំណែកចំពោះសហគមន៍ទាំងមូល។

| |
|---|
| *៤១. បង្ហាញពីការយកចិត្តទុកដាក់ នឹងថែរក្សាសិស្សហើយជានិច្ចកាលធ្វើការ ដើម្បីប្រយោជន៍សិស្ស និងសង្គម* |
| និយាយទៅកាន់សិស្ស សហការី និងអ្នកឯទៀតនៅក្នុងសហគមន៍ដោយមានការគោរព និងលើកទឹកចិត្ត បង្ហាញពីការគោរពសិទ្ធិកុមារមិនត្រូវនិយាយមើលងាយ ឬដាក់ពិន័យសិស្សតាមរបៀប អំពើហិង្សា ធ្វើការជាមួយសហការី និងសមាជិកសហគមន៍ឯទៀតដើម្បីប្រយោជន៍សិស្ស។ |
| ៤២. បង្ហាញពីការប្តេជ្ញាចិត្ត និងចូលរួមចំណែកក្នុងវិជ្ជាជីវៈគ្រូបង្រៀនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ |
| ទៅថ្នាក់រៀន និងចូលរួមព្រឹត្តិការណ៍ផ្សេងៗបានទៀងទាត់ និងទាន់ពេលវេលា<br>បង្ហាញពីអាកប្បកិរិយា រាក់ទាក់ និងសប្បុរសធម៌<br>បង្ហាញពីការគោរពសិស្ស សហការី និងអ្នកឯទៀតក្នុងសហគមន៍<br>បង្ហាញពីអារម្មណ៍ជក់ចិត្ត និងគំនិតផ្តួចផ្តើមលើគ្រប់ទិដ្ឋភាពនៃសកម្មភាពវិជ្ជាជីវៈ<br>បង្ហាញពីចំណេះដឹងលើក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន និងច្បាប់ស្តីពីការអប់រំ។ |

| |
|---|
| ៤៣. បង្ហាញអាកប្បកិរិយាវិជ្ជមានជាគំរូប្រកបដោយសីលធម៌ និងមានទំនាក់ទំនងដោយសុខដុម ជាមួយ សិស្ស និងសហគមន៍ |
| ស្លៀកពាក់សមរម្យ<br>បង្ហាញពីអារម្មណ៍វិជ្ជមានចំពោះសិស្ស និងអ្នកឯទៀត<br>បង្ហាញពីសមត្ថភាព ដើម្បីរក្សាទំនាក់ទំនងប្រកបដោយសុខដុម<br>ផ្តល់តម្លៃសីលធម៌ទៅមាតាបិតាសិស្ស និងអ្នកឯទៀត។ |
| ៤៤. ប្រើប្រាស់ភាពយុត្តិធម៌ និងតម្លាភាព ក្នុងការប្រព្រឹត្តជាមួយសិស្ស សហសេវិក និងសមាជិកផ្សេងៗរបស់សហគមន៍ |
| បង្ហាញពីការស្មោះត្រង់ក្នុងមុខវិជ្ជាជីវៈដោយសំដែងនូវសុភាវធម៌ និងភាពមិនលំអៀង<br>ផ្តល់ឱកាសដល់សិស្សគ្រប់រូបមានលទ្ធភាពទទួលបាននូវពេលវេលា និងធនធានស្មើៗគ្នា ដោយមិនគិតពីភេទ ជនជាតិភាគតិច ឬអ្នកក្រីក្រ និងពិការភាព<br>វាយតម្លៃលទ្ធផលសិក្សាប្រកបដោយយុត្តិធម៌។ |

## សេចក្ដីព្រាងស្តង់ដាវិជ្ជាជីវៈនាយកសាលារៀនចំណេះទូទៅ

ស្តង់ដាសមត្ថភាពវិជ្ជាជីវៈនាយកសាលារៀនមាន ៥សមាសភាគ ១៦សមត្ថភាព ៤២សមត្ថភាពរង និង ១៣៦ស្តង់ដាសមត្ថភាព។

| **១.សមាសភាគ ៖ ការគិតជាយុទ្ធសាស្ត្រ និងនវានុវត្តន៍** | | |
|---|---|---|
| **សមត្ថភាព** | **សមត្ថភាពរង** | **ស្តង់ដាសមត្ថភាព** |
| 1. ការលើកផែនការទិសដៅយុទ្ធសាស្ត្រសម្រាប់សាលារៀន | 1.1. ធ្វើការជាមួយសាលារៀន សហគមន៍ និង ភាគីពាក់ព័ន្ធដើម្បី អភិវឌ្ឍផែនការ យុទ្ធសាស្ត្រ | 1.1.1. បង្ហាញការយល់ដឹងពីនីតិវិធីធ្វើផែនការយុទ្ធសាស្ត្រ<br>1.1.2. អភិវឌ្ឍចក្ខុវិស័យច្បាស់លាស់ជាមួយសាលារៀន និងអ្នកពាក់ព័ន្ធក្នុងសហគមន៍សម្រាប់អភិវឌ្ឍសាលារៀន ដែលនាំការសិក្សាប្រកបដោយប្រសិទ្ធភាព<br>1.1.3. បង្កើតគោលបំណងជាក់លាក់ដើម្បីសម្រេចឱ្យបានចក្ខុវិស័យសម្រាប់អភិវឌ្ឍសាលារៀន<br>1.1.4. ធានាថាផែនការមានភាពពេញលេញនូវតម្រូវការសម្រាប់សមាជិកសហគមន៍ សាលារៀន<br>1.1.5. ផ្សព្វផ្សាយផែនការឱ្យបានទូលំទូលាយ ដល់ភាគីពាក់ព័ន្ធដើម្បីអនុវត្តនិងធ្វើជាម្ចាស់ផែនការ |
| | 1.2. ដឹកនាំអនុវត្តផែនការយុទ្ធសាស្ត្រ | 1.2.1. ធ្វើប្រតិភូកម្មមានប្រសិទ្ធភាពដើម្បីសម្រេចគោលបំណងរបស់ ផែនការយុទ្ធសាស្ត្រ<br>1.2.2. ចាត់ចែងការប្រើប្រាស់ធនធានដែលមាននៅពេលត្រូវការ<br>1.2.3. ធានាថាធនធានមនុស្ស សម្ភារៈ និងហិរញ្ញវត្ថុមានគ្រប់គ្រាន់ ពេលត្រូវការ<br>1.2.4. ពិនិត្យតាមដាន និងវាយតម្លៃសកម្មភាពផែនការយុទ្ធសាស្ត្រ និងប្រើប្រាស់លទ្ធផលការតាមដានសម្រាប់កែលម្អសកម្មភាពផ្សេងៗទៀត |
| | 1.3. បង្ហាញពីចក្ខុវិស័យ និងធ្វើជាគំរូបង្ហាញពីតម្លៃការងារ និងការប្រតិបត្តិជារៀងរាល់ថ្ងៃ | 1.3.1. សម្រេចចិត្តឱ្យស្របតាមចក្ខុវិស័យ និងគោលបំណងរបស់ផែនការយុទ្ធសាស្ត្រ<br>1.3.2. ធ្វើការជាមួយភាគីពាក់ព័ន្ធដើម្បីបង្កើតបរិយាកាសវិជ្ជមានក្នុង<br>សាលារៀន<br>1.3.3. ធានាថានាយកសាលា និងបុគ្គលិកធ្វើការជាមួយគ្នា |

| | | |
|---|---|---|
| | | សំដៅសម្រេចឱ្យបានតាមគោលបំណងនៅក្នុងផែនការ |
| 2. ការធ្វើការសម្រេចចិត្ត | 2.1. ប្រើទិន្នន័យជាភស្តុតាង ដើម្បីគាំទ្រ តាមដាន វាយតម្លៃ និងកែលម្អផែនការយុទ្ធសាស្ត្រ | 2.1.1. អាន និងប្រើព័ត៌មានដែលទទួលបានពីប្រភពផ្សេងៗ<br>2.1.2. ប្រើទិន្នន័យព័ត៌មានដែលរកឃើញ ដើម្បីកែលម្អផែនការយុទ្ធសាស្ត្រ<br>2.1.3. ធានាថាទិន្នន័យ និងសូចនាកររបស់សាលារៀនជឿទុកបាន<br>2.1.4. ធានាថាទិន្នន័យ និងសូចនាករមានភាពទាក់ទងគ្នា ហើយអ្នកពាក់ព័ន្ធអាចយកប្រើប្រាស់បាន |
| | 2.2. ពិនិត្យកែលម្អជាទៀងទាត់នូវការអនុវត្តផែនការដើម្បីដោះស្រាយបញ្ហា | 2.2.1. ដឹកនាំប្រមូលទិន្នន័យសម្រាប់កែលម្អការបំពេញការងាររបស់សាលារៀន<br>2.2.2. វិភាគទិន្នន័យ(ឧទាហរណ៍សូចនាករបំពេញការងាររបស់សាលា) ដើម្បីជួយបន្ថែមវឌ្ឍនៈភាពសំដៅសម្រេចគោលបំណងនៅក្នុងផែនការយុទ្ធសាស្ត្រសាលារៀន<br>2.2.3. ធ្វើអាទិភាពការដោះស្រាយបញ្ហាតាមតម្រូវការ ដើម្បីសម្រេចឱ្យបាននូវ ការបង្រៀន និងការរៀនប្រកបដោយប្រសិទ្ធភាព និងការអភិវឌ្ឍសាលារៀន |
| 3.ការដឹកនាំឱ្យមានការផ្លាស់ ប្តូរីកចម្រើន និងនវានុវត្តន៍ | 3.1. ដឹកនាំដំណើរការនៃការផ្លាស់ប្តូរីកចម្រើនដើម្បីបង្កើតឡើងនូវវិធីថ្មីៗហើយល្អសម្រាប់ធ្វើការងារ | 3.1.1. វាយតម្លៃតម្រូវការអប់រំតាមមូលដ្ឋាន និងលក្ខខណ្ឌតម្រូវគោលនយោបាយអប់រំជាតិដើម្បីដោះស្រាយតម្រូវការជាក់ស្តែងសម្រាប់ការអភិវឌ្ឍសាលារៀន<br>3.1.2. លើកទឹកចិត្តបុគ្គលិកសាលារៀនដើម្បីអនុវត្តគំនិតថ្មីៗសម្រាប់ការបង្រៀន និងការរៀនមានប្រសិទ្ធភាព<br>3.1.3. អនុវត្តគំនិតថ្មីសម្រាប់បង្រៀននិងរៀនប្រកបដោយប្រសិទ្ធភាពស្របទៅតាមតម្រូវការសាលារៀន និងសហគមន៍មូលដ្ឋាន |
| | 3.2. ទ្រទ្រង់គំនិតថ្មីៗសម្រាប់ការរៀនមានប្រសិទ្ធភាពនៅក្នុងសហគមន៍សាលារៀន | 3.2.1. ទទួលស្គាល់ និងផ្តល់រង្វាន់ដល់បុគ្គលិកសាលារៀនដែលអនុវត្តបានជោគជ័យនូវគំនិតថ្មីៗដើម្បីកែលម្អការបង្រៀននិងការរៀនមានប្រសិទ្ធភាព។<br>3.2.2. វាយតម្លៃលទ្ធផលនៃការអនុវត្តគំនិតថ្មីនេះដើម្បីកែលម្អការបំពេញការងាររបស់សាលារៀន<br>3.2.3. ចែករំលែកការអនុវត្តល្អៗជាមួយដៃគូក្នុងស្រុក ឬសាលារៀនដទៃ |

| ២.សមាសភាគ ៖ ភាពជាអ្នកដឹកនាំការបង្រៀន និងរៀន | | |
|---|---|---|
| 1. ការដឹកនាំការអនុវត្តនិងការកែលម្អកម្មវិធីសិក្សា | 1.1. គ្រប់គ្រងការអនុវត្តកម្មវិធីសិក្សា | 1.1.1. ពិនិត្យកែលម្អកម្មវិធីសិក្សា និងធនធានសិក្សាឱ្យបានទៀងទាត់ដើម្បីធានាឱ្យបាននូវការបង្រៀន និងការរៀនមានប្រសិទ្ធភាព<br>1.1.2. ដឹកនាំអភិវឌ្ឍ និងអនុវត្តកម្មវិធីសិក្សាការ<br>1.1.3. រៀបចំប្រជុំជាមួយបុគ្គលិក និងសហគមន៍ឱ្យបានទៀងទាត់ដើម្បីកែលម្អការអនុវត្តកម្មវិធីសិក្សានិងការបង្រៀននិងការរៀនមានប្រសិទ្ធភាព<br>1.1.4. ផ្តួចផ្តើមសកម្មភាព ដែលនាំឱ្យការបង្រៀននិងការរៀនមានប្រសិទ្ធភាព |
| | 1.2. ជំរុញឱ្យមានការចាប់អារម្មណ៍លើកម្មវិធីនៃការបង្រៀន និងការរៀន ផ្សេងៗគ្នា | 1.2.1. ធានាថាគ្រូបង្រៀនធ្វើការសម្រាប់បរិយាប័ន្នដល់សិស្សគ្រប់ប្រភេទ<br>1.2.2. ធានាថាគ្រូបង្រៀនផ្តល់ការងារឬបង្រៀនឱ្យឆ្លើយតបតាមតម្រូវការផ្សេងៗគ្នារបស់សិស្សទាំងអស់ |
| 2. ការបង្កើតបរិស្ថានអ្នកសិក្សាមជ្ឈមណ្ឌល | 2.1. ជំរុញឱ្យមានសកម្មភាពអ្នកសិក្សាមជ្ឈមណ្ឌល | 2.1.1. ធ្វើការជាមួយគ្រូបង្រៀនវាយតម្លៃការងារសិស្សដើម្បីធ្វើឱ្យប្រសើរឡើងនូវការបង្រៀន និងការរៀនមានប្រសិទ្ធភាព<br>2.1.2. ពិនិត្យបរិស្ថានសិក្សាដើម្បីធានាឱ្យទីកន្លែងសិក្សាស្អាត និងមានសណ្តាប់ ធ្នាប់ល្អដែលធ្វើឱ្យសិស្សរៀនប្រកបដោយប្រសិទ្ធភាព<br>2.1.3. ធានាថាគ្រូបង្រៀនលើកទឹកចិត្តសិស្សឱ្យចេះឆក់យកឱកាសសិក្សាដោយខ្លួនឯង<br>2.1.4. ធានាថាគ្រូបង្រៀនប្រើគរុកោសល្យបង្រៀនមានប្រសិទ្ធភាព តាមរយៈការតាមដានជាប្រចាំ |
| | 2.2. ជំរុញឱ្យបរិស្ថានសិក្សាមានសុខភាពសុវត្ថិភាពនិងបរិយាបន្ន | 2.2.1. ធានាថាសម្ភាររូបវន្ត និងធនធានសិក្សារបស់សាលាអ្នកសិក្សាទាំងអស់មានសិទ្ធិប្រើបាន<br>2.2.2. ថែរក្សាបរិស្ថានសាលារៀនឱ្យមានសុវត្ថិភាព ស្អាត និងគ្មានគ្រោះថ្នាក់<br>2.2.3. វាយតម្លៃផលប៉ះពាល់បរិស្ថានសាលារៀនដែលមានឥទ្ធិពលដល់លទ្ធផលការសិក្សារបស់សិស្ស |

| | | |
|---|---|---|
| | 2.3. ជំរុញឱ្យមានវប្បធម៌សន្តិភាព និងគោរពភាពទីទៃៗពីគ្នា | 2.3.1. អនុវត្តគោលនយោបាយសាលារៀនដែលជំរុញឱ្យមានសន្តិភាព និងមានការគោរពពិពិធកម្ម<br>2.3.2. ធានាឱ្យការអប់រំមានសន្តិភាព និងការគោរពពិពិធកម្មវប្បធម៌ ដែលត្រូវបានបង្កប់ក្នុងកម្មវិធីសិក្សា និងអនុវត្តជារៀងរាល់ថ្ងៃក្នុងថ្នាក់រៀន<br>2.3.3. ធ្វើប្រតិភូកម្មការទទួលខុសត្រូវឱ្យគ្រូបង្រៀននិង ឬសមាជិកក្រុមប្រឹក្សាសិស្សទទួលខុសត្រូវ |
| 3. ការអធិការកិច្ច និងការវាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀន | 3.1. អនុវត្តមានគំរូសមស្រប សម្រាប់អធិការកិច្ច និងការវាយតម្លៃ | 3.1.1. បង្ហាញពីចំណេះដឹង និងការយល់ដឹងពីនីតិវិធីត្រឹមត្រូវសម្រាប់អធិការកិច្ច<br>3.1.2. អភិវឌ្ឍ និងអនុវត្តប្រក្រតិទិនតាមដានការបង្រៀន និងការរៀន<br>3.1.3. វាយតម្លៃការងារគ្រូបង្រៀននៅក្នុងថ្នាក់រៀន<br>3.1.4. ផ្តល់ព័ត៌ត្រឡប់ដល់គ្រូបង្រៀនដែលអាចអនុវត្តបាននៅក្នុងមេរៀនប្រចាំថ្ងៃ<br>3.1.5. វាយតម្លៃប្រសិទ្ធភាពមេរៀនផ្អែលលើភាពជោគជ័យនៃការសិក្សាធៀបទៅនឹងវត្ថុបំណងមេរៀន |
| | 3.2. អប់រំគ្រូដែលមានឧបនិស្ស័យជាអ្នកដឹកនាំ | 3.2.1. កំណត់បានអ្នកដែលមានឧបនិស្ស័យដឹកនាំ និងជួយអភិវឌ្ឍពួកគេ<br>3.2.2. ធានាថាមុខងារសំខាន់ៗរបស់អ្នកដឹកនាំត្រូវបានផ្ទេរជូន<br>3.2.3. គាំទ្របុគ្គលិកដែលស្ថិតក្នុងភារកិច្ចជាអ្នកដឹកនាំ |
| 4. ការផ្តល់លទ្ធផលសិក្សាតាមផែនការ | 4.1. ជំរុញឱ្យមានគោលវិធីផ្អែកលើក្រុមការងារចំពោះភាពជាអ្នកដឹកនាំការបង្រៀន និងរៀន | 4.1.1. លើកទឹកចិត្តដល់គ្រូបង្រៀនក្នុងការចែករំលែកការប្រត្តិបត្តិល្អដើម្បីលើកកម្ពស់ការបង្រៀន និងការរៀឱ្យមានប្រសិទ្ធភាព<br>4.1.2. ផ្តល់ឱកាសដល់គ្រូបង្រៀនដើម្បីចែករំលែកការប្រតិបត្តិល្អៗ<br>4.1.3. តាមដានគំនិតផ្តួចផ្តើមរបស់ក្រុម |
| | 4.2. គ្រប់គ្រងការវាយតម្លៃដើម្បីកែលម្អការបង្រៀន និងរៀន | 4.2.1. ធានាថាការវាយតម្លៃគឺស្មើភាព ត្រឹមត្រូវ មានតម្លាភាព និងទៀងទាត់<br>4.2.2. ធានាថាលទ្ធផលនៃការវាយតម្លៃត្រូវបានដាក់ឱ្យភាគីពាក់ព័ន្ធប្រើប្រាស់បាន<br>4.2.3. ធានាថាការវាយតម្លៃការសិក្សាត្រូវបានប្រើប្រាស់ដើម្បីជូនដំណឹងដល់ការធ្វើកិច្ចតែងការបង្រៀនសម្រាប់ការបង្រៀន និងការរៀនមានប្រសិទ្ធភាព |

| ៣.សមាសភាគ៖ ភាពខ្លាំងផ្ទាល់ខ្លួន | | |
|---|---|---|
| 1. ការគ្រប់គ្រងប្រសិទ្ធភាពផ្ទាល់ខ្លួន | 1.1. ដឹកនាំដោយមានឧទាហរណ៍គំរូ | 1.1.1. ធ្វើជាគំរូតាមក្រមសីលធម៌វិជ្ជាជីវៈ តម្លៃ និងភាពជាអ្នកដឹកនាំមានសីលធម៌<br>1.1.2. ផ្ដោតលើជំនាញសម្រាប់ស្វ័យកែលម្អ<br>1.1.3. ផ្ដល់ឧទាហរណ៍នៃភាពជាអ្នកដឹកនាំនិងការប្រតិបត្តិល្អៗសម្រាប់សមាជិកទាំងអស់របស់សហគមន៍សាលា (បុគ្គលិក សិស្ស ឪពុកម្ដាយ សហគមន៍) |
| | 1.2. បង្ហាញពីតម្លាភាព និងគណនេយ្យភាព | 1.2.1. ផ្ដល់ដំណឹងដល់ភាគីពាក់ព័ន្ធនៃសូចនាករបំពេញការរំពឹងទុកនិងគោលបំណងផែនការកែលម្អសាលារៀន<br>1.2.2. បង្ហាញតម្លាភាពនៅក្នុងសូចនាករ បំពេញការងាររបស់សាលារៀន<br>1.2.3. ទទួលខុសត្រូវលើនីតិវិធីរៀបចំចាត់ចែងក្នុងសាលារៀន និងនីតិវិធីឆ្លើយតបទៅនឹងបញ្ហាបានត្រឹមត្រូវ |
| | 1.3. ប្រតិបត្តិពីរបៀបរស់នៅដែលធ្វើឱ្យសុខភាពមានតុល្យភាព | 1.3.1. រស់នៅតាមរបៀបមួយដែលជំរុញឱ្យមានសុខភាពល្អ<br>1.3.2. បង្ហាញពីភាពអត់ធ្មត់ពេលស្ថិតនៅក្រោមសំពាធអ្វីមួយ និងបំណិនសម្របខ្លួនទៅតាមស្ថានការណ៍លំបាក<br>1.3.3. បង្ហាញពីបញ្ញាចលករក្នុងការដោះស្រាយជាមួយអ្នកដទៃ<br>1.3.4. ប្រតិបត្តិស្វ័យឆ្លុះបញ្ចាំងដើម្បីកែលម្អការបំពេញការងារ |
| | 1.4. មានមោទនភាពលើវិជ្ជាជីវៈរបស់ខ្លួន | 1.4.1. បង្ហាញពីការពេញចិត្តចំពោះតួនាទីជានាកយសាលារៀន<br>1.4.2. បង្ហាញពីទំនុកចិត្តខ្លួនឯង ការសង្ឃឹម និងភាពមិនចុះចាញ់ការងារ<br>1.4.3. បង្ហាញពីភាពប៉ិនប្រសប់ធ្វើឱ្យសម្រេចការងារ |
| | 1.5. ផ្សព្វផ្សាយលទ្ធផល | 1.5.1. សម្រេចឱ្យបាននូវសូចនាករបំពេញការងារសាលារៀនស្របតាមការរំពឹងទុក<br>1.5.2. ធ្វើប្រតិភូកម្មមានប្រសិទ្ធភាពឱ្យបានតាមគោលបំណងដែលបានកំណត់ទុកនៅក្នុងផែនការកែលម្អសាលារៀន |
| 2. ការធ្វើការងារឱ្យអស់សមត្ថភាព និងលទ្ធភាព | 2.1. គ្រប់គ្រងអាទិភាព | 2.1.1. បង្ហាញភាពប៉ិនប្រសប់ធ្វើអាទិភាពការងារដែលមានឥទ្ធិពលទៅលើការកែលម្អមានប្រសិទ្ធភាពចំពោះការបង្រៀន និងរៀន<br>2.1.2. គ្រប់គ្រងពេលវេលាមានប្រសិទ្ធភាព |

| | | |
|---|---|---|
| | 2.2. បង្ហាញប្រាប់ការសម្រេចចិត្តក្នុងការដោះស្រាយបញ្ហាប្រឈម | 2.2.1. ធ្វើការសម្រេចចិត្តផ្អែកលើបទពិសោធន៍ ការវិនិច្ឆ័យ និងពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធដែលមានបទពិសោធន៍<br>2.2.2. ធ្វើការសម្រេចចិត្តទាន់ពេល និងមានប្រសិទ្ធភាព ផ្អែកលើគោលនយោបាយជាតិ និងលក្ខខណ្ឌតម្រូវតាមមូលដ្ឋានទទួលខុសត្រូវចំពោះការសម្រេចចិត្ត |
| | 2.3. បង្ហាញប្រាប់ពីឥរិយាបថជាសហាគ្រិនភាព | 2.3.1. បង្ហាញឥរិយាបថវិជ្ជមានដរាបណាមានលទ្ធភាព<br>2.3.2. គាំទ្រសកម្មភាពគ្រូ និងសិស្សដូចជាគំនិតថ្មីៗ និងនវានុវត្តន៍ |
| 3. ការបន្តអភិវឌ្ឍជំនាញវិជ្ជាជីវៈជាបន្តបន្ទាប់ | 3.1. ទទួលខុសត្រូវចំពោះការសិក្សាពេញមួយជីវិត | 3.1.1. ស្រាវជ្រាវឯកសារសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈ<br>3.1.2. ចូលរួមវគ្គវិក្រឹតការសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈ<br>3.1.3. ទទួលបានគុណវុឌ្ឍិវិជ្ជាជីវៈ និងសមត្ថភាពតាមបញ្ញត្តិ<br>3.1.4. ស្វែងរកអ្នកជំនាញដើម្បីជួយអភិវឌ្ឍបំណិនវិជ្ជាជីវៈ<br>3.1.5. ប្រើប្រាស់ឧបករណ៍ ICT បើមានលទ្ធភាពដើម្បីធ្វើឱ្យប្រសើរឡើងចំណេះដឹងវិជ្ជាជីវៈ<br>3.1.6. ប្រជុំជាមួយនាយកសាលារៀនផ្សេងៗ និងអ្នកដឹកនាំអប់រំដទៃទៀតទៀងទាត់ |
| | 3.2. គាំទ្រតម្លៃ និងទស្សនៈវិស័យរបស់អាស៊ាន | 3.2.1. បង្ហាញពីការយល់ដឹងហេតុផលបង្កប់នៅក្នុងក្របខ័ណ្ឌអាស៊ាន<br>3.2.2. ចែករំលែកចំណេះដឹងគោលនយោបាយអប់រំ ក្នុងការគាំទ្រ<br>សមាហរណកម្មអាស៊ាន<br>3.2.3. ជំរុញឱ្យមានការយល់ដឹងពីពហុវប្បធម៌ និងគោរពភាពទីទៃពីគ្នា<br>3.2.4. អភិវឌ្ឍបំណិន និងតម្លៃក្នុងការប្រើប្រាស់ភាសាទំនាក់ទំនងក្នុងតំបន់<br>អាស៊ាន |

| **៤. សមាសភាគ ៖ ការចូលរួមពីភាគពាក់ព័ន្ធ** | | |
|---|---|---|
| 1. ជំរុញឱ្យមានការទទួលខុសត្រូវរួមគ្នាសម្រាប់ការកែលម្អសាលារៀន | 1.1. កសាងទំនុកចិត្ត និងដឹកនាំក្រុម/សហគមន៍កែលម្អសាលារៀន | 1.1.1. កំណត់ការរំពឹងងទុក តួនាទី និងការទទួលខុសត្រូវរបស់សាលារៀន និងសហគមន៍ក្នុងការផ្តល់ការអប់រំប្រកបដោយគុណភាព<br>1.1.2. បង្កើតការសហការជាមួយឪពុកម្តាយ និងសហគមន៍ដើម្បីគាំទ្រគំនិតផ្តួចផ្តើមរបស់សាលារៀន<br>1.1.3. រៀបចំពិធីផ្សេងៗឱ្យបានញឹកញាប់ (ដូចជាការប្រជុំ |

| | | |
|---|---|---|
| | | ជាមួយសហគមន៍ |
| | | 1.1.4. ការប្រជុំជាមួយឪពុកម្តាយ សកម្មភាពតាមមុខវិជ្ជាឯកទេស) ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ<br>1.1.5. ធានាឱ្យភាគីពាក់ព័ន្ធក្នុងសហគមន៍មានគំនិតម្ចាស់ការក្នុងការអនុវត្តគម្រោងរបស់សាលារៀន<br>1.1.6. ធានាឱ្យភាគីពាក់ព័ន្ធចូលរួមយ៉ាងសកម្មក្នុងតួនាទីអភិបាលកិច្ចសាលារៀន |
| | 1.2. ផ្តល់សិទ្ធិអំណាចឱ្យសហគមន៍ដើម្បីជួយអភិវឌ្ឍសាលារៀន | 1.2.1. ផ្តល់ឱកាសដល់ឪពុកម្តាយ សហគមន៍សម្រាប់ចែករំលែកចំណេះដឹង គ្នាទៅវិញទៅមក<br>1.2.2. អញ្ជើញភាគីពាក់ព័ន្ធចូលរួមក្នុងការធ្វើផែនការ អនុវត្តគម្រោងនិងអនុវត្តកម្មវិធីនានារបស់សាលារៀន<br>1.2.3. ផ្តល់ឱកាសដល់ភាគីពាក់ព័ន្ធដើម្បីវិនិយោគ និងដាក់ទន្សួមសម្រាប់កែលម្អលទ្ធផលសិក្សា |
| 2. ការគ្រប់គ្រងសម្ព័ន្ធភាពអប់រំនិងបណ្តាញ ការងារ | 2.1. ទំនាក់ទំនងមានប្រសិទ្ធភាពជាមួយភាគីពាក់ព័ន្ធ | 2.1.1. ប្រើប្រាស់ភាសាសមរម្យសម្រាប់ទាក់ទងជាមួយភាគីពាក់ព័ន្ធ<br>2.1.2. ប្រើប្រាស់ឧបករណ៍ទាក់ទងបើមានលទ្ធភាពសម្រាប់ទាក់ទងជាមួយ ភាគីពាក់ព័ន្ធ |
| | 2.2. សម្របសម្រួលសកម្មភាពសហគមន៍និងដៃគូអភិវឌ្ឍ | 2.2.1. កំណត់បានសហគមន៍ដែលមានបំណិន និងបទពិសោធន៍ឱ្យចូលរួមធ្វើការសម្រេចចិត្ត<br>2.2.2. អនុវត្ត និងពិនិត្យតាមដានរាល់ការសម្រេចចិត្តជាមួយសហគមន៍<br>2.2.3. ដើរតួជាអ្នកសម្របសម្រួលរវាងសាលារៀន និងសហគមន៍ |
| | 2.3. ជំរុញឱ្យមានការកសាងមតិឯកច្ឆ័ន | 2.3.1. បង្កលក្ខណៈឱ្យក្រុមសហគមន៍ផ្សេងៗគ្នាមានឱកាសចូលរួមប្រជុំ<br>2.3.2. សម្របសម្រួលអង្គប្រជុំ និងការសម្រេចចិត្តរបស់ក្រុមឱ្យមានការ<br>ឯកភាពគ្នា |
| | 2.4. គ្រប់គ្រងភាពមិនចុះសម្រុងនឹងគ្នា និងអនុវត្តបំណិនចរចា | 2.4.1. កំណត់បញ្ហាឱ្យបានច្បាស់លាស់ និងដោះស្រាយទៅតាមវិធីមួយដែលសហគមន៍សាលារៀនទទួលបានផលប្រយោជន៍<br>2.4.2. ចរចាស្វែងរកប្រភពធនធានសម្ភារៈ និងធនធានមនុស្សដែលមានឥទ្ធិពលដល់ការកែលម្អសាលារៀន<br>2.4.3. ផ្តល់ឱកាសដល់ឪពុកម្តាយ និងសហគមន៍ដើម្បីផ្តល់យោបល់លើសកម្មភាពកែលម្អសាលារៀន |

| | | |
|---|---|---|
| 3. ការរក្សាចិរភាពទំនាក់ទំនងសហការជាមួយ ភាគីពាក់ព័ន្ធ | 3.1. គាំទ្រគម្រោង និងកម្មវិធីផ្អែកលើសហគមន៍ | 3.1.1. អញ្ជើញ និងស្វាគមន៍មាតាបិតាសិស្ស និងសហគមន៍ឱ្យចូលរួមសកម្មភាពរបស់សាលារៀន<br>3.1.2. រៀបចំ និងជួយចាត់ចែងកម្មវិធីអប់រំផ្អែកលើសាលារៀនស្របតាមតម្រូវការមូលដ្ឋាន |

| | | |
|---|---|---|
| | 3.2. ផ្សព្វផ្សាយរបាយការណ៍ការបំពេញការងាររបស់សាលារៀនដល់ភាគីពាក់ព័ន្ធ | 3.2.1. រៀបចំរបាយការណ៍ស្តីពីការបំពេញការងាររបស់សាលារៀនស្របតាមលក្ខខណ្ឌតម្រូវរបស់ក្រសួងអប់រំ យុវជន និងកីឡា<br>3.2.2. ផ្សព្វផ្សាយរបាយការណ៍តាមរយៈពហុឧបករណ៍បើមានលទ្ធភាព<br>3.2.3. ឱ្យសហគមន៍សាលារៀនចូលរួមវាយតម្លៃជាប្រព័ន្ធ និងហ្មត់ចត់នូវប្រសិទ្ធភាពលទ្ធផលរបស់សាលារៀន<br>3.2.4. លើកកម្ពស់ការផ្សព្វផ្សាយសមិទ្ធផលសាលារៀនដល់សហគមន៍ |

| **៥.សមាសភាគ ៖ ភាពជាអ្នកដឹកនាំគ្រប់គ្រង** | | |
|---|---|---|
| 1. ការគ្រប់គ្រងធនធាន និងប្រព័ន្ធរបស់សាលារៀន | 1.1. គ្រប់គ្រងធនធានហិរញ្ញវត្ថុ | 1.1.1. អភិវឌ្ឍផែនការថវិការស្របតាមផែនការកែលម្អសាលារៀន<br>1.1.2. ប្រើប្រាស់ធនធានថវិកាដែលទទួលបានពីប្រភពផ្សេងៗមានប្រសិទ្ធ ភាពសម្រាប់សាលារៀន<br>1.1.3. ទទួលខុសត្រូវមូលនិធិសាលារៀននិងការចំណាយមានតម្លាភាព |
| | 1.2. គ្រប់គ្រងបរិស្ថានសិក្សា | 1.2.1. បញ្ចូលសកម្មភាពអភិវឌ្ឍបរិស្ថានសាលារៀនក្នុងផែនការកែលម្អសាលារៀន<br>1.2.2. បែងចែកថវិកាសម្រាប់កែលម្អសម្ភាររូបវន្ត និងហេដ្ឋារចនាសម្ព័ន្ធស្របតាមថវិកាដែលមាន<br>1.2.3. បង្កើតប្រព័ន្ធធានាបរិស្ថានសាលារៀនដែលមានសុវត្ថិភាព |
| | 1.3. គ្រប់គ្រងប្រព័ន្ធ និងនីតិវិធីធ្វើការងារ | 1.3.1. គ្រប់គ្រងការបង្រៀន និងរៀនមានប្រសិទ្ធភាព និងទំនាក់ទំនងល្អ<br>1.3.2. ប្រើប្រាស់បច្ចេកវិទ្យាសម្រាប់គ្រប់គ្រងសាលារៀន និងបណ្តាញការងារប្រកបដោយប្រសិទ្ធភាព |

| | | |
|---|---|---|
| 2. គ្រប់គ្រងការបំពេញការងាររបស់បុគ្គលិក | 2.1. គ្រប់គ្រងលក្ខខណ្ឌតម្រូវរបស់បុគ្គលិកសាលារៀន | 2.1.1. បែងចែកតួនាទីឱ្យបុគ្គលិកសាលារៀនដើម្បីកែលម្អការបង្រៀន និងរៀនប្រកបដោយប្រសិទ្ធភាព<br>2.1.2. ប្រើទិន្នន័យពីលទ្ធផលសិក្សាដើម្បីបែងចែកតួនាទី និងភារកិច្ច<br>2.1.3. រៀបចំការវាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀន |
| | 2.2. គាំទ្រការអភិវឌ្ឍ វិជ្ជាជីវៈរបស់បុគ្គលិក | 2.2.1. បង្កើតវប្បធម៌សាលារៀនដែលធ្វើឱ្យគ្រូបង្រៀនធ្វើការសហការអភិវឌ្ឍវិជ្ជាជីវៈ<br>2.2.2. លើកទឹកចិត្តបុគ្គលិកឱ្យធ្វើការស្រាវជ្រាវដើម្បីពង្រីកចំណេះដឹងលើ មុខវិជ្ជាបង្រៀន និងគរុកោសល្យ<br>2.2.3. បង្កើតកម្មវិធីតាមដានឱ្យអ្នកមានបទពិសោធច្រើនជួយអ្នកដែលមាន បទពិសោធតិច<br>2.2.4. អភិវឌ្ឍសមត្ថភាពបុគ្គលិកដើម្បីវាយតម្លៃការបំពេញការងារ |
| | 2.3. ទទួលស្គាល់ការបំពេញការងាររបស់បុគ្គលិក | 2.3.1. ផ្តល់ការរំពឹងទុកច្បាស់លាស់សម្រាប់ការបំពេញការងាររបស់បុគ្គលិក<br>2.3.2. ធានាឱ្យបុគ្គលិកទាំងអស់ទទួលខុសត្រូវដើម្បីសម្រេចឱ្យបានការរំពឹងទុកនៃការបំពេញការងាររបស់ខ្លួន<br>2.3.3. អភិវឌ្ឍផែនការលាភការដើម្បីផ្តល់ឱ្យបានសមស្របដល់បុគ្គលិក ដែលសម្រេចបានតាមស្តង់ដាបំពេញការងារ<br>2.3.4. អភិវឌ្ឍផែនការសាលារៀន ដើម្បីផ្តល់ការគាំទ្រដល់បុគ្គលិក ដែល មិន បានសម្រេចបានតាមស្តង់ដាបំពេញការងារ |
| 3. គ្រប់គ្រងកម្មវិធី និងគម្រោងរបស់សាលារៀនមាន និរន្តភាព | 3.1. បង្ហាញបំណិនគ្រប់គ្រងកម្មវិធី និងគម្រោង | 3.1.1. បង្កើតកម្មវិធី និងគម្រោងសម្រាប់អភិវឌ្ឍសាលារៀន<br>3.1.2. ធានាឱ្យមានកម្មវិធី និងគម្រោងគាំទ្រការបង្រៀន និងរៀនមានប្រសិទ្ធភាព<br>3.1.3. ធ្វើអធិការ និងតាមដានកម្មវិធី និងគម្រោងសម្រាប់អភិវឌ្ឍសាលារៀន |
| | 3.2. ជំរុញឱ្យមានកម្មវិធី និងគម្រោងផ្អែកលើសាលារៀនដែល គាំទ្រការអភិវឌ្ឍ ប្រកបដោយចិរភាព | 3.2.1. បង្ហាញការយល់ដឹងពីការអប់រំសម្រាប់អភិវឌ្ឍប្រកបដោយចិរភាព<br>3.2.2. សហការជាមួយដៃគូរពាក់ព័ន្ធដែលគាំទ្រការអប់រំសម្រាប់អភិវឌ្ឍប្រកបដោយចិរភាព<br>3.2.3. ឱ្យសហគមន៍ចូលរួមបង្កើតបរិស្ថានដែលមានសុវត្ថិភាព សុខភាព ភាពតស៊ូ និង បរិស្ថានសិស្សមជ្ឈមណ្ឌល<br>3.2.4. អភិវឌ្ឍ និងធ្វើការសហការលើកម្មវិធី និងគម្រោងដែលគាំទ្រ ការអភិវឌ្ឍប្រកបដោយចិរភាព |